នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ*

*ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

# សិក្សាកងធម៌

## ពួក១

### ធម៌មួយគួរដឹងច្បាស់

សព្វេ សត្តា អាហារដ្ឋិតិកា *សត្វទាំងអស់ តាំងនៅដោយសារអាហារ ។*

### ធម៌វិន័យមានរសតែមួយ

អយំ ធម្មវិនយោ ឯករសោ វិមុត្តិរសោ *ធម៌វិន័យនេះមានរសតែមួយ គឺ វិមុត្តិរស ។*

### សភាវៈ១ដែលបុគ្គលទូន្មានហើយ តែងប្រព្រឹត្តទៅដើម្បីប្រយោជន៍យ៉ាងធំ

ចិត្តំ ភិក្ខវេ ទន្តំ គុត្តំ រក្ខិតំ សំវុតំ

មហតោ អត្ថាយ សំវត្តតិ ម្នាលភិក្ខុទាំងឡាយ ចិត្ត ដែលបុគ្គលបានទូន្មាន បានគ្រប់គ្រង បានរក្សា បានសង្រួម ហើយ តែងប្រព្រឹត្តទៅដើម្បីប្រយោជន៍យ៉ាងធំ ។

## មេត្តាចិត្ត ១ ផ្ទាត់ម្រាមដៃ

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុកប់ប្រសព្វនឹងមេត្តាចិត្ត សូម្បី ១ ផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគត ហៅថា មានឈានមិនបានលះបង់ ជាអ្នកធ្វើតាមសាសនាព្រះ សាស្តា ជាអ្នកធ្វើតាមឱវាទព្រះសាស្តា បរិភោគបិណ្ឌបាតអ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វីដល់ពួកភិក្ខុដែលសន្សំរឿយៗ នូវមេត្តាចិត្តនោះ ។

សូម្បីភិក្ខុចម្រើននូវមេត្តាចិត្ត, ភិក្ខុត្រិះរិះនូវមេត្តាចិត្ត ក៏ ព្រះមានព្រះភាគ ត្រាស់ដូចគ្នា ។ (សុត្តន្តបិដក ៤០ / ២០)

## សភាវៈ ១ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ច្រើន

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមិនឃើញសភាវៈ ដទៃសូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ច្រើន ដូចសេចក្តីមិនប្រមាទ (**អប្បមាទោ**) នេះសោះឡើយ ម្នាលភិក្ខុ

*ទាំងឡាយ មានតែសេចក្ដីមិនប្រមាទ ទើបប្រព្រឹត្តទៅដើម្បីប្រយោជន៍ច្រើន ។*

**សូម្បីសភាវៈដទៃទៀត** *ព្រះមានព្រះភាគត្រាស់ថា*

វីរិយារម្ភោ *ការផ្ដងព្យាយាម,*

អប្បិច្ឆតា *សេចក្ដីប្រាថ្នាតិច,*

សន្តុដ្ឋិតា *សេចក្ដីសន្ដោស*

យោនិសោ មនសិការោ *ការធ្វើទុកក្នុងចិត្តត្រូវទំនង*

សម្បជញ្ញំ *សម្បជញ្ញៈ (សេចក្ដីដឹងខ្លួន),*

កល្យាណមិត្តតា *ការមានកល្យាណមិត្ត,*

អនុយោគោ កុសលានំ ធម្មានំ អននុយោគោ អកុសលានំ ធម្មានំ *កិរិយាប្រកបរឿយៗនូវកុសលធម៌ និងកិរិយាមិនប្រកបរឿយៗនូវអកុសលធម៌ ។*

*(សុត្តន្ត. ៤០ / ៣០-៣៤)*

## ពួក២

### ធម៌ ២ ប្រការដែលរក្សានូវសត្វលោក

១–ហិរិ *សេចក្ដីខ្មាសបាប*

២–ឱត្តប្បៈ *សេចក្ដីខ្លាចបាប ។*

### បុគ្គលពីរពួករកបានដោយកម្រក្នុងលោក

១–បុព្វការី *បុគ្គលដែលធ្វើឧបការៈទុកមុន*

២–កតញ្ញូ កតវេទី *បុគ្គលដែលដឹងឧបការៈ ដែលគេធ្វើហើយធ្វើតបវិញ ។* *(សុត្តន្ត. ៤០,១៩៥)*

### ធម៌មានឧបការៈពីរយ៉ាង

១–សតិ *សេចក្ដីរលឹកបាន*

២–សម្បជញ្ញៈ *សេចក្ដីដឹងខ្លួន ។*

### សីលមានអត្ថជាប្រក្រតីដោយហេតុ ២ យ៉ាង

១–សមាធាន *កិរិយារួបរួមទុក,*

<u>អធិប្បាយ</u> *ភាវៈនៃកម្មទាំងឡាយមានកាយកម្មជាដើម មិនរាត់រាយ ដោយអំណាចភាវៈនៃបុគ្គលអ្នកមានសីល ។*

២-ឧបធារណា កិរិយាចូលទៅទ្រទ្រង់ទុក,

<u>អធិប្បាយ</u> ភាវៈនៃកិរិយាទ្រទ្រង់ទូទៅ ដោយអំណាចនៃកិរិយាប្រតិស្ឋាននៃធម៌ទាំងឡាយជាកុសលម្យ៉ាង ។

ដ្បិតថា អ្នកប្រាជ្ញដែលដឹងច្បាស់នូវលក្ខណៈនៃសព្ទក្នុងបទសីលសព្ទនេះ តែងអនុញ្ញាតនូវប្រជុំពីរ នៃអត្ថត្រឹមប៉ុណ្ណោះ ។ ចំណែកអាចារ្យឯទៀត ពណ៌នានូវអត្ថក្នុងសីលសព្ទនេះ ដោយន័យមានយ៉ាងនេះជាដើមដែរថា

សិរដ្ឋោ សីលមានអត្ថថា ជាកំពូល, សីសដ្ឋោ សីលមានអត្ថថា ជាប្រធាន, សីតលដ្ឋោ សីលមានអត្ថថា ត្រជាក់, សិវដ្ឋោ សីលមានអត្ថថា ក្សេមក្សាន្ត ។ (វិសុទ្ធិមគ្គ ១,១៣)

## ហេតុជាទីតាំងនៃសីល

១-ហិរិ សេចក្ដីខ្មាសចំពោះទុច្ចរិតបាបធម៌

២-ឱត្តប្បៈ សេចក្ដីតក់ស្លុតចំពោះទុច្ចរិតបាបធម៌

ក៏ឯហិរិនិងឱត្តប្បៈ អ្នកប្រាជ្ញទាំងឡាយពណ៌នាថា ជាទីតាំងនៃសីលនោះ ។ សេចក្ដីអធិប្បាយថា ជាអាសន្នហេតុ ។

*ដ្បិតថា កាលបើហិរិនិងឱត្តប្បៈមាន សីលរមែងកើតឡើងផង តាំងនៅផង កាលបើហិរិនិងឱត្តប្បៈ មិនមានទេ សីលក៏មិនកើតឡើង មិនតាំងនៅ ។* *(វិសុទ្ធិមគ្គ ១ / ១៥)*

## ចង្ហាន់បិណ្ឌបាត ២ មានផលស្មើគ្នា

១-យញ្ច បិណ្ឌបាតំ បរិភុញ្ជិត្វា តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ *ព្រះតថាគតទ្រង់សោយចង្ហាន់បិណ្ឌបាតណា ហើយទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ*

២-យញ្ច បិណ្ឌបាតំ បរិភុញ្ជិត្វា តថាគតោ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយតិ *ព្រះតថាគតទ្រង់សោយចង្ហាន់បិណ្ឌបាតណា ហើយទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។*

*ចង្ហាន់បិណ្ឌបាតទាំងពីរនេះឯង មានផលស្មើៗ គ្នា មានវិបាកស្មើៗ គ្នា មានផលច្រើនផង មានអានិសង្សច្រើនផង ក្រៃលែងជាងចង្ហាន់បិណ្ឌបាតដទៃ ។ល។* *(សុត្តន្ត. ១៦,២៨៧)*

## អដ្ឋកថា

សួរថា ព្រះតថាគតសរសើរបិណ្ឌបាតណា ដែលនាងសុជាតាថ្វាយហើយត្រាស់ដឹង បិណ្ឌបាតនោះព្រះអង្គសោយក្នុងវេលាដែលនៅមានរាគៈ ទោសៈ មោហៈ តែបិណ្ឌបាតនេះដែលចុន្ទកម្មារបុត្តថ្វាយហើយ ព្រះអង្គសោយក្នុងវេលាដែលប្រាសចាករាគៈ ទោសៈ មោហៈ មិនមែនឬ តែព្រោះហេតុអ្វីបិណ្ឌបាតទាំងពីរនេះ ទើបមានផលស្មើៗ គ្នា ?

ឆ្លើយថា ព្រោះស្មើគ្នាដោយការបរិនិព្វាន ស្មើគ្នាដោយការចូលសមាបត្តិ និងស្មើគ្នាដោយការរលឹក ។ មែនពិត ព្រះមានព្រះភាគ ទ្រង់សោយចង្ហាន់បិណ្ឌបាតដែលនាងសុជាតាថ្វាយហើយ ស្តេចបរិនិព្វានដោយសឧបាទិសេសនិព្វាន និងសោយចង្ហាន់បិណ្ឌបាតដែលចុន្ទកម្មារបុត្តថ្វាយហើយ ស្តេចបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ រួមសេចក្តីថា មានផលស្មើគ្នាដោយការបរិនិព្វាន ។

ក៏ក្នុងថ្ងៃដែលព្រះអង្គត្រាស់ដឹង ព្រះអង្គទ្រង់ចូលសមាបត្តិចំនួនពីរលានបួនសែនកោដិ សូម្បីក្នុងថ្ងៃទ្រង់បរិនិព្វាន ព្រះអង្គ

ទ្រង់ចូលសមាបត្តិនោះទាំងអស់ ។ រួមសេចក្ដីថា មានផល ស្មើគ្នាដោយការចូលសមាបត្តិស្មើគ្នា ។

ក្នុងកាលក្រោយមក នាងសុជាតា បានជ្រាបថា ឮថា អ្នកដែលយើងឃើញនោះ មិនមែនរុក្ខទេវតា ជាព្រះពោធិសត្វ បានឮថា ព្រះពោធិសត្វនោះ ឆាន់បិណ្ឌបាតនោះហើយ ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ព្រះអង្គស្ថិតនៅបានដោយបិណ្ឌបាតនោះអស់ ៧ សប្ដាហ៍ ។ កាលនាងបានស្ដាប់ដូច្នោះ ក៏រលឹកបានថា ជាលាភរបស់យើងហ្ន៎ ទើបកើតបីតិសោមនស្ស យ៉ាងខ្លាំង ។ ក្នុងកាលក្រោយមក ចុន្ទកម្មារបុត្តមានអាយុ បានស្ដាប់ថា បិណ្ឌបាតចុងក្រោយដែលយើងថ្វាយ យើងបាន កំពូលធម៌ហើយ បានឮថា ព្រះសាស្ដាសោយចង្ហាន់បិណ្ឌបាត របស់យើង ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ត្រឡប់រលឹកបានថា ជាលាភរបស់យើងហ្ន៎ ទើបកើតសោមនស្ស យ៉ាងខ្លាំង គប្បីជ្រាបថា មានផលស្មើគ្នាសូម្បីដោយការ ស្មើគ្នានៃការរលឹកដល់យ៉ាងនេះ ដោយប្រការដូច្នេះ ។

(អដ្ឋកថាមហាបរិនិព្វានសូត្រ ទំព័រ៤១៣)

## ទិដ្ឋិ ២ យ៉ាង

១-សាមញ្ញទិដ្ឋិ បានដល់ សក្កាយទិដ្ឋិដែលមានការយល់ខុសចាកបរមត្ថថា "ជាមនុស្ស ជាសត្វ ជាអត្តា" ។

ទិដ្ឋិនេះ មានទូទៅដល់បុថុជ្ជន វៀរព្រះអរិយៈប៉ុណ្ណោះ ទើបហៅថា សាមញ្ញទិដ្ឋិ ។

២-ទិដ្ឋិវិសេស បានដល់ ទិដ្ឋិ ៦២ វៀរសក្កាយទិដ្ឋិ ព្រោះទិដ្ឋិនេះ មានដល់មនុស្សពួកខ្លះ និងឱកាសខ្លះ ដូចនិយតមិច្ឆាទិដ្ឋិ ៣ គឺ នត្ថិកទិដ្ឋិ ១ អហេតុកទិដ្ឋិ ១ និងអកិរិយទិដ្ឋិ ១ ។ (ចាកអភិធម្មត្ថសង្គហៈ)

## ធម៌ទេសនា ២ យ៉ាង

ម្នាលភិក្ខុទាំងឡាយ ព្រះធម៌ទេសនារបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ មាន ២ យ៉ាងដោយបរិយាយ ។

១-អ្នកទាំងឡាយ ចូរឃើញនូវបាបថាជាបាប

២-លុះអ្នកទាំងឡាយឃើញនូវបាបថាជាបាបហើយ ចូរនឿយណាយ ចូរជិនឆ្អន់ ចូរផុតស្រឡះចាកបាបនោះ ។

## ពួកព

## កុលបុត្តមានសទ្ធារមែងបានបុណ្យច្រើន ព្រោះមានរបស់ ៣ ក្នុងទីចំពោះមុខ

១-សទ្ធាយ ភិក្ខវេ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ម្នាលភិក្ខុទាំងឡាយ *កុលបុត្រមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះមានសទ្ធាក្នុងទីចំពោះមុខ*

២-ទេយ្យធម្មស្ស ភិក្ខវេ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ម្នាលភិក្ខុទាំងឡាយ *កុលបុត្រមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះមានទេយ្យធម៌ក្នុងទីចំពោះមុខ*

៣-ទក្ខិណេយ្យានំ ភិក្ខវេ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ម្នាលភិក្ខុទាំងឡាយ *កុលបុត្រមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះមានទក្ខិណេយ្យបុគ្គលក្នុងទីចំពោះមុខ ។*

## បុគ្គលមានសទ្ធាបណ្ឌិតត្រូវដឹងដោយហេតុ ៣ យ៉ាង

១-សីលវន្តំ ទស្សនកាមោ ហោតិ

*បុគ្គលនោះចង់ឃើញបុគ្គលមានសីល*

២-សទ្ធម្មំ សោតុកាមោ ហោតិ

*ចង់ស្ដាប់ព្រះសទ្ធម្ម*

៣-វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ បយតបាណិ វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ *មានចិត្តប្រាសចាកសេចក្ដីកំណាញ់ជាមន្ទិល នៅគ្រប់គ្រងផ្ទះ មានការលះរួចហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះ ជាអ្នកគួរដល់ស្នូម ជាអ្នកត្រេកអរក្នុងការឲ្យនិងការចែករំលែក ។*

*បុគ្គលណា ចង់ឃើញពួកបុគ្គលមានសីល ចង់ស្ដាប់ព្រះសទ្ធម្ម កំចាត់បង់នូវមន្ទិល គឺសេចក្ដីកំណាញ់ បុគ្គលនោះឯង ហៅថា អ្នកមានសទ្ធា ។*

*(សុត្តន្តបិដក ៤១ / ១២០)*

## បុត្តមាន ៣ ប្រភេទរមែងប្រាកដក្នុងលោក

១-អតិជាតបុត្ត បុត្រដែលល្អជាងមាតាបិតា ខាងផ្នែកគុណធម៌ មានសីលគុណជាដើម ។

២-អនុជាតបុត្ត បុត្រដែលល្អតាមមាតាបិតា

៣-អវជាតបុត្ត បុត្រដែលអន់ទន់ទាបជាង មាតាបិតា ។

☞ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា : ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុត្តក្នុងលោកនេះ ជាអ្នកមិនដល់ព្រះពុទ្ធជាទីរឭក មិនដល់ព្រះធម៌ជាទីរឭក មិនដល់ព្រះសង្ឃ ជាទីរឭក មិនវៀរចាកបាណាតិបាត ។លៗ មិនវៀរចាក សុរា-មេរយមជ្ជប្បមាទដ្ឋាន ជាបុគ្គលទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក ទើបឯកូនរបស់មាតាបិតាទាំងនោះ ជាអ្នកដល់ព្រះពុទ្ធជាទីរឭក ដល់ព្រះធម៌ជាទីរឭក ដល់ព្រះសង្ឃជាទីរឭក វៀរចាកបាណាតិបាត ។លៗ វៀរចាកសុរាមេរយមជ្ជប្បមាទ-ដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ម្នាលភិក្ខុទាំងឡាយ កូននេះឯង ឈ្មោះថា អតិជាតបុត្ត ។

ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុគ្គក្នុងលោកនេះ ជាអ្នកដល់ព្រះពុទ្ធជាទីរឭក ដល់ព្រះធម៌ជាទីរឭក ដល់ព្រះសង្ឃជាទីរឭក វៀរចាកបាណាតិបាត ។ល។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ឯកូនរបស់មាតាបិតាទាំងនោះ ដល់ព្រះពុទ្ធជាទីរឭក ដល់ព្រះធម៌ជាទីរឭក ដល់ព្រះសង្ឃជាទីរឭក វៀរចាកបាណាតិបាត ។ល។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ដែរ ម្នាលភិក្ខុទាំងឡាយ កូនយ៉ាងនេះឯង ឈ្មោះថា អនុជាតបុត្ត ។

ម្នាលភិក្ខុទាំងឡាយ មាតាបិតារបស់បុគ្គក្នុងលោកនេះ ជាអ្នកដល់ព្រះពុទ្ធជាទីរឭក ដល់ព្រះធម៌ជាទីរឭក ដល់ព្រះសង្ឃជាទីរឭក វៀរចាកបាណាតិបាត ។ល។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាអ្នកមានសីល មានកល្យាណធម៌ ទើបឯកូនរបស់មាតាបិតាទាំងនោះ មិនដល់ព្រះពុទ្ធជាទីរឭក មិនដល់ព្រះធម៌ជាទីរឭក មិនដល់ព្រះសង្ឃជាទីរឭក មិនវៀរចាកបាណាតិបាត ។ល។ មិនវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ជាបុគ្គលទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក ម្នាលភិក្ខុ

ទាំងឡាយ កូនយ៉ាងនេះឯង ឈ្មោះថា អវជាតបុត្ត ។

បណ្ឌិតទាំងឡាយ តែងប្រាថ្នាអតិជាតបុត្ត និងអនុជាត-បុត្ត មិនប្រាថ្នាអវជាតបុត្ត ដែលជាកូនផ្ដាច់បង់ត្រកូលឡើយ ។ កូនទាំងនេះឯង តែងមានក្នុងលោក ម្យ៉ាងទៀត កូនទាំងឡាយណា ជាឧបាសក (កូនទាំងនោះ) ឈ្មោះថា ជាអ្នកបរិបូរណ៍ដោយសទ្ធា និងសីល ជាអ្នកដឹងពាក្យពេចន៍ ជាអ្នកប្រាសចាកសេចក្ដីកំណាញ់ រមែងរុងរឿងក្នុងពួកបរិស័ទ ដូចជាព្រះចន្ទដែលផុតស្រឡះហើយចាកដុំនៃពពកដូច្នោះ ។

(សុត្តន្តបិដក ៥៣ / ៨៦)

## វិន័យទាំងអស់មានអត្ថ ៣ ប្រការ

១-វិវិធនយត្តា ព្រោះអត្ថថា មានន័យផ្សេងៗ

២-វិសេសនយត្តា ព្រោះអត្ថថា មានន័យដ៏វិសេស

៣-កាយវាចានំ វិនយនតោ ព្រោះអត្ថថា ជាគ្រឿងកាត់ ឬទូន្មាននូវកាយនិងវាចា ។

## ភិក្ខុប្រកបដោយអង្គ ៣

**១.អលជ្ជី** ភិក្ខុមិនមានអៀនខ្មាស

**២.ពាលោ** ភិក្ខុពាល

**៣.អបកតត្តោ** ភិក្ខុមិនមែនជាបកតត្ត

- មិនត្រូវបញ្ឈប់ឧបោសថ ក្នុងកណ្ដាលជំនុំសង្ឃ
- មិនត្រូវបញ្ឈប់បវារណា ក្នុងកណ្ដាលជំនុំសង្ឃ
- សង្ឃសម្មតិណាមួយ សង្ឃមិនត្រូវឲ្យ
- មិនត្រូវស្ដីពោលរកសង្ឃ
- សង្ឃមិនត្រូវតម្កល់ទុកក្នុងតំណែងផ្សេងណាមួយ
- ភិក្ខុមិនត្រូវអាស្រ័យនៅ (ជាមួយ)
- ភិក្ខុមិនត្រូវឲ្យនិស្ស័យ
- ភិក្ខុមិនត្រូវធ្វើឱកាសកម្ម
- ភិក្ខុមិនត្រូវជឿស្ដាប់ពាក្យ
- ភិក្ខុមិនត្រូវសួរវិន័យ (ចំពោះលោក)
- មិនត្រូវសួរវិន័យ (នឹងភិក្ខុណាមួយ)

*- ភិក្ខុមិនត្រូវដោះស្រាយវិន័យ (ចំពោះលោក)*

*- មិនត្រូវដោះស្រាយវិន័យ (នឹងភិក្ខុណាមួយ)*

*- ភិក្ខុមិនត្រូវឲ្យការសាកសួរ*

*- ភិក្ខុមិនត្រូវសាកច្ឆាវិន័យជាមួយ*

*- មិនត្រូវឲ្យឧបសម្បទា មិនត្រូវឲ្យនិស្ស័យ មិនត្រូវឲ្យសាមណេរបម្រើខ្លួន ។*

*(វិនយបិដក ភាគ១៣ ទំព័រ៣៥-៣៧)*

*-មិនត្រូវបរិភោគរួម ។ (អដ្ឋកថានិស្សគ្គិយ)*

### វត្ថុ ៣ យ៉ាងបើកទើបរុងរឿង

***១-មណ្ឌលព្រះចន្ទ*** *បើកឡើងទើបរុងរឿង តែបិទបាំងទុក មិនរុងរឿង*

***២-មណ្ឌលព្រះអាទិត្យ*** *បើកឡើងទើបរុងរឿង តែបិទបាំងទុក មិនរុងរឿង*

***៣-ធម្មវិន័យដែលព្រះតថាគតសម្តែងហើយ*** *បើកឡើង ទើបរុងរឿង តែបិទបាំងទុកមិនរុងរឿង ។*

*(វិនយបិដក ១៣,២៩)*

## វិជ្ជា ៣

១-បុព្វេនិវាសញ្ញាណ ប្រាជ្ញារឭកឃើញនូវលំដាប់ខន្ធដែលសត្វអាស្រ័យនៅក្នុងកាលមុន គឺអតីតជាតិ ។

២-ចុតូបបាតញ្ញាណ ប្រាជ្ញាដឹងនូវចុតិនិងបដិសន្ធិរបស់សត្វ ។

៣-អាសវក្ខយញ្ញាណ ប្រាជ្ញាដឹងនូវធម៌ដែលធ្វើអាសវៈឲ្យអស់ទៅ ។

## ប្រយោជន៍ ៣ យ៉ាង

១-ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍ក្នុងលោកនេះ ។

២-សម្បរាយិកត្ថៈ ប្រយោជន៍ក្នុងលោកខាងមុខនេះ។

៣-បរមត្ថៈ ប្រយោជន៍ដ៏ខ្ពង់ខ្ពស់ គឺព្រះនិព្វាន ។

## ញាណ ៣ យ៉ាង

១-សច្ចញ្ញាណ : សេចក្តីដឹងតាមពិត ក្នុងសច្ចទាំង ៤, យ៉ាងនេះថា នេះទុក្ខអរិយសច្ច នេះទុក្ខសមុទយអរិយសច្ច

នេះទុក្ខនិរោធអរិយសច្ច នេះទុក្ខនិរោធគាមិនីបដិបទាអរិយ-សច្ច ឈ្មោះថា សច្ចញ្ញាណ ។

២-កិច្ចញ្ញាណ : ញាណ គឺសេចក្ដីដឹងកិច្ចដែលគួរធ្វើ, យ៉ាងនេះថា គួរកំណត់ដឹង គួរលះ គួរធ្វើឲ្យជាក់ច្បាស់ គួរចម្រើន ឈ្មោះថា កិច្ចញ្ញាណ ។

៣-កតញ្ញាណ : ញាណ គឺការដឹងសេចក្ដីដែលសច្ចៈនោះបានធ្វើហើយ, យ៉ាងនេះថា បានកំណត់ដឹងហើយ បានលះហើយ បានធ្វើឲ្យជាក់ច្បាស់ហើយ បានចម្រើនហើយ ឈ្មោះថា កតញ្ញាណ ។

## បាដិហារ្យ ៣ យ៉ាង

១-ឥទ្ធិបាដិហារ្យ : ការសម្ដែងឫទ្ធិដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា "ភិក្ខុក្នុងសាសនានេះ រមែងបាននូវការតាក់តែង ឬសម្ដែងឫទ្ធច្រើនប្រការបាន គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ធ្វើទីវាលឲ្យទៅជាទីកំបាំងក៏បាន ដើរ(ទម្លុះ)ទៅក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំ ឥតទើសទាល់ ដូចដើរទៅ

ក្នុងអាកាសក៏បាន ធ្វើនូវការមុជងើបក្នុងផែនដី ដូចមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹក ឥតបែកធ្លាយទឹក ដូចជាដើរលើផែនដីក៏បាន អណ្តែតទៅឯអាកាសទាំងភ្នែន ដូចជាសត្វស្លាបក៏បាន ចាប់ស្ទាបអង្អែលព្រះចន្ទ្រ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយដៃក៏បាន ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយរហូតដល់ព្រហ្មលោកក៏បាន" ឈ្មោះថា **ឥទ្ធិបាដិហារ្យ** ។

២-អាទេសនាបាដិហារ្យ : ការដឹងចិត្តរបស់អ្នកដទៃ ដឹងសេចក្តីត្រិះរិះក្នុងចិត្ត ដឹងការនឹកគិត ដឹងការពិនិត្យពិច័យរបស់សត្វដទៃ របស់បុគ្គលដទៃណាថា ចិត្តរបស់លោកជាយ៉ាងនេះ ចិត្តរបស់លោកប្រព្រឹត្តទៅដោយអាការយ៉ាងនេះដូច្នេះ ហើយនិយាយដែលប្រព្រឹត្តទៅដោយន័យជាដើមថា "ភិក្ខុក្នុងធម្មវិន័យនេះ រមែងកំណត់ដឹងច្បាស់នូវចិត្តរបស់សត្វដទៃ បុគ្គលដទៃ ដោយចិត្តរបស់ខ្លួន គឺចិត្តប្រកបដោយរាគៈក្តីដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ, ចិត្តដែលប្រាសចាករាគៈក្តី... ចិត្តដែលប្រកបដោយទោសៈក្តី... ចិត្តដែលប្រាសចាកទោសៈក្តី... ចិត្តដែលប្រកបដោយមោហៈក្តី... ចិត្តដែលប្រាស

*ចាកមោហៈក្តី... ចិត្តដែលរួញរាក្តី... ចិត្តដែលរាយមាយក្តី... ចិត្តដែលជាមហគ្គតៈក្តី... ចិត្តដែលមិនមែនជាមហគ្គតៈក្តី... ចិត្តដែលជាសឧត្តរៈក្តី... ចិត្តដែលជាលោកុត្តរៈក្តី... ចិត្តដែលតាំងមាំក្តី... ចិត្តដែលមិនតាំងមាំក្តី... ចិត្តដែលរួចចាកកិលេសក្តី... ចិត្តមិនរួចចាកកិលេសក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចចាកកិលេស" ឈ្មោះថា* ***អាទេសនាបាដិហារ្យ*** *។*

៣-អនុសាសនីបាដិហារ្យ : *ការសម្តែងធម៌ដែលគប្បីសម្តែងរហូតអស់កាលទាំងពួង របស់ព្រះសាវកទាំងឡាយ និងរបស់ព្រះពុទ្ធទាំងឡាយ ដែលប្រព្រឹត្តទៅដោយន័យមានជាដើមយ៉ាងនេះថា "ភិក្ខុក្នុងធម្មវិន័យនេះ រមែងប្រៀនប្រដៅយ៉ាងនេះថា លោកចូរត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនោះ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ កុំធ្វើទុកក្នុងចិត្តយ៉ាងនោះ ចូរលះបង់វត្ថុនេះ ចូរកាន់យកវត្ថុនេះចុះ" ឈ្មោះថា អនុសាសនីបាដិហារ្យ ។*

*(សុត្តន្ត. ភាគ៤៦ ទំព័រ០៣, សារត្ថ. ភាគ៣ ទំព័រ២៥០)*

# ពួក៤

## ធម្មុទ្ទេស ៤ យ៉ាង

១-ឧបនីយតិ លោកោ អទ្ធុវោ *សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ(រកមរណៈ)*

២-អតាណោ លោកោ អនភិស្សរោ *សត្វលោក មិនមានគ្រឿងការពារ មិនមានទីពឹងឡើយ*

៣-អស្សកោ លោកោ សព្វំ បហាយ គមនីយំ *សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវលះបង់របស់ទាំងពួងហើយទៅ*

៤-ឩនោ លោកោ អតិត្តោ តណ្ហាទាសោ *សត្វលោកមានតែសេចក្តីខ្វះខាតមិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ។* *(សុត្តន្ត. ២៤ / ២៩៨)*

## អារក្ខកម្មដ្ឋាន ៤

១-ពុទ្ធានុស្សតិ *រលឹកដល់គុណព្រះពុទ្ធ*

២-មេត្តា ផ្សាយមេត្តា

៣-អសុភៈ ចម្រើនអសុភកម្មដ្ឋាន

៤-មរណស្សតិ រលឹកដល់សេចក្តីស្លាប់ ។

## សេចក្តីស្លាប់ ៤ យ៉ាង

១-អាយុក្ខយ ព្រោះអស់អាយុ

២-កម្មក្ខយ ព្រោះអស់កម្ម

៣-ឧភយក្ខយ ព្រោះអស់អាយុនិងកម្មទាំងពីរ

៤-ឧបច្ឆេទក ព្រោះប្រសព្វឧបទ្រវហេតុ អាយុ និង កម្មនូវមិនទាន់អស់ ។ (បរមត្ថជោតិក ៥ / ២៦៨)

## ចក្កធម៌ ៤ យ៉ាង

១-បដិរូបទេសវាសោ ការនៅក្នុងប្រទេសដ៏សមគួរ

២-សប្បុរិសូបស្សយោ ការចូលទៅសេពគប់ នឹងពួកសប្បុរស

៣-អត្តសម្មាបណិធិ ការតម្កល់ខ្លួនទុកដោយល្អ

៤-បុព្វេ ច កតបុញ្ញតា ភាពនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ។

ម្នាលភិក្ខុទាំងឡាយ ចក្រនេះមាន ៤ យ៉ាង ចក្រ ៤ នេះតែងប្រព្រឹត្តទៅដល់ពួកទេវតា និងមនុស្សដែលប្រកបព្រមដោយចក្រ ពួកទេវតានិងមនុស្សដែលប្រកបដោយចក្រហើយមិនយូរប៉ុន្មានគង់បានដល់នូវភាវៈនៃខ្លួនជាធំទូលាយ ក្នុងភោគៈទាំងឡាយ ។

*ជនណា នៅក្នុងប្រទេសដ៏សមគួរ សេពគប់នូវមិត្តដ៏ប្រសើរ ប្រកបដោយការតម្កល់ទុកនូវខ្លួនដោយល្អបាន ធ្វើបុណ្យទុកក្នុងកាលមុន ធញ្ញជាត ទ្រព្យ យសសេចក្ដីសរសើរ សុខ តែងឃុំគ្រងនូវជននុ៎ះ ។*

(សុត្តន្តបិដក ៤២, ៧៩)

## អដ្ឋកថាចក្កសូត្រ

បទថា ចក្កានិ គឺ សម្បត្តិ ។ បទថា ចតុចក្កំ វត្តតិ សេចក្ដីថា ចក្រគឺ សម្បត្តិ ៤ រមែងវិលបន្តគ្នាទៅ ។ បរិស័ទ ៤ រមែងប្រាកដព្រមក្នុងអាវាសណា ការនៅក្នុងអាវាសដែល

សមគួរបែបនោះ ឈ្មោះថា **បដិរូបទេសវាសៈ** ការនៅក្នុងប្រទេសដែលសមគួរ ។ ការពឹងផ្អែកគប់រកសប្បុរស មានព្រះពុទ្ធជាដើម ឈ្មោះថា **សប្បុរិសូបស្សយៈ** ការចូលទៅសេពគប់សប្បុរស ។ ការតម្កល់ខ្លួនទុកដោយប្រពៃ គឺ បើជាអ្នកប្រកបដោយការមិនមានសទ្ធាជាដើមមកមុន ការលះភាពមិនមានសទ្ធាទាំងនោះចេញ ហើយតាំងនៅក្នុងសទ្ធាជាដើម ឈ្មោះថា **អត្តសម្មាបណិធិ** ការតម្កល់ខ្លួនទុកដោយប្រពៃ ។ ភាពជាអ្នកមានកុសលដែលសន្សំទុកក្នុងកាលមុន ឈ្មោះថា បុព្វេ ច កតបុញ្ញតា ភាពជាអ្នកធ្វើបុណ្យមកមុន ។ សេចក្តីនេះឯងកាន់យកជាប្រមាណក្នុងចក្រ ៤ នេះ ។ ព្រោះថា កុសលកម្មប៉ុណ្ណោះ ដែលអ្នកណាធ្វើដោយចិត្តដែលសម្បយុត្តដោយញាណយ៉ាងណា កុសលចិត្តនោះឯង រមែងនាំអ្នកនោះចូលទៅនៅក្នុងប្រទេសដ៏សមគួរ ឲ្យគេគប់រកសប្បុរស ។ ក៏បុគ្គលនោះឈ្មោះថា តម្កល់ខ្លួនទុកដោយប្រពៃ ដោយអាការយ៉ាងនេះ ។ បទថា បុញ្ញកតោ ប្រែថា បានធ្វើបុណ្យទុកហើយ ។ បទថា សុខញ្ចេតំ អធិវត្តតិ សេចក្តីថា ក៏

សេចក្ដីសុខ រមែងឃុំគ្រង គឺ ផ្សាយចុះមកកាន់បុគ្គលនោះ ដូច្នេះ ។ (ចាកអដ្ឋកថា មនោរថបូរណី)

## សង្គហវត្ថុមាន ៤ យ៉ាង

១–ទានំ ការឲ្យទាន

២–បេយ្យវជ្ជំ ការពោលពាក្យគួរស្រឡាញ់បាន

៣–អត្ថចរិយា ការប្រព្រឹត្តិជាប្រយោជន៍

៤–សមានត្តតា ភាពនៃបុគ្គលអ្នកមានខ្លួនស្មើ ។

ការឲ្យទាន ១ ការពោលពាក្យគួរស្រឡាញ់បាន ១ ការប្រព្រឹត្តិជាប្រយោជន៍ ១ ភាពនៃបុគ្គលអ្នកមានខ្លួនស្មើ ១ ដែលមានក្នុងលោកនេះ តាមសមគួរក្នុងធម៌ទាំងឡាយនោះៗ បើសង្គហវត្ថុទាំងឡាយនេះ មានក្នុងលោក ដូចជាភ្លៅរបស់រថដែលអាចវិលទៅបាន ។ បើពួកសង្គហៈនេះ មិនមានទេ មាតាមិនគួរបាននូវសេចក្ដីរាប់អាន ឬការបូជាអំពីបុត្រ បិតា ក៏មិនគួរបាននូវសេចក្ដីរាប់អាន ឬការបូជាអំពីបុត្រ (ប្រុស ស្រី) ឡើយ ព្រោះហេតុណា ហេតុនោះ បានជាបណ្ឌិតទាំងឡាយ

តែងសម្លឹងមើលនូវសង្គហៈទាំងឡាយនេះ បណ្ឌិតទាំងឡាយនោះ ក៏បានដល់នូវភាពនៃខ្លួនជាធំផង ជាបុគ្គល គួរសរសើរផង ។ (សុត្តន្ត. ៤២,៨០)

## របស់ដែលឆ្ងាយក្រៃលែងឆ្ងាយ

១-មេឃនិងផែនដី

២-ត្រើយសមុទ្រខាងអាយនិងត្រើយសមុទ្រខាងនាយ

៣-ព្រះអាទិត្យរះឡើងអំពីទិសណា អស្តង្គតទៅក្នុងទិសណា

៤-ធម៌របស់ពួកសប្បុរសនិងធម៌របស់ពួកអសប្បុរស ។

## គិហិសុខ ៤ យ៉ាង

១-អត្ថិសុខ សុខព្រោះចេះតែមាន (ភោគៈដែលបានមកដោយធម៌)

២-ភោគសុខ សុខព្រោះចេះប្រើប្រាស់ (គឺប្រើប្រាស់នូវភោគៈទាំងឡាយផង ធ្វើបុណ្យទាំងឡាយផង)

៣-អនណសុខ សុខព្រោះមិនជំពាក់បំណុលគេ

៤-អនវជ្ជសុខ សុខព្រោះមិនមានទោស ។

បុគ្គលដឹងនូវសុខដែលមិនមានបំណុលក្តី រលឹកឃើញនូវសុខដែលមានភោគៈក្តី ពិចារណាឃើញនូវសុខដែលកំពុងប្រើប្រាស់នូវភោគៈដោយប្រាជ្ញាក្តី កាលពិចារណាឃើញច្បាស់ រមែងដឹងនូវចំណែកទាំងពីរ ដោយប្រាជ្ញាដ៏ប្រពៃថា សុខ(ទាំង៣)នុ៎ះ មិនដល់នូវចំណែកមួយក្នុងចំណែកទី ១៦ របស់អនវជ្ជសុខឡើយ ។

(សុត្តន្ត. ៤២ / ១៧០-១៧៣)

## កម្មដ៏សមគួរ ៤ យ៉ាងដោយភោគៈទាំងឡាយ

ព្រះមានព្រះភាគ ត្រាស់ថា ៖

ម្នាលគហបតិ អរិយសាវកនោះ ជាអ្នកធ្វើកម្មដ៏សមគួរ ៤ ប្រការ ដោយភោគៈទាំងឡាយ ដែលអរិយសាវក បានដោយសេចក្តីព្យាយាម ពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌បានមកដោយធម៌ ។

កម្មដ៏សម គួរ ៤ ប្រការ ដូចម្តេច ។

ម្នាលគហបតី អរិយសាវក ក្នុងសាសនានេះ ញុំាងខ្លួន

ឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងមាតាបិតាឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងកូនប្រពន្ធនិងបុរសជាទាសកម្មករ ឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ញុំាងមិត្តអមាត្យ ឲ្យសុខ ឲ្យឆ្អែត រក្សាសុខដោយប្រពៃ ដោយភោគៈទាំងឡាយដែលបានមកដោយសេចក្ដីព្យាយាម ពោលគឺសេចក្ដីខ្នះខ្នែង សន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញជារបស់ប្រកបដោយធម៌បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ១ ដែលអរិយសាវកនោះ បានដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។

ម្នាលគហបតី ប្រការមួយទៀត សេចក្ដីអន្តរាយណា ដែលកើតអំពីភ្លើងក្ដី អំពីទឹកក្ដី អំពីស្ដេចក្ដី អំពីចោរក្ដី អំពីបុគ្គលមិនជាទីស្រលាញ់ក្ដី អំពីអ្នកទទួលមរតកក្ដី អរិយសាវកក៏ការពារទប់ទល់ចំពោះអន្តរាយមានសភាពដូច្នេះ បានដោយភោគៈទាំងឡាយ ធ្វើខ្លួនឲ្យដល់នូវសួស្ដីបាន ក៏ដោយភោគៈទាំងឡាយ ដែលបានមកដោយសេចក្ដីព្យាយាម ពោលគឺសេចក្ដីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។

នេះចាត់ជាហេតុទី ២ ដែលអរិយសាវកនោះ បានដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។

ម្នាលគហបតី ប្រការមួយទៀត អរិយសាវកធ្វើពលិកម្មទាំង ៥ គឺញាតិពលិ ១ អតិថិពលិ ១ បុព្វបេតពលិ ១ រាជពលិ ១ទេវតាពលិ ១ ដោយភោគៈទាំងឡាយ ដែលបានមកដោយព្យាយាមពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ៣ ដែលអរិយសាវកនោះបានដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។

ម្នាលគហបតី ប្រការមួយទៀត ពួកសមណព្រាហ្មណ៍ណា វៀរចាកសេចក្តីវង្វេង និងសេចក្តីប្រមាទ ឋិតនៅក្នុងខន្តិ និងសោរច្ចៈ ទូន្មានតែខ្លួនមួយ រម្ងាប់កិលេសចំពោះខ្លួនមួយ ញ៉ាំងតែខ្លួនមួយឲ្យបរិនិព្វាន អរិយសាវក រមែងញ៉ាំងទក្ខិណាទាន មានផលដ៏ខ្ពស់ប្រសើរ នាំឲ្យទៅកើតក្នុងស្ថានសួគ៌ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ ឲ្យប្រតិស្ឋាននៅក្នុងពួកសមណព្រាហ្មណ៍ មានសភាពដូច្នោះ បានដោយភោគៈ

ទាំងឡាយ ដែលបានមកដោយព្យាយាម ពោលគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ប្រកបដោយធម៌ បានមកដោយធម៌ ។ នេះចាត់ជាហេតុទី ៤ ដែលអរិយសាវកនោះ បានដល់ហើយ បានសម្រេចហើយ បរិភោគហើយ ដោយទំនងដ៏សមគួរ ។

ម្នាលគហបតី អរិយសាវកនោះឯង ជាអ្នកធ្វើកម្មដ៏សមគួរទាំង ៤ ប្រការនេះ បានដោយភោគៈទាំងឡាយដែលបានមក ដោយព្យាយាមពោកគឺសេចក្តីខ្នះខ្នែង ដែលសន្សំបានមកដោយកម្លាំងដៃ មានញើសហូរចេញ ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ ។ ម្នាលគហបតី ភោគៈទាំងឡាយរបស់បុគ្គលណាមួយ តែវៀរលែងចាកកម្មដ៏សមគួរទាំង ៤ ប្រការចេញហើយ រមែងដល់នូវការអស់ទៅ ម្នាលគហបតី ភោគៈទាំងឡាយនេះ ហៅថា មិនដល់នូវហេតុដ៏សមគួរ មិនបានសម្រេច មិនបានបរិភោគដោយទំនងដ៏សមគួរ ។ ម្នាលគហបតី ភោគៈទាំងឡាយរបស់បុគ្គលណា អស់ទៅដោយកម្មដ៏សមគួរទាំង ៤ នេះ ម្នាលគហបតី ភោគៈទាំងនេះ ហៅថា ដល់នូវហេតុដ៏សមគួរ បានសម្រេច បានបរិភោគដោយទំនងដ៏សមគួរ ។

*ភោគៈទាំងឡាយ អាត្មាអញបរិភោគហើយ មិត្តអមាត្យ អាត្មាអញចិញ្ចឹមហើយ អាត្មាអញឆ្លងអន្តរាយទាំងឡាយបានហើយ ទក្ខិណាទានមានផលដ៏ខ្ពស់ប្រសើរ អាត្មាអញបានឲ្យហើយ ឯពលីទាំង ៥ អាត្មាអញបានធ្វើហើយ អ្នកមានសីល មានសេចក្តីសង្រួម មានព្រហ្មចរិយធម៌ អាត្មាអញបានទំនុកបំរុងហើយ បណ្ឌិតកាលនៅគ្រប់គ្រងផ្ទះ គប្បីប្រាថ្នាភោគៈ ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ អាត្មាអញបានសម្រេចហើយ កម្មដែលមិននាំឲ្យកើតសេចក្តីក្តៅក្រហាយ អាត្មាអញបានធ្វើហើយ ជនអ្នកមានសេចក្តីស្លាប់ជាធម្មតា កាលរលឹកឃើញនូវប្រយោជន៍នុ៎ះ រមែងឋិតនៅក្នុងអរិយធម៌ បណ្ឌិតទាំងឡាយ រមែងសរសើរជននោះ ក្នុងលោកនេះដោយពិត ជននោះលុះលះលោកនេះទៅ រមែងត្រេកអរក្នុងឋានសួគ៌ ។*

*(សុត្តន្តបិដក ៤២, ១៦៦-១៧០)*

## បុគ្គលជ្រះថ្លា ៤ ពួក

១-រូបប្បមាណោ រូបប្បសន្នោ បុគ្គលជ្រះថ្លាក្នុងរូប ឈ្មោះថា រូបប្បមាណ

២–ឃោសប្បមាណោ ឃោសប្បសន្នោ ជ្រះថ្លាក្នុងសំឡេង ឈ្មោះថា ឃោសប្បមាណ

៣–លូខប្បមាណោ លូខប្បសន្នោ ជ្រះថ្លាក្នុងវត្ថុសៅហ្មង(របស់ចីវរនិងបាត្រ) ឈ្មោះថា លូខប្បមាណ

៤–ធម្មប្បមាណោ ធម្មប្បសន្នោ ជ្រះថ្លាក្នុងធម៌ ឈ្មោះថា ធម្មប្បមាណ ។ (សុត្តន្ត. ៤២,១៧៥)

## អដ្ឋកថារូបសូត្រ

បុគ្គលកាន់យកប្រមាណក្នុងធម៌ ហើយជ្រះថ្លា ឈ្មោះ **ធម្មប្បមាណ** ។ បទក្រៅពីនេះ ជាវេវចនៈសេចក្ដីរបស់បទទាំងនោះឯង ។ ចែកសត្វទាំងអស់ចេញជាបីចំណែក ពីរចំណែកកាន់យករូបជាប្រមាណ មួយចំណែកមិនកាន់យករូបជាប្រមាណទេ ។ ចែកសត្វទាំងអស់ចេញជាប្រាំចំណែក បួនចំណែកកាន់យកសំឡេងជាប្រមាណ មួយចំណែកមិនកាន់យកសំឡេង ជាប្រមាណទេ ។ ចែកសត្វទាំងអស់ចេញជាដប់ចំណែក ប្រាំបួនចំណែកកាន់យកសេចក្ដីសៅហ្មងជាប្រមាណ មួយចំណែកមិនកាន់យកសេចក្ដីសៅហ្មងជាប្រមាណទេ ។

សតសហស្សំ កោដ្ឋាសេ កត្វា បន ឯកោ កោដ្ឋាសោវ ធម្មប្បមាណោ, សេសា ន ធម្មប្បមាណាតិ វេទិតព្វា ។ *កាលបែកសត្វទាំងអស់ចេញជា ១ សែនចំណែក តែមួយចំណែកប៉ុណ្ណោះ កាន់យកធម៌ជាប្រមាណ, ដ៏សេស គប្បីជ្រាបថា មិនកាន់យកធម៌ជាប្រមាណទេ ។*

*បទថា* រូបេ បមាណឹសុ *សេចក្ដីថា បុគ្គលពួកណា ឃើញរូបហើយជ្រះថ្លា បុគ្គលទាំងនោះ ឈ្មោះថា កាន់រូបជាប្រមាណ អធិប្បាយថា រាប់អានហើយ ។ បទថា* ឃោសេន អន្វគូ *សេចក្ដីថា បុគ្គលពួកណាហូរទៅតាមសំឡេង អធិប្បាយថា បុគ្គលទាំងនោះកាន់យកសំឡេងជាប្រមាណ ហើយទើបជ្រះថ្លា ។ បទថា* ឆន្ទរាគវសូបេតា *បានដល់ ធ្លាក់នៅក្នុងអំណាចសេចក្ដីពេញចិត្ត និងស្រឡាញ់ចេញហើយ ។ បទថា* អជ្ឈត្តញ្ច ន ជានាតិ *សេចក្ដីថា អ្នកល្ងង់ រមែងមិនស្គាល់គុណខាងក្នុងរបស់គេ ។ បទថា* ពហិទ្ធា ច ន បស្សតិ *សេចក្ដីថា រមែងមិនឃើញការបដិបត្តិខាងក្រៅរបស់*

*គេ ។ បទថា សមន្តាវរណោ បានដល់ ត្រូវសំឡេងបិទបាំង ដោយជុំវិញ ។ មួយយ៉ាងទៀត ឈ្មោះថា សមន្តាវរណៈ ព្រោះសំឡេងរារាំងទុកជុំវិញ ។ បទថា* យោសេន វុយ្ហតិ *សេចក្ដីថា អ្នកល្ងង់នោះទើបត្រូវសំឡេងដឹកនាំទៅ មិនមែនត្រូវគុណនាំទៅទេ ។ បទថា* អជ្ឈត្តញ្ច ន ជានាតិ, ពហិទ្ធា ច វិបស្សតិ *សេចក្ដីថា បុគ្គលមិនដឹងគុណខាងក្នុង តែឃើញការបដិបត្តិខាងក្រៅរបស់គេ ។ បទថា* ពហិទ្ធា ផលទស្សាវី *សេចក្ដីថា ឃើញផលសក្ការៈខាងក្រៅដែលបុគ្គលដទៃធ្វើដល់គេ ។ បទថា* វិធីវរណាទស្សាវី *សេចក្ដីថា ឃើញដូចមិនមានអ្វីបិទបាំង ។ បទថា* ន សោ យោសេន វុយ្ហតិ *សេចក្ដីថា បុគ្គលនោះ ទើបមិនត្រូវសំឡេងដឹកនាំទៅ ។ (ចាកអដ្ឋកថា មនោរថបូរណី)*

## ការប្រតិបត្តិមិនខុស ៤ យ៉ាង

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថា ជាអ្នកប្រតិបត្តិចំពោះអបណ្ណកបដិបទា គឺ ប្រតិបត្តិ*

*មិនខុសផង ភិក្ខុនោះ ឈ្មោះថា ជាអ្នកប្រារព្ធហេតុ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយផង ។*

១-សីលវា ហោតិ *ជាអ្នកមានសីល*

២-ពហុស្សុតោ ហោតិ *ជាអ្នកចេះដឹងច្រើន*

៣-អារទ្ធវីរិយោ ហោតិ *ជាអ្នកមានព្យាយាមប្រារព្ធ*

៤-បញ្ញវា ហោតិ *ជាអ្នកមានប្រាជ្ញា ។*

### *៤ យ៉ាងទៀត*

១-នេក្ខម្មវិតក្កោ *សេចក្ដីត្រិះរិះ ក្នុងការចេញចាកកាម*

២-អព្យាបាទវិតក្កោ *សេចក្ដីត្រិះរិះ ក្នុងការមិនព្យាបាទ*

៣-អវិហឹសាវិតក្កោ *សេចក្ដីត្រិះរិះ ក្នុងការមិនបៀតបៀន*

៤-សម្មាទិដ្ឋិយា *សេចក្ដីឃើញត្រូវ ។ (៤២, ១៨៩)*

## ទក្ខិណាវិសុទ្ធិ ៤

*១-ទក្ខិណា បរិសុទ្ធិអំពីទាយក មិនបរិសុទ្ធិអំពីបដិគ្គាហកៈ ក៏មាន ។*

*(ទាយក មានសីល មានកល្យាណធម៌ តែបដិគ្គាហកៈ ជាអ្នកទ្រុស្តសីល មានបាបធម៌)*

*២-ទក្ខិណា បរិសុទ្ធិអំពីបដិគ្គាហកៈ មិនបរិសុទ្ធិអំពីទាយក ក៏មាន ។*

*(ទាយក ជាអ្នកទ្រុស្តសីល មានបាបធម៌ តែបដិគ្គាហកៈ ជាអ្នកមានសីល មានកល្យាណធម៌)*

*៣-ទក្ខិណា មិនបរិសុទ្ធិអំពីទាយក ទាំងមិនបរិសុទ្ធិអំពីបដិគ្គាហកៈ ក៏មាន ។*

*(ទាយក ជាអ្នកទ្រុស្តសីល មានបាបធម៌ ទាំងបដិគ្គាហកៈ ក៏ជាអ្នកទ្រុស្តសីល មានបាបធម៌)*

*៤-ទក្ខិណា បរិសុទ្ធិអំពីទាយកផង បរិសុទ្ធិអំពី បដិគ្គាហកៈផង ក៏មាន ។*

*(ទាយក ជាអ្នកមានសីល មានកល្យាណធម៌ បដិគ្គាហកៈ ក៏ជាអ្នកមានសីល មានកល្យាណធម៌ដូចគ្នា) ។*

## អដ្ឋកថាទក្ខិណាសូត្រ

បទថា ទក្ខិណាវិសុទ្ធិយោ បានដល់ ហេតុទាំងឡាយនៃសេចក្ដីបរិសុទ្ធិរបស់ទក្ខិណា គឺ ទាន ។ បទថា ទាយកតោ វិសុជ្ឈតិ សេចក្ដីថា រមែងបរិសុទ្ធិដោយការមានផលច្រើន ។ បទថា កល្យាណធម្មោ គឺ ជាអ្នកមានធម៌ដែលស្អាត ។

បទថា ទាបធម្មោ គឺជាអ្នកមានធម៌លាមក ។ ក្នុងបទថា ទាយកតោ វិសុជ្ឈតិ នេះ គួរពោលដល់វេស្សន្តរមហារាជ ។ បានឮថា វេស្សន្តរមហារាជនោះ ឲ្យទារកដល់ព្រាហ្មណ៍ឈ្មោះជូជក ធ្វើមហាប្រថពីឲ្យញ័រហើយ ។ ក្នុងបទថា បដិគ្គាហកតោ វិសុជ្ឈតិ នេះ គួរពោលដល់អ្នកប្រមង់ (កេវដ្ដ) អ្នកនៅត្រង់ទ្វារមាត់ទន្លេកល្យាណី ។ បានឮថា អ្នកប្រមង់នោះ បានថ្វាយបិណ្ឌបាតបីគ្រាដល់ព្រះទីឃសុមនត្ថេរដេកលើគ្រែមរណៈ ពោលថា បិណ្ឌបាតដែលបានថ្វាយដល់ព្រះអង្គម្ចាស់ទីឃសុមនត្ថេរ លើកយើងឡើងបាន ។

ក្នុងបទថា នេវ ទាយកតោ នេះ គួរពោលដល់នាយព្រានអ្នកនៅស្រុក**វឌ្ឍមាន** បានឮថា នាយព្រាននោះ កាល

*ធ្វើបុណ្យឧទ្ទិសដើម្បីអ្នកដែលស្លាប់ហើយ ទើបបានឲ្យដល់បដិគ្គាហកទ្រុស្តសីលម្នាក់បីគ្រា ។ ក្នុងគ្រាទីបី អមនុស្ស (អ្នកស្លាប់ទៅកើតជាប្រេត) ស្រែកថា បដិគ្គាហកទ្រុស្តសីលប្លន់យើងដូច្នេះ ។ ទក្ខិណាដល់អ្នកស្លាប់នោះ ក្នុងវេលាដែលទក្ខិណាដែលគេថ្វាយដល់ភិក្ខុដែលមានសីលមួយរូបហើយ ។ ក្នុងបទថា* នាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច *នេះ បណ្ឌិតគួរពោលអសទិសទាន ។*

*(ចាកអដ្ឋកថា មនោរថបូរណី ៣៥,២៣៧)*

## បុគ្គល ៤ ពួក

១-តមោ តមបរាយនោ *បុគ្គលងងឹត មានងងឹតទៅខាងមុខ*

២-តមោ ជោតិបរាយនោ *បុគ្គលងងឹត មានពន្លឺទៅខាងមុខ*

៣-ជោតិ តមបរាយនោ *បុគ្គលភ្លឺ មានងងឹតទៅខាងមុខ*

៤–ជោតិ ជោតិបរាយនោ *បុគ្គលភ្លឺ មានពន្លឺទៅខាងមុខ ។* *(សុត្តន្ត. ២៩, ២៥៣)*

## បុគ្គល ៤ ពួកនេះ រមែងមានក្នុងលោក

១–ឱណតោណតោ *បុគ្គលទាបកាន់តែទាបទៅ*

២–ឱណតុណ្ណតោ *បុគ្គលទាបត្រឡប់ទៅជាខ្ពស់វិញ*

៣–ឧណ្ណតោណតោ *បុគ្គលខ្ពស់ត្រឡប់មកជាទាបវិញ*

៤–ឧណ្ណតុណ្ណតោ *បុគ្គលខ្ពស់កាន់តែខ្ពស់ឡើង ។*

*(សុត្តន្ត. ៤២,២១៣)*

## សមណៈ ៤ ពួក

១–សមណមចលោ *សមណៈមិនរំភើប*

*(ភិក្ខុក្នុងសាសនានេះ ជាសេក្ខៈ អ្នកប្រតិបត្តិ ប្រាថ្នានូវធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ)* ។

២–សមណបុណ្ឌរីកោ *សមណៈឈូកស*

*(ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់*

*អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន តែមិនទាន់ពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយ) ។*

៣-សមណបទុមោ *សមណៈឈូកក្រហម*

*(ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ។បេ។ ទាំងបានពាល់ត្រូវនូវវិមោក្ខ ៨ ដោយនាមកាយទៀតផង) ។*

៤-សមណេសុ សមណសុខុមាលោ *សមណៈចម្រើនដោយសុខ ក្នុងពួកសមណៈ ។*

*(ភិក្ខុក្នុងសាសនានេះ បើទាយកអង្វរ ទើបប្រើប្រាស់ចីវរ- បិណ្ឌបាត- សេនាសន- គិលានប្បច្ចយភេសជ្ជបរិក្ខារច្រើន បើគេមិនអង្វរទេ ក៏ប្រើប្រាស់តិច ជាដើម) ។*

*(សុត្តន្ត. ៤២,២១៦-២២០)*

## ភ័យនេះមាន ៤ យ៉ាង

**១-អត្តានុវាទភ័យ** *(ភ័យអំពីការតិះដៀលខ្លួនឯង)*

**២-បរានុវាទភ័យ** *(ភ័យអំពីការតិះដៀលរបស់បុគ្គលដទៃ)*

**៣-ទណ្ឌភ័យ** *(ភ័យអំពីទណ្ឌកម្ម)*

*៤-ទុគ្គតិភ័យ (ភ័យអំពីទុគ្គតិ គឺអបាយទាំង ៤)*

## ភ័យនេះមាន ៤ យ៉ាងរមែងមានប្រាកដ ដល់បុគ្គលអ្នកចុះទឹក

១-ឩមិភយំ *ឩមិភ័យ (ភ័យអំពីរលកទឹក)*

២-កុម្ភីលភយំ *កុម្ភីលភ័យ (ភ័យអំពីក្រពើ)*

៣-អាវដ្ដភយំ *អាវដ្ដភ័យ(ភ័យអំពីទឹកក្ដួចវិលវល់)*

៤-សុសុកាភយំ *សុសុកាភ័យ(ភ័យអំពីត្រីកាច) ។*

*ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាងនេះឯង រមែងមានប្រាកដដល់បុគ្គលកាលចុះទឹក ។*

*ម្នាលភិក្ខុទាំងឡាយ ភ័យនេះមាន ៤ យ៉ាង រមែងមានប្រាកដដល់កុលបុត្រខ្លះ ក្នុងសាសនានេះ ដែលមានសទ្ធាក្នុងធម្មវិន័យនេះ ចេញចាកផ្ទះចូលកាន់ផ្នួស ក៏យ៉ាងនោះដែរ ។ ភ័យ ៤ យ៉ាង ដូចម្ដេចខ្លះ ។ គឺឩមិភ័យ ១ កុម្ភីលភ័យ ១ អាវដ្ដភ័យ ១ សុសុកាភ័យ ១ ។ល។*

*(សុត្តន្តបិដក ៤២, ៣០៩-៣១៥)*

## ភិក្ខុប្រកបដោយធម៌ ៤ ប្រការ

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ ប្រការ ទើបជាអ្នកគួរទទួលគ្រឿងដែលគេនាំមកបូជា គួរទទួលរបស់ដែលគេទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរគេធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ក៏ដូច្នោះដែរ ។*

*ប្រកបដោយអង្គ ៤ តើអ្វីខ្លះ ។*

១–ឋានកុសលោ *ជាអ្នកឈ្លាសក្នុងជយភូមិ,*

*(ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ល។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ) ។*

២–ទូរេបាតី *ជាអ្នកបាញ់បានឆ្ងាយ ,*

*(ភិក្ខុក្នុងសាសនានេះ ឃើញដោយបញ្ញាដ៏ប្រពៃតាមពិតនូវរូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជារូបក្នុងខ្លួនក្តី ក្រៅខ្លួនក្តី គ្រោតគ្រាតក្តី ល្អិតក្តី អាក្រក់ក្តី ល្អក្តី នៅឆ្ងាយក្តី នៅជិតក្តី ទាំងអស់នុ៎ះ យ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនខ្លួនអញ, វេទនា... សញ្ញា... សង្ខារទាំងឡាយ... វិញ្ញាណ...) ។*

៣-អក្ខណវេធី *ជាអ្នកបាញ់ត្រង់,*

*(ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទាប្រព្រឹត្តទៅ ដើម្បីរលត់ទុក្ខ) ។*

៤-មហតោ ច កាយស្ស បទាលេតា *ជាអ្នកទំលាយនូវកងព័ទដ៏ធំបាន,*

*(ភិក្ខុក្នុងសាសនានេះ ទំលាយគំនរអវិជ្ជាដ៏ធំបាន) ។*

*(សុត្តន្តបិដក ៤៣,៧៣-៧៥)*

## ដំណេក ៤ យ៉ាង

១-បេតសេយ្យា *ដំណេកដូចមនុស្សស្លាប់* [១] *(មនុស្សស្លាប់ច្រើនតែដេកផ្ងារ)*

២-កាមភោគិសេយ្យា *ដំណេកអ្នកបរិភោគកាម,*

---

១- ព្រោះស័ព្ទថា **បេតៈ** ប្រែថា ប្រេតក៏បាន ទើបអដ្ឋកថាអធិប្បាយជាពីរន័យ បើសំដៅយកប្រេត លោកអធិប្បាយថា ប្រេតនោះ ជាអ្នកអត់ឃ្លាន ស្គមរយាំងមានសាច់ឈាមតិច ឆ្អឹងឡើងរគាម ដូចមនុស្សឈឺធ្ងន់យូរ មិនអាចដេកផ្អៀងបាន បានតែដេកផ្ងារ ។

(ពួកអ្នកបរិភោគកាម ច្រើនតែដេកផ្អៀងទៅខាងឆ្វេង)

៣-សីហសេយ្យា ដំណេកសីហៈ,

សីហមិគរាជ សម្រេចការដេកដោយខាងៗ ស្តាំ យកជើងតម្រួតលើជើង ស៊កកន្ទុយក្នុងចន្លោះភ្លៅ សីហមិគរាជនោះលុះភ្ញាក់ឡើង ងើបកាយខាងមុខ គឺងើបក្បាល សម្លឹងមើលកាយខាងក្រោម ។ បើសីហមិគរាជនោះ ឃើញសេចក្តីភ្ញាំងភ្ញាត់ ឬឃ្លៀងឃ្លាតកាយណាមួយសោត សីហមិគរាជ រមែងតូចចិត្តព្រោះការភ្ញាំងភ្ញាត់ និង ឃ្លៀងឃ្លាតនៃកាយនោះ,

ប្រសិនបើសីហមិគរាជ មិនឃើញសេចក្តីភ្ញាំងភ្ញាត់ ឬឃ្លៀងឃ្លាតនៃកាយណាមួយទេ សីហមិគរាជ រមែងត្រេកអរដោយការមិនភ្ញាំងភ្ញាត់ និងឃ្លៀងឃ្លាតនៃកាយនេះ ។

៤-តថាគតសេយ្យា ដំណេកព្រះតថាគត ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ល។ ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលភិក្ខុ-ទាំងឡាយ នេះហៅថា ដំណេកព្រះតថាគត ។

(សុត្តន្តបិដក ៤៣ / ២៦០)

## ធម៌ ៤ ប្រការប្រព្រឹត្តទៅដើម្បីចម្រើនបញ្ញា ឬធម៌មានឧបការៈច្រើនដល់មនុស្ស

១-សប្បុរិសសំសេវោ *ការសេពគប់សប្បុរស*

២-សទ្ធម្មស្សវនំ *ការស្តាប់ធម៌របស់សប្បុរស*

៣-យោនិសោមនសិការោ *យកចិត្តទុកដាក់ដោយឧបាយ*

៤-ធម្មានុធម្មប្បដិបត្តិ *ប្រតិបត្តិធម៌ដ៏សមគួរតាមធម៌ ។*

*(សុត្តន្តបិដក ៤៣ / ២៦២)*

## កាលនៃកុសលនេះមាន ៤ យ៉ាង

១-កាលេន ធម្មស្សវនំ *ការស្តាប់ធម៌តាមកាល*

២-កាលេន ធម្មសាកច្ឆា *សាកច្ឆាធម៌តាមកាល*

៣-កាលេន សមថោ *ការចម្រើនសមថៈតាមកាល*

៤-កាលេន វិបស្សនា *ការចម្រើនវិបស្សនាតាមកាល ។* *(សុត្តន្តបិដក ៤២,៣៥៤)*

## ហេតុឱ្យបានបញ្ញា ៤ យ៉ាង

១–សទ្ធា *ការជឿ (ធម៌របស់ព្រះអរហន្ត)*

២–សុស្សូសាយ សក្កច្ចំ បញ្ញាធិគមុបាយំ សុណាតិ, *ស្ដាប់ឧបាយដែលជាគ្រឿងសម្រេចបញ្ញា ដោយការស្ដាប់ដោយល្អ គឺដោយគោរព,*

៣–អប្បមាទេន គហិតំ ន សម្មុស្សតិ, *មិនវង្វេងភ្លេចវត្ថុ កាន់យកហើយ ដោយសេចក្ដីមិនប្រមាទ,*

៤–វិចក្ខណតាយ អនូនាធិកំ អវិបរីតញ្ច គហេត្វា វិត្ថារិកំ ករោតិ *និងកាន់យកវត្ថុ មិនខ្វះមិនលើស និងមិនខុស ដោយភាពជាអ្នកមានបញ្ញា ជាគ្រឿងពិចារណា រមែងធ្វើឲ្យធំទូលាយ ។*

*លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងការបានបញ្ញាដោយហេតុ ៤ យ៉ាង ដល់អាឡវកយក្ខនោះ ទើបត្រាស់ថា* ***សទ្ទហានោ*** *ជាដើម ។ គាថានោះ មានអធិប្បាយថា ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះសាវក ជាព្រះអរហន្ត សម្រេចព្រះនិព្វានដោយធម៌ណា ក្នុងបុព្វភាគដែលផ្សេងដោយកាយសុចរិតជាដើម*

ក្នុងអបរភាគដែលផ្សេងដោយពោធិបក្ខិយធម៌ ៣៧ ប្រការ បុគ្គលជឿធម៌នោះ គឺធម៌របស់ព្រះអរហន្តទាំងឡាយ រមែងបានបញ្ញាដែលជាលោកិយៈនិងលោកុត្តរៈ ដើម្បីសម្រេចព្រះនិព្វាន ក៏រមែងបានបញ្ញាដែលជាលោកិយៈ និងលោកុត្តរៈ ។

ដោយហេតុត្រឹមតែសទ្ធាប៉ុណ្ណោះក៏ទេ ក៏ព្រោះបុគ្គលកើតសទ្ធាហើយ រមែងចូលទៅរក កាលចូលទៅរក រមែងអង្គុយជិត កាលអង្គុយជិត រមែងផ្ទៀងសោតៈ ផ្ទៀងសោតៈហើយ រមែងស្តាប់ធម៌ ព្រោះដូច្នោះ ស្តាប់ដោយល្អ ចាប់ផ្តើមតាំងពីចូលទៅរក ដរាបដល់ការស្តាប់ធម៌ រមែងបានបញ្ញា ។

មានអធិប្បាយយ៉ាងណា មានអធិប្បាយថា សូម្បីជឿធម៌នោះហើយ ចូលទៅរកអាចារ្យនិងឧបជ្ឈាយ៍តាមកាល ចូលទៅអង្គុយជិតដោយការធ្វើវត្ត ក្នុងកាលណាអាចារ្យនិងឧបជ្ឈាយ៍មានចិត្តដែលការចូលទៅអង្គុយជិតឲ្យត្រេកអរហើយ ប្រាថ្នានឹងពោលពាក្យណាមួយ ក្នុងកាលនោះ ក៏ផ្ទៀងសោតៈ ដោយភាពជាអ្នកប្រាថ្នានឹងស្តាប់ ដែលដល់ហើយស្តាប់ រមែងបានបញ្ញា ។ ក៏សូម្បីស្តាប់ដោយល្អយ៉ាងនេះ ជាអ្នកមិនប្រមាទ ដោយការមិនទៅប្រាសចាកសតិ និងមានបញ្ញាជាគ្រឿងពិចារណា ដោយ

ភាពជាអ្នកដឹងសុភាសិតនិងទុភាសិតទុំះឯង រមែងបានបញ្ញា បុគ្គលក្រៅនេះ រមែងមិនបានបញ្ញា ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា “**អប្បមត្តោ វិចក្ខណោ :** ជាអ្នកមិនប្រមាទ មានបញ្ញាជាគ្រឿងពិចារណា” ។

ព្រោះបុគ្គលបដិបត្តិបដិបទា ដែលប្រព្រឹត្តទៅដើម្បីបានបញ្ញា ដោយសទ្ធាយ៉ាងនេះហើយ, ស្តាប់ឧបាយដែលជាគ្រឿងសម្រេចបញ្ញា ដោយការស្តាប់ដោយល្អ គឺដោយគោរព, មិនវង្វេងភ្លេចវត្ថុ កាន់យកហើយដោយសេចក្តីមិនប្រមាទ, និងកាន់យកវត្ថុមិនខ្វះមិនលើស និងមិនខុស ដោយភាពជាអ្នកមានបញ្ញាជាគ្រឿងពិចារណា រមែងធ្វើឲ្យធំទូលាយ ។

ឬផ្ទៀងសោតៈចុះ ដោយការស្តាប់ដោយល្អ រមែងស្តាប់ធម៌ដែលជាហេតុបានចំពោះនូវបញ្ញា កាលស្តាប់ដោយសេចក្តីមិនប្រមាទហើយ រមែងទ្រទ្រង់ធម៌ រមែងពិចារណាអត្ថនៃធម៌ទាំងឡាយ ដែលទ្រទ្រង់ចាំ ដោយភាពជាអ្នកមានបញ្ញាជាគ្រឿងពិចារណា ក្នុងលំដាប់នោះ រមែងធ្វើឲ្យច្បាស់នូវបរមត្ថ ដោយលំដាប់ ព្រោះដូច្នោះ ព្រះមានព្រះភាគ ត្រូវអាឡវកយក្ខ ទូលសួរថា បុគ្គលរមែងបានបញ្ញាដោយអ្វី កាលនឹងទ្រង់សម្តែង

ហេតុទាំង ៤ នេះ ទើបត្រាស់គាថានេះថា **សទ្ទហានោ ។ល។ វិចក្ខណោ** ។

(ចាកសុត្តនិបាត អដ្ឋកថា បរមត្ថជោតិកា)

## ពាក្យថាជាអនត្តាដោយហេតុ ៤ យ៉ាង

១–អវសវត្តនដ្ឋេន ដោយអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច

២–អសាមិកដ្ឋេន ដោយអត្ថថា មិនជាម្ចាស់

៣–សុញ្ញតដ្ឋេន ដោយអត្ថថា ជារបស់សោះសូន្យទទេ

៤–អត្តបដិក្ខេបដ្ឋេន ដោយអត្ថថា បដិសេធអត្តា ។

## អធិប្បាយ

ក្នុងបណ្តាហេតុ ៤ យ៉ាងនោះ អ្នកណាៗ ក៏ជាអ្នកមិនមានអំណាចក្នុងរូបនេះថា សូមរូបដែលកើតឡើងហើយ ចូរដល់ការតាំងនៅ សូមរូបដែលដល់ការតាំងនៅ ចូរកុំចាស់ សូមរូបដែលដល់ការចាស់ហើយ ចូរកុំបែកធ្លាយ សូមកុំលំបាកដោយការកើតឡើង និងការសូន្យទៅឡើយ ។ សេចក្តី

នេះ ជាអត្ថថា មិននៅក្នុងអំណាចរបស់រូបនោះ ។ សេចក្តីមិនមានអ្នកណាៗ ជាម្ចាស់របស់ដោយអត្ថថា មិនមានម្ចាស់ ។ សេចក្តីដែលរូបនោះសោះសូន្យទទេចាកភាវៈនោះ ដោយវៀរចាកអ្នកនៅអាស្រ័យ អ្នកកសាង អ្នកគ្រប់គ្រង ឈ្មោះថា អត្ថថា សោះសូន្យទទេ ភាពមិនមានសភាវៈដែលជាអត្តាដែលពួកលទ្ធិដទៃគិតទុកជាមុន ឬគិតទុកហើយនោះឯង ឈ្មោះថា អត្ថថា បដិសេធអត្តា ។

**ម្យ៉ាងទៀតមិនទៀងដោយហេតុសម្បើនាំង៤នេះ គឺ**

១–ឧប្បាទវយវត្តតាយ ព្រោះមានការកើតឡើងនិងការសាបសូន្យទៅជាទីបំផុត ។

២–តាវកាលិកតាយ ព្រោះជារបស់បណ្តោះអាសន្ន

៣–វិបរិណាមកោដិយា ព្រោះមានការប្រែប្រួលជាទីបំផុត

៤–និច្ចប្បដិក្ខេបតោ ព្រោះជំទាស់ចំពោះការទៀង,

## អធិប្បាយ

*ក៏ក្នុងបណ្ដាហេតុទាំង ៤ យ៉ាងនេះ ដែលឈ្មោះថា ភាវៈ ដែលរូបមានការកើតឡើង និងការសូន្យទៅជាទីបំផុត, ព្រោះប្រព្រឹត្តទៅ ដោយអំណាចការកើតឡើង និងដោយអំណាចការរលត់ទៅគ្រប់ៗ ខណៈ ។ សេចក្ដីជារបស់បណ្ដោះអាសន្ន ឬមួយរំពេចៗ ព្រោះជារបស់មាននៅក្នុងខណៈនោះ ។ ដែលឈ្មោះថា មានសេចក្ដីប្រែប្រួលជាទីបំផុត ព្រោះភាវៈជារបស់មានការប្រែប្រួល ។ ពិតមែន រូបកាលប្រែប្រួលទៅដោយការដល់នូវភាពវិការ មានការកើតឡើងជាដើម រមែងដល់សេចក្ដីវិនាស ។ សេចក្ដីដែលរូបមិនមានសភាពដែលទៀងនោះឯង ឈ្មោះថា ការបដិសេធសេចក្ដីទៀង ។ ពិតមែន ធម៌ទាំងឡាយដែលមិនទៀង ឈ្មោះថា រមែងបដិសេធសេចក្ដីជាសភាពទៀង ដោយអត្ថថា ព្រោះភាវៈដែលខ្លួនជាសភាពមិនទៀងនោះៗឯង។*

**ម្យ៉ាងទៀតឈ្មោះថា ទុក្ខ ដោយហេតុ ៤ យ៉ាង គឺ**

*១–សន្តាបដ្ឋេន ដោយអត្ថថា ជារបស់ក្ដៅក្រហាយ*

*២–ទុក្ខមដ្ឋេន ដោយអត្ថថា ទ្រាំបានដោយលំបាក*

៣-ទុក្ខវត្ថុកដ្ឋេន ដោយអត្ថថា ជាទីតាំងនៃទុក្ខ
៤-សុខបដិក្ខេបដ្ឋេន ដោយអត្ថថា បដិសេធ
សេចក្តីសុខ ។

## អធិប្បាយ

ក៏ក្នុងហេតុទាំង ៤ យ៉ាងនេះដែលឈ្មោះថា សេចក្តីក្តៅក្រហាយ បានដល់ ការដុតកោល គឺសេចក្តីក្តៅក្រហាយដោយអំណាចភាវៈជាទុក្ខពិតៗ ជាដើម ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា ទ្រាំបានដោយលំបាក ។ ឈ្មោះថា ជាទីតាំងនៃទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំង ៣ យ៉ាង និងនៃសង្ខារទុក្ខ ។ ភាវៈមិនមាននៃសភាពដែលជាសុខនោះឯង ឈ្មោះថា ការបដិសេធសេចក្តីសុខ ។ (សារត្ថ. ភាគ៣, ទំព័រ២២៣-២២៤)

## ឧបាទាន ៤ យ៉ាង

### ឧបាទានស័ព្ទ

ពាក្យថា **ឧបាទាន** ប្រែថា ប្រកាន់មាំ (គឺប្រកាន់ទុក) ព្រោះឧបស័ព្ទ ក្នុងទីនេះមាន **ទឡ្ហ** ស័ព្ទ (មាំ) ជាអត្ថ ដូច**ឧប**

ក្នុងពាក្យ**ឧបាយាស** *(សេចក្ដីចង្អៀតចង្អល់ចិត្ត)* និងពាក្យ **ឧបកដ្ឋ** *(ចូលទៅកាន់ទីជិត)* ជាដើម ។

## ១-កាមុបាទាន

វត្ថុសង្ខាតំ កាមំ ឧបាទិយតីតិ **កាមុបាទានំ,** កាមោ ច សោ ឧបាទានញ្ចាតិបិ កាមុបាទានំ ។

*(អត្ថថា) បុគ្គលរមែងប្រកាន់មាំនូវកាម ដែលបានដល់វត្ថុ ហេតុនោះទើបឈ្មោះ* ***កាមុបាទាន*** *(ប្រែថា ការប្រកាន់មាំកាម នៃបុគ្គលនោះ) ដូច្នេះខ្លះ ,*

*(អត្ថថា)* ***កាម*** *(គឺកិលេស) ផង កាមនោះជាធម្មជាត ដែលប្រកាន់មាំផង ហេតុនោះទើបឈ្មោះ* ***កាមុបាទាន*** *(ប្រែថា កាមអ្នកប្រកាន់មាំ) ដូច្នេះខ្លះ ។*

## ២-ទិដ្ឋុបាទាន

*ន័យជាមួយគ្នានោះ (គឺឧបាទានស័ព្ទ មានអត្ថថា ប្រកាន់មាំ ប្រកាន់ទុក ដូចគ្នាតែម្ដង) គឺ (អត្ថថា) ទិដ្ឋិផង ទិដ្ឋិនោះ ជាធម្មជាតប្រកាន់មាំផង ហេតុនោះទើបឈ្មោះ* ***ទិដ្ឋុបាទាន*** *(ប្រែថា ទិដ្ឋិដែលប្រកាន់ទុក) មានអត្ថម្យ៉ាងទៀតថា ទិដ្ឋិរមែងប្រកាន់*

មាំទិដ្ឋិ ហេតុនោះ ទើបឈ្មោះ **ទិដ្ឋុបាទាន** (ប្រែថា ទិដ្ឋិប្រកាន់ទិដ្ឋិ) ព្រោះថា **ឧត្តរទិដ្ឋិ** (ការឃើញក្រោយមក) រមែងប្រកាន់បុរិមទិដ្ឋិ (ការឃើញដែលមានមកអំពីមុន) ក្នុងការឃើញខុសទាំងឡាយ មានឃើញថា អត្តាទៀង និងលោកទៀង ជាដើម ។

## ៣-សីលព្វតុបាទាន

ន័យដូចគ្នា គឺ (អត្ថថា) បុគ្គលរមែងប្រកាន់មាំសីល និងវត ហេតុនេះ ទើបឈ្មោះ **សីលព្វតុបាទាន** (ប្រែថា ការប្រកាន់មាំសីលនិងវតនៃបុគ្គល) ដូច្នេះខ្លះ, (អត្ថថា) សីលព្វតផង សីលព្វតនោះ ជាធម្មជាតប្រកាន់មាំផង ហេតុនេះទើបឈ្មោះ **សីលព្វតុបាទាន** (ប្រែថា សីលនិងវតដែលប្រកាន់មាំ) ដូច្នេះខ្លះ, ព្រោះថា សីលព្វតផ្សេងៗ មានគោសីល និងគោវត្ត[១] ជាដើម ជាឧបាទាននៅក្នុងខ្លួននោះឯង ព្រោះប្រកាន់មាំថា សេចក្តីបរិសុទ្ធិនឹងមានដោយសីលព្វតយ៉ាងនោះ ។

---

១-សុត្តន្ត.២៣,៨៤,១៣៥ ។

## ៤-អត្តវាទុបាទាន

ន័យដូចគ្នា បុគ្គលទាំងឡាយរមែងពោលព្រោះវត្ថុនោះ (ជាហេតុ) ហេតុនេះ វត្ថុនោះទើបឈ្មោះ **វាទៈ** (ប្រែថា វត្ថុជាហេតុពោល) ។ សត្វទាំងឡាយ រមែងប្រកាន់មាំ សូម្បីព្រោះវត្ថុនោះ (ជាហេតុ) ហេតុនេះ វត្ថុនោះទើបឈ្មោះ **ឧបាទាន** ។ សួរថា បុគ្គលទាំងឡាយរមែងពោលក្តី រមែងប្រកាន់មាំក្តី នូវអ្វី? ឆ្លើយថា ... នូវអត្តា ។ វត្ថុជាហេតុពោល ជាហេតុប្រកាន់មាំនូវអត្តា ឈ្មោះថា **អត្តវាទុបាទាន** ។

អត្ថម្យ៉ាងទៀត បុគ្គលទាំងឡាយរមែងប្រកាន់មាំយកត្រឹមពាក្យថា អត្តាប៉ុណ្ណោះឯង ថាជាអត្តា ព្រោះវត្ថុនោះ (ជាហេតុ) ហេតុនេះ វត្ថុនោះទើបឈ្មោះ **អត្តវាទុបាទាន** (ប្រែថា វត្ថុជាហេតុប្រកាន់មាំត្រឹមពាក្យថា អត្តា) ។

នេះជាអត្ថវិភាគនៃឧបាទានទាំងនោះ ជាដំបូង ។

## ដោយសង្ខេបនិងពិស្តារនៃឧបាទាន

ចំណែកក្នុងសេចក្តីសង្ខេបនិងពិស្តារនៃធម៌ (នោះ) ដោយសង្ខេបមុន **តណ្ហាទឡ្ហត្តៈ** (ការមាំទាំនៃតណ្ហា) ហៅថា **កាមុ-**

**បាទាន** ព្រោះមកក្នុងបាលីថា "តត្ថ កតមំ កាមុបាទានំ? យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទិ កាមតណ្ហា កាមសិនេហោ កាមបរិឡាហោ កាមមុច្ឆា កាមជ្ឈោសានំ, ឥទំ វុច្ចតិ កាមុបាទានំ" បណ្ដាឧបាទានទាំងនោះ កាមុបាទាន តើដូចម្ដេច ? សេចក្ដីប្រាថ្នាចំពោះកាម ការត្រេកអរចំពោះកាម ការរីករាយចំពោះកាម ការអន្ទះសាចំពោះកាម សេចក្ដីស្រឡាញ់ចំពោះកាម ការរោលរាលចំពោះកាម ការជ្រុលជ្រប់ចំពោះកាម ការងប់ងល់ចំពោះកាមណា ក្នុងកាមទាំងឡាយ នេះហៅថា **កាមុបាទាន** ។

**ឧត្តរតណ្ហា** (តណ្ហាដែលកើតក្រោយៗមក) ដែលកើតជាទោសក្រាស់ឡើង ព្រោះមាន**បុរិមតណ្ហា** (តណ្ហាដែលកើតមុនៗ) ជាឧបនិស្សយបច្ច័យនោះឯង ឈ្មោះ**តណ្ហាទឡ្ហត្តៈ** ។

តែអាចារ្យពួកខ្លះពោលថា "ការប្រាថ្នាអារម្មណ៍ដែលនៅមិនទាន់មកដល់ ជាតណ្ហា ឧបមាដូចជាការលូកដៃរបស់ចោរ (រាវរកវត្ថុ) ក្នុងទីងងឹត ដូច្នោះ ការកាន់យកអារម្មណ៍ដែលមកដល់ទុកជាឧបាទាន ឧបមាដូចជាចោះយកវត្ថុ (ដែលរាវជួប) របស់ចោរនោះៗឯង ដែលធម៌ (ទាំងពីរ) នោះជាបដិបក្ខចំពោះ

អប្បិច្ឆតានិងសត្តុដ្ឋិតា ។ ម្យ៉ាងទៀត ជាមូលនៃបរិយេសនទុក្ខ (ទុក្ខព្រោះការស្វែងរក) និងអារក្ខទុក្ខ (ទុក្ខព្រោះការរក្សា)" ។

ចំណែកឧបាទាន ៣ ដ៏សេស ដោយសង្ខេបត្រឹមតែជាទិដ្ឋិ (ម្យ៉ាងៗ) ប៉ុណ្ណោះ ។

<u>ចំណែកសេចក្តីពិស្តារ</u> សេចក្តីប្រកាន់មាំនៃតណ្ហា ក្នុងអារម្មណ៍ទាំងឡាយមានរូបជាដើម ដែលមានប្រភេទទាំង ១០៨ ដែលពោលមកមុន (នោះ) ជាកាមុបាទាន ។ មិច្ឆាទិដ្ឋិមានវត្ថុ ១០ ជាទិដ្ឋុបាទាន ។ ដូចបាលីថា "តត្ថ កតមំ ទិដ្ឋុបាទានំ បណ្តាឧបាទានទាំងនោះ ទិដ្ឋុបាទានតើដូចម្តេច ?

នត្ថិ ទិន្នំ, នត្ថិ យិដ្ឋំ, នត្ថិ ហុតំ, នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ, ។បេ។ នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា, យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ការយល់ថា ទានដែលបានឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អ ឬអាក្រក់ មិនមាន ។ល។

*ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្តែងប្រាប់បាន ក៏មិនមាន,*

យា ឯវរូបា ទិដ្ឋិ ទិដ្ឋិគតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារោ ទិដ្ឋិវិសូកាយិកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសំយោជនំ គាហោ បតិដ្ឋាហោ អភិនិវេសោ បរាមាសោ កុម្មគ្គោ មិច្ឆាបថោ មិច្ឆត្តំ តិត្ថាយតនំ វិបរិយាសគ្គាហោ : ឥទំ វុច្ចតិ ទិដ្ឋុបាទានំ ។ ឋបេត្វា សីលព្វតុបាទានញ្ច អត្តវាទុបាទានញ្ច សព្វាបិ មិច្ឆាទិដ្ឋិ ទិដ្ឋុបាទានំ ។

*និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូវគឺទិដ្ឋិ ការយល់ឆ្វេងគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការក្ដួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋុបាទាន ។ លើកតែសីលព្វតុបាទាន និងអត្តវាទុបាទានចេញ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា ទិដ្ឋុបាទានដែរ ។*

*ចំណែកសេចក្ដីប្រកាន់មាំថា សេចក្ដីបរិសុទ្ធិមានដោយសីលនិងវត្តទាំងឡាយ ជា**សីលព្វតុបាទាន** , ដូចបាលីថា*

"តត្ថ កតមំ សីលព្វតុបាទានំ ? *បណ្ដាឧបាទានទាំងនោះ សីលព្វតុបាទាន តើដូចម្ដេច ?*

ឥតោ ពហិទ្ធា សមណព្រាហ្មណានំ សីលេន សុទ្ធិ, វតេន សុទ្ធិ, សីលព្វតេន សុទ្ធីតិ : *ពួកសមណព្រាហ្មណ៍ខាងក្រៅអំពីសាសនានេះ (ប្រកាន់ថា) សេចក្ដីបរិសុទ្ធិដោយសីល បរិសុទ្ធិដោយវត បរិសុទ្ធិដោយសីលនិងវត,*

*និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ល។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា **សីលព្វតុបាទាន** ។*

*សក្កាយទិដ្ឋិមានវត្ថុ ២០ ជាអត្តវាទុបាទាន ។ ដូចបាលីថា*

"តត្ថ កតមំ អត្តវាទុបាទានំ ? *បណ្ដាឧបាទានទាំងនោះ អត្តវាទុបាទាន តើដូចម្ដេច ?*

ឥធ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ

សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ, រូបវន្តំ វា អត្តានំ, អត្តនិ វា រូបំ, រូបស្មឹ វា អត្តានំ ។ វេទនំ ។បេ។ សញ្ញំ ។បេ។ សង្ខារេ ។បេ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ, វិញ្ញាណវន្តំ វា អត្តានំ, អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ *បុថុជ្ជន ជាអ្នកមិនចេះដឹង ក្នុងលោកនេះ មិនធ្លាប់ឃើញពួកព្រះអរិយៈ មិនឈ្លាសវៃ ក្នុងអរិយធម៌ មិនទូន្មានខ្លួន ក្នុងអរិយធម៌ មិនធ្លាប់ឃើញពួកសប្បុរស មិនឈ្លាសវៃ ក្នុងសប្បុរិសធម៌ មិនទូន្មានខ្លួន ក្នុងសប្បុរិសធម៌ រមែងយល់ឃើញរូបថាជាខ្លួន ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងរូបខ្លះ ។ វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារទាំងឡាយ ។បេ។ ឃើញវិញ្ញាណថាជាខ្លួន ឃើញខ្លួនថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ ។*

*និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។ល។ សេចក្តីប្រកាន់ក្នុងការ*

ស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា អត្តវាទុបាទាន ។

នេះសេចក្តីសង្ខេបនិងពិស្តារនៃធម៌ក្នុងឧបាទាននោះ ។

(ចាកគម្ពីរវិសុទ្ធិមគ្គ បញ្ញាភូមិនិទ្ទេស
និងអភិធម្មបិដក ធម្មសង្គណិ ៧៩,១៩២)

## បដិច្ចសមុប្បាទឈ្មោះថាជារបស់ជ្រាលជ្រៅ ដោយអាការ ៤ យ៉ាង

*១-អត្ថគម្ភីរតាយ ដោយសេចក្តីជ្រាលជ្រៅដោយអត្ថ,*

*២-ធម្មគម្ភីរតាយ ដោយសេចក្តីជ្រាលជ្រៅដោយធម៌,*

*៣-ទេសនាគម្ភីរតាយ ដោយសេចក្តីជ្រាលជ្រៅដោយ ទេសនា ,*

*៤-បដិវេធគម្ភីរតាយ ដោយសេចក្តីជ្រៅដោយបដិវេធ ។*

ក្នុងសេចក្តីជ្រាលជ្រៅ ៤ យ៉ាងនោះ បដិច្ចសមុប្បាទជារបស់ជ្រាលជ្រៅ មានអត្ថថា មាននិងកើតឡើង ព្រោះជាតិជាបច្ច័យនៃជរានិងមរណៈ ជារបស់ជ្រាលជ្រៅ មានអត្ថថា មាននិងកើតឡើង ព្រោះអវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ព្រោះហេតុនោះ នេះគឺសេចក្តីដែលបដិច្ចសមុប្បាទ មានសេចក្តីជ្រាល

ជ្រៅដោយអត្ថ, បដិច្ចសមុប្បាទជារបស់ជ្រាលជ្រៅ មានអត្ថគឺ អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ជារបស់ជ្រាលជ្រៅ មានអត្ថ គឺជាតិជាបច្ច័យនៃជរានិងមរណៈ ព្រោះហេតុនោះ នេះឈ្មោះថា សេចក្តីដែលបដិច្ចសមុប្បាទ មានសេចក្តីជ្រាលជ្រៅដោយធម៌, ក្នុងសូត្រខ្លះលោកសម្តែងបដិច្ចសមុប្បាទដោយអនុលោម ក្នុងសូត្រខ្លះដោយបដិលោម ក្នុងសូត្រខ្លះទាំងដោយអនុលោម និងបដិលោម ក្នុងសូត្រខ្លះដោយអនុលោម ឬដោយបដិលោម តាំងពីផ្នែកកណ្តាល ក្នុងសូត្រខ្លះដោយអនុលោម ឬដោយបដិលោម តាំងពីផ្នែកចុង ក្នុងសូត្រខ្លះមានសន្ធិ ៣ សង្ខេប ៤ ក្នុងសូត្រខ្លះមានសន្ធិ ២ សង្ខេប ៣ ក្នុងសូត្រខ្លះមានសន្ធិ ១ សង្ខេប ២ ព្រោះហេតុនោះ នេះឈ្មោះថា សេចក្តីដែលបដិច្ចសមុប្បាទ មានសេចក្តីជ្រាលជ្រៅដោយទេសនា, មួយទៀត បដិច្ចសមុប្បាទជារបស់ជ្រាលជ្រៅ មានអត្ថថា មិនដឹង មិនឃើញ មិនចាក់ធ្លុះសច្ចធម៌នៃអវិជ្ជា ជារបស់ជ្រាលជ្រៅ មានអត្ថថា គាក់តែងរូបរួមសង្ខារទាំងឡាយមានតម្រេកនិងកំចាត់សេចក្តីតម្រេក មានអត្ថថា សេចក្តីជារបស់សូន្យ សេចក្តីមិនខ្វល់ខ្វាយ សេចក្តីមិនឃ្លាតចាកទី និងសេចក្តីប្រាកដនៃបដិសន្ធិរបស់វិញ្ញាណ មានអត្ថថា

កើតតែមួយដង ការបែកគ្នា ការមិនបែកគ្នា ការបង្អោនទៅ ការទម្លាយរបស់នាមរូប មានអត្ថថា ជាធំ ជាទ្វារ និងខេត្តរបស់លោក និងសេចក្ដីជាធម៌មានអារម្មណ៍របស់អាយតនៈ ៦ មានអត្ថថា សម្ផស្សប៉ះខ្ទប់ទៅរួមនិងប្រជុំរបស់ផស្សៈ មានអត្ថថា ការសោយអារម្មណ៍និងរស និងការសោយវត្ថុគ្មានជីវិត គឺសេចក្ដីជាសុខ ជាទុក្ខនិងកណ្ដាលៗ របស់វេទនា មានអត្ថថា ត្រេកអរក្រៃលែង កន្លល់ក្រៃលែង ខ្សែទឹកស្ទឹងគឺតណ្ហា មហាសមុទ្រគឺតណ្ហា ពេញបានលំបាករបស់តណ្ហា មានអត្ថថា កាន់ ទទួលគោង ពាល់ត្រូវ កន្ទងទៅបានលំបាករបស់ឧបាទាន មានអត្ថថា ប្រមូលតាក់តែង និងការបោះទៅក្នុង យោនិ គតិ ឋិតិ និងនិវាសស្ថានទាំងឡាយរបស់ភព មានអត្ថថា សេចក្ដីប្រាកដជាតិសញ្ជាតិ សេចក្ដីឈានចុះការកើតឡើងរបស់ជាតិ មានអត្ថថា អស់ទៅ សាបសូន្យទៅ បែកទៅ និងប្រែប្រួល របស់ជរា និងមរណៈដោយប្រការយ៉ាងនេះ សភាវៈនៃអវិជ្ជាជាដើមណា ធម៌ទាំងឡាយមានអវិជ្ជាជាដើម ជាការដឹងច្បាស់នូវលក្ខណៈដែលមានរស ដោយបដិវេធណា សភាវៈនិងបដិវេធនោះ ជារបស់ជ្រាលជ្រៅ ព្រោះហេតុនោះ គប្បីជ្រាបថា នេះគឺសេចក្ដីដែល

*បដិច្ចសមុប្បាទ មានសេចក្ដីជ្រាលជ្រៅដោយបដិវេធ ។*

*(ចាកអដ្ឋកថា សុមង្គលវិលាសិនី)*

## ធម៌ជាហេតុកើតសតិសម្ពោជ្ឈង្គ ៤ ប្រការ

*ម្យ៉ាងទៀត ធម៌ ៤ ប្រការ ជាហេតុនាំឲ្យកើតសតិ-សម្ពោជ្ឈង្គៈ*

១-សតិសម្បជញ្ញំ *ត្រូវមានសតិនិងសម្បជញ្ញៈ*

២-មុដ្ឋស្សតិបុគ្គលបរិវជ្ជនតា *វៀរចាកបុគ្គលវង្វេងភ្លេចស្មារតី*

៣-ឧបដ្ឋិតស្សតិបុគ្គលសេវនតា *ការគប់រកបុគ្គលមានស្មារតីខ្ជាប់ខ្ជួន*

៤-តទធិមុត្តតា *ការបង្អោនចិត្តទៅក្នុងសតិសម្ពោជ្ឈង្គនោះ ។*

*ក៏សតិសម្ពោជ្ឈង្គ រមែងកើតដោយសតិសម្បជញ្ញៈ ក្នុងឋានៈទាំង ៧ មានឈានទៅខាងមុខជាដើម ដោយការវៀរចាកបុគ្គលអ្នកមានសតិវង្វេងភ្លេចស្មារតី ដូចគ្នានឹងការខ្ជួនរក្សា*

អាហារ ដោយការគប់រកបុគ្គលអ្នកមានសតិខ្ជាប់ខ្ជួន ដូចគ្នានឹងព្រះតិស្សទត្តត្ថេរៈ និងព្រះអភយត្ថេរៈជាដើម និងដោយភាពជាអ្នកមានចិត្តបង្អោនទៅដើម្បីតាំងសតិ ក្នុងឥរិយាបថទាំងឡាយមានឈរ អង្គុយជាដើម ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏សតិ-សម្ពោជ្ឈង្គនោះ ដែលកើតឡើងហើយ ដោយហេតុ ៤ ប្រការយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ ដោយអរហត្តមគ្គ ។

(ចាកអដ្ឋកថា សុមង្គលវិលាសិនី)

## ពួក ៥

## វេសារជ្ជករណធម៌ ៥ យ៉ាង

ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេខបុគ្គលនេះ មាន ៥ យ៉ាង

១-សទ្ធោ ហោតិ ជាអ្នកមានសទ្ធា

២-សីលវា ហោតិ ជាអ្នកមានសីល

៣-ពហុស្សុតោ ហោតិ ជាអ្នកបានស្តាប់ច្រើន

៤-អារទ្ធវីរិយោ ហោតិ ជាអ្នកប្រារព្ធព្យាយាម

៥-បញ្ញវា ហោតិ ជាអ្នកមានប្រាជ្ញា ។

(សុត្តន្តបិដក ៤៥,០១)

## ធម៌ ៥ យ៉ាងជាហេតុកើតឧបេក្ខាសម្ពោជ្ឈង្គ

ម្យ៉ាងទៀត ធម៌ ៥ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គ គឺ

១-សត្តមជ្ឈត្តតា ដាក់ខ្លួនជាកណ្ដាលក្នុងសត្វ

២-សង្ខារមជ្ឈត្តតា ដាក់ខ្លួនជាកណ្ដាលក្នុងសង្ខារ

៣-សត្តសង្ខារកេលាយនបុគ្គលបរិវជ្ជនតា វៀរចាកបុគ្គលអ្នកប្រកាន់សត្វនិងសង្ខារ

៤-សត្តសង្ខារមជ្ឈត្តបុគ្គលសេវនតា គប់រកបុគ្គលអ្នកដាក់ខ្លួនជាកណ្ដាលក្នុងសត្វនិងសង្ខារ

៥-តទធិមុត្តតា បង្អោនចិត្តទៅក្នុងឧបេក្ខាសម្ពោជ្ឈង្គនោះ ។

ក្នុងធម៌ ៥ ប្រការនោះ អ្នកចម្រើនឧបេក្ខាសម្ពោជ្ឈង្គរមែងតាំងខ្លួននៅជាកណ្ដាលក្នុងសត្វដោយអាការៈ ២ យ៉ាង គឺ

ដោយការពិចារណាដល់សេចក្តីដែលខ្លួននិងអ្នកដទៃ មានកម្មជារបស់ខ្លួនៗ យ៉ាងនេះថា លោកមកដោយកម្មរបស់ខ្លួន ក៏នឹងទៅដោយកម្មរបស់ខ្លួន សូម្បីគេក៏មកដោយកម្មរបស់ខ្លួន (គេ) នឹងទៅដោយកម្មរបស់ខ្លួន(គេ) ដូចគ្នា លោកនឹងប្រកាន់អ្វីគ្នា ដូច្នេះ និងដោយការពិចារណាដល់សេចក្តីមិនមានសត្វ យ៉ាងនេះថា កាលពោលដោយបរមត្ថ ដែលថា សត្វៗ មិនមាន លោកនឹងប្រកាន់យ៉ាងណាហ្ន៎ ដូច្នេះ ។

តាំងខ្លួនជាកណ្តាលក្នុងសង្ខារ ដោយអាការៈ ២ យ៉ាង គឺ ដោយការពិចារណា ដោយសេចក្តីជារបស់មិនមានម្ចាស់ យ៉ាងនេះថា "ចីវរនេះនឹងចូលដល់ភាវៈផ្លាស់ពណ៌ និងការចាស់គ្រាំគ្រា ជាសំពត់ជូតជើង ត្រូវគៀរចោលដោយចុងឈើច្រត់ ក៏បើថាចីវរនោះ គប្បីមានម្ចាស់សោត គេក៏មិនគប្បីឲ្យវាវិនាសអស់យ៉ាងនេះ" ដូច្នេះ និងដោយការពិចារណា ដោយសេចក្តីជារបស់ប្រព្រឹត្តទៅតាមកាលកំណត់យ៉ាងនេះថា "ចីវរនេះនៅមិនបានយូរ ជារបស់ប្រព្រឹត្តទៅតាមកាលកំណត់" ដូច្នេះ ។ សូម្បីក្នុងបរិក្ខារមានបាត្រជាដើម ក៏គប្បីប្រកបសេចក្តីដូចក្នុងចីវរ ។

ក្នុងពាក្យថា វៀរចាកបុគ្គលអ្នកប្រកាន់ក្នុងសត្វនិងសង្ខារ

មានវិនិច្ឆ័យដូច្នេះ ៖ បុគ្គលណាជាគ្រហស្ថ ក៏ប្រកាន់បិយជន មានបុត្រធីតាជាដើមរបស់ខ្លួន ឬជាបព្វជិតក៏ប្រកាន់បព្វជិត មានអន្តេវាសិក និងអ្នករួមឧបជ្ឈាយ៍គ្នាជាដើមរបស់ខ្លួន រវល់តែធ្វើកិច្ចកម្ម មានកោរសក់ ដេរចីវរ ជ្រលក់ចីវរ ដុតបាត្រជាដើម របស់ជនទាំងនោះ ដោយដៃរបស់ខ្លួនតែម្តង កាលមិនឃើញត្រឹមតែមួយភ្លែត ក៏រអ៊ូរទាំថា សាមណេររូបឯណោះទៅណា ភិក្ខុកំលោះរូបឯណោះទៅណា ក្រឡេកឆ្វេងស្តាំ ដូចម្រឹគភ្ញាក់ផ្អើល ដូច្នោះ សូម្បីអ្នកដទៃអង្វរថា មេត្តាបញ្ជូនសាមណេរឈ្មោះឯណោះ ទៅជួយកោរសក់ជាដើម ត្រឹមតែមួយភ្លែត ដូច្នេះ ក៏មិនព្រមឲ្យដោយនិយាយថា ពួកយើងនឹងមិនឲ្យធ្វើកិច្ចកម្មរបស់ខ្លួនខ្លះឬ ពួកលោកនាំលោកទៅនឹងលំបាក ដូច្នេះ បុគ្គលនេះឈ្មោះថា ប្រកាន់សត្វ ។

ចំណែកបុគ្គលណា ប្រកាន់បរិក្ខារមានចីវរបាត្រ ស្មោកបាត្រ ឈើប្រត់ជាដើម សូម្បីអ្នកដទៃយកដៃចាប់ ក៏មិនឲ្យចាប់ សូមខ្ចីក៏ពោលជំទាស់ថា យើងត្រូវការប្រើទ្រព្យក៏មិនទាន់ប្រើ នឹងឲ្យពួកលោកបានយ៉ាងណា ដូច្នេះ បុគ្គលនេះឈ្មោះថា ប្រកាន់សង្ខារ ។

ចំណែកបុគ្គលណា ដាក់ខ្លួនជាកណ្ដាល ទៀងត្រង់ក្នុងវត្ថុទាំងពីរនោះ បុគ្គលនេះឈ្មោះថា ដាក់ខ្លួនជាកណ្ដាល ក្នុងសត្វនិងសង្ខារ ។

កាលវៀរចាកបុគ្គលអ្នកប្រកាន់សត្វនិងសង្ខារ បែបដូច្នេះក្ដី គប់រកបុគ្គលអ្នកដាក់ខ្លួនជាកណ្ដាលក្នុងសត្វ និងសង្ខារក្ដី មានចិត្តបង្អោនទៅដើម្បីឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយ ជាដើមក្ដី ឧបេក្ខាសម្ពោជ្ឈង្គនេះ រមែងកើតបានដោយប្រការដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏ឧបេក្ខាសម្ពោជ្ឈង្គនោះ ដែលកើតឡើងហើយ ដោយអាការៈយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។

(ចាកអដ្ឋកថា សុមង្គលវិលាសិនី)

## អនុបុព្វីកថា

១-ទានកថា សម្ដែងអំពីទាន

២-សីលកថា សម្ដែងអំពីសីល

៣-សគ្គកថា សម្ដែងអំពីឋានសួគ៌

៤-កាមានំ អាទីនវំ ឱការំ សង្កិលេសំ *ទោសនៃកាមទាំងឡាយដ៏លាមក សៅហ្មង*

៥-នេក្ខម្មេ អានិសំសំ *អានិសង្សក្នុងការចេញចាក កាម (បួសក្នុងភាពនៃបុគ្គលមិនមានការងារជាប្រយោជន៍ ដល់ផ្ទះ) ។*

## អធិប្បាយតាមន័យអដ្ឋកថា

*បទថា អនុបុព្វឹ កថំ បានដល់ ពាក្យតាមលំដាប់ យ៉ាងនេះ គឺសីលក្នុងលំដាប់នៃទាន សួគ៌ ក្នុងលំដាប់នៃសីល មគ្គ ក្នុងលំដាប់នៃសួគ៌ ។*

### ១-ទានកថា

តត្ថ ទានកថា នាម ឥទំ ទានំ នាម សុខានំ និទានំ សម្បត្តីនំ មូលំ ភោគានំ បតិដ្ឋា វិសមគតស្ស តាណំ លេណំ គតិ បរាយណំ ឥធលោកបរលោកេសុ ទានសទិសោ អវស្សយោ

បតិដ្ឋា អារម្មណំ តាណំ លេណំ គតិ បរាយណំ ឧត្តិ : *ក្នុងបណ្តាអនុបុព្វីកថានោះ ដែលឈ្មោះថា* ***ទានកថា*** *បានដល់ កថាប្រកបដោយគុណរបស់ទាន មានជាដើមយ៉ាងនេះ ថា ឈ្មោះថា ទាននេះ ជាហេតុនៃសេចក្តីសុខទាំងឡាយ ជាមូលនៃសម្បត្តិទាំងឡាយ ជាទីតាំង ទីអាស្រ័យនៃភោគៈទាំងឡាយ ជាទីទប់ទល់ ជាទីលាក់ពួន ជាផ្លូវដើរ ជាទីទៅក្នុងខាងមុខរបស់មនុស្សអ្នកដើរទៅក្នុងទីប្រាសចាកសេចក្តីមិនរាបស្មើ ជាទីអាស្រ័យ ទីតាំង អារម្មណ៍ ទីទប់ទល់ ទីការពារ ជាទីទៅទីទៅក្នុងខាងមុខដែលប្រាកដស្មើដូចជាទាន ក្នុងលោកនេះ និងលោកខាងមុខមិនមាន ។*

ឥទញ្ហិ អវស្សយដ្ឋេន រតនមយសីហាសនសទិសំ : *ដោយអត្ថថា ទាននេះ ប្រាកដស្មើដូចជាសីហាសនៈដែលសម្រេចដោយរតនៈ ដោយអត្ថថា ជាទីអាស្រ័យ ។*

បតិដ្ឋានដ្ឋេន មហាបថវីសទិសំ : *ប្រាកដស្មើដូចជាមហាប្រថពី ដោយអត្ថថា ជាទីប្រតិស្ឋាន ។*

អារម្មណដ្ឋេន អាលម្ពនរជ្ជុសទិសំ : ប្រាកដស្មើដូចខ្សែសម្រាប់តោង ដោយអត្ថថា ជាអារម្មណ៍ ។

ឥនញ្ចិ ទុក្ខនិត្ថរណដ្ឋេន នាវា : មែនពិតទាននេះជានាវា ដោយអត្ថថា រុះរើចេញនូវទុក្ខ ។

សមស្សាសនដ្ឋេន សង្គាមសូរោ : ជាអ្នកក្លាហានក្នុងសង្គ្រាម ដោយអត្ថថា លួងលោមចិត្តបាន ។

ភយបរិត្តាណដ្ឋេន សុសង្ខតនគរំ : ជានគរដែលបែងចែកល្អហើយ ដោយអត្ថថា ជាទីការពារភ័យ ។

មច្ឆេរមលានីហិ អនុបលិត្តដ្ឋេន បទុមំ : ជាផ្កាបទុម ដោយអត្ថថា មិនចូលទៅជាប់មន្ទិលទាំងឡាយ មានមន្ទិលគឺសេចក្តីកំណាញ់ស្វិតជាដើម ។

តេសំ និទហនដ្ឋេន អគ្គិ : ជាភ្លើង ដោយអត្ថថា ដុតបំផ្លាញដោយមិនសល់នូវមន្ទិលទាំងឡាយ គឺសេចក្តីកំណាញ់ស្វិតជាដើមទាំងនោះ ។

ទុរាសទដ្ឋេន អាសីវិសោ : ជាអសិរពិស ព្រោះអត្ថថា ចូលជិតបានដោយលំបាក ។

អសន្តាសនដ្ឋេន សីហោ : *ជាសីហៈ ព្រោះអត្ថថា មិនមានការញាប់ញ័រតក់ស្លុត ។*

ពលវន្តដ្ឋេន ហត្ថី : *ជាដំរី ព្រោះអត្ថថា មានកំលាំង ។*

អភិមង្គលសម្មតដ្ឋេន សេតឧសភោ : *ជាគោ-ឧសភៈពណ៌ស ព្រោះអត្ថថា បានទទួលសេចក្តីលើកតម្កើងថា ជាមង្គលដ៏ប្រសើរ,*

ខេមន្តភូមិសម្បាបនដ្ឋេន វលាហកោ អស្ស-រាជា : *ជាស្តេចសេះវលាហកៈ ព្រោះអត្ថថា ធ្វើឲ្យដល់ភូមិ ដែលជាដែនក្សេម ។*

ធានំ ឆាមេតំ មយា គតមគ្គោ មយ្ហោវេសោ វំសោ *ធម្មតាទាននេះ ជាផ្លូវដែលតថាគតធ្លាប់បានដើរមក ហើយ, នេះជាវង្សរបស់តថាគត ។*

*តថាគតកាលបំពេញបារមី ១០ បានបដិបត្តិមហាយញ្ញ ដ៏ច្រើន គឺមហាយញ្ញ កាលនៅជាវេលាមព្រាហ្មណ៍ មហាយញ្ញ*

*កាលនៅជាមហាគោវិន្ទព្រាហ្មណ៍ មហាយញ្ញកាលនៅជាព្រះបាទមហាសុទស្សនៈ មហាយញ្ញកាលនៅជាព្រះបាទវេស្សន្តរ ។*

*តថាគតកាលជាទនព្វាយ រមែងប្រគល់ខ្លួន លោតចុះក្នុងគំនរភ្លើង ដែលកំពុងឆេះសន្ធោសន្ធៅ យកចិត្តយាចកដែលមកដល់ហើយទាំងឡាយ ។*

ទានញ្ហិ លោកេ សក្កសម្បត្តឹ ទេតិ មារសម្បត្តឹ ព្រហ្មសម្បត្តឹ ចក្កវត្តិសម្បត្តឹ សាវកបារមិញាណំ បច្ចេកពោធិញាណំ អភិសម្ពោធិញាណំ ទេតិ : *ពិតមែន ទានរមែងឲ្យសម្រេចសម្បត្តិ របស់ស្តេចសក្កៈ សម្បត្តិរបស់មារ សម្បត្តិរបស់ព្រហ្ម សម្បត្តិរបស់ស្តេចចក្រពត្តិ រមែងឲ្យ(សម្រេច)សាវកបារមីញាណ បច្ចេកពោធិញាណ អភិសម្ពោធិញាណក្នុងលោក ។*

*ក៏ព្រោះបុគ្គលកាលឲ្យទាន រមែងអាចនឹងសមាទានសីល ព្រោះហេតុនោះ ទើបត្រាស់សីលកថា ក្នុងលំដាប់របស់ទាននោះ មែនពិត ទានជាការបរិច្ចាគវត្ថុដែលជារបស់ខ្លួនដោយអធ្យាស្រ័យគាំទ្រ ឬដោយអធ្យាស្រ័យបូជាក្នុងទក្ខិណេយ្យបុគ្គលទាំងឡាយ*

ដល់ជនពួកដទៃ ព្រោះហេតុនោះ អ្នកឲ្យទើបជាបុរសបុគ្គលអ្នកមានអធ្យាស្រ័យគាំទ្រដោយចំណែកមួយ ក្នុងសត្វទាំងឡាយ ។ ពាក្យដែលថានឹងសម្លាប់សត្វដទៃ ឬ នឹងលួចយករបស់អ្នកដទៃទៀតនេះ មិនមែនហេតុដែលនឹងកើតមានបាន ព្រោះហេតុនោះ បុគ្គលអ្នកឲ្យទាន រមែងអាចនឹងមាទានសីលបាន ដូច្នោះ ទើបត្រាស់សីលទុកក្នុងលំដាប់នៃទាន ។

ប្រការមួយទៀត **ទានកថា** បានជាទ្រង់ត្រាស់ទុកខាងដើម ព្រោះជាសព្វសាធារណៈ ដោយការប្រព្រឹត្តិក្នុងជនពួកច្រើន ព្រោះធ្វើបានដោយងាយ និងព្រោះជាឧបាយនៃការប្រតិស្ឋានក្នុងសីលដោយពិត ។ ព្រោះថា បុគ្គលដែលមានការបរិច្ចាគជាប្រក្រតី រមែងសមាទានសីលបានដោយងាយ ព្រោះភាពជាអ្នកមិនមានការជាប់ជំពាក់នៅក្នុងវត្ថុដែលហួងហែង និងរមែងជាអ្នកតាំងនៅល្អហើយក្នុងសីលទាំងនោះ ព្រោះត្រាស់ការអនុគ្រោះបុគ្គលដទៃដោយសេចក្តីបរិសុទ្ធិនៃទាយក និង បដិគ្គាហកៈ ហើយទើបត្រាស់ការហាមការបៀតបៀនអ្នកដទៃ ព្រោះត្រាស់ធម៌គឺការធ្វើហើយ ទើបត្រាស់ធម៌គឺការមិនធ្វើ និងព្រោះត្រាស់ហេតុនៃភោគ-សម្បត្តិ និងយសសម្បត្តិហើយ ទើបត្រាស់ហេតុនៃភវសម្បត្តិ

ដោយសីល ទើបត្រាស់សីលកថា ក្នុងលំដាប់នៃទានកថា ។

## ២.សីលកថា

សីលកថា នាម សីលំ នាមេតំ អវស្សយោ បតិដ្ឋា អារម្មណំ តាណំ លេណំ គតិ បរាយណំ។ សីលំ នាមេតំ មម វំសោ ។ ដែលឈ្មោះថា សីលកថា បានដល់ ពាក្យដែលទាក់ទងដោយគុណរបស់សីល មានជាដើមយ៉ាងនេះថា ធម្មតាថា សីលនេះ ជាទីអាស្រ័យ ជាទីតាំង ជាអារម្មណ៍ ជាទីទប់ទល់ ជាទីការពារ ជាផ្លូវទៅ ជាទីទៅខាងមុខ ។ ឈ្មោះថា សីលនេះ ជាវង្សរបស់តថាគត ។

តថាគត បានបំពេញសីលទុកក្នុងអត្តភាព មិនមានទីបំផុត គឺ ក្នុងកាលដែលជាស្តេចសង្ខបាលនាគរាជ ក្នុងកាលជាស្តេចភូរិទត្តនាគរាជ ក្នុងកាលដែលជាស្តេចចម្បេយ្យនាគ-រាជ ក្នុងកាលដែលជាស្តេចដំរីសីលវរាជ ក្នុងកាលដែលជាស្តេចដំរីមាតុបោសកហត្ថី ក្នុងកាលដែលជាស្តេចដំរីឆទ្ទន្ត ។

ឥធលោក-បរលោក-សម្បត្តីនញ្ហិ សីលសទិ-សោ អវស្សយោ សីលសទិសា បតិដ្ឋា អារម្មណំ

តាណំ លេណំ គតិ បរាយនំ នត្ថិ : *ក៏ទីអាស្រ័យប្រាកដស្មើដោយសីល នៃសម្បត្តិក្នុងលោកនេះ និងក្នុងលោកខាងមុខ ទីតាំង អារម្មណ៍ ទីទប់ទល់ ទីការពារ ទីដើរទៅ ទីទៅក្នុងខាងមុខ ប្រាកដស្មើដោយសីលមិនមាន ។*

សីលាលង្ការសទិសោ អលង្ការោ នត្ថិ, *អលង្ការប្រាកដដូចជាគ្រឿងអលង្ការគឺសីលមិនមាន,*

សីលបុប្ផសទិសំ បុប្ផំ នត្ថិ : *ផ្កាឈើ ប្រាកដដូចជាផ្កាគឺសីលមិនមាន,*

សីលគន្ធសទិសោ គន្ធោ នត្ថិ : *ក្លិនប្រាកដដូចជាក្លិនគឺសីលមិនមាន,*

សីលាលង្ការេន ហិ អលង្កតំ សីលកុសុមបិឡន្ធនំ សីលគន្ធានុលិត្តំ សទេវកោបិ លោកោ ឱលោកេន្តោ តិត្តឹ ន គច្ឆតិ : *ក៏លោកនេះ ព្រមទាំងទេវលោក សម្លឹងមើលបុគ្គលដែល ប្រដាប់ដោយគ្រឿងប្រដាប់គឺសីល មានផ្កាឈើគឺសីល ជាគ្រឿងលំអ ដែលក្លិនគឺសីលលាបហើយ រមែងមិនដល់ការឆ្អែត ៗ (សារត្ថ. ៣,២៣៥-៣៦)*

ន បុប្ផគន្ធោ បដិវាតមេតិ

ន ចន្ទនំ តគរមល្លិកា វា

សតញ្ច គន្ធោ បដិវាតមេតិ

សព្វា ទិសា សប្បុរិសោ បវាយតិ ។

*ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹម ចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។*

ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី

ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។

*ក្លិននៃសីល ជាគុណជាតិប្រសើរបំផុតជាងគន្ធជាតទាំងនេះ គឺខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា ។*

អប្បមត្តោ អយំ គន្ធោ យ្វាយំ តគរចន្ទនី

យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ។

ក្លិនក្រស្នា និងក្លិនចន្ទន៍ណា ក្លិននេះ ក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះ ទើបក្រអូបលើសលប់ ផ្សាយទៅក្នុងទេវលោក និងមនុស្សលោកបាន ។

តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ
សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។

មារាធិរាជ (ទុកជាខំស្វែងរក) ក៏មិនជួបនូវផ្លូវរបស់លោកអ្នកមានសីលបរិបូរណ៍ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះ (ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។ (សុត្តន្ត. ៥២, ៣៣)

## ៣.សគ្គកថា

ដើម្បីនឹងសម្តែងថា ក៏សួគ៌នេះ បុគ្គលរមែងបាន ព្រោះអាស្រ័យសីលនេះ ព្រះមានព្រះភាគ ទើបត្រាស់សម្តែងសគ្គកថាទុកក្នុងលំដាប់នៃសីល ។

សគ្គកថា នាម អយំ សគ្គោ នាម ឥដ្ឋោ កន្តោ មនាបោ និច្ចមេត្ថ កីឡា និច្ចំ សម្បត្តិយោ

លក្ខន្តិ ៖ *ដែលឈ្មោះថា **សគ្គកថា** បានដល់ ពាក្យទាក់ទង ដោយគុណរបស់សួគ៌ មានជាដើមយ៉ាងនេះថា ឈ្មោះថា សួគ៌នេះ គួរប្រាថ្នា គួរត្រេកអរ គួរពេញចិត្ត ក្នុងសួគ៌នេះមានការលេងជានិច្ច មានសម្បត្តិជានិច្ច ។*

*ទេវតាជាន់ចាតុម្មហារាជិកា បានសុខជាទិព្វ សម្បត្តិជាទិព្វ រហូតអស់វេលា ៩ លានឆ្នាំ, ទេវតាជាន់តាវត្តិង្ស បានទិព្វសុខ ទិព្វសម្បត្តិ រហូតអស់វេលា ៣ កោដិ ៦ លានឆ្នាំ ។ ក៏ព្រះឱស្ឋរបស់ព្រះពុទ្ធទាំងឡាយ មិនល្មមនឹងត្រាស់សម្បត្តិសួគ៌ឲ្យអស់បានឡើយ ។ សេចក្តីនេះ សមនឹងព្រះបាលីដែលព្រះមានព្រះភាគ ត្រាស់ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតគប្បីពោលសគ្គកថា ដោយអនេកបរិយាយ ។*

## ៤. ទោសរបស់កាម

*ព្រះមានព្រះភាគ កាលទ្រង់ប្រលោមដោយសគ្គកថាយ៉ាងនេះហើយ តទៅបានត្រាស់ទោសដ៏ថោកទាប សេចក្តីសៅហ្មងរបស់កាមទាំងឡាយដោយន័យជាដើមថា កាមទាំងឡាយមានសេចក្តីត្រេកអរតិច មានសេចក្តីទុក្ខច្រើន មាន*

សេចក្ដីចង្អៀតចង្អល់ច្រើន ក្នុងកាមនេះ មានតែទោសច្រើន ដូច្នេះ ។ ដើម្បីនឹងសម្ដែងថា សូម្បីសួគ៌នេះ ក៏មិនទៀង មិនយឺនយូរ មិនគួរធ្វើឆន្ទរាគៈ នៅក្នុងសួគ៌នេះ ដូចបុគ្គល គុបតែងដំរីហើយ កាត់ប្រមោយដំរីនោះចេញ ។

បណ្ដាបទទាំងនេះបទថា **អាទីនវោ** ប្រែថា ទោស អធិប្បាយថា បានដល់ ការៈដែលត្រូវសេចក្ដីមិនទៀងជាដើម និងជាវត្ថុដែលមានសេចក្ដីសុខតិចជាដើម ប្រទូសរ៉ាយហើយ។ ម្យ៉ាងវិញទៀត វត្ថុណារមែងដល់ គឺប្រព្រឹត្តទៅដើម្បីសេចក្ដីគួរ ឲ្យអាណិត ហេតុនោះ វត្ថុនោះ ឈ្មោះថា **អាទីនវោ** ប្រែថា ដល់សេចក្ដីគួរឲ្យអាណិត បានដល់ ជាអ្នកគួរឲ្យអាណិត យ៉ាងក្រៃលែង ។ មួយទៀត កាមទាំងឡាយ រមែងប្រាកដដល់ បុគ្គលទាំងឡាយ អ្នកពិចារណាឃើញតាមសេចក្ដីពិតយ៉ាង នោះ ។ បទថា **ឱការោ** ប្រែថា សេចក្ដីលាមក គឺជារបស់ អាក្រក់ ព្រោះជាធម៌ដែលមនុស្សមិនប្រសើរទាំងឡាយតែង-សេព និងព្រោះជាធម៌ដែលមនុស្សប្រសើរទាំងឡាយ មិនគប្បី សេព ។ បទថា **សំកិលេសោ** សេចក្ដីថា សេចក្ដីសៅហ្មង របស់សត្វទាំងឡាយដោយកាមទាំងនោះ អធិប្បាយថា ការ

ដែលសត្វទាំងឡាយ ដែលកាមទាំងឡាយនោះ គប្បីបៀតបៀន គឺគប្បីចូលទៅធ្វើឲ្យក្តៅក្រហាយ ។

## ៥-អានិសង្សក្នុងនេក្ខម្មៈ

ព្រះមានព្រះភាគ កាលទ្រង់គំរាមដោយទោសនៃកាមយ៉ាងនេះហើយ ទ្រង់ប្រកាសអានិសង្សក្នុងនេក្ខម្មៈ ។

យត្តកា ច កាមេសុ អាទីនវា បដិបក្ខតោ តត្តកាវ នេក្ខម្មេ អានិសំសា ក៏ទោសក្នុងកាមទាំងឡាយ មានប្រមាណប៉ុនណា អានិសង្សក្នុងនេក្ខម្មៈ មានប្រមាណប៉ុណ្ណោះឯង ព្រោះជាបដិបក្ខចំពោះកាមនោះ ។

អបិ ច នេក្ខម្មំ នាមេតំ អសម្ពាធំ អសំកិលិដ្ឋំ និក្ខន្តំ កាមេហិ និក្ខន្តំ កាមសញ្ញាយ និក្ខន្តំ កាមវិតក្កេហិ និក្ខន្តំ កាមបរិឡាហេហិ និក្ខន្តំ ព្យាបាទតោតិអាទិនា នយេន នេក្ខម្មេ អានិសំសំ បកាសេសិ ។

ម្យ៉ាងទៀត ទ្រង់ប្រកាសអានិសង្សក្នុងនេក្ខម្មៈដោយន័យជាដើមថា ឈ្មោះថា នេក្ខម្មៈនេះ មិនតូចចង្អៀត មិនសៅហ្មង ចេញចាកកាមទាំងឡាយ ចេញចាកកាមសញ្ញាទាំងឡាយ ចេញចាកកាមវិតក្កៈទាំងឡាយ ចេញចាកសេចក្ដីក្ដៅក្រហាយ គឺកាមទាំងឡាយ ចេញចាកសេចក្ដីខ្វល់ខ្វាយ ។

ព្រះមានព្រះភាគ ទ្រង់សរសើរគុណក្នុងបព្វជ្ជា និងក្នុងធម៌ទាំងឡាយ មានឈានជាដើម ។ ក៏ក្នុងអនុបុព្វីកថា ព្រះមានព្រះភាគ កាលត្រាស់សួគ៌ហើយ នឹងគប្បីត្រាស់មគ្គទុកក្នុងលំដាប់នៃសួគ៌ ដើម្បីនឹងទ្រង់សម្ដែងថា សួគ៌នោះសៅហ្មងទៅដោយកិលេសមានរាគៈជាដើម និងអរិយមគ្គ មិនសៅហ្មងដោយប្រការទាំងពួង ។ ក៏កាលត្រាស់មគ្គ ទើបនឹងគប្បីត្រាស់ទោសរបស់កាមទាំងឡាយថា កាមទាំងឡាយសូម្បីរាប់ជាប់ដោយសួគ៌ ដែលឈ្មោះថា កាមទាំងអស់ សូម្បីក្រៅពីនេះមានទោសច្រើន មិនទៀង មិនយឺនយូរ មានការប្រែប្រួលទៅជាធម្មតា គប្បីត្រាស់សេចក្ដីថោកទាប គឺសេចក្ដីលាមករបស់កាមទាំងនោះថា កាមទាំងឡាយអាក្រក់ ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនរបស់អរិយៈ មិនប្រកបដោយ

ប្រយោជន៍ និងត្រាស់សេចក្ដីសៅហ្មងក្នុងកាមទាំងឡាយនោះថា ភពសូម្បីទាំងពួងជាទីតាំងនៃកិលេសទាំងឡាយ និងគប្បីត្រាស់អានិសង្សក្នុងនេក្ខម្មៈថា និព្វានផុតចាកសេចក្ដីសៅហ្មងនៃកិលេសទាំងពួង ដើម្បីនឹងទ្រង់បង្ហាញឧបាយដែលជាហេតុសម្រេចមគ្គនោះ ព្រោះហេតុនោះ គប្បីឃើញថា ព្រះមានព្រះភាគ ទ្រង់ប្រកាសទោស សេចក្ដីថោកទាប សេចក្ដីសៅហ្មងក្នុងកាមទាំងឡាយ និងទ្រង់ប្រកាសអានិសង្សក្នុងនេក្ខម្មៈ ។

(សារត្ថទីបនីដីកា ៣, ២៣៧)

## អនាយុស្សធម៌ ៥ យ៉ាង

(ធម៌ធ្វើឲ្យអាយុថយ)

១-អសប្បាយការី មិនចេះធ្វើខ្លួនឲ្យសប្បាយ

២-សប្បាយេ មត្តំ ន ជានាតិ មិនដឹងប្រមាណក្នុងការសប្បាយ

៣-អបរិណតភោជី ជាអ្នកបរិភោគអាហារមិនរលួយ

៤-អកាលចារី ជាអ្នកត្រាច់ទៅមិនត្រូវតាមកាល

៥–អព្រហ្មចារី ជាអ្នកមិនប្រព្រឹត្តធម៌ដ៏ប្រសើរ ។

## អាយុស្សធម៌ ៥ យ៉ាង

*(ធម៌ធ្វើឲ្យចម្រើនអាយុ)*

១–សប្បាយការី *ចេះធ្វើខ្លួនឲ្យសប្បាយ*

២–សប្បាយេ មត្តំ ជានាតិ *ដឹងប្រមាណ*
*ក្នុងការសប្បាយ*

៣–បរិណតភោជី *ជាអ្នកបរិភោគអាហាររលួយ*

៤–កាលចារី *ជាអ្នកត្រាច់ទៅត្រូវតាមកាល*

៥–ព្រហ្មចារី *ប្រព្រឹត្តធម៌ដ៏ប្រសើរ ។*

## អនាយុស្សធម៌មាន៥ទៀត

១–*ជាអ្នកមិនចេះធ្វើខ្លួនឲ្យសប្បាយ*

២–*មិនដឹងប្រមាណក្នុងការសប្បាយ*

៣–*ជាអ្នកបរិភោគអាហារមិនរលួយ*

៤–ទុស្សីលោ *ជាអ្នកទ្រុស្តសីល*

៥-ទាបមិត្តោ ជាអ្នកមានមិត្តអាក្រក់ ។

## អាយុស្សធម៌មាន៥ទៀត

១-ជាអ្នកចេះធ្វើខ្លួនឲ្យសប្បាយ

២-ដឹងប្រមាណក្នុងការសប្បាយ

៣-ជាអ្នកបរិភោគអាហាររលួយ

៤-សីលវា ជាអ្នកមានសីល

៥-កល្យាណមិត្តោ ជាអ្នកមានកល្យាណមិត្ត ។

(សុត្តន្តបិដក ៤៥, ៣៥)

## បុគ្គលស្តាប់ព្រះសទ្ធម្មមិនឈានចុះកាន់និយាម និងគួរឈានចុះកាន់និយាម

ក / បុគ្គលប្រកបដោយធម៌ ៥ យ៉ាង ស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម គឺមគ្គ ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន

១-កថំ បរិភោតិ មើលងាយពាក្យពោល

២-កថិកំ បរិភោតិ *មើលងាយបុគ្គល*
*អ្នកពោល*

៣-អត្តានំ បរិភោតិ *មើលងាយខ្លួនឯង*

៤-វិក្ខិត្តចិត្តោ ធម្មំ សុណាតិ *មានចិត្ត*
*រវើរវាយស្តាប់ធម៌*

៥-អនេកគ្គចិត្តោ អយោនិសោ មនសិករោតិ
*មានចិត្តមិននឹងនួនទៅក្នុងអារម្មណ៍តែមួយ គឺមិនយកចិត្តទុកដាក់ដោយឧបាយប្រាជ្ញា ។*

***៩ / បុគ្គលប្រកបដោយធម៌ ៥ យ៉ាងកាលស្តាប់ព្រះសទ្ធម្ម គួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃក្នុងកុសលធម៌ទាំងឡាយបាន***

១-ន កថំ បរិភោតិ *មិនមើលងាយពាក្យពោល*

២-ន កថិកំ បរិភោតិ *មិនមើលងាយ*
*បុគ្គលអ្នកពោល*

៣-ន អត្តានំ បរិភោតិ *មិនមើលងាយខ្លួនឯង*

៤-អវិក្ខិត្តចិត្តោ ធម្មំ សុណាតិ *មានចិត្ត*

*មិនរវើរវាយស្តាប់ធម៌*

៥-ឯកគ្គចិត្តោ យោនិសោ ច មនសិករោតិ

*មានចិត្តនឹងនួននៅក្នុងអារម្មណ៍តែមួយ គឺយកចិត្តទុកដាក់ ដោយឧបាយប្រាជ្ញា ។*

*គ / បុគ្គលប្រកបដោយធម៌ ៥ យ៉ាងសូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃក្នុងកុសលធម៌ទាំងឡាយបាន*

១-កថំ បរិភោតិ *មើលងាយពាក្យពោល*

២-កថិកំ បរិភោតិ *មើលងាយបុគ្គលអ្នកពោល*

៣-អត្តានំ បរិភោតិ *មើលងាយខ្លួនឯង*

៤-ទុប្បញ្ញោ ហោតិ ជឡោ ឯឡមូគោ
*អ័ប្បឥតប្រាជ្ញា ល្ងង់ខ្លៅលលា*

៥-អនញ្ញាតេ អញ្ញាតមានី *សម្គាល់ថា*
*បានដឹងក្នុងហេតុដែលខ្លួនមិនដឹង ។*

*៧ / បុគ្គលប្រកបដោយធម៌ ៥ យ៉ាងកាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃក្នុងកុសលធម៌ទាំងឡាយបាន*

១-ន កថំ បរិភោតិ *មិនមើលងាយពាក្យពោល*

២-ន កថិកំ បរិភោតិ *មិនមើលងាយបុគ្គលអ្នកពោល*

៣-ន អត្តានំ បរិភោតិ *មិនមើលងាយខ្លួនឯង*

៤-បញ្ញវា ហោតិ អជឡោ អនេឡមូគោ *ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនលលា*

៥-ន អនញ្ញាតេ អញ្ញាតមានី *មិនសម្គាល់ថាបានដឹងក្នុងហេតុដែលខ្លួនមិនបានដឹង ។*

*៨ / បុគ្គលប្រកបដោយធម៌ ៥ យ៉ាង សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលទាំងឡាយបាន*

១-មក្ខី ធម្មំ សុណាតិ មក្ខបរិយុដ្ឋិតោ

*ជាអ្នកលុបគុណគេ មានសេចក្ដីលុបគុណគ្របសង្កត់ ហើយស្ដាប់ធម៌*

២-សឧចារម្ភចិត្តោ ធម្មំ សុណាតិ រន្ធគវេសី *មានចិត្តប្រុងសង្កត់សង្កិនស្វែងរកទោស ហើយស្ដាប់ធម៌*

៣-ធម្មទេសកេ អាហាតចិត្តោ ហោតិ ខិល-ជាតោ *ជាអ្នកមានចិត្តតក់ម៉ក់របឹងរឹងរូស ក្នុងបុគ្គលអ្នកសម្ដែងធម៌*

៤-ទុប្បញ្ញោ ហោតិ ជឡោ ឯឡមូគោ *ជាអ្នកអប្បឥតបញ្ញា ល្ងង់ខ្លៅលលា*

៥-អនញ្ញាតេ អញ្ញាតមានី *ជាអ្នកសម្គាល់ថាបានដឹងក្នុងហេតុដែលខ្លួនមិនបានដឹង ។*

***ច / បុគ្គលប្រកបដោយធម៌ ៥ យ៉ាង កាលស្ដាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន***

១-អមក្ខី ធម្មំ សុណាតិ ន មក្ខបរិយុដ្ឋិតោ *ជាអ្នកមិនលុបគុណគេ មិនមានសេចក្ដីលុបគុណគ្របសង្កត់*

ហើយស្ដាប់ធម៌

២-អនុបារម្ភចិត្តោ ធម្មំ សុណាតិ ជនដែលគរវៈសី មានចិត្តមិនប្រុងសង្កត់សង្កិន មិនស្វែងរកទោស ហើយស្ដាប់ធម៌

៣-ធម្មទេសកេ អនាហតចិត្តោ ហោតិ អខីលជាតោ ជាអ្នកមានចិត្តមិនតក់ម៉ក់ មិនរបឹងរឹងរូស ក្នុងបុគ្គលអ្នកសម្ដែងធម៌

៤-បញ្ញវា ហោតិ អជឡោ អនេឡមូគោ ជាអ្នកមានបញ្ញា មិនល្ងង់ខ្លៅ មិនលលា

៥-ន អនញ្ញាតេ អញ្ញាតមានី មិនសម្គាល់ថាបានដឹងក្នុងហេតុដែលខ្លួនមិនដឹង ។

## ធម៌ ៥ យ៉ាង ប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធាន

១-ន សក្កច្ចំ ធម្មំ សុណន្តិ មិនស្ដាប់ធម៌ ដោយគោរព

២-ន សក្កច្ចំ ធម្មំ បរិយាបុណន្តិ មិនរៀនធម៌ ដោយគោរព

៣-ន សក្កច្ចំ ធម្មំ ធារេន្តិ មិនទ្រទ្រង់(ចាំទុក) នូវធម៌ដោយគោរព

៤-ន សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ មិនពិចារណាអត្ថនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយ ដោយគោរព

៥-ន សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ ដឹងអត្ថ ដឹងធម៌ហើយ មិនប្រតិបត្តិធម៌តាមសមគួរដល់ធម៌ដោយគោរព ។

**ធម៌ ៥ យ៉ាងប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម ឋិតថេរ មិនសាបសូន្យ មិនអន្តរធាន**

១-សក្កច្ចំ ធម្មំ សុណន្តិ ស្តាប់ធម៌ដោយគោរព

២-សក្កច្ចំ ធម្មំ បរិយាបុណន្តិ រៀនធម៌ ដោយគោរព

៣-សក្កច្ចំ ធម្មំ ធារេន្តិ *ទ្រទ្រង់ធម៌ដោយគោរព*

៤-សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ *ពិចារណាអត្ថនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយ ដោយគោរព*

៥-សក្កច្ចំ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ *ដឹងអត្ថ ដឹងធម៌ហើយ ប្រតិបត្តិធម៌តាមសមគួរដល់ធម៌ដោយគោរព*

## ធម៌ ៥ យ៉ាងប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធាន

១-ភិក្ខូ ធម្មំ ន បរិយាបុណន្តិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភូតធម្មំ វេទល្លំ : *ភិក្ខុទាំងឡាយ មិនរៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ ;*

២-ភិក្ខូ យថាសុតំ យថាបរិយត្តំ ធម្មំ ន វិត្ថារេន បរេសំ ទេសេន្តិ *ភិក្ខុទាំងឡាយ មិនសម្ដែង-*

ធម៌ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃដោយពិស្ដារ

៣-ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ ន វិត្ថារេន បរេសំ វាចេន្តិ ភិក្ខុទាំងឡាយ មិនបង្ហាញធម៌ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃដោយពិស្ដារ

៤-ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ ន វិត្ថារេន សជ្ឈាយំ ករោន្តិ ភិក្ខុទាំងឡាយមិនធ្វើនូវការស្វាធ្យាយ (ទន្ទេញ)ធម៌ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃដោយពិស្ដារ

៥-ភិក្ខុ យថាសុតំ យថាបរិយត្តំ ធម្មំ ន ចេតសា អនុវិតក្កេន្តិ អនុវិចារេន្តិ មនសា-នុបេក្ខន្តិ ភិក្ខុទាំងឡាយ មិនត្រិះរិះរឿយៗ មិនពិចារណារឿយៗ ដោយចិត្ត មិនជញ្ជឹងរឿយៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក ។

## ធម៌ ៥ យ៉ាងប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម មិនសាបសូន្យ មិនអន្តរធាន

*១-ភិក្ខុទាំងឡាយ រៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ.*

*២-ភិក្ខុទាំងឡាយ សម្តែងធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃដោយពិស្តារ*

*៣-ភិក្ខុទាំងឡាយ បង្ហាញធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃដោយពិស្តារ*

*៤-ភិក្ខុទាំងឡាយ ធ្វើនូវការស្វាធ្យាយធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ*

*៥-ភិក្ខុទាំងឡាយ ត្រិះរិះរឿយៗ ពិចារណារឿយៗ ដោយចិត្ត ជញ្ជឹងរឿយៗ ក្នុងចិត្តនូវធម៌តាមដែលបានស្តាប់មក តាមដែលបានរៀនមក ។*

*(សុត្តន្តបិដក ៤៥, ៩៦-៩៨)*

## ធម៌ ៥ យ៉ាងប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធាន

១-ភិក្ខុទាំងឡាយ ក្នុងសាសនានេះ រៀននូវព្រះសូត្រ ដែលខ្លួនរៀនខុស ដោយបទនិងព្យញ្ជនៈ ដែលរៀបរៀងខុស ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈ ដែលរៀបរៀងខុស រមែងយល់សេចក្តីបានដោយកម្រ ។

២-ភិក្ខុទាំងឡាយ ជាអ្នកប្រដៅបានដោយក្រ ប្រកប ដោយធម៌ ដែលធ្វើឲ្យគេប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ ទទួលពាក្យប្រៀនប្រដៅខាងស្តាំ

៣-ភិក្ខុទាំងឡាយ ជាអ្នកចេះដឹងច្រើន មានអាគម គឺ និកាយដ៏ស្ទាត់ ចងចាំនូវព្រះសូត្រ ចងចាំនូវវិន័យ ចងចាំនូវ មាតិកា ភិក្ខុទាំងនោះ មិនឲ្យភិក្ខុដទៃរៀនព្រះសូត្រដោយ គោរព លុះអំណើះ ឥតពីភិក្ខុនោះទៅ ព្រះសូត្រក៏ដាច់ឫស មិនប្រតិស្ឋាននៅ

៤-ភិក្ខុទាំងឡាយជាថេរៈ ជាអ្នកប្រតិបត្តិដើម្បីឲ្យកើត លាភច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិ បន្ធូរបន្ថយ ដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាម ដើម្បីដល់

នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណ-វិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតខាងក្រោយ គឺសទ្ធិវិហារិក អន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុជាថេរៈទាំងនោះ ប្រជុំជនខាងក្រោយទាំងនោះ ក៏ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈក្នុងវិវេក មិនប្រារព្ធនូវព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួន មិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

៥-សង្ឃបែកគ្នា ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ ការជេរគ្នានឹងគ្នា ក៏មានការប្រទេចផ្ដាសាគ្នានឹងគ្នា ក៏មាន ការបោះពាក្យសំដីទៅរកគ្នានឹងគ្នា ក៏មានការលះបង់គ្នានឹងគ្នា ក៏មាន ពួកជនដែលមិនទាន់ជ្រះថ្លាក្នុងសង្ឃទាំងនោះ ក៏មិនមានសេចក្ដីជ្រះថ្លា ដែលជ្រះថ្លាស្រាប់ហើយ ក៏ងាកចិត្តលែងជ្រះថ្លាវិញ ។

## ធម៌ ៥ យ៉ាងប្រព្រឹត្តទៅដើម្បីឱ្យព្រះសទ្ធម្ម ឋិតថេរ មិនសាបសូន្យ មិនអន្តរធាន

១-ភិក្ខុទាំងឡាយ រៀននូវព្រះសូត្រ ដែលខ្លួនរៀន ត្រូវដោយបទនិងព្យញ្ជនៈ ដែលរៀបរៀងត្រូវ ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈ ដែលរៀបរៀងត្រូវ រមែងយល់សេចក្ដីបានងាយ ។

២-ភិក្ខុទាំងឡាយ ជាអ្នកប្រដៅងាយ ប្រកបដោយធម៌ដែលធ្វើឲ្យជាអ្នកប្រដៅងាយ ជាអ្នកចេះអត់ធន់ ទទួលពាក្យប្រៀនប្រដៅខាងស្ដាំ

៣-ភិក្ខុទាំងឡាយណា មានសេចក្ដីចេះដឹងច្រើន មានអាគម គឺនិកាយដ៏ស្ទាត់ ចងចាំនូវព្រះសូត្រ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ ឲ្យភិក្ខុដទៃរៀនព្រះសូត្រ ដោយគោរព លុះអំណើះតពីភិក្ខុនោះទៅ ព្រះសូត្រ ក៏មិនបានដាច់ឫស ប្រតិស្ឋាននៅបាន

៤-ភិក្ខុទាំងឡាយជាថេរៈ មិនប្រតិបត្តិ ដើម្បីឲ្យកើតលាភច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈក្នុងការប្រតិបត្តិបន្ធូរបន្ថយចេញ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បី

ដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតជាខាងក្រោយ គឺសទ្ធិវិហារិក អន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុជាថេរៈទាំងនោះ បច្ឆិមជនទាំងនោះឯង ក៏មិនជាអ្នកប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈក្នុងការប្រតិបត្តិបន្ធូរបន្ថយចេញ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណវិសេសដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។

៥-សង្ឃព្រមព្រៀងគ្នា មានសេចក្តីរីករាយរកគ្នា មិនទាស់ទែងគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅជាសុខ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃព្រមព្រៀងគ្នាហើយ ការជេរគ្នានឹងគ្នា ក៏មិនមាន ការប្រទេចផ្តាសាគ្នានឹងគ្នា ក៏មិនមាន ការបោះពាក្យសំដីទៅរកគ្នានឹងគ្នា ក៏មិនមាន ការលះបង់គ្នានឹងគ្នា ក៏មិនមាន ពួកជនដែលមិនទាន់ជ្រះថ្លាក្នុងសង្ឃទាំងនោះ ក៏រមែងជ្រះថ្លា

*ដែលជ្រះថ្លាស្រាប់ហើយ ក៏រឹងរឹតតែជ្រះថ្លាឡើង ។*

*(សុត្តន្តបិដក ៤៥ / ៩៩-១០៣)*

**ចណ្ឌាលខុបាសក**

១-អស្សទ្ធោ ហោតិ *ជាអ្នកមិនមានសទ្ធា*

២-ទុស្សីលោ ហោតិ *ជាអ្នកទ្រុស្តសីល*

៣-កោតុហលមង្គលិកោ ហោតិ *ប្រកាន់មង្គលភ្ញាក់ផ្អើល*

៤-មង្គលំ បច្ចេតិ នោ កម្មំ *ជឿតែមង្គលមិនជឿកម្ម*

៥-ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ *ស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅពុទ្ធសាសនា ហើយធ្វើបុណ្យនឹងទក្ខិណេយ្យបុគ្គលនោះ ។*

**បទុមខុបាសក**

១-សទ្ធោ ហោតិ *ជាអ្នកមានសទ្ធា*

២-សីលវា ហោតិ *ជាអ្នកមានសីល*

៣-អកោតុហលមង្គលិកោ ហោតិ *ជាអ្នក មិនប្រកាន់មង្គលភ្ញាក់ផ្អើល*

៤-កម្មំ បច្ចេតិ នោ មង្គលំ *ជឿតែកម្ម មិនជឿមង្គល*

៥-ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ *មិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យតែក្នុងពុទ្ធសាសនានេះ ។*

*(សុត្តន្តបិដក ៤៥ / ១៥៥)*

## ជំនួញខុស ៥ យ៉ាង

១-សត្ថវណិជ្ជា *ការជួញគ្រឿងសស្ត្រាវុធ*

២-សត្តវណិជ្ជា *ការជួញមនុស្ស*

៣-មំសវណិជ្ជា *ការជួញ (សត្វដែលគេ សម្លាប់យក) សាច់*

៤-មជ្ជវណិជ្ជា *ការជួញគ្រឿងស្រវឹង*

*៥-វិសវណិជ្ជា ការជួញថ្នាំពិស ។*

*(សុត្តន្តបិដក ៤៥ / ១៦០)*

## អភិណ្ហបច្ចវេក្ខណធម៌ ៥ យ៉ាង

១-ជរាធម្មោម្ហិ ជរំ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា, *ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ*

២-ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា, *ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបានឡើយ*

៣-មរណធម្មោម្ហិ មរណំ អនតីតោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន

វា បព្វជិតេន វា, *ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា អាត្មាអញ មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ*

៤-សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា, *ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗថា អាត្មាអញតែងមានសេចក្តីព្រាត់ប្រាស និរាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីគាប់ចិត្តទាំងពួង;*

៥-កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមីតិ អភិណ្ហំ បច្ចវេក្ខិតព្វំ ឥត្ថិយា វា បុរិសេន វា គហដ្ឋេន វា បព្វជិតេន វា, *ស្ត្រីក្តី បុរសក្តី គ្រហស្ថក្តី បព្វជិតក្តី គួរពិចារណារឿយៗ ថា*

*អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីរលឹក អាត្មាអញនឹងធ្វើនូវកម្មណា ទោះល្អក្តី អាក្រក់ក្តី នឹងជាអ្នកទទួលនូវផលនៃកម្មនោះ (ពុំខានឡើយ) ។*

## ព្រះគាថា

*ធម៌ទាំងឡាយ គឺព្យាធិធម៌ ជរាធម៌ និងមរណធម៌ មាននៅយ៉ាងណា ពួកបុថុជ្ជន ជាសប្បុរស រមែងស្អប់ខ្ពើមយ៉ាងនោះ ។ កាលបើពួកសត្វ មានសភាវៈយ៉ាងនេះហើយ តថាគតក៏គួរធុញទ្រាន់នឹងសភាវៈនោះដែរ ហេតុនោះ មិនមានដល់តថាគត មានសភាពដ៏សមគួរ មានវិហារធម៌យ៉ាងនេះ ។ តថាគតនោះ កាលបើនៅយ៉ាងនេះ ក៏ដឹងនូវធម៌ដែលប្រាសចាកឧបធិ បានឃើញបព្វជ្ជាថា ជាការក្សេមគ្របសង្កត់នូវសេចក្តីស្រវឹងទាំងពួង គឺស្រវឹងក្នុងភាវៈនៃខ្លួនជាបុគ្គលមិនមានរោគ ក្នុងវ័យក្នុងជីវិតបាន ។ សេចក្តីព្យាយាមក៏កើតមានដល់តថាគតនោះ កាលដែលឃើញច្បាស់នូវព្រះនិព្វាន តថាគតមិនគួរដើម្បីសេពកាមទាំងឡាយបានវិញ ក្នុងកាលឥឡូវនេះទេ តថាគតនឹងជាអ្នក*

*ប្រព្រឹត្តព្រហ្មចរិយធម៌តទៅ មិនបានត្រឡប់វិញឡើយ ។*

*(សុត្តន្ត. ៤៤ / ១៤៦-១៥៤)*

## វាចាសុភាសិត

*វាចាដែលប្រកបដោយអង្គ ៥ ឈ្មោះថាសុភាសិត មិនមែនជាទុព្ភាសិត ជាវាចាមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញ មិនគប្បីតិះដៀលផង*

១-កាលេន ភាសិតា *វាចាដែលពោលប្រកបតាមកាល*

២-សច្ចា ភាសិតា *វាចាដែលពោលពិត*

៣-សណ្ហា ភាសិតា *វាចាដែលពោលទន់ភ្លន់*

៤-អត្ថសញ្ហិតា ភាសិតា *វាចាដែលពោលប្រកបដោយប្រយោជន៍*

៥-មេត្តចិត្តេន ភាសិតា *វាចាដែលពោលប្រកបដោយមេត្តាចិត្ត ។ (សុត្តន្ត. ៤៥,២៣១)*

## អានិសង្សនៃការស្តាប់ព្រះសទ្ធម្ម ៥ យ៉ាង

១-អស្សុតំ សុណាតិ *អ្នកស្តាប់តែងបានស្តាប់ រឿងមិនទាន់បានស្តាប់*

២-សុតំ បរិយោទបេតិ *រឿងណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្តច្បាស់ នឹងចូលចិត្តច្បាស់ឡើងបាន*

៣-កង្ខំ វិហានតិ *កំចាត់បង់សេចក្តីសង្ស័យចេញបាន*

៤-ទិដ្ឋឹ ឧជុំ ករោតិ *ធ្វើសេចក្តីឃើញឲ្យត្រង់*

៥-ចិត្តមស្ស បសីទតិ *ចិត្តអ្នកស្តាប់រមែងជ្រះថ្លា។*

*(សុត្តន្តបិដក ៤៥ / ២៣៨)*

## ទោសនៃសេចក្តីមិនអត់ធន់មាន ៥ យ៉ាង

១-ពហុនោ ជនស្ស អប្បិយោ ហោតិ អមនាបោ *មិនជាទីស្រឡាញ់ពេញចិត្តនៃជនច្រើន*

២-វេរពហុលោ *ជាអ្នកច្រើនដោយពៀរ*

៣-វជ្ជពហុលោ *ច្រើនដោយទោស*

៤-សម្មូឡ្ហោ កាលំ ករោតិ *តែងស្លាប់វង្វេងស្មារតី*

៥-កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងកំណើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ។*

**អានិសង្សនៃសេចក្តីអត់ធន់មាន ៥ យ៉ាង**

១-ពហុនោ ជនស្ស បិយោ ហោតិ មនាបោ *ជាទីស្រឡាញ់ជាទីពេញចិត្តរបស់ជនច្រើន*

២-ន វេរពហុលោ *មិនច្រើនដោយពៀរ*

៣-ន វជ្ជពហុលោ *មិនច្រើនដោយទោស*

៤-អសម្មូឡ្ហោ កាលំ ករោតិ *តែងស្លាប់មិនវង្វេងស្មារតី*

៥-កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយស្លាប់ទៅ តែង*

*ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។* *(សុត្តន្តបិដក ៤៥,២៥១)*

## ទោសនៃសេចក្តីមិនអត់ធន់មាន ៥ យ៉ាង

១-ពហុនោ ជនស្ស អប្បិយោ ហោតិ អមនាបោ *មិនជាទីស្រឡាញ់ជាទីពេញចិត្តរបស់ជនច្រើន*

២-លុទ្ទោ *ជាមនុស្សអាក្រក់*

៣-វិប្បដិសារី *ជាមនុស្សមានសេចក្តីក្តៅក្រហាយ*

៤-សម្មូឡ្ហោ កាលំ ករោតិ *តែងស្លាប់វង្វេងស្មារតី*

៥-កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងកំណើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ។*

## អានិសង្សនៃសេចក្តីអត់ធន់មាន ៥ យ៉ាង

១-ពហុនោ ជនស្ស បិយោ ហោតិ មនាបោ

*ជាទីស្រឡាញ់ជាទីពេញចិត្តរបស់ជនច្រើន*

២-អលុទ្ធោ *មិនជាមនុស្សអាក្រក់*

៣-អវិប្បដិសារី *មិនក្តៅក្រហាយ*

៤-អសម្មូឡ្ហោ កាលំ ករោតិ *តែងស្លាប់មិនវង្វេងស្មារតី*

៥-កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។*

(សុត្តន្ត. ៤៥ , ២៥១)

## ទោស៥យ៉ាងមានដល់បុគ្គលប្រព្រឹត្តអាក្រក់

១-អត្តាបិ អត្តានំ ឧបវទតិ *ខ្លួនឯងតិះដៀលខ្លួនឯងបាន*

២-អនុវិច្ច វិញ្ញូ គរហន្តិ *អ្នកប្រាជ្ញទាំងឡាយពិចារណាហើយ តិះដៀលបាន*

៣-ចាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កិត្តិសព្ទ

*ដ៏អាក្រក់ខ្ចរខ្ចាយទៅ*

៤-សម្មុឡ្ហោ កាលំ ករោតិ *វេលាស្លាប់វង្វេងស្មារតី*

៥-កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយនិងនរក ។*

## អានិសង្ស ៥ យ៉ាងមានដល់បុគ្គលប្រព្រឹត្តល្អ

១-អត្តាបិ អត្តានំ ន ឧបវទតិ *ខ្លួនឯងមិនតិះដៀលខ្លួនឯងបាន*

២-អនុវិច្ច វិញ្ញូ បសំសន្តិ *អ្នកប្រាជ្ញទាំងឡាយពិចារណាហើយសរសើរ*

៣-កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ *កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ*

៤-អសម្មុឡ្ហោ កាលំ ករោតិ *វេលាស្លាប់*

*មិនវង្វេងស្មារតី*

៥-កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។*

*(សុត្តន្តបិដក ៤៥ / ២៧៤)*

## អសប្បុរិសទាន ៥ យ៉ាង

១-អសក្កច្ចំ ទេតិ *ឲ្យទានដោយមិនគោរព (ក្នុងទេយ្យធម៌ បានដល់ មិនគោរព គឺធ្វើចិត្តឲ្យស្អាតឲ្យទានទេ)*

២-អចិត្តឹ កត្វា ទេតិ *ឲ្យទានដោយមិនធ្វើនូវសេចក្ដីគោរព (ក្នុងបដិគ្គាហកៈ បានដល់ ឲ្យដោយអាការៈមិនកោតក្រែងដោយសេចក្ដីមិនគោរព)*

៣-អសហត្ថា ទេតិ *មិនឲ្យដោយដៃខ្លួនឯង*

៤-អបវិទ្ធំ ទេតិ *ឲ្យទានដូចជាបោះចោល*

៥-អនាគមនទិដ្ឋិកោ ទេតិ *ឲ្យទានដោយឃើញថា មិនឲ្យផល (បានដល់ មិនធ្វើសេចក្ដីឃើញផលកម្មនឹង*

មកយ៉ាងនេះថា ផលនៃកម្មដែលធ្វើនឹងមកដល់ ដូច្នេះ ឲ្យកើតឡើងទេ) ។

## សប្បុរិសទាន ៥ យ៉ាង

១-សក្កច្ចំ ទេតិ ឲ្យទានដោយគោរព (ក្នុងទេយ្យធម៌)

២-ចិត្តីកត្វា ទេតិ ឲ្យទានដោយធ្វើនូវសេចក្ដីគោរព (ក្នុងបដិគ្គាហកៈ)

៣-សហត្ថា ទេតិ ឲ្យទានដោយដៃខ្លួនឯង

៤-អនបវិទ្ធំ ទេតិ ឲ្យទានមិនដូចជាបោះចោល

៥-អាគមនទិដ្ឋិកោ ទេតិ ឲ្យទានដោយឃើញថាឲ្យផល (គឺធ្វើសេចក្ដីឃើញផលកម្មនឹងមកយ៉ាង នេះថា ផលនៃកម្មដែលធ្វើនឹងមកដល់ដូច្នេះ ឲ្យកើតឡើង) ។

(សុត្តន្ត. អង្គុត្តរនិកាយ ៤៥ / ៨៧)

# អដ្ឋកថា

*បទថា ចិតី កត្វា ចេតិ បានដល់ ចូលទៅតាំងសេចក្ដីកោតក្រែងក្នុងទេយ្យធម៌ និងទក្ខិណេយ្យបុគ្គល ហើយឲ្យ ។ ក្នុងពីរយ៉ាងនោះ បុគ្គលធ្វើទេយ្យធម៌ឲ្យប្រណីត មានរសឆ្ងាញ់ហើយឲ្យ ឈ្មោះថា ចូលទៅតាំងសេចក្ដីកោតក្រែងក្នុងទេយ្យធម៌ ។ បុគ្គលជ្រើសរើសបុគ្គលហើយឲ្យ ឈ្មោះថាតាំងសេចក្ដីកោតក្រែងក្នុងទក្ខិណេយ្យបុគ្គល ។*

*បទថា សហត្ថា ទេតិ សេចក្ដីថា មិនប្រើដៃរបស់អ្នកដទៃ ឲ្យតាមពាក្យបញ្ជា ឲ្យដោយដៃខ្លួនឯងប៉ុណ្ណោះ ដោយគិតថា ឈ្មោះថា វេលាដែលយើងត្រាច់រង្គាត់ទៅក្នុងសង្សារវដ្ដដែលមិនមានខាងដើម និងខាងចុងហើយ បានប្រើដៃនិងជើងនោះ មិនមានប្រមាណឡើយ យើងនឹងធ្វើសេចក្ដីរួចផុតទៅអំពីវដ្ដៈ សេចក្ដីចេញចាកភពដូច្នោះ ។*

*បទថា អាគមនទិដ្ឋិកោ បានដល់ ជឿកម្មនិងវិបាក ថានឹងជាបច្ច័យនៃភពក្នុងអនាគតហើយឲ្យ ដូច្នេះ ។*

*(មនោរថបូរណី អដ្ឋកថា អង្គុត្តរនិកាយ បញ្ចកនិបាត)*

## សប្បុរិសទាន ៥ យ៉ាង ព្រមទាំងអានិសង្ស

បញ្ចិមានិ ភិក្ខវេ សប្បុរិសទានានិ *ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះ មាន ៥ យ៉ាង ។*

កតមានិ បញ្ច *សប្បុរិសទាន៥យ៉ាង ដូចម្តេចខ្លះ?*

១-សទ្ធាយ ទានំ ទេតិ *ឲ្យទានដោយសទ្ធា*

២-សក្កច្ចំ ទានំ ទេតិ *ឲ្យទានដោយគោរព*

៣-កាលេន ទានំ ទេតិ *ឲ្យទានតាមកាលដ៏សមគួរ*

៤-អនុគ្គហិតចិត្តោ ទានំ ទេតិ *ឲ្យទានដោយចិត្តអនុគ្រោះ*

៥-អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ *ឲ្យទានដោយមិនបានបៀតបៀនខ្លួនឯងនិងអ្នកដទៃ ។*

### សេចក្តីអធិប្បាយ

*សទ្ធាទាន “ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយសទ្ធា ដោយផលទាននេះ កាលកើតក្នុងទីណាៗ ជាបុគ្គល*

ស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ជាបុគ្គលមានរូបល្អ គួររមិលមើល ជាទីជ្រះថ្លា ប្រកបដោយភាពជាអ្នកមានសម្បុរល្អដ៏ក្រៃលែងផង” ។

សក្កច្ចទាន “ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយគោរព ដោយផលទាននេះ កាលកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ពួកជនណាទោះកូនក្តី ប្រពន្ធក្តី ខ្ញុំបំរើក្តី អ្នកធ្វើការងារក្តី របស់បុគ្គលនោះ ជនទាំងនោះស្តាប់ដោយល្អ ផ្ទៀងសោតតាំងចិត្តស្តាប់ ដើម្បីដឹងផង” ។ (រមែងជឿសំដីគ្រប់ពាក្យពេចន៍ យកចិត្ត យកថ្លើម មិនឲ្យខកចិត្តក្នុងការងារ) ។

កាលទាន “ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានតាមកាលដ៏សមគួរដោយផលទាននេះ កាលកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ប្រយោជន៍គឺ ភោគៈដ៏ពោរពេញ រមែងមកតាមកាលដ៏គួរ ដល់បុគ្គលនោះផង” ។ (នៅក្នុងបរមត្ថជោតិកៈថា មានសេចក្តីចម្រើនរុងរឿង តាំងអំពីបឋមវ័យ ដែលជាវ័យកំលោះក្រមុំ មានផលប្រយោជន៍ ដែលគប្បីបានយ៉ាងបរិបូរណ៍ ហូរហៀរ) ។

អនុគ្គហិតទាន "ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទាន ដោយចិត្តអនុគ្រោះ ដោយផលទាននេះ កាលកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើនផង រមែង បង្អោនចិត្តទៅដើម្បីបរិភោគក្នុងកាមគុណ៥ ដ៏លើសលប់ផង។

អនុបហច្ចទាន "ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទាន ដោយមិនបានបៀតបៀនខ្លួនឯង និងអ្នកដទៃ ដោយផលទាន នេះ កាលកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង សេចក្តីអន្តរាយនៃភោគៈទាំងឡាយ មិន មានមកអំពីទីណាមួយ គឺអំពីភ្លើង អំពីទឹក អំពីស្តេច អំពីចោរ អំពីហេតុមិនជាទីស្រឡាញ់ និងអំពីមនុស្សជាទាយាទ" ។

(សុត្តន្តបិដក ៤៥ / ៨៨)

## កាលទាន ៥ យ៉ាង

១-អាគន្តុកស្ស ទានំ ទេតិ ឲ្យទានដល់អ្នកមកថ្មី

២-គមិកស្ស ទានំ ទេតិ ឲ្យទានដល់អ្នកដំណើរ

៣-គិលានស្ស ទានំ ទេតិ ឲ្យទានដល់អ្នកមានជម្ងឺ

៤-ទុព្ភិក្ខេ ទានំ ទេតិ *ឲ្យទានក្នុងពេលអត់បាយ*

៥-យានិ តានិ នវសស្សានិ នវផលានិ តានិ បឋមំ សីលវន្តេសុ បតិដ្ឋាបេតិ *បានតម្កល់ ស្រូវថ្មី ផ្លែឈើដំបូង ដល់បុគ្គលមានសីលទាំងឡាយជាដំបូង ។*

## ព្រះគាថា

*ពួកជនមានបញ្ញា ដឹងការសិតរបស់អ្នកប្រាជ្ញ មានសេចក្តីកំណាញ់ប្រាសចេញហើយ មានចិត្តជ្រះថ្លាហើយ រមែងឲ្យទានក្នុងកាលគួរ ទានដែលបុគ្គលឲ្យតាមកាលសមគួរ ចំពោះព្រះអរិយបុគ្គលទាំងឡាយ ដែលជាបុគ្គលមានកាយ និងចិត្តប្រកបដោយតាទិគុណ ទក្ខិណាទានរបស់បុគ្គលនោះ ជាទានមានផលបរិបូរណ៍ ។ ពួកជនណា អនុមោទនា ឬធ្វើនូវសេចក្តីខ្វល់ខ្វាយ ក្នុងទក្ខិណាទាននោះ ទក្ខិណាទានរបស់អ្នកទាំងនោះ នឹងបានឈ្មោះថា ថយថោក ព្រោះតែអនុមោទនា ឬធ្វើការខ្វល់ខ្វាយនោះក៏ទេ ពួកជនទាំងនោះ ជាអ្នកបានចំណែកបុណ្យដែរ ។ ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយដល់បុគ្គលណា ជាទានមានផលច្រើន*

*បុគ្គលមានចិត្តមិនបានរួញរា គប្បីឲ្យទានចំពោះបុគ្គលនោះ ព្រោះថា បុណ្យទាំងឡាយ រមែងជាទីពឹងនៃពួកសត្វ ក្នុងលោកខាងមុខ ។ (សុត្តន្តបិដក ៤៤ / ៨១)*

## អានិសង្សទាន ៥ យ៉ាង

១-ពហុនោ ជនស្ស បិយោ ហោតិ មនាបោ *គឺជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃជនច្រើន*

២-សន្តោ សប្បុរិសា ភជន្តិ *ពួកសប្បុរស អ្នកស្ងប់ រមែងគប់រក*

៣-កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ *មានកិត្តិស័ព្ទដ៏ពីរោះខ្ចរខ្ចាយទៅ*

៤-គិហិធម្មា អនបគតោ ហោតិ *មិនបាន ប្រាសចាកធម៌របស់គ្រហស្ថ*

៥-កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងកើតក្នុងសុគតិសួគ៌ទេវលោក ។*

បុគ្គលកាលឲ្យទាន រមែងជាទីស្រឡាញ់ ជាអ្នកអនុកូល ទៅតាមធម៌របស់ពួកសប្បុរស ពួកសព្រហ្មចារី អ្នកសង្រួម មានចិត្តស្ងប់រម្ងាប់ រមែងរាប់រកបុគ្គលនោះ សព្វៗកាល ពួកសព្រហ្មចារីនោះ រមែងសម្តែងធម៌ ជាគ្រឿងបន្ទោបង់នូវទុក្ខទាំងអស់ ដល់បុគ្គលនោះ ទាំងបុគ្គលនោះដឹងនូវធម៌ហើយ ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វានក្នុងលោកនេះ ។ (សុត្តន្ត. ៤៤ / ៨០)

## អានិសង្សសីល ៥ យ៉ាង

នៅក្នុងវិនយបិដកមហាវគ្គ ទុតិយភាគ ៧ ទំព័រ ៣០៥ ព្រះមានព្រះភាគ ទ្រង់ត្រាស់អានិសង្ស ៥ ប្រការ នៃបុគ្គលមានសីល ឬ បរិបូរណ៍ដោយសីល ។

១-អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ តែងបាននូវគំនរនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីមិនប្រមាទ ។

២-កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ តែងមានកិត្តិស័ព្ទដ៏ពីរោះឮខ្ចរខ្ចាយទៅ ។

៣-វិសារទោ ឧបសង្កមតិ អមង្កុភូតោ *(បើ) ចូលទៅកាន់បរិស័ទ ក៏ក្លៀវក្លា មិនឱនមុខចុះ គឺជាមិនក្រអឺមក្រអៀន ហើយដើរចូលទៅ ។*

៤-អសម្មូឡ្ហោ កាលំ ករោតិ *លុះវេលាទៀបស្លាប់ ក៏មិនវង្វេងស្មារតីឡើយ*

៥-កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំលោកំ ឧបបជ្ជតិ *លុះរំលាងខន្ធបន្ទាប់អំពីមរណៈ រមែងទៅកាន់មនុស្សលោក ឬទេវលោក ។*

## **ការកើតប្រាកដនៃរតនៈ ៥ យ៉ាង រកបានដោយក្រក្នុងលោក**

១-តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស ធាតុភាវោ ទុល្លភោ លោកស្មឹ *ការកើតប្រាកដនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ រកបានដោយក្រក្នុងលោក*

២-តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិតា បុគ្គលោ ទុល្លភោ លោកស្មឹ *បុគ្គលបេះ សម្តែង*

*ធម្មវិន័យដែលព្រះតថាគតបានប្រកាសហើយ រកបានដោយក្រ ក្នុងលោក*

៣–តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិ–តស្ស វិញ្ញាតា បុគ្គលោ ទុល្លភោ លោកស្មឹ *បុគ្គលដែលដឹងច្បាស់លាស់នូវធម៌វិន័យ ដែលព្រះតថាគតបានប្រកាសហើយ សម្ដែងហើយ រកបានដោយក្រក្នុងលោក*

៤–តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសិ–តស្ស វិញ្ញាតា ធម្មានុធម្មប្បដិបន្នោ បុគ្គលោ ទុល្លភោ លោកស្មឹ *បុគ្គលដែលដឹងច្បាស់លាស់នូវធម៌វិន័យ ដែលព្រះតថាគតប្រកាសហើយ សម្ដែងហើយ ប្រតិបត្តិនូវធម៌តាមធម៌ រកបានដោយក្រក្នុងលោក*

៥–កតញ្ញូកតវេទី បុគ្គលោ ទុល្លភោ លោកស្មឹ *កតញ្ញូកតវេទីបុគ្គលរកបានដោយក្រក្នុងលោក ។*

*(សុត្តន្ត. ៤៥ / ២២៣-២២៤)*

## ព្រះអភិធម្មមានអត្ថ ៥ ប្រការ

១-វុឌ្ឍិមន្តោ មានអត្ថថា ធម៌មានសេចក្ដីចំរើន,

២-សលក្ខណា មានអត្ថថា ធម៌ប្រកបដោយសេចក្ដីកំណត់ ,

៣-បូជិតា មានអត្ថថា ធម៌គួរបូជា ,

៤-បរិច្ឆន្នា មានអត្ថថា ធម៌ជាចំណែកៗ មិនច្រឡំគ្នា ,

៥-អធិកា មានអត្ថថា ធម៌ដ៏ក្រៃលែង ។

## ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបគួរចូលកាន់សម្មាសមាធិបាន

*១-ជាអ្នកអត់ធន់នឹងរូប*

*២-អត់ធន់នឹងសំឡេង*

*៣-អត់ធន់នឹងក្លិន*

*៤-អត់ធន់នឹងរស*

*៥-អត់ធន់នឹងផ្សព្វ ។* *(៤៥, ២១)*

## មហាចោរប្រកបដោយអង្គ ៥ យ៉ាង

*មហាចោរប្រកបដោយអង្គ ៥ យ៉ាង រមែងកាត់ទីតខ្លះ ប្លន់ធំខ្លះ ប្លន់ផ្ទះខ្លះ ឈរចាំស្ទាក់អ្នកដំណើរតាមផ្លូវខ្លះ ។*

*១-ជាអ្នកអាស្រ័យនូវទីមិនស្មើ*

*២-អាស្រ័យព្រៃស្បាត*

*៣-អាស្រ័យជនអ្នកមានកម្លាំង*

*៤-ជាអ្នកសូកទ្រព្យ*

*៥-ជាអ្នកត្រាច់ទៅតែម្នាក់ឯង ។ (៤៥ / ០៣)*

## សមណសុខមាន ៥ យ៉ាង

*១-ភិក្ខុជាអ្នកសន្តោសដោយចីវរ តាមមានតាមបាន*

*២-សន្តោសដោយបិណ្ឌបាត តាមមានតាមបាន*

*៣-សន្តោសដោយសេនាសនៈ តាមមានតាមបាន*

*៤-សន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន*

*៥-ប្រព្រឹត្តព្រហ្មចរិយៈដោយសេចក្តីត្រេកអរ ។*

*(៤៥ / ៣៧)*

## តួនាទីបុត្តធីតា ៥ យ៉ាង

១–ភតោ នេសំ ភរិស្សាមិ *កូនត្រូវតាំងចិត្តថា អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ*

២–កិច្ចំ នេសំ ករិស្សាមិ *នឹងជួយធ្វើការងាររបស់មាតាបិតា*

៣–កុលវំសំ ឋបេស្សាមិ *ទាំងតម្កល់វង្សត្រកូល*

៤–ទាយជ្ជំ បដិបជ្ជាមិ *ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន*

៥–អថវា បន បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សាមិ *មួយទៀត ឧទ្ទិសទក្ខិណាទាន ដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ។*

## តួនាទីមាតាបិតា ៥ យ៉ាង

១–បាបា និវារេន្តិ *ហាមឃាត់កូនចាកអំពើអាក្រក់*

២–កល្យាណេ និវេសេន្តិ *ឲ្យកូនតម្កល់នៅ*

*តែក្នុងអំពើល្អ*

៣-សិប្បំ សិក្ខាបេន្តិ *ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ*

៤-បដិរូបេន ទារេន សញ្ញោជេន្តិ *ដណ្ដឹងកិរិយាស្វាមីសមគួរឲ្យ*

៥-សមយេ ទាយជ្ជំ និយ្យាទេន្តិ *ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ ។*

**គួនាទីសិស្ស ៥ យ៉ាង**

១-ឧដ្ឋានេន *ដោយការក្រោកឡើងទទួល*

២-ឧបដ្ឋានេន *ដោយការគាល់បម្រើ*

៣-សុស្សូសាយ *ដោយការជឿស្ដាប់ឱវាទ*

៤-ចារិចរិយាយ *ដោយការបម្រើតូច ៗ (មានឲ្យទឹកលុបមុខ និងឈើស្ទន់ជាដើម)*

៥-សក្កច្ចំ សិប្បំ បដិគ្គហណេន *ដោយការរៀនសិល្បសាស្ត្រដោយគោរព ។*

## តួនាទីអាចារ្យ ៥ យ៉ាង

១-សុវិនីតំ វិនេន្តិ *ដឹកនាំល្អ*

២-សុគ្គហិតំ គាហាបេន្តិ *ឲ្យរៀនល្អ*

៣-សព្វសិប្បេសុ តំ សមក្ខាយិនោ ភវន្តិ *បង្រៀនប្រដៅសិស្សឲ្យចេះត្រឹមត្រូវក្នុងសិល្បសាស្ត្រសព្វគ្រប់*

៤-មិត្តាមច្ចេសុ បដិវេទេន្តិ *តែងលើកតម្កើងក្នុងទីប្រជុំមិត្តអមាត្យ*

៥-ទិសាសុ បរិត្តាណំ ករោន្តិ *ធ្វើសេចក្ដីការពារក្នុងទិសទាំងឡាយ ។*

## តួនាទីស្វាមី ៥ យ៉ាង

១-សម្មាននាយ *ដោយការរាប់អានជាភរិយាពេញទី*

២-អវិមាននាយ *ដោយមិនមើលងាយ*

៣-អនតិចរិយាយ *ដោយមិនប្រព្រឹត្តក្បត់ចិត្ត*

៤-ឥស្សរិយវោស្សគ្គេន *ដោយប្រគល់ឲ្យជាធំ (ក្នុងការផ្ទះ)*

៥-អលង្ការានុប្បទានេន ដោយការឲ្យគ្រឿងតែងខ្លួន។

## ភរិយាមានតួនាទី ៥ យ៉ាង

១-សុសំវិហិតកម្មន្តា ចាត់ចែងការងារដោយល្អ

២-សុសង្គហិតបរិជនា សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ

៣-អនតិចារិនី មិនប្រព្រឹត្តក្បត់ចិត្ត

៤-សម្ភតញ្ច អនុរក្ខតិ ថែទាំទ្រព្យដែលស្វាមីរកបាន

៥-ទក្ខា ហោតិ អនលសា សព្វកិច្ចេសុ ឈ្លាស មិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់ ។

## មិត្តមានតួនាទី ៥ យ៉ាង

១-ទានេន ដោយការឲ្យរបស់

២-បិយវជ្ជេន ដោយការនិយាយតែពាក្យគាប់ចិត្ត

៣-អត្ថចរិយាយ ដោយការប្រព្រឹត្តិឲ្យជាប្រយោជន៍

៤-សមានត្តតាយ *ដោយការប្រព្រឹត្តិខ្លួនស្មើ*

៥-អវិសំវាទនតាយ *ដោយការមិនកុហកបញ្ឆោត ។*

## តួនាទីមិត្តអនុគ្រោះមិត្ត ៥ យ៉ាង

១-បមត្តំ រក្ខន្តិ *រក្សាមិត្តដែលធ្វេសប្រហែស*

២-បមត្តស្ស សាបតេយ្យំ រក្ខន្តិ *ជួយថែទាំទ្រព្យសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស*

៣-ភីតស្ស សរណំ ហោន្តិ *ជាទីពឹងរបស់មិត្តដែលមានភ័យ*

៤-អាបទាសុ ន វិជហន្តិ *មិនបោះបង់គ្នាក្នុងគ្រាវិបត្តិ*

៥-អបរបជំបិស្ស បដិបូជេន្តិ *រាប់អានរហូតដល់ផៅពង្សរបស់មិត្ត ។*

## តួនាទីចៅហ្វាយនាយ ៥ យ៉ាង

១-យថាពលំ កម្មន្តំ សំវិធានេន *ដោយការចាត់ចែងការងារសមគួរតាមកម្លាំង*

២-ភត្តវេត្តនេនុប្បទានេន *ដោយការឲ្យនូវភត្តាហារ និងថ្លៃឈ្នួល*

៣-គិលានុបដ្ឋានេន *ដោយការព្យាបាលក្នុងវេលាឈឺថ្កាត់*

៤-អច្ឆរិយានំ រសានំ សំវិភាគេន *ដោយការចែករំលែកនូវរបស់ដែលមានរសត្រកាលចំឡែក*

៥-សមយេ វោស្សគ្គេន *ដោយការឲ្យឈប់សម្រាកក្នុងសម័យគួរ ។*

**ធ្ងនាទីទាសៈនិងកម្មករ ៥ យ៉ាង**

១-បុព្វុដ្ឋាយិនោ ហោន្តិ *ក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ*

២-បច្ឆានិបាតិនោ *ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ*

៣-ទិន្នាទាយិនោ *កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ*

៤-សុកតកម្មករា *ធ្វើការងាររបស់ចៅហ្វាយនាយដោយយកចិត្តទុកដាក់*

៥-កិត្តិវណ្ណហរា *នាំកិត្តិគុណរបស់ចៅហ្វាយនាយទៅថ្លែងក្នុងទីនោះៗ ។*

## គួនាធីពុទ្ធបរិស័ទ ៥ យ៉ាង

១-មេត្តេន កាយកម្មេន *ដោយកាយកម្មប្រកបដោយមេត្តា*

២-មេត្តេន វចីកម្មេន *ដោយវចីកម្មប្រកបដោយមេត្តា*

៣-មេត្តេន មនោកម្មេន *ដោយមនោកម្មប្រកបដោយមេត្តា*

៤-អនាវដទ្វារតាយ *ជាអ្នកមិនបិទទ្វារផ្ទះ*

៥-អាមិសានុប្បទានេន *ដោយកិរិយាឲ្យអាមិសទាន ។*

## សំវរៈវិន័យ ៥ យ៉ាង

១-សីលសំវរៈ *សេចក្តីសង្រួមដោយសីល*

២-សតិសំវរៈ *សេចក្តីសង្រួមដោយសតិ*

៣-ញាណសំវរៈ សេចក្ដីសង្រួមដោយញាណ

៤-ខន្តិសំវរៈ សេចក្ដីសង្រួមដោយខន្តិ

៥-វីរិយសំវរៈ សេចក្ដីសង្រួមដោយសេចក្ដីព្យាយាម។

## អធិប្បាយសំវរៈ ៥ យ៉ាង

បណ្ដាសំវរៈ ៥ ទាំងនោះ ភិក្ខុដែលចូលដល់ហើយ ចូលដល់ល្អហើយដោយសំវរៈ គឺ បាដិមោក្ខនេះ នេះឈ្មោះថា សីលសំវរៈ ភិក្ខុរមែងរក្សាចក្ខុន្ទ្រិយ រមែងដល់សេចក្ដីសង្រួមក្នុងចក្ខុន្ទ្រិយ នេះឈ្មោះថា សតិសំវរៈ ។

យានិ សោតានិ លោកស្មឹ សតិ តេសំ និវារណំ

សោតានំ សំវរំ ព្រូមិ បញ្ញាយេតេ បិធិយ្យរេ

ព្រះដ៏មានព្រះភាគ ត្រាស់ថា ម្នាលអជិតៈ ក្រសែពួកណាក្នុងលោក សតិជាគ្រឿងការពារក្រសែទាំងនោះ តថាគតរមែងពោលការការពារក្រសែទាំងឡាយ ក្រសែទាំងនេះ បុគ្គលរមែងបិទដោយបញ្ញា នេះឈ្មោះថា ញាណសំវរៈ ។

*បុគ្គលអ្នកអត់ធន់ចំពោះការត្រជាក់ការក្តៅ នេះឈ្មោះថា ខន្តិសំវរៈ ។ បុគ្គលអ្នកញ៉ាំងកាមវិតក្កៈដែលកើតឡើងហើយ មិនឲ្យប៉ះពាល់ខ្លួន នេះឈ្មោះថា* ***វីរិយសំវរៈ*** *។*

*សំវរៈនេះ សូម្បីទាំងអស់ ត្រាស់ហៅថា* ***សំវរៈ*** *ព្រោះការការពារ និងត្រាស់ហៅថា វិន័យ ព្រោះការនាំចេញនូវកាយទុច្ចរិតជាដើម ដែលគួរដល់ការការពារ និងគួរដល់ការនាំចេញ ដែលសមគួរដល់សីលសំវរៈជាដើមរបស់ខ្លួន បណ្ឌិតគប្បីជ្រាបថា សំវរៈវិន័យ រមែងចែកចេញ ៥ យ៉ាង ដោយប្រការដូច្នេះ ។*

## បហានវិន័យមាន ៥ យ៉ាង

១-តទង្គបហាន *ការលះដោយអង្គញាណនោះ*

២-វិក្ខម្ភនបហាន *ការលះដោយការគ្របសង្កត់*

៣-សមុច្ឆេទបហាន *ការលះដោយអរិយមគ្គ*

៤-បដិបស្សទ្ធិបហាន *ការលះដោយអរិយផល*

៥-និស្សរណបហាន *ការលះដោយនិព្វាន ។*

# សេចក្តីអធិប្បាយ

បណ្តាវិបស្សនាញាណទាំងឡាយ មាននាមរូបបរិច្ឆេទ-ញាណជាដើម ការលះធម៌ដែលរកប្រយោជន៍មិនបាននោះ ដោយវិបស្សនាញាណនោះៗ ព្រោះជាបដិបក្ខគ្នាដូចលះចេញនូវការងងឹត ដោយពន្លឺភ្លឺស្វាងនៃប្រទីបដូច្នោះ យ៉ាងណា ? គឺការលះសក្កាយទិដ្ឋិ ដោយកំណត់ចែកនាមរូប (នាមរូប-បរិច្ឆេទញាណ) លះទិដ្ឋិដែលឃើញថា នាមរូបមិនមានហេតុនិងមានហេតុមិនស្មើគ្នាដោយការកំណត់ដឹងបច្ច័យ (បច្ចយ-បរិគ្គហញាណ) លះសេចក្តីសង្ស័យដោយកង្ខាវិតរណញាណក្នុងកាលដទៃទៀតរបស់បច្ចយបរិគ្គហញាណនោះឯង លះបង់សេចក្តីប្រកាន់ថា **យើង របស់យើង** ដោយកលាបសម្ម-សនញាណ លះសេចក្តីសម្គាល់ក្នុងវត្ថុដែលមិនមែនផ្លូវ ថាជាផ្លូវ ដោយការកំណត់ផ្លូវ និងមិនមែនផ្លូវ លះឧច្ឆេទទិដ្ឋិ ដោយឃើញការកើត លះសស្សតទិដ្ឋិដោយឃើញការសាបសូន្យ លះសេចក្តីឃើញក្នុងវត្ថុដែលមានភ័យថា មិនមានភ័យ ដោយសេចក្តីឃើញថា មានភ័យ លះសេចក្តីសម្គាល់ក្នុងវត្ថុ ដែលពេញចិត្តដោយការឃើញអាទីនវៈ លះសេចក្តីសម្គាល់ដែល

ពេញចិត្តក្រៃលែង ដោយនិព្វិទានុបស្សនា លះភាពជាអ្នកមិនប្រាថ្នានឹងរួចផុតដោយមុញ្ចិតុកម្មយតាញាណ លះសេចក្តីមិនដាក់ព្រងើយក្នុងសង្ខារដោយឧបេក្ខាញាណ លះធម្មឋិតិ (បដិច្ចសមុប្បាទ) ដោយអនុលោមញាណ លះភាពជាបដិលោមដោយនិព្វាន លះសេចក្តីប្រកាន់និមិត្ត គឺសង្ខារ ដោយគោត្រភូញាណយ៉ាងណា នេះឈ្មោះថា **តទង្គបហាន** (ការលះដោយអង្គរបស់វិបស្សនាញាណនោះៗ) ។

ការលះធម៌ មាននីវរណៈជាដើមនោះៗ ដោយហាមការប្រព្រឹត្តទៅនៃធម៌ មាននីវរណៈជាដើមនោះ ដោយសមាធិឧបចារៈ និងអប្បនា ដូចការលះសារាយលើខ្នងទឹកមិនឲ្យបន្តយ៉ាងណា នេះឈ្មោះថា **វិក្ខម្ភនបហាន** ។ ការលះពួកកិលេសដែលជាចំណែកសមុទ័យ ដោយមិនឲ្យប្រព្រឹត្តទៅ ដោយសព្វគ្រប់ ដូចដែលត្រាស់ទុកដោយន័យមានអាទិថា ដើម្បីលះនូវទិដ្ឋិទាំងឡាយក្នុងសន្តានរបស់ខ្លួន ដោយមានមគ្គនោះៗ ព្រោះសេចក្តីដែលអរិយមគ្គ ៤ ដែលខ្លួនអប់រំហើយយ៉ាងណា នេះឈ្មោះថា **សមុច្ឆេទបហាន** ។ ក៏ការដែលកិលេសទាំងឡាយស្ងប់រម្ងាប់ក្នុងខណៈនៃផល យ៉ាងណានេះ ឈ្មោះថា

**បដិបស្សទ្ធិបហាន** ។ ព្រះនិព្វានមានសង្ខតធម៌ទាំងពួងដែលលះបានហើយ ព្រោះជាធម៌រលាស់សង្ខតធម៌ទាំងពួងចេញទៅយ៉ាងណា នេះឈ្មោះថា **និស្សរណបហាន** ។

ក៏ព្រោះការលះសូម្បីទាំងអស់នេះ ឈ្មោះថា **បហានៈ** ដោយអត្ថថា លះបង់ ឈ្មោះថា **វិន័យ** ដោយអត្ថថា កម្ចាត់ ព្រោះដូច្នោះ ទើបត្រាស់ហៅថា **បហានវិន័យ** ។

ម្យ៉ាងទៀត បហានៈនេះ ហៅថា **បហានវិន័យ** ព្រោះសេចក្តីកើតនៃការលះ ដោយតទង្គបហានជាដើមនោះៗ ខ្វះ ព្រោះសេចក្តីកើតឡើងនៃការកម្ចាត់នោះៗ ខ្វះ ។ បណ្ឌិតគប្បីជ្រាបថា សូម្បីបហានវិន័យក៏រមែងចែកបាន ៥ យ៉ាង ដោយប្រការដូច្នេះ ។

វិន័យនេះដោយបំព្រួញរមែងមាន ២ ប្រភេទ(សំវរវិន័យ ១ បហានវិន័យ ១) ដោយការចែកមាន ១០ ប្រភេទ (សំវរ-វិន័យ ៥ បហានវិន័យ ៥) ព្រោះរមែងមិនមានដល់បុថុជ្ជនយ៉ាងណា ការសិក្សានេះ ព្រោះមានសំវរៈដែលទំលាយហើយនិងព្រោះលះធម៌ ដែលគួរលះមិនទាន់បាន ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ ទើបត្រាស់ហៅថា អ្នកមិនបានទូន្មាននេះ

ព្រោះការមិនមានវិន័យនេះ ដោយប្រការដូច្នេះ ។ សូម្បីក្នុងពាក្យថា បុគ្គលអ្នកមិនបានឃើញសប្បុរស អ្នកមិនឆ្លាតក្នុងធម៌របស់សប្បុរស អ្នកមិនបានទូន្មានក្នុងធម៌របស់សប្បុរសនេះ ក៏មានន័យដូចគ្នា ព្រោះពោលដោយអត្ថ ពាក្យថា សប្បុរស និងព្រះអរិយៈ មិនមានហេតុផ្សេងគ្នា ដូចដែលពោលថា បុគ្គលពួកណាជាព្រះអរិយៈ បុគ្គលទាំងនោះឯងឈ្មោះថា **សប្បុរស** បុគ្គលពួកណាជាសប្បុរស បុគ្គលទាំងនោះឯង ឈ្មោះថាព្រះអរិយៈ ធម៌ណាជារបស់ព្រះអរិយៈទាំងឡាយ ធម៌នោះៗឯង ឈ្មោះថា ជារបស់សប្បុរស ធម៌ណាជារបស់សប្បុរស ធម៌នោះៗឯង ឈ្មោះថា ជាធម៌របស់ព្រះអរិយៈ វិន័យរបស់ព្រះអរិយៈ ក៏គឺ វិន័យរបស់សប្បុរស វិន័យរបស់សប្បុរស ក៏គឺ វិន័យរបស់ព្រះអរិយៈ ពាក្យថា **អរិយៈ** ឬពាក្យថា **សប្បុរស** ក៏បានដល់អរិយធម៌ ឬសប្បុរិសធម៌ ពាក្យថា អរិយវិន័យ ឬសប្បុរិសវិន័យនេះនោះ ជាពាក្យតែមួយជាមួយគ្នា តាំងនៅក្នុងទីតែមួយ ស្មើគ្នា មានចំណែកស្មើគ្នា ឬមានភាពតែមួយនុ៎ះឯង ។

(អដ្ឋសាលិណី. ៧៦ / ៣៦៤)

## សំយោជនៈជាចំណែកខាងក្រោម ៥ យ៉ាង

១-សក្កាយទិដ្ឋិ *ប្រកាន់កាយ*

២-វិចិកិច្ឆា *សេចក្តីសង្ស័យ ឬស្ទាក់ស្ទើរ*

៣-សីលព្វតបរាមាសៈ *ស្ទាបអង្អែលនូវសីល និងវត្ត (បានដល់សីលនិងវត្តរបស់និគ្រន្ថ)*

៤-កាមឆន្ទៈ *សេចក្តីត្រេកអរក្នុងកាម*

៥-ព្យាបាទៈ *ខឹង ឬគំនុំ ។*

## សំយោជនៈជាចំណែកខាងលើ ៥ យ៉ាង

១-រូបរាគោ *សេចក្តីត្រេកអរក្នុងរូបភព*

២-អរូបរាគោ *សេចក្តីត្រេកអរក្នុងអរូបភព*

៣-មានោ *សេចក្តីលើកខ្លួនឯង*

៤-ឧទ្ធច្ចំ *ចិត្តអណ្តែតអណ្តូង*

៥-អវិជ្ជា *សេចក្តីល្ងង់ ។*

*(សុត្តន្តបិដក ៤៩ / ២១៩)*

## សេចក្តីកំណាញ់ ៥ យ៉ាង

១-អាវាសមច្ឆរិយំ កំណាញ់អាវាស

២-កុលមច្ឆរិយំ កំណាញ់ត្រកូល

៣-លាភមច្ឆរិយំ កំណាញ់លាភ

៤-វណ្ណមច្ឆរិយំ កំណាញ់សេចក្តីសរសើរ

៥-ធម្មមច្ឆរិយំ កំណាញ់ធម៌ ។

*និងសេចក្តីកំណាញ់ អាការកំណាញ់ ភាពនៃចិត្តកំណាញ់ ការប្រាថ្នាផ្សេងៗ ការស្វិតស្វាញ ការរឹតត្បិត ភាពនៃចិត្តប្រាថ្នាប្រយោជន៍ដ៏លើសណា ដែលមានសភាពបែបនេះ នេះហៅថា មច្ឆរិយសញ្ញោជនៈ ។*

*(អភិធម្មបិដក ៧៩ / ២១៨)*

## អដ្ឋកថាមច្ឆរិយៈ

*គប្បីជ្រាបវិនិច្ឆ័យមច្ឆរិយនិទ្ទេសតទៅ ៖*

*ដើម្បីទ្រង់សម្តែងមច្ឆរិយៈ (សេចក្តីកំណាញ់) ដោយវត្ថុ ទើបត្រាស់ពាក្យមានអាទិថា* ***បញ្ច មច្ឆរិយានិ*** *អាវាសមច្ឆរិយំ*

(កំណាញ់ ៥ គឺកំណាញ់អាវាស) ដូច្នេះ ។ ក្នុងមច្ឆរិយៈទាំងនោះ សេចក្តីកំណាញ់ក្នុងអាវាស ឈ្មោះថា **អាវាសមច្ឆរិយំ** ។ សូម្បីបទដ៏សេសក៏ន័យនេះ ដូចគ្នា ។ អារាមទាំងអស់ក្តី បរិវេណអារាមក្តី បន្ទប់តូចក្តី ទីសម្រាកក្នុងវេលារាត្រីជាដើមក្តី ឈ្មោះថា **អាវាស** ។ ពួកភិក្ខុដែលនៅក្នុងអាវាសនោះ រមែងនៅសប្បាយ រមែងបានបច្ច័យទាំងឡាយ ភិក្ខុមួយរូបអ្នកកំណាញ់ រមែងមិនប្រាថ្នាឲ្យភិក្ខុដែលដល់ព្រមដោយវត្ត អ្នកមានសីលជាទីស្រឡាញ់មកក្នុងទីនៅនោះ សូម្បីមកហើយ ក៏គិតថា ភិក្ខុនេះចូរទៅដោយរហ័សចុះ នេះឈ្មោះថា **អាវាសមច្ឆរិយៈ** (កំណាញ់អាវាស) តែភិក្ខុដែលមិនប្រាថ្នាការនៅក្នុងទីនោះរបស់ពួកអ្នកបង្កជម្លោះជាដើម មិនឈ្មោះថា អាវាសមច្ឆរិយៈ (នេះជាសេចក្តីកំណាញ់ទី ១) ។

បទថា **កុលំ** បានដល់ ត្រកូលឧបដ្ឋាកខ្លះ ត្រកូលញាតិខ្លះ កាលភិក្ខុមិនប្រាថ្នាឲ្យភិក្ខុដទៃចូលទៅកាន់ត្រកូលនោះ រមែងជាកុលមច្ឆរិយៈ (កំណាញ់ត្រកូល) តែភិក្ខុមិនប្រាថ្នាឲ្យបុគ្គលលាមកចូលទៅក្នុងត្រកូលនោះ មិនឈ្មោះថា មច្ឆរិយៈ ព្រោះបុគ្គលលាមកនោះ រមែងបដិបត្តិដើម្បីទំលាយ សេចក្តី

ជ្រះថ្លារបស់ត្រកូលទាំងនោះ តែភិក្ខុដែលអាចរក្សា សេចក្ដីជ្រះថ្លាទុកបាន មិនប្រាថ្នាឲ្យភិក្ខុនោះចូលទៅក្នុងត្រកូលនោះ ទើបឈ្មោះ មច្ឆរិយៈ (នេះជាសេចក្ដីកំណាញ់ទី ២) ។

បទថា **លាភោ** បានដល់ ការបានបច្ច័យ ៤ កាលភិក្ខុដែលមានសីលដទៃបាននូវបច្ច័យ ៤ នោះឯង ភិក្ខុដែលកំណាញ់គិតថា សូមកុំបាន ដូចនេះ រមែងជាលាភមច្ឆរិយៈ (កំណាញ់លាភ) តែភិក្ខុណាញាំងសទ្ធាទេយ្យ (របស់អ្នកថ្វាយទានដោយសទ្ធា) ឲ្យធ្លាក់ចុះទៅក្ដី រមែងធ្វើបច្ច័យដែលបានមកឲ្យវិនាសអស់ ដោយអំណាចនៃការមិនបរិភោគ ឬបរិភោគមិនល្អជាដើមក្ដី មិនឲ្យវត្ថុសូម្បីដល់ស្អុយ ដល់ភិក្ខុដទៃក្ដី ភិក្ខុដែលកំណាញ់ឃើញភិក្ខុនោះហើយ គិតថា បើភិក្ខុរូបនេះមិនបានបច្ច័យនេះ ភិក្ខុដទៃអ្នកមានសីលគប្បីបាន គប្បីបរិភោគ ដូច្នេះ មិនឈ្មោះថា មច្ឆរិយៈ (នេះជាសេចក្ដីកំណាញ់ទី ៣) ។

**សរីរវណ្ណៈ** (ពណ៌សម្បុរនៃសរីរៈ)ក្ដី **គុណវណ្ណៈ** (ការសរសើរគុណសេចក្ដីល្អ)ក្ដី ឈ្មោះថា **វណ្ណៈ** ក្នុងវណ្ណៈ ទាំង ២ នោះ បុគ្គលអ្នកកំណាញ់សរីរៈវណ្ណៈ កាលមានអ្នកនិយាយ ថា

បុគ្គលដទៃគួរជ្រះថ្លា មានរូបល្អ ដូច្នេះ មិនប្រាថ្នានឹងពោលដល់បុគ្គលនោះ ។ បុគ្គលអ្នកកំណាញ់**គុណវណ្ណៈ** (គឺការសរសើរគុណសេចក្តីល្អ) រមែងមិនប្រាថ្នានឹងពោលសរសើរគុណសេចក្តីល្អរបស់អ្នកដទៃដោយសីល ដោយធុតង្គ ដោយបដិបទា ដោយអាចារៈ (នេះជាវណ្ណមច្ឆរិយៈទី ៤) ។

បទថា **ធម្មោ** បានដល់ បរិយត្តិធម៌ និងបដិវេធធម៌ ។ ក្នុងធម៌ទាំង ២ នោះ ព្រះអរិយសាវកទាំងឡាយ រមែងមិនកំណាញ់បដិវេធធម៌ រមែងប្រាថ្នាការចាក់ធ្លុះដល់លោក ព្រមទាំងទេវលោក ក្នុងធម៌ដែលខ្លួនចាក់ធ្លុះហើយ គឺ រមែងប្រាថ្នាថា សូមសត្វពួកដទៃចូរដឹងការចាក់ធ្លុះធម៌នោះ ដែលឈ្មោះថាធម្មមច្ឆរិយៈ (សេចក្តីកំណាញ់ធម៌) រមែងមានក្នុងតន្តិធម៌ (តន្តិធម៌ គឺ ធម៌ និងវិន័យ ធម៌ដែលជាគម្ពីរ) ប៉ុណ្ណោះ បុគ្គលអ្នកប្រកបតន្តិធម៌នោះ រមែងដឹងគម្ពីរដែលលាក់បាំង ឬកថាមគ្គយ៉ាងណា មិនប្រាថ្នានឹងឲ្យអ្នកដទៃដឹងគម្ពីរ ឬកថាមគ្គនោះ ប៉ុន្តែថា បុគ្គលណា ត្រិះរិះពិចារណាដល់បុគ្គល ឬត្រិះរិះពិចារណាធម៌ដោយការរក្សាធម៌ មិនឲ្យដោយការរក្សាបុគ្គលភិក្ខុនេះមិនឈ្មោះថា **ធម្មមច្ឆរិយៈ** ។

ក្នុងសេចក្ដីនេះ បុគ្គលខ្លះជាអ្នករឡេករឡក់ ពេលខ្លះជាសមណៈ ពេលខ្លះជាព្រាហ្មណ៍ ពេលខ្លះជាគ្រហស្ថ ក៏ភិក្ខុណាមិនឲ្យដោយគិតថា បុគ្គលនេះនឹងទំលាយតន្តិធម៌ ដែលល្អិតសុខុម ជាធម៌ដែលក្រៃលែង ជាប្រពៃណីបន្តគ្នាមក ឲ្យវិវត់ ភិក្ខុនេះត្រិះរិះពិចារណាដល់បុគ្គលហើយ ឈ្មោះថា រមែងមិនឲ្យព្រោះរក្សាធម៌ទុក ចំណែកភិក្ខុណា រមែងមិនឲ្យ ដោយគិតថា ធម៌នេះល្អិតសុខុម បើបុគ្គលនេះ នឹងរៀនយក នឹងព្យាករណ៍អរហត្តផល នឹងសម្ដែងខ្លួនឲ្យដល់សេចក្ដីវិនាស ភិក្ខុនេះត្រិះរិះពិចារណាធម៌ហើយ ឈ្មោះថា រមែងមិនឲ្យដោយការរក្សាបុគ្គល តែបុគ្គលណា រមែងមិនឲ្យដោយគិតថា បើបុគ្គលនេះ រៀនធម៌នេះ នឹងអាចទំលាយលទ្ធិ (សមយំ) របស់ពួកយើង ដូច្នេះ បុគ្គលនេះ ឈ្មោះថា ជាអ្នកកំណាញ់ធម៌ (នេះជាធម្មមច្ឆរិយៈទី ៥) ។

បណ្ដាមច្ឆរិយៈទាំង ៥ នេះ ពោលអំពីអាវាសមច្ឆរិយៈមុន បុគ្គលកើតជាយក្ខ ឬជាប្រេត ហើយនឹងយកក្បាលទូលសម្រាមរបស់ដែលនៅនោះឯងត្រាច់ទៅ ។ ពោលអំពីកុលមច្ឆរិយៈ កាលត្រកូលនោះធ្វើទាន និងរាប់អានបុគ្គលទាំងនោះ

កាលគេឃើញក៏គិតថា ត្រកូលនេះរបស់យើងបែកហើយហ្ន៎ លោហិតនឹងហូរចេញពីមាត់ មានការបន្ទោបង់លាមកខ្លះ ពោះវៀនធំទាំងឡាយក៏នឹងជាកំណាត់តូចៗ ចេញមកខ្លះ ។ ពោលដោយលាភមច្ឆរិយៈ កំណាញ់ក្នុងលាភដែល ជារបស់សង្ឃ ឬគណៈ ឬបុគ្គលបរិភោគដូចជាគ្រឿងប្រើប្រាស់របស់បុគ្គល រមែងកើតជាយក្ខ ឬប្រេត ឬពស់ថ្លាន់ធំ ។ ពោលអំពីសរីរវណ្ណគុណមច្ឆរិយៈ និង បរិយត្តិធម្មមច្ឆរិយៈ បុគ្គលរមែងសរសើរវណ្ណៈរបស់ខ្លួន មិនសរសើរវណ្ណៈរបស់អ្នកដទៃ កាលនឹងពោលទោសដោយពាក្យថា នេះវណ្ណៈអ្វី ? ដូច្នេះ កាលមិនឲ្យបរិយត្តិធម៌ យ៉ាងណា ដល់អ្នកណាៗ រមែងជាអ្នកមានពណ៌អាក្រក់ និង នឹងជាអ្នកឆ្កួតទឹកមាត់ ។

ម្យ៉ាងទៀត បុគ្គលរមែងត្រូវភ្លើងឆេះ ក្នុងផ្ទះលោហៈ ដោយសេចក្ដីកំណាញ់អាវាស រមែងជាអ្នកមានលាភតិច ដោយសេចក្ដីកំណាញ់ត្រកូល រមែងកើតក្នុងគូថនរក ដោយសេចក្ដីកំណាញ់លាភ បុគ្គលកាលកើតគ្រប់ ៗ ភព រមែងមិនមានពណ៌សម្បុរល្អ ដោយការកំណាញ់វណ្ណៈ រមែងកើតក្នុងកុកកុលនរក ដោយការកំណាញ់ធម៌ ។

*ដែលឈ្មោះថា* **មច្ឆរិយំ** *ដោយអំណាចឃើញដល់ខ្លួន អាការៈនៃសេចក្តីកំណាញ់ ឈ្មោះថា* **មច្ឆរាយនា** *(អាការកំណាញ់) ភាវៈនៃចិត្តដែលត្រូវសេចក្តីកំណាញ់ ឲ្យប្រព្រឹត្តទៅហើយ ព្រមព្រៀងដោយសេចក្តីកំណាញ់ ឈ្មោះថា* **មច្ឆរាយិតត្តំ** *(ភាពនៃចិត្តកំណាញ់) ។ បុគ្គលដែលឈ្មោះថា* **វិវិច្ឆោ** *(ការប្រាថ្នាផ្សេងៗ) ព្រោះអត្ថថា ប្រារព្ធសម្បត្តិទាំងអស់ របស់ខ្លួនមិនឲ្យសាបសូន្យទៅ ដោយគិតថា សូមសម្បត្តិទាំងពួង ចូរមានដល់យើងប៉ុណ្ណោះ ចូរកុំមានដល់អ្នកដទៃដូច្នេះ ។ ភាវៈនៃបុគ្គលអ្នកហួងហែង ឈ្មោះថា* **វេវិច្ឆំ** *(សេចក្តីហួងហែង) ពាក្យថា សេចក្តីហួងហែងនេះ ជាឈ្មោះរបស់សេចក្តីកំណាញ់យ៉ាងខ្សោយ ។*

*បុគ្គលមិនអើពើ ត្រាស់ថា* **កទរិយោ** *(អ្នកឃើញដល់ខ្លួន) ភាវៈនៃបុគ្គលអ្នកឃើញដល់ខ្លួននោះ ហៅថា* **កទរិយំ** *(ការស្វិតស្វាញ) ពាក្យថា ការស្វិតស្វាញនេះ ជាឈ្មោះរបស់សេចក្តីកំណាញ់ខ្លាំងក្លា ព្រោះបុគ្គលអ្នកប្រកបដោយសេចក្តីកំណាញ់នោះ រមែងហាមសូម្បីបុគ្គលដទៃអ្នកឲ្យដល់បុគ្គល*

ពួកដទៃ ពាក្យនេះសមដោយព្រះបាលីដែលត្រាស់ទុក ក្នុងសំយុត្តនិកាយសគាថវគ្គថា

កទរិយោ ចាបសំកប្បោ មិច្ឆាទិដ្ឋិ អនាទរោ

ទទមានំ និវារេតិ យាចមានាន ភោជនំ

បុគ្គលអ្នកស្វិតស្វាញ មានសេចក្ដីត្រិះរិះអាក្រក់ ជាមិច្ឆាទិដ្ឋិ មិនមានសេចក្ដីអើពើ រមែងហាមអ្នកដែលកំពុងឲ្យភោជនាហារដល់មនុស្សទាំងឡាយដែលសូម ដូច្នេះ ។

បុគ្គលណា ឃើញយាចកទាំងឡាយហើយ ឲ្យចិត្តបញ្ឈប់ គឺ ឲ្យអត់ទ្រាំ ស្ទុតចិត្តដោយសេចក្ដីកំណាញ់ស្វិត ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **កទរិយោ** (អ្នកមិនអើពើ) ។ ភាវៈជាអ្នកមិនអើពើនោះ ឈ្មោះថា **កទរិយំ** (អ្នកមិនអើពើ) ។

ន័យមួយទៀត បុគ្គលអ្នកមានវែកក្នុងដៃ ត្រាស់ហៅថា **កដច្ឆុកតា** ក៏បុគ្គលកាលនឹងកាន់យកបាយពីឆ្នាំង ដែលពេញស្មើមាត់ឆ្នាំង រមែងកាន់យកដោយចុងវែកតូច គ្រប់ចំណែកក៏មិនអាចដើម្បីកាន់យកឲ្យពេញយ៉ាងណា ចិត្តរបស់បុគ្គលអ្នកកំណាញ់ក៏ដូច្នោះ រមែងចង្អៀតចង្អល់ កាលចិត្តចង្អៀត

ចង្អុល់ ស្មម្បីកាយក៏ចង្អៀតចង្អល់រួញថយ រមែងមិនប្រគល់ឲ្យដើម្បីពួកជនដទៃ ព្រោះដូច្នោះ សេចក្ដីកំណាញ់ទើបត្រាស់ហៅថា **កតកញ្ចុកតា** (សេចក្ដីជាអ្នកមានចិត្តចង្អៀតដូចវែកដួសបាយ) ។

បទថា **អគ្គហិតត្តំ ចិត្តស្ស** (ភាពនៃចិត្តប្រាថ្នាប្រយោជន៍ដ៏លើស) បានដល់ ការដែលចិត្តកាន់យកទុក ដោយប្រការដែលមិនលាទៅ ដោយអាការៈមានការឲ្យទានជាដើម ក្នុងការធ្វើឧបការៈដល់ពួកជនដទៃ ។ ក៏ព្រោះមនុស្សកំណាញ់ មិនប្រាថ្នានឹងឲ្យវត្ថុដែលមានរបស់ខ្លួនដល់ពួកជនដទៃ ចង់ទទួលតែរបស់អ្នកដទៃ ដូច្នោះ បណ្ឌិតគប្បីជ្រាបសេចក្ដីកំណាញ់នោះមានការលាក់ទុកសម្បត្តិរបស់ខ្លួនជាលក្ខណៈ ឬសេចក្ដីកំណាញ់នោះ មានការកាន់យកសម្បត្តិរបស់អ្នកដទៃ ជាលក្ខណៈ ដោយអំណាចនៃការប្រព្រឹត្តទៅថា សេចក្ដីអស្ចារ្យចូរមានដល់យើងតែម្នាក់ កុំមានដល់អ្នកដទៃ ដូច្នេះ ។ ពាក្យដ៏សេសក្នុងគោច្ឆកៈនេះ មានសេចក្ដីងាយទាំងនោះ ។

ក៏សញ្ញោជនៈទាំងនេះ គួរនាំមកសម្ដែងដោយលំដាប់កិលេសទ្វេះ ដោយលំដាប់មគ្គទ្វេះ ពោលអំពីលំដាប់កិលេស

កាមរាគសញ្ញោជនៈ និងបដិឃសញ្ញោជនៈអនាគាមិមគ្គ រមែង លះបង់ មានសញ្ញោជនៈដែលអរហត្តមគ្គ រមែងលះបង់ ទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសដែលសោតាបត្តិមគ្គ រមែង លះបង់ ភវរាគសញ្ញោជនៈដែលអរហត្តមគ្គ រមែងលះបង់ ឥស្សា មច្ឆរិយៈដែលសោតាបត្តិមគ្គ រមែងលះបង់ អវិជ្ជា ដែលអរហត្តមគ្គ រមែងលះបង់ ។ ពោលដោយលំដាប់នៃមគ្គ សោតាបត្តិមគ្គ រមែងលះបង់ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ឥស្សា និងមច្ឆរិយៈ អនាគាមិមគ្គ រមែងលះបង់ កាមរាគៈ និងបដិឃៈ អរហត្តមគ្គ រមែងលះបង់ មានះ ភវរាគៈ និង អវិជ្ជា ដូច្នេះឯង ។ (អដ្ឋកថាធម្មសង្គណី ៧៦ / ៤២៩)

## អានិសង្សនៃការបោសមាន ៥ យ៉ាង

១-សកចិត្តំ បសីទតិ ចិត្តរបស់ខ្លួនក៏ជ្រះថ្លា

២-បរចិត្តំ បសីទតិ ចិត្តរបស់អ្នកដទៃក៏ជ្រះថ្លា

៣-ទេវតា អត្តមនា ហោន្តិ ពួកទេវតាតែង ពេញចិត្ត

៤-បសាទិកសំវត្តនិយំ កម្មំ ឧបចិនតិ *អ្នកបោសរមែងសន្សំនូវកម្មដែលប្រព្រឹត្តទៅដើម្បីសេចក្ដីជ្រះថ្លា*

៥-កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្ដីស្លាប់ ក៏រមែងទៅកាន់សុគតិសួគ៌ ទេវលោក ។*

## អានិសង្សការបោសមាន ៥ យ៉ាងដទៃទៀត

*១-ចិត្តរបស់ខ្លួនក៏ជ្រះថ្លា*

*២-ចិត្តរបស់អ្នកដទៃក៏ជ្រះថ្លា*

*៣-ពួកទេវតាតែងពេញចិត្ត*

៤-សត្ថុសាសនំ កតំ ហោតិ *ឈ្មោះថា ធ្វើតាមសាសនារបស់ព្រះសាស្ដា*

៥-បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ *ប្រជុំជនជាខាងក្រោយនឹងយកតម្រាប់តាម ។*

## អន្តរាយិកធម៌ ៥ យ៉ាង

*ធម៌ពួកណា រមែងធ្វើអន្តរាយដល់សួគ៌និងនិព្វាន ព្រោះហេតុនោះ ធម៌ទាំងនោះ ឈ្មោះថា អន្តរាយិកធម៌ ។*

១-កម្ម *បានដល់ អនន្តរិយកម្ម ៥ យ៉ាង, សូម្បីភិក្ខុនីទូសកកម្ម ក៏យ៉ាងនោះ, តែភិក្ខុនីទូសកកម្មនោះ រមែងធ្វើអន្តរាយដល់ព្រះនិព្វានប៉ុណ្ណោះ មិនធ្វើអន្តរាយដល់សួគ៌ទេ ។*

២-កិលេស *បានដល់ និយតមិច្ឆាទិដ្ឋិ*

៣-វិបាក *បានដល់ បដិសន្ធិរបស់ពួកបណ្ឌកៈ (ខ្ទើយ) តិរច្ឆាន និងឧភតោព្យញ្ជនកៈ (មនុស្សមានភេទពីរ)*

៤-ឧបវាទ *បានដល់ ការចូលទៅផ្ចាសាព្រះអរិយៈ*

*តែឧបវាទន្តរាយិកធម៌ទាំងនោះ ជាអន្តរាយរហូតវេលាដែលនៅមិនទាន់ឲ្យព្រះអរិយទាំងឡាយ អត់ទោសឲ្យប៉ុណ្ណោះ ក្រោយអំពីឲ្យលោកអត់ទោសឲ្យទៅ មិនជាអន្តរាយទេ ។*

៥-អាណាវីតិក្កមៈ *បានដល់ ក្លែងត្រូវឲ្យអាបត្តិ, អាបត្តិសូម្បីទាំងនោះ ក៏ជាអន្តរាយរហូតវេលាដែលភិក្ខុអ្នកត្រូវនៅប្ដេជ្ញាភាពជាភិក្ខុ ឬនៅមិនចេញ ឬនៅមិនទាន់សម្ដែង*

*ប៉ុណ្ណោះ តាំងអំពីចេញតាមករណីយនោះៗហើយ មិនជាអន្តរាយទេ ។ (សមន្តប្បាសាទិកា ២, ៣០២)*

## ព្រះវិន័យមាន ៥ គម្ពីរ

*១-គម្ពីរអាទិកម្ម ,*

*២-គម្ពីរបាចិត្តិយ,*

*៣-គម្ពីរមហាវគ្គ ,*

*៤-គម្ពីរចុល្លវគ្គ,*

*៥-គម្ពីរបរិវារៈ ។*

*ព្រះវិន័យ ៥ គម្ពីរនេះ ចាត់ជាបិដកមួយ ឈ្មោះវិនយបិដក បែកជាធម្មខន្ធ មាន ២១.០០០ ព្រះធម្មខន្ធ ។*

## ព្រះសុត្តន្តបិដកមាន ៥ គម្ពីរ គឺ

១-ទីឃនិកាយ *មាន ៣៤ សូត្រ មានព្រហ្មជាលសូត្រជាដើម*

២-មជ្ឈិមនិកាយ *មាន ១៥២ សូត្រ មានមូល-*

បរិយាយ សូត្រជាដើម

៣–សំយុត្តនិកាយ មាន ៧៧៦២ សូត្រ មាន
ឱឃតរណសូត្រជាដើម ។

៤–អង្គុត្តរនិកាយ មាន ៩៥៥៧ សូត្រ មានចិត្ត-
បរិយាទានសូត្រជាដើម ។

៥–ខុទ្ទកនិកាយ ចែកចេញជាគម្ពីរ មាន ១៥
គម្ពីរទៀត គឺ

១. ខុទ្ទកបាឋៈ , ២. ធម្មបទ , ៣. ឧទាន, ៤. ឥតិវុត្តកៈ, ៥. សុត្តនិបាត, ៦. វិមានវត្ថុ, ៧. បេតវត្ថុ, ៨. ថេរគាថា, ៩. ថេរីគាថា, ១០. ជាតក, ១១. និទ្ទេស, ១២. បដិសម្ភិទា, ១៣. អបទាន, ១៤. ពុទ្ធវង្ស, ១៥. ចរិយាបិដក ។

ព្រះសូត្រទាំងអស់រួមជាបិដកមួយ ហៅថា សុត្តន្តបិដក ចែកជាធម្មខន្ធមាន ២១.០០០ ព្រះធម្មខន្ធ ៗ

# ពួក ៦

## ធម៌ ៦ ប្រការសម្រាប់លះកាមឆន្ទៈ

អបិច ឆ ធម្មា កាមច្ឆន្ទស្ស បហានាយ សំវត្តន្តិ : *មា៉្យងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីលះកាមឆន្ទៈ គឺ*

១-អសុភនិមិត្តស្ស ឧគ្គហោ *ការកំណត់ ឬរៀន នូវអសុភនិមិត្តជាអារម្មណ៍*

២-អសុភភាវនានុយោគោ *ការប្រកបរឿយៗ នូវអសុភភាវនា*

៣-ឥន្ទ្រិយេសុ គុត្តទ្វារតា *ការរក្សាទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ*

៤-ភោជនេ មត្តញ្ញុតា *ការស្គាល់ប្រមាណ ក្នុងភោជន*

៥-កល្យាណមិត្តតា *ការមានកល្យាណមិត្ត*

៦-សប្បាយកថាតិ *និយាយតែពាក្យ*

ដែលជាទីសប្បាយ ។

ពិតមែន កាលភិក្ខុកំណត់អសុភនិមិត្ត ១០ យ៉ាង ក៏លះកាមឆន្ទៈបាន ។ កាលចម្រើនអសុភ ១០ ក្តី កាលគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយក្តី ស្គាល់ប្រមាណក្នុងភោជន ព្រោះកាលមានឱកាសទទឹងបរិភោគ ៤-៥ ពំនូតមាន ក៏ផឹកទឹក ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ក៏រមែងលះកាមឆន្ទៈបាន ។ ព្រោះហេតុនោះ លោកទើបពោលទុកថា

"ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ
អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ" ។

ភិក្ខុឈប់បរិភោគ ៤ ឬ ៥ ពំនូត (ក្នុងកាលជិតឆ្អែត) ហើយគប្បីផឹកទឹក នេះជាការល្មមដល់កិរិយានៅជាសុខ នៃភិក្ខុដែលមានចិត្តស្ងប់ទៅ (រកព្រះនិព្វាន)[១] ។

សូម្បីភិក្ខុដែលសេពកល្យាណមិត្ត ដែលជាអ្នកត្រេកអរក្នុងការចម្រើនអសុភ ដូចព្រះតិស្សត្ថេរ អ្នកចម្រើនអសុភកម្មដ្ឋាន ក៏រមែងលះកាមឆន្ទៈបាន ។ សូម្បីដោយការនិយាយប្រារព្ធរឿងជាទីសប្បាយ ដែលអាស្រ័យអសុភ ១០ ក្នុងឥរិ-

---

១. ខុទ្ទ. ថេរ. សារីបុត្តថេរគាថា. ៥៧. ២៦០/៨៨ ។

យាបថឈរនិងអង្គុយជាដើម ក៏រមែងលះកាមឆន្ទៈបាន ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមឆន្ទៈដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏កាមឆន្ទៈដែលលះបានហើយដោយធម៌ ៦ ប្រការនេះ រមែងមិនកើតទៀតតទៅដោយអរហត្តមគ្គ ។

## ធម៌ ៦ ប្រការសម្រាប់លះព្យាបាទ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ គឺ

១–មេត្តានិមិត្តស្ស ឧគ្គហោ ការកំណត់និមិត្តក្នុងមេត្តាជាអារម្មណ៍

២–មេត្តាភាវនានុយោគោ ការប្រកបរឿយៗនូវមេត្តាភាវនា

៣–កម្មស្សកតាបច្ចវេក្ខណា ការពិចារណាឃើញនូវភាវនៃសត្វមានកម្មជារបស់ខ្លួន

៤–បដិសង្ខានពហុលតា ការធ្វើឲ្យច្រើននូវការពិចារណា

៥-កល្យាណមិត្តតា ភាពជាអ្នកមានកល្យាណមិត្ត

៦-សប្បាយកថាតិ ការនិយាយនូវពាក្យដែលជាទីសប្បាយ ។

ពិតមែន សូម្បីកាលភិក្ខុកំណត់មេត្តាកម្មដ្ឋាន ដោយការផ្សាយមេត្តាទូទៅគ្រប់ទិសដោយចំពោះ ឬមិនចំពោះយ៉ាងណាមួយ រមែងលះព្យាបាទបាន ។ កាលភិក្ខុចម្រើនមេត្តា ដោយផ្សាយទូទៅគ្រប់ទិសដោយចំពោះក្តី មិនចំពោះក្តី កាលពិចារណាដល់ភាពដែលខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួនយ៉ាងនេះថា "លោកក្រោធអ្នកនោះ នឹងធ្វើអ្វីគេបាន លោកអាចនឹងធ្វើសីលជាដើមរបស់គេឲ្យវិនាសបានឬ លោកមកហើយដោយកម្មរបស់ខ្លួន នឹងទៅដោយកម្មរបស់ខ្លួននុ៎ះឯង ដែលឈ្មោះថា ការក្រោធអ្នកដទៃ ក៏ដូចគ្នានឹងអ្នកប្រាថ្នានឹងចាប់រងើកភ្លើងដែលឆាបឆេះ ប្រវាក់ដែកដែលក្តៅ និងឧច្ចារៈជាដើមប្រហារអ្នកដទៃ" ដូច្នោះ ឬសូម្បីអ្នកនោះក្រោធលោក នឹងធ្វើអ្វីបាន គេនឹងអាចធ្វើសីលជាដើមរបស់លោកឲ្យវិនាសបានឬ គេមកដោយកម្មរបស់ខ្លួនក៏នឹងទៅតាមកម្មរបស់គេនុ៎ះឯង សេចក្តីក្រោធនោះនឹងធ្លាក់ចុះលើក្បាលរបស់គេនុ៎ះឯង ដូចប្រហារអ្នកមិនប្រហារតប

និងដូចនាំធូលីបោះទៅក្នុងទីប្រាសខ្យល់ដូច្នោះ ដូច្នេះក្តី កាលពិចារណាកម្មស្សកតាទាំងពីរ ឋិតក្នុងការពិចារណាក្តី សេពគប់កល្យាណមិត្ត អ្នកត្រេកអរក្នុងការចម្រើនមេត្តា ដូចព្រះអស្សគុត្តត្ថេរក្តី រមែងលះព្យាបាទបាន ។ សូម្បីដោយការនិយាយរឿងដែលជាទីសប្បាយដែលអាស្រ័យមេត្តា ក្នុងឥរិយាបថទាំងឡាយមានឈរ អង្គុយជាដើម ក៏លះព្យាបាទបាន ។ ព្រោះហេតុនោះ លោកទើបពោលថា ធម៌ ៦ ប្រការ រមែងជាទៅដើម្បីលះព្យាបាទ ដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏ព្យាបាទដែលលះបានហើយដោយធម៌ ៦ ប្រការនេះ រមែងមិនកើតតទៅដោយអនាគាមិមគ្គ ។

## ធម៌ ៦ ប្រការសម្រាប់លះថីនមិទ្ធៈ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ គឺ

១-អតិភោជនេ និមិត្តគ្គាហោ ការកំណត់និមិត្តក្នុងភោជនដ៏លើស

២-ឥរិយាបថសម្បរិវត្តនតា ការផ្លាស់ប្តូរឥរិយាបថ

៣-អាលោកសញ្ញាមនសិការោ ការដាក់ចិត្តដល់អាលោកសញ្ញា (គឺសេចក្ដីសម្គាល់ថាភ្លឺៗ)

៤-អព្ភោកាសវាសោ ការនៅក្នុងឱកាសដែលស្រឡះ

៥-កល្យាណមិត្តតា ភាពជាអ្នកមានកល្យាណមិត្ត

៦-សប្បាយកថា ភាពជាអ្នកនិយាយនូវពាក្យជាទីសប្បាយ ។

ព្រោះថា កាលភិក្ខុបរិភោគភោជន ដូចព្រាហ្មណ៍ឈ្មោះអាហារហត្ថកៈ ឈ្មោះតត្រវដ្ដកៈ ឈ្មោះអលំសាដកៈ ឈ្មោះកាកមាសកៈ និងឈ្មោះភុត្តវមិតកៈ អង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ធ្វើសមណធម៌ ថីនមិទ្ធៈ រមែងមកគ្របសង្កត់បានដូចដំរីធំ តែថីនមិទ្ធៈនោះ នឹងមិនមានដល់ភិក្ខុដែលវៀរឱកាសបរិភោគ ៤-៥ ពំនូត ហើយផឹកទឹកផឹកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅជាប្រក្រតី ព្រោះហេតុនោះ កាលភិក្ខុកំណត់និមិត្តក្នុងភោជនដ៏លើសយ៉ាងនេះ រមែងលះថីនមិទ្ធៈបាន កាលភិក្ខុចូលកាន់ថីនមិទ្ធៈ ក្នុងឥរិយាបថណា ផ្លាស់ឥរិយាបថ

ជាយ៉ាងដទៃពីឥរិយាបថនោះចេញ ក៏លះថីនមិទ្ធៈបាន ។ កាលភិក្ខុដាក់ចិត្តពន្លឺព្រះចន្ទ ពន្លឺប្រទីប ពន្លឺគប់ភ្លើង ក្នុងវេលាយប់ ពន្លឺព្រះអាទិត្យវេលាថ្ងៃក្តី នៅក្នុងទីកណ្តាលវាលក្តី សេពគប់កល្យាណមិត្ត អ្នកលះថីនមិទ្ធៈបាន ដូចព្រះមហាកស្សបត្ថេរក្តី ក៏លះថីនមិទ្ធៈបាន ។ សូម្បីដោយការនិយាយតែរឿងដែលជាទីសប្បាយ ដែលអាស្រ័យធុតង្គ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ក៏លះថីនមិទ្ធៈបាន ។ ព្រោះដូច្នោះ លោកទើបពោលធម៌ ៦ ប្រការនេះ រមែងប្រព្រឹត្តទៅ ដើម្បីលះថីនមិទ្ធៈ ។ ភិក្ខុរមែងដឹងច្បាស់ថា ថីនមិទ្ធៈដែលលះបាន ដោយធម៌ ៦ ប្រការ នឹងមិនកើតតទៅដោយអរហត្តមគ្គ ដូច្នេះ ។

## ធម៌ ៦ ប្រការសម្រាប់លះឧទ្ធច្ចកុក្កុច្ចៈ

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺ

១-ពហុស្សុតតា ភាពជាអ្នកចេះដឹង ឬស្តាប់ច្រើន

២-បរិបុច្ឆកតា ភាពជាអ្នកសាកសួរ

៣-វិនយេ បកតញ្ញុតា ការជំនាញក្នុងវិន័យ

៤-វុឌ្ឍសេវិតា ការសេពគប់នូវបុគ្គលដ៏ចម្រើន

៥-កល្យាណមិត្តតា ភាពជាអ្នកមានកល្យាណមិត្ត

៦-សប្បាយកថា ជាអ្នកនិយាយពាក្យដែលជាទីសប្បាយ ។

ពិតមែន កាលភិក្ខុសូម្បីសិក្សារៀនសូត្រទាំងបាលី ទាំងអដ្ឋកថា និកាយមួយ ពីរ បី បួន និកាយ ឬ ៥ និកាយ រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ សូម្បីដោយភាពជាពហុស្សូត (ភាពជាអ្នកស្តាប់ច្រើន) ។ ភិក្ខុដែលច្រើនដោយការសាកសួរវត្ថុដែលគួរនិងមិនគួរក្តី អ្នកជំនាញ ព្រោះមានការជំនាញដែលសន្សំទុកក្នុងវិនយបញ្ញត្តិក្តី អ្នកចូលរកព្រះថេរៈចាស់ អ្នកចំណាស់ក្តីសេពគប់កល្យាណមិត្ត អ្នកទ្រង់វិនយ ដូចព្រះឧបាលីត្ថេរក្តី រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ សូម្បីដោយការនិយាយតែរឿងដែលជាទីសប្បាយ ដែលអាស្រ័យវត្ថុដែលគួរ និងមិនគួរ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ក៏លះឧទ្ធច្ចកុក្កុច្ចៈបាន ។ ព្រោះដូច្នោះ លោកទើបពោលថា ធម៌ ៦ ប្រការនេះរមែងជាដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ។ ភិក្ខុ រមែងដឹងច្បាស់ថា កាលឧទ្ធច្ចកុក្កុច្ចៈលះបានហើយដោយធម៌ ៦ ប្រការនេះ **ឧទ្ធច្ចៈ** នឹង

មិនកើតតទៅដោយអរហត្តមគ្គ, **កុក្កុច្ចៈ** មិនកើតតទៅដោយអនាគាមិមគ្គ ។

## ធម៌ ៦ ប្រការសម្រាប់លះវិចិកិច្ឆា

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺ

១-ពហុស្សុតតា ភាពជាអ្នកចេះដឹង ឬស្តាប់ច្រើន

២-បរិបុច្ឆកតា ភាពជាអ្នកសាកសួរ

៣-វិនយេ បកតញ្ញុតា ការជំនាញក្នុងវិន័យ

៤-អធិមោក្ខពហុលតា ភាពជាអ្នកច្រើនដោយការបង្អោនចិត្តជឿស៊ប់

៥-កល្យាណមិត្តតា ភាពជាអ្នកមានកល្យាណមិត្ត

៦-សប្បាយកថា ជាអ្នកនិយាយពាក្យដែលជាទីសប្បាយ ។

ពិតមែន សូម្បីកាលភិក្ខុសិក្សារៀនសូត្រទាំងបាលី ទាំងអដ្ឋកថា និកាយមួយ ពីរ បី បួន ឬប្រាំនិកាយ រមែងលះ

*វិចិកិច្ឆាបាន ដោយភាពជាពហុស្សូត ។ កាលភិក្ខុច្រើនដោយការប្រារព្ធព្រះរតនត្រ័យ សាកសួរក្តី មានសេចក្តីជំនាញដែលសន្សំទុកក្នុងវិនយក្តី ច្រើនទៅដោយការបង្អោនចិត្តជឿ ពោលគឺសទ្ធាដែលនៅកម្រើកបានក្នុងព្រះរតនត្រ័យក្តី សេពគប់កល្យាណមិត្តដូចព្រះវក្កលិ អ្នកបង្អោនចិត្តទៅក្នុងសទ្ធាក្តី រមែងលះវិចិកិច្ឆាបាន ។ សូម្បីដោយការនិយាយតែរឿងដែលជាទីសប្បាយ ដែលអាស្រ័យគុណរបស់ព្រះរតនត្រ័យ ក្នុងឥរិយាបថទាំងឡាយមានឈរ អង្គុយជាដើម ក៏លះវិចិកិច្ឆាបាន ។ ព្រោះហេតុនោះលោកទើបពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា ។ ភិក្ខុ រមែងដឹងច្បាស់ថា វិចិកិច្ឆាដែលលះបានដោយធម៌ទាំងនេះ រមែងមិនកើតតទៅ ដោយសោតាបត្តិមគ្គ ដូច្នេះ ។*

*(ចាកអដ្ឋកថា សុមង្គលវិលាសិនី)*

## សេចក្តីមិនគោរព ៦ យ៉ាង

| | |
|---|---|
| ១-ពុទ្ធេ អគារវោ | សេចក្តីមិនគោរពព្រះពុទ្ធ |
| ២-ធម្មេ អគារវោ | មិនគោរពព្រះធម៌ |
| ៣-សង្ឃេ អគារវោ | មិនគោរពព្រះសង្ឃ |

៤-សិក្ខាយ អគារវោ មិនគោរពសិក្ខា

៥-អប្បមាទេ អគារវោ មិនគោរពសេចក្ដីមិនប្រមាទ

៦-បដិសណ្ឋារេ អគារវោ មិនគោរពការបដិសន្ថារ ។

## សេចក្ដីគោរព ៦ យ៉ាង

១-ពុទ្ធេ គារវោ ការគោរពព្រះពុទ្ធ

២-ធម្មេ គារវោ គោរពព្រះធម៌

៣-សង្ឃេ គារវោ គោរពព្រះសង្ឃ

៤-សិក្ខាយ គារវោ គោរពសិក្ខា

៥-អប្បមាទេ គារវោ គោរពសេចក្ដីមិនប្រមាទ

៦-បដិសណ្ឋារេ គារវោ គោរពក្នុងការបដិសន្ថារ;

## សង្ខារ ៦ យ៉ាង

បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ កាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ ។

១-បុញ្ញាភិសង្ខារ : ចេតនាជាកុសល ១៣ គឺ កាមា-

*វចរកុសលចេតនា ៨ ដួង ដែលប្រព្រឹត្តទៅដោយអំណាចកុសលមានទានជាដើម និងរូបាវចរកុសលចេតនា ៥ ដួង ដែលប្រព្រឹត្តទៅដោយអំណាចភាវនាតែម្យ៉ាង*

២-អបុញ្ញាភិសង្ខារ : *ចេតនាជាអកុសលចិត្ត ១២ ជាកាមាវចរ ដែលប្រព្រឹត្តទៅដោយអំណាចអកុសល មានបាណាតិបាតជាដើម ។*

៣-អនេញ្ជាភិសង្ខារ : *ចេតនាជាកុសល ជាអរូបាវចរ ៤ ដួង ដែលប្រព្រឹត្តទៅដោយអំណាចភាវនាដូចគ្នា ។*

## អធិប្បាយបុញ្ញាភិសង្ខារ

*ក្នុងព្រះបាលីនោះ សូម្បីចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ត្រាស់ដោយមិនកំណត់ទុកថា* ***ចេតនាជាកុសល*** *តែព្រោះទ្រង់កំណត់ថា* ***កាមាវចរ រូបាវចរ*** *ដូច្នេះ ចេតនា ១៣ ដួង គឺ កាមាវចរកុសលចេតនា ៨ ដួង និង រូបាវចរកុសលចេតនា ៥ ដួង ឈ្មោះថា* ***បុញ្ញាភិសង្ខារ*** *។ ដោយបទទាំងឡាយថា* ***ទានមយា*** *(សម្រេចដោយទាន)ជាដើម ទ្រង់សម្តែងការប្រព្រឹត្តទៅដោយអំណាចនៃបុញ្ញកិរិយាវត្ថុនៃចេតនាទាំងនោះឯង ។*

ក្នុងព្រះបាលីនោះ ចេតនា ៨ ដួងជាកាមាវចរ រមែង សម្រេចដោយទាន និងសីលប៉ុណ្ណោះ តែចេតនាសូម្បីទាំង ១៣ ដួង សម្រេចដោយភាវនា ប្រៀបដូចបុគ្គលស្វាធ្យាយធម៌ ស្ទាត់ជំនាញ រមែងមិនដឹងនូវធម៌ដែលប្រព្រឹត្តទៅ សូម្បីសន្ធិមួយ សូម្បីសន្ធិពីរ កាលនឹកដល់ទើបដឹងជាខាងក្រោយ យ៉ាងណា កាលព្រះយោគាវចរធ្វើកសិណបរិកម្ម ពិចារណាឈានដែល កើតស្ទាត់ជំនាញ និងកាលមនសិការកម្មដ្ឋានដែលជំនាញ ក៏ដូច្នោះដែរ ចេតនាសូម្បីប្រាសចាកញាណ ក៏រមែងសម្រេចជាភាវនា ដោយហេតុនោះ ខ្ញុំទើបពោលថា ចេតនាសូម្បីទាំង ១៣ ដួង សម្រេចដោយភាវនា ដូច្នេះ ។

ក្នុងទេសនានេះ ជាទេសនាដោយសង្ខេប ក្នុងបុញ្ញ-កិរិយាវត្ថុមានទានជាដើមថា **ចេតនា សញ្ចេតនា** (ការតាំងចិត្ត) ការគិតប្រារព្ធទាន ធ្វើទានឲ្យជាធំយ៉ាងណា រមែងកើតឡើង នេះហៅថា **បុញ្ញាភិសង្ខារ** សម្រេចដោយទានចេតនា ការតាំងចិត្ត ការគិត ប្រារព្ធសីល ។បេ។ ប្រារព្ធភាវនា ធ្វើភាវនាឲ្យជាធំយ៉ាងណា នេះហៅថា **បុញ្ញាភិសង្ខារ** សម្រេចដោយភាវនា ដូច្នេះ ។

ចំណែកកថានេះ ជាកថាដោយពិស្តារថា បណ្តាបច្ច័យ ៤ មានចីវរជាដើម ឬបណ្តាអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ឬទានវត្ថុ ១០ មានការឲ្យបាយជាដើម ចេតនារបស់បុគ្គលអ្នកឲ្យវត្ថុនោះៗ ដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ គឺ ក្នុងបុព្វភាគ (ចំណែកខាងដើម) ចាប់ផ្តើមតាំងពីការកើតឡើងនៃរបស់នោះៗ ១ ក្នុងវេលាបរិច្ចាគ ១ ក្នុងការរលឹកដល់ ដោយចិត្តសោមនស្សជាខាងក្រោយ ១ ឈ្មោះថា **ទានមយៈ** ។ ចំណែកចេតនា ដែលប្រព្រឹត្តទៅដល់បុគ្គលដែលទៅកាន់វិហារ ដោយតាំងចិត្តថា យើងនឹងបួសដើម្បីបំពេញសីល ដូច្នេះ បួសហើយញ៉ាំងមនោរថឲ្យដល់ទីបំផុតហើយ រំពឹងគិតថា យើងបួសហើយជាការល្អពិត ដូច្នេះ យើងនឹងសង្រួមក្នុងព្រះ-បាដិមោក្ខ ពិចារណានូវបច្ច័យទាំងឡាយមានចីវរជាដើម ប្រុងប្រយ័ត្ននូវចក្ខុទ្វារជាដើម ក្នុងអារម្មណ៍មានរូបជាដើម ដែលមកកាន់គន្លង និងជម្រះអាជីវៈឲ្យបរិសុទ្ធិ ឈ្មោះថា **សីលមយៈ** ។ ចេតនាដែលប្រព្រឹត្តទៅដល់ព្រះយោគាវចរ អ្នកចម្រើននូវចក្ខុដោយភាពជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ចម្រើនរូបទាំងឡាយ ។បេ។ ចម្រើនធម៌ទាំងឡាយ ចម្រើនចក្ខុវិញ្ញាណ ។បេ។

ចម្រើនមនោវិញ្ញាណ ចម្រើនចក្ខុសម្ផស្ស ។ល។ ចម្រើនមនោ-សម្ផស្ស ចម្រើនចក្ខុសម្ផស្ស ជាវេទនា ។ល។ ចម្រើនមនោ-សម្ផស្សជាវេទនា ។ល។ ចម្រើនរូបសញ្ញា ។ល។ ចម្រើនជរាមរណៈ ដោយភាពជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ដោយផ្លូវនៃវិបស្សនា ដែលពោលទុកក្នុងបដិសម្ភិទាមគ្គ ឈ្មោះថា **ភាវនាមយៈ** ដូច្នេះ ។

## អធិប្បាយអបុញ្ញាភិសង្ខារ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសអបុញ្ញាភិសង្ខារ តទៅ ៖

បទថា អកុសលា ចេតនា (ចេតនាជាអកុសល) បានដល់ ចេតនាសម្បយុត្តដោយអកុសលចិត្ត ១២ ដួង ។

បទថា កាមាវចរា (ជាកាមាវចរ) សេចក្ដីថា បណ្ដាអកុសលចេតនាទាំង ១២ ដួងនោះ វៀរចេតនាដែលសហគតដោយទោមនស្ស ២ ដួងដែលនៅសល់ រមែងកើតឡើង សូម្បីក្នុងរូបភព និងអរូបភព ក៏ពិតមែន តែក៏មិននាំមកនូវបដិសន្ធិក្នុងរូបភព និងអរូបភពនោះ រមែងញ៉ាំងវិបាកឲ្យអន្ទោលទៅក្នុងកាមាវចរ ដោយអំណាចបដិសន្ធិនិ៍ះឯង ព្រោះដូច្នោះ

ទើបត្រាស់ថា ជាកាមាវចរប៉ុណ្ណោះ ដូច្នេះ ។

## អធិប្បាយអានេញ្ជាភិសង្ខារ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសអានេញ្ជាភិសង្ខារ តទៅ ៖

បទថា **កុសលា ចេតនា អរូបាវចរា** (កុសលចេតនាជាអរូបាវចរ) បានដល់ កុសលចេតនាជាអរូបាវចរ ៤ ពិតមែនកុសលចេតនាជាអរូបាវចរ ៤ ទាំងនេះ ត្រាស់ហៅថា អានេញ្ជាភិសង្ខារ ព្រោះអត្ថថា មិនញាប់ញ័រ និងព្រោះអត្ថថា ប្រជុំតាក់តែងការមិនញាប់ញ័រ ព្រោះថា ធម៌ ១៥ គឺ ចេតនាដែលជាកុសលវិបាក កិរិយាដែលកើតពីចតុត្ថឈានដែលជារូបាវចរ ៣ ដួង ចេតនាដែលជាអរូបាវចរ ១២ ដួង ឈ្មោះថា **អានេញ្ជា** ព្រោះអត្ថថា តាំងមាំ, មិនញាប់ញ័រ ។ បណ្ដាចេតនាទាំង ១៥ នោះ រូបាវចរកុសលចេតនា សូម្បីជាសភាពមិនញាប់ញ័រ តែក៏ឲ្យកើតរូបនិងអរូប ដែលដូចគ្នានឹងខ្លួនខ្លះ មិនដូចគ្នានឹងខ្លួនខ្លះ ឲ្យមានសេចក្ដីញាប់ញ័រខ្លះ មិនមានសេចក្ដីញាប់ញ័រខ្លះ ព្រោះដូច្នោះ ទើបមិនឈ្មោះថា **អានេញ្ជាភិសង្ខារ** ចំណែករូបាវចរវិបាកចេតនា និងរូបាវចរកិរិយាចេតនា រមែង

តាក់តែងវិបាកមិនបាន ព្រោះមិនមានវិបាក ទើបឈ្មោះថា ជាអានេញ្ជាភិសង្ខារមិនបាន ចេតនាដែលជាអរូបាវចរវិបាក និងកិរិយា ក៏ជាអានេញ្ជាភិសង្ខារមិនបាន ដូចគ្នា ព្រោះដូច្នោះ ចេតនាទាំងនេះសូម្បីទាំង ១១ ដួង (ចេតនាក្នុងរូបាវចរចតុត្ថ-ឈាន ៣ អរូបាវចរវិបាក ៤ និង កិរិយា៤) ទើបជា **អានេញ្ជា** ប៉ុណ្ណោះ មិនជាអានេញ្ជាភិសង្ខារ។ តែ**អរូបាវចរកុសលចេតនា ៤ ដួង** ប៉ុណ្ណោះ ត្រាស់ហៅថា **អានេញ្ជាភិសង្ខារ** ព្រោះអត្ថថា រមែងឲ្យកើត**អរូប** ដែលមិនញាប់ញ័រដូចនឹងខ្លួន ដូចស្រមោលរបស់សត្វ មានដំរីសេះ ជាដើម ក៏ជាស្រមោល មានរូបដូចគ្នានឹងដំរីសេះជាដើមនោះ ដូច្នោះ ចេតនាទាំងអស់នេះ គឺកុសល-ចេតនា ១៣ ដួង ដោយអំណាចនៃបុញ្ញាភិសង្ខារ, អកុសល-ចេតនា ១២ ដួង ដោយអំណាចនៃអបុញ្ញាភិសង្ខារ, អរូប-កុសលចេតនា ៤ ដួង ដោយអំណាចអានេញ្ជាភិសង្ខារ, រួមជាចេតនា ២៩ ដួង ដោយប្រការដូច្នេះ ។

ព្រះដ៏មានព្រះភាគ ទ្រង់កំណត់ចេតនាដែលជាកុសល និង អកុសលដែលកើតឡើងដល់ពួកសត្វ មានប្រមាណរាប់មិនបានក្នុងចក្រវាឡ ដែលប្រមាណមិនបានដោយព្រះសព្វ-

ញាតញាណ ទ្រង់សម្តែងចេតនាទុក ២៩ ដួងប៉ុណ្ណោះ ដូចទ្រង់ថ្លឹងដោយជញ្ជីងដ៏ធំ និង ដូចទ្រង់វាល់ដោយនាឡិទុំ៖ឯង ដោយប្រការដូច្នេះ ។

## ពោលដោយទ្វារនៃកម្ម

ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់សម្តែងទ្វារនៃកម្ម ៣ ដល់ពួកសត្វមានប្រមាណមិនបាន ក្នុងចក្រវាឡដែលរាប់មិនបាន អ្នកប្រកបនូវកុសលកម្ម និង អកុសលកម្ម រមែងប្រកបដោយទ្វារទាំងនោះ ទើបត្រាស់ពាក្យថា **តត្ថ កតមោ កាយសង្ខារោ កាយសញ្ចេតនា** បណ្តាសង្ខារទាំងនោះ កាយសង្ខារតើដូចម្តេច ? គឺកាយសញ្ចេតនា ដូច្នេះជាដើម ។

ក្នុងព្រះបាលីនោះ ពាក្យថា **កាយសញ្ចេតនា** បានដល់ចេតនា ២០ គត់ គឺ កាមាវចរកុសលចេតនា ៨ ដួង អកុសលចេតនា ១២ ដួង ដែលប្រព្រឹត្តទៅដោយកាយទ្វារ ដែលញ៉ាំងកាយវិញ្ញត្តិឲ្យតាំងឡើង សូម្បីនឹងពោលថា ចេតនាដែលជាកុសល និងអកុសល ២០ ដែលកើតឡើងឲ្យដល់ការញ៉័រទៅដោយការតោង និងការកាន់យកក្នុងកាយទ្វារ ដូច្នេះក៏សមគួរ ។

ពាក្យថា **វចីសញ្ចេតនា** បានដល់ ចេតនា ២០ ដួងនោះឯង ប្រព្រឹត្តទៅតាមវចីទ្វារ ញុំាងវចីវិញ្ញត្តិឲ្យតាំងឡើង សូម្បីនឹងពោលថា ចេតនា ២០ ដួង ដែលកើតឡើងឲ្យកម្រើកញ័រដរាបដល់បញ្ចេញវាចា ក្នុងវចីទ្វារដូច្នេះក៏គួរ ។ តែក្នុងអធិការនេះ អភិញ្ញាចេតនា រមែងមិនជាបច្ច័យដល់វិញ្ញាណខាងមុខ ព្រោះដូច្នោះ លោកទើបមិនកាន់យកសូម្បីឧទ្ធច្ចចេតនាក៏មិនជាបច្ច័យដូចអភិញ្ញាចេតនា ព្រោះដូច្នោះ សូម្បីឧទ្ធច្ច-ចេតនានោះ ក៏គប្បីនាំចេញចាកភាពជាបច្ច័យរបស់វិញ្ញាណក៏ចេតនាសូម្បីទាំងអស់នេះ រមែងមាន ព្រោះអវិជ្ជាជាបច្ច័យ ។

ពាក្យថា **មនោសញ្ចេតនា** បានដល់ សូម្បីចេតនា ២៩ ដួង ទាំងអស់ដែលកើតឡើងក្នុងមនោទ្វារ មិនញុំាងវិញ្ញត្តិទាំង ២ ឲ្យតាំងឡើង ។

ព្រះមានព្រះភាគ ទ្រង់សម្តែងទ្វារនៃកម្មដែលសត្វព្យា-យាមទុកថា "សត្វទាំងឡាយក្នុងចក្រវាឡដែលរាប់ប្រមាណមិនបាន កាលប្រកបកុសល និង អកុសលកម្ម រមែងប្រកបដោយទ្វារទាំង ៣ នេះ" ដោយប្រការដូច្នេះឯង ។

(អដ្ឋកថា មធុរត្ថវិលាសិនី ៧៧ / ៤៦៦)

## អភិញ្ញា ៦

១-ឥទ្ធិវិធ *សម្ដែងឫទ្ធិបាន*

២-ទិព្វសោត *ត្រចៀកទិព្វ*

៣-ចេតោបរិយញ្ញាណ *កំណត់ដឹងចិត្តអ្នកដទៃបាន ។*

*៤,៥,៦- និងវិជ្ជា ៣ មានបុព្វេនិវាសញ្ញាណ ជាដើម ។*

## គុណនាទីសមណព្រាហ្មណ៍ ៦ យ៉ាង

១-ចាចា និវារេន្តិ *ហាមឃាត់កុលបុត្តចាកអំពើអាក្រក់*

២-កល្យាណេ និវេសេន្តិ *ឲ្យតាំងនៅក្នុងអំពើល្អ*

៣-កល្យាណេន មនសា អនុកម្បន្តិ *អនុគ្រោះដោយចិត្តដ៏ល្អ*

៤-អស្សុតំ សាវេន្តិ *ឲ្យបានស្ដាប់ពាក្យដែលមិនធ្លាប់ស្ដាប់*

៥-សុតំ បរិយោទបេន្តិ *បំភ្លឺសេចក្ដីដែលធ្លាប់ស្ដាប់ហើយ*

៦-សគ្គស្ស មគ្គំ អាចិក្ខន្តិ ប្រាប់ផ្លូវសួគ៌ ។

## អង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាង

១-អតិទូរំ អង្គុយឆ្ងាយពេក

២-អច្ចាសន្នំ អង្គុយជិតពេក

៣-ឧបរិវាតំ អង្គុយលើខ្យល់

៤-ឧន្នតប្បទេសំ អង្គុយទីខ្ពស់

៥-អតិសម្មុខំ អង្គុយចំពោះមុខពេក

៦-អតិបច្ឆាតិ អង្គុយខាងក្រោយពេក ។

ព្រោះអង្គុយឆ្ងាយពេក បើចង់សួរ ក៏ត្រូវនិយាយដោយសំឡេងខ្លាំង, អង្គុយជិតពេក នឹងត្រូវធ្វើសេចក្ដីប្រៀតបៀតគ្នា, អង្គុយក្នុងទីលើខ្យល់ រមែងរុកកួន (អ្នកដទៃ) ដោយក្លិនរបស់ខ្លួន, អង្គុយក្នុងទីខ្ពស់ រមែងសម្ដែងការមិនគោរព, អង្គុយក្នុងទីចំពោះមុខពេក បើប្រាថ្នានឹងមើល នឹងត្រូវសម្លឹងមើលទល់ភ្នែកគ្នានឹងគ្នា, អង្គុយខាងក្រោយពេក បើប្រាថ្នានឹងមើល នឹងត្រូវអើតកចេញទៅមើល ។ សុមង្គលវិលាសិនី ។

## ការកើតឡើងនៃសភាវៈ៦យ៉ាងគឺបុគ្គលបានដោយក្រក្នុងលោក

១-តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវោ ទុល្លភោ លោកស្មឹ *ការកើតឡើងនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ បុគ្គលបានដោយក្រក្នុងលោក*

២-តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសេតា បុគ្គលោ ទុល្លភោ លោកស្មឹ *បុគ្គលជាអ្នកសម្តែងធម្មវិន័យ ដែលព្រះតថាគតបានប្រកាសហើយ បុគ្គលបានដោយក្រក្នុងលោក*

៣-អរិយាយតនេ បច្ចាជាតោ បុគ្គលោ ទុល្លភោ លោកស្មឹ *សត្វត្រឡប់មកកើតក្នុងប្រទេសជាទីនៅនៃអរិយជន បុគ្គលបានដោយក្រក្នុងលោក*

៤-ឥន្ទ្រិយានំ អវេកល្លតា ទុល្លភា លោកស្មឹ *ការមិនខូចខាតឥន្ទ្រិយទាំងឡាយ បុគ្គលបានដោយក្រក្នុងលោក*

៥-អជឡតា អនេឡមូគតា ទុល្លភា លោកស្មឹ *ភាពនៃបុគ្គលមិនលេលាមិនឆ្គួត បុគ្គលបានដោយក្រក្នុងលោក*

៦-កុសលធម្មច្ឆន្ទោ ទុល្លភោ លោកស្មឹ *សេចក្តីពេញចិត្តក្នុងកុសលធម៌ បុគ្គលបានដោយក្រក្នុងលោក ។*

*(សុត្តន្តបិដក ៤៦ / ៣១៩)*

## ធម៌៦យ៉ាងជាទ្វារនាំឱ្យជាប្រធាននៃសេចក្តីចម្រើន

១-អារោគ្យមិច្ឆេ បរមញ្ច លាភំ *បុគ្គលគប្បីប្រាថ្នាលាភដ៏ឧត្តម គឺការមិនមានរោគ*

២-សីលំ *សីល (គឺមារយាទ)*

៣-ពុទ្ធានុមតំ *ការយល់ឃើញតាមបណ្ឌិតអ្នកដឹង*

៤-សុតំ *ការឧស្សាហ៍ស្តាប់*

៥-ធម្មានុវត្តី *ការអនុវត្តន៍នូវសុចរិតធម៌*

៦- អលីនតា *ការមិនរួញរានៃចិត្ត ។*

*(សុត្តន្តបិដក ៥៨ / ៣៧)*

## អធិប្បាយតាមអដ្ឋកថា

*ដែលឈ្មោះថា ភាពជាអ្នកមិនមានរោគ ក្នុងបាទគាថាថា អារោគ្យមិច្ឆេ បរមញ្ច លាភំ ត្រឹមតែជានិបាត ។ បានដល់ អាការដែលមិនមានសភាវៈចាក់ដោត មិនមានអាការខ្វល់ខ្វាយនៃកាយនិងចិត្ត ។ ព្រោះថា កាលរាងកាយត្រូវចាក់ដោត ខ្វល់ខ្វាយ បុគ្គលរមែងមិនអាចនឹងញ៉ាំងលាភដែលនៅមិនទាន់បានឲ្យកើតឡើង ដែលបានរក្សាទុកហើយក៏មិនអាចនឹងប្រើប្រាស់ តែកាលមិនខ្វល់ខ្វាយ រមែងអាចបណ្ដាលឲ្យកើតបានទាំងពីរស្ថាន មួយទៀត កាលចិត្តក្ដៅក្រហាយព្រោះឧបក្កិលេស បុគ្គលក៏មិនអាចដូចគ្នានឹងបង្កលាភគឺ គុណវិសេស មានឈានជាដើម ដែលនៅមិនទាន់កើតឲ្យកើតឡើង ដែលបានហើយ ក៏អាចនឹងលើកតម្កើងដោយអំណាចនៃសមាបត្តិទៀតបាន កាលរោគនេះនៅមាន សូម្បីលាភដែលនៅមិនទាន់បាន ក៏ជាការមិនបាន សូម្បីបានហើយក៏គ្មានប្រយោជន៍, តែកាលរោគនេះមិនមាន សូម្បីលាភដែលនៅមិនទាន់បាន ក៏នឹងត្រូវបាន សូម្បីបានហើយ ក៏រមែងជំនួយប្រយោជន៍ ហេតុនោះ ការមិនមានរោគ ទើបឈ្មោះថា*

ជាលោកយ៉ាងក្រៃលែង ចាំបាច់ត្រូវប្រាថ្នា ការមិនមានរោគនោះ មុនដទៃទាំងអស់ នេះជាទ្វារឯកនៃប្រយោជន៍ ទាំងអស់នេះ ជាអត្ថាធិប្បាយក្នុងសេចក្ដីនោះ ។

បទថា សីលញ្ច បានដល់ អាចារសីល គឺរបៀបក្នុងចំណែកដែលជាមារយាទ ។ ព្រះពោធិសត្វសម្ដែងដល់ចារិតរបស់លោក ដោយបទនេះ ។

បទថា ពុទ្ធានុមតំ (ការយល់ឃើញតាមបណ្ឌិតអ្នកដឹង) បានដល់ ការបណ្ដោយតាមបណ្ឌិតអ្នកចម្រើនដោយគុណទាំងឡាយ ព្រះពោធិសត្វសម្ដែងឱវាទរបស់គ្រូទាំងឡាយ អ្នកបរិបូរណ៍ដោយការដឹង ដោយបទនេះ ។

បទថា សុតញ្ច គឺ ការស្ដាប់ដែលអាស្រ័យលើហេតុ ព្រះពោធិសត្វសម្ដែងពាហុសច្ចៈ ភាពជាអ្នកប្រាជ្ញ ដែលអាស្រ័យខ្លួនក្នុងលោកនេះ ដោយបទនេះ ។

បទថា ធម្មានុវត្តី ច បានដល់ ការអនុវត្តន៍តាមសុចរិតធម៌មាន ៣ យ៉ាង ។ ព្រះពោធិសត្វសម្ដែងការវៀរទុច្ចរិតធម៌ ហើយប្រព្រឹត្តសុចរិតធម៌ ដោយបទនេះ ។

បទថា អលីនតា ៩ បានដល់ សេចក្តីដែលចិត្ត មិនរួញរា មិនធ្លាក់ចុះ ។ ព្រះពោធិសត្វសម្តែងសេចក្តីដែលចិត្តជាសភាពប្រណីត និងជាសភាពខ្ពស់យ៉ាងក្រៃលែង មិនអន់ថយ ដោយបទនេះ ។

បទថា អត្ថស្ស ទ្វារា បមុខា ឆឡេតេ សេចក្តីថា សេចក្តីចម្រើន ឈ្មោះថា ប្រយោជន៍ ធម៌ទាំង ៦ ប្រការនេះ ជាទ្វារ ជាឧបាយ គឺជាផ្លូវសម្រេចមុនដំបូង គឺខ្ពស់បំផុត នៃប្រយោជន៍ ទាំងជាលោកិយៈទាំងជាលោកុត្តរៈ ពោលគឺ សេចក្តីចម្រើន ។ (អដ្ឋកថា ៥៦ , ២៨៩-២៩២ )

## សារាណីយធម៌ ៦

ធម៌ដែលបុគ្គលគប្បីរលឹក ឈ្មោះថា ធ្វើនូវសេចក្តីស្រឡាញ់ ឈ្មោះថា ធ្វើនូវសេចក្តីគោរពដល់សព្រហ្មចារីបុគ្គល ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនវិវាទ ដើម្បីការព្រមព្រៀង ដើម្បីសេចក្តីស្ងប់ស្ងាត់ ។

១-ភិក្ខុក្នុងសាសនានេះ បានតាំងកាយកម្មប្រកបដោយមេត្តា ក្នុងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទី

កំបាំងមុខ ។

២-ភិក្ខុ (ក្នុងសាសនានេះ) បានតាំងវចីកម្មប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ

៣-ភិក្ខុ (ក្នុងសាសនានេះ) បានតាំងមនោកម្មប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គលទាំងក្នុងទីចំពោះមុខទាំងក្នុងទីកំបាំងមុខ

៤-លាភណា ដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីគ្រាន់តែអាហារបិណ្ឌបាត ភិក្ខុអ្នកមិនទាន់បានបរិភោគ ទាំងមិនទាន់បានចែកលាភដូច្នោះនៅឡើយ ជាអ្នកបរិភោគសាធារណៈ (ជាមួយ) នឹងសព្រហ្មចារីបុគ្គលទាំងឡាយ ។

៥-សីលណា ដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះ ជាសីលល្អ ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលដែលតណ្ហានិងទិដ្ឋិ មិនបានប៉ះពាល់ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ភិក្ខុជាអ្នកមានសីលស្មើគ្នា ក្នុងសីលទាំងឡាយ មាន

សភាពដូច្នោះ ជាមួយនឹងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ ។

៦-ទិដ្ឋិណាដ៏ប្រសើរ ជាទីនាំសត្វចេញចាកវដ្តទុក្ខ របស់បុគ្គលអ្នកធ្វើយ៉ាងនោះ ដើម្បីជាទីអស់ទៅនៃកងទុក្ខ ដោយប្រពៃ ភិក្ខុប្រកបដោយសេចក្ដីយល់ឃើញស្មើគ្នា ដោយទិដ្ឋិមានសភាពដូច្នោះ (ជាមួយ) នឹងសព្រហ្មចារីបុគ្គលទាំងក្នុងទីចំពោះមុខទាំងក្នុងទីកំបាំងមុខ ។

## ឆឡង្គទាន

**អង្គរបស់ទាយក មាន ៣**

១-បុព្វេវ ទានា សុមនោ ហោតិ *ទាយក ជាអ្នកមានចិត្តត្រេកអរមុន អំពីកាលឲ្យ*

២-ទទំ ចិត្តំ បសាទេតិ *កំពុងតែឲ្យធ្វើចិត្តឲ្យជ្រះថ្លា*

៣-ទត្វា អត្តមនោ ហោតិ *លុះឲ្យហើយមានចិត្តរីករាយ*

***អង្គរបស់បដិគ្គាហកៈទាំងឡាយ មាន ៣***

១-វីតរាគា វា ហោន្តិ រាគវិនយាយ វា បដិបន្នា *ពួកបដិគ្គាហកៈជាអ្នកប្រាសចាករាគៈ ឬប្រតិបត្តិដើម្បីបន្ទោបង់រាគៈ*

២-វីតទោសា វា ហោន្តិ ទោសវិនយាយ វា បដិបន្នា *ពួកបដិគ្គាហកៈ ជាអ្នកប្រាសចាកទោសៈ ឬប្រតិបត្តិដើម្បីបន្ទោបង់ទោសៈ*

៣-វីតមោហា វា ហោន្តិ មោហាវិនយាយ វា បដិបន្នា *ពួកបដិគ្គាហកៈ ជាអ្នកប្រាសចាកមោហៈ ឬប្រតិបត្តិ ដើម្បីបន្ទោបង់មោហៈ*

**សេចក្តីអធិប្បាយ**

*អង្គរបស់ទាយកមាន ៣ អង្គរបស់បដិគ្គាហកៈ មាន ៣ ដូច្នេះ យ៉ាងនេះឯង ជាទានប្រកបដោយអង្គ ៦ ។*

*ព្រះអង្គទ្រង់ត្រាស់ដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់នូវប្រមាណនៃបុណ្យរបស់ទាន ដែលប្រកបដោយអង្គ ៦ យ៉ាងនេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿង*

នាំមកនូវសេចក្ដីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នា ត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខបានឡើយ ។ ដោយពិតនោះថា រាប់មិនបាន ប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យច្រើនប៉ុណ្ណោះបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលដែលមិនងាយកំណត់ ប្រមាណនូវទឹកក្នុងមហាសមុទ្រថា ទឹកប៉ុណ្ណោះអាឡ្ហកៈក្ដី ទឹកប៉ុណ្ណោះរយ អាឡ្ហកៈក្ដី ទឹកប៉ុណ្ណោះពាន់អាឡ្ហកៈក្ដី ទឹកប៉ុណ្ណោះសែនអាឡ្ហកៈក្ដី បានឡើយ ។ ដោយពិតនោះថា រាប់មិនបាន ប្រមាណមិនកើតគ្រាន់តែរាប់ថា ជាគំនរទឹកដ៏ច្រើនប៉ុណ្ណោះបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលដែលមិនងាយ កំណត់ប្រមាណនូវបុណ្យនូវទានប្រកបដោយអង្គ ៦ យ៉ាង យ៉ាងនេះថា គំនរបុណ្យគំនរកុសល ជាគ្រឿងនាំមកនូវសេចក្ដីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នា ត្រេកអរ គាប់ចិត្តជាប្រយោជន៍ ជាសុខបានឡើយ ។ ដោយពិតនោះថា រាប់មិនបាន ប្រមាណ

មិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យដ៏ច្រើនប៉ុណ្ណោះបាន ក៏យ៉ាងនោះដែរ ។

ព្រះមានព្រះភាគ បានត្រាស់សូត្រនេះហើយ ព្រះសុគត ជាសាស្តា លុះទ្រង់ត្រាស់សូត្រនេះរួចហើយ ទើបត្រាស់គាថាព័ន្ធនេះទៀតថា ៖

ទាយកមានចិត្តរីករាយ ក្នុងវេលាមុនអំពីការឲ្យ កំពុងឲ្យធ្វើចិត្តឲ្យជ្រះថ្លា លុះឲ្យហើយ ក៏មានចិត្តត្រេកអរ(តាមក្រោយ) នេះជាសេចក្តីបរិបូរណ៍របស់ទាន ។ បុគ្គលអ្នកប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈ ជាព្រហ្មចារី មានសេចក្តីសង្រួម ឈ្មោះថា ជាខេត្តនៃទានដ៏បរិបូរណ៍ (ដោយគុណ) ។ បុគ្គលខ្វល់ខ្វាយដោយខ្លួនឯង ឲ្យទានដោយដៃរបស់ខ្លួន ។ ទាននុ៎ះ ជាទានមានផលច្រើន ព្រោះខ្លួនផង ព្រោះបុគ្គលដទៃផង ។ អ្នកប្រាជ្ញជាបណ្ឌិត អ្នកមានសទ្ធា មានចិត្តផុតស្រឡះ (ចាកសេចក្តីកំណាញ់) លុះឲ្យទានយ៉ាងនេះហើយ ក៏រមែងទៅកើតក្នុងទេវលោកជាសុខ ឥតមានទុក្ខ ។ (សុត្តន្ត. ៤៦ / ១១៤)

## ព្រះសូត្រនាំងអស់មានអត្ថ ៦ ប្រការ

១-សូចនតោ ព្រោះអត្ថថា សម្ដែងចេញនូវប្រយោជន៍ដល់សត្វដទៃដោយល្អ,

២-សុវុត្តតោ ព្រោះអត្ថថា សម្ដែងអនុលោមតាមអជ្ឈាស្រ័យ និងចរិតរបស់វេនេយ្យសត្វ ,

៣-សវនតោ ព្រោះអត្ថថា ឲ្យសម្រេចប្រយោជន៍ដល់សព្វសត្វ ដូចស្រូវសន្ទូងឲ្យសម្រេចផល ,

៤-សូទនតោ ព្រោះអត្ថថា ជាទីហូរចេញនូវផលដូចដោះមេគោដែលជាទីហូរចេញនៃទឹកដោះ ,

៥-សុត្តាណា ព្រោះអត្ថថា រក្សាទុកនូវប្រយោជន៍ដោយល្អដល់សត្វអ្នកប្រតិបត្តិ ។

៦-សុត្តសភាគតោ ព្រោះអត្ថថា ជាមគ្គាដ៏ត្រង់បើឲ្យសត្វអ្នកប្រតិបត្តិដើរឆ្ពោះទៅកាន់ស្ថានព្រះនិព្វាន ដូចជាខ្សែបន្ទាត់នៃជាងឈើ ។ (ចាកអដ្ឋកថា សមន្ត.)

## ពួក ៧

### ធម៌ ៧ ប្រការ ជាហេតុកើតធម្មវិចយសម្ពោជ្ឈង្គ

អបិច សត្ត ធម្មា ធម្មវិចយសម្ពោជ្ឈង្គស្ស ឧប្បាទាយ សំវត្តន្តិ ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែង ប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ គឺ

១-បរិបុច្ឆកតា ការសាកសួរ

២-វត្ថុវិសទកិរិយា ការធ្វើវត្ថុឲ្យស្អាតរៀបរយ

៣-ឥន្ទ្រិយសមត្តបដិបាទនា ការប្រមូលឥន្ទ្រិយឲ្យស្មើគ្នា

៤-ទុប្បញ្ញបុគ្គលបរិវជ្ជនា វៀរចាកបុគ្គលដែលអាប់ឥតបញ្ញា

៥-បញ្ញវន្តបុគ្គលសេវនា គប់រកបុគ្គលដែលមានបញ្ញា

៦-គម្ភីរញាណចរិយបច្ចវេក្ខណា ពិចារណាចំពោះបញ្ហាក្ខន្ធដ៏ជ្រៅ ដោយញាណចរិយា

៧-តទធិមុត្តតា ការបង្អោនចិត្តទៅក្នុង
ធម្មវិចយសម្ពោជ្ឈង្គនោះ ។

បណ្ដាធម៌ ៧ ប្រការនោះ សេចក្ដីជាអ្នកច្រើនទៅដោយការសាកសួរដែលអាស្រ័យអត្ថនៃខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គ អង្គមគ្គ អង្គឈាន សមថៈ និង វិបស្សនា ឈ្មោះថា ការសាកសួរ ។

ការធ្វើវត្ថុខាងក្នុងនិងខាងក្រៅឲ្យស្អាត ឈ្មោះថា ការធ្វើវត្ថុឲ្យស្អាត ។ ក៏វេលាណា ភិក្ខុមានសក់ ក្រចក និង រោមវែងពេក ឬរាងកាយស្មោកគ្រោក ប្រឡាក់ប្រឡូសដោយញើសនិងក្អែល វេលានោះ វត្ថុខាងក្នុង (គឺរាងកាយ) មិនស្អាតរៀបរយ មិនស្អាត ។ តែក្នុងវេលាណា ចីវរចាស់គ្រាំគ្រា ស្មោកគ្រោក ស្អុយឆ្អេះឆ្អាប ឬសេនាសនស៊ុបទ្រុប ក្នុងវេលានោះ វត្ថុខាងក្រៅមិនស្អាតរៀបរយ មិនស្អាត ។ ព្រោះដូច្នោះ ទើបគួរធ្វើវត្ថុខាងក្នុងឲ្យស្អាត ដោយកិច្ចមានការកោរសក់ជាដើម ដោយការធ្វើរាងកាយឲ្យស្រាល សប្បាយដោយកិច្ចមានការបន្ទោបង់ជម្រះមន្ទិល ឲ្យទូទៅទាំងខាងលើខាងក្រោមជាដើម និងដោយការខាត់ពណ៌ ងូតទឹក បន្ទោបង់ក្លិនស្អុយ ។ គប្បីធ្វើវត្ថុខាងក្រៅ

ឲ្យស្អាត ដោយកិច្ចមានការដេរ ជ្រលក់ គក់ចីវរ និងធ្វើការដុតបាត្រជាដើម ។ ព្រោះកាលវត្ថុខាងក្នុង និងខាងក្រៅនោះ មិនស្អាត កាលចិត្ត និងចេតសិកកើតឡើង សូម្បីបញ្ញា ក៏មិនផូរផង់ ដូចការភ្លឺស្វាងរបស់ប្រទីបដែលកើតឡើង ព្រោះអាស្រ័យ តួចង្កៀង ប្រេះ និងប្រេង ដែលមិនស្អាតបរិសុទ្ធដូច្នោះ តែកាលវត្ថុខាងក្នុងនិងខាងក្រៅស្អាត កាលចិត្ត និងចេតសិកកើតឡើង សូម្បីបញ្ញាក៏ផូរផង់ ដូចការភ្លឺស្វាងរបស់ដួងប្រទីបដែលកើតឡើង ព្រោះអាស្រ័យតួចង្កៀង ប្រេះ និងប្រេង ដែលស្អាតបរិសុទ្ធដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ការធ្វើវត្ថុឲ្យស្អាត រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ ដូច្នេះ ។

ការប្រមូលឥន្ទ្រិយ មានសទ្ធាជាដើមឲ្យស្មើគ្នា ឈ្មោះថា ការប្រមូលឥន្ទ្រិយឲ្យស្មើ ។ ព្រោះថា បើឥន្ទ្រិយ គឺសទ្ធារបស់លោកមានកម្លាំងខ្លាំងក្លា ឥន្ទ្រិយក្រៅនេះខ្សោយ អំពីនោះ ឥន្ទ្រិយគឺ វីរិយៈ ក៏មិនអាចធ្វើកិច្ច គឺការផ្គងចិត្តបាន ឥន្ទ្រិយ គឺសតិក៏មិនអាចធ្វើកិច្ច គឺការប្រោកដ ឥន្ទ្រិយ គឺសមាធិ ក៏មិនអាចធ្វើកិច្ច គឺសេចក្តីមិនរវើរវាយ ឥន្ទ្រិយ គឺបញ្ញាក៏មិនអាចធ្វើកិច្ច

គឺការឃើញបាន ព្រោះដូច្នោះ កាលមនសិការដល់ឥន្ទ្រិយ គឺសទ្ធានោះ ដោយការពិចារណាសភាវធម៌ ឬដោយហេតុណា ឥន្ទ្រិយ គឺសទ្ធាមានកម្លាំងខ្លាំងក្លា គប្បីថយចុះដោយការមិនមនសិការដោយហេតុនោះ ។ ក្នុងហេតុនេះ មានរឿងព្រះវក្កលិត្ថេរៈ ជាឧទាហរណ៍ ។ បើឥន្ទ្រិយ គឺវីរិយៈមានកម្លាំងខ្លាំងក្លា កាលជាដូច្នោះ ឥន្ទ្រិយ គឺសទ្ធាក៏មិនអាចធ្វើកិច្ច គឺការបង្អោនចិត្តជឿបាន ឥន្ទ្រិយក្រៅនេះ ក៏មិនអាចធ្វើកិច្ច គឺនាទីផ្សេងៗ របស់ខ្លួនបាន ព្រោះដូច្នោះ ទើបគួរបន្ថយឥន្ទ្រិយ គឺវីរិយៈនោះចុះ ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គជាដើម ។ សូម្បីក្នុងហេតុនោះ គប្បីសម្តែងរឿងព្រះសោណត្ថេរៈ ជាឧទាហរណ៍ ។ សូម្បីក្នុងឥន្ទ្រិយដ៏សេសក៏ដូចគ្នា កាលឥន្ទ្រិយយ៉ាងណាមួយមានកម្លាំងខ្លាំងក្លា ក៏គប្បីជ្រាបថា ឥន្ទ្រិយក្រៅនេះ ក៏មិនអាចក្នុងកិច្ច គឺនាទីរបស់ខ្លួនបាន ។ តែដោយចំពោះយ៉ាងក្រៃលែង ក្នុងរឿងឥន្ទ្រិយនេះ លោកសរសើរសទ្ធា និង បញ្ញា និង សមាធិនិងវីរិយៈ ត្រូវស្មើគ្នា ។ ព្រោះអ្នកមានសទ្ធាខ្លាំងក្លា តែមានបញ្ញាទន់ខ្សោយ មានសេចក្តីជ្រះថ្លាខ្លាំង រមែងជ្រះថ្លាទៅក្រៅរឿង ។ មានបញ្ញាខ្លាំងក្លា តែមានសទ្ធាខ្សោយ រមែងគប់រក

នូវពួកជនអែបអប ដូចរោគកើតព្រោះខុសថ្នាំ កែខែមិនបាន ដូច្នោះ ។ អ្នកមានបញ្ញាខ្លាំងក្លា ក៏ស្ទុះលោតឆ្វេឆ្វាទៅថា កុសល មានបានដោយត្រឹមតែចិត្តុប្បាទចិត្ត គិតមួយខណៈប៉ុណ្ណោះ ដូច្នេះ ហើយ ក៏មិនធ្វើបុណ្យ មានទានជាដើម រមែងកើតក្នុងនរក ។ ព្រោះឥន្ទ្រិយ គឺសទ្ធានិងបញ្ញា ទាំងពីរស្មើគ្នា ទើបជ្រះថ្លាក្នុងវត្ថុ គឺព្រះរតនត្រ័យតែម្យ៉ាង ។ តែសមាធិខ្លាំងក្លា វីរិយៈខ្សោយ កោសជ្ជៈ សេចក្ដីខ្ជិលច្រអូស រមែងគ្របសង្កត់បាន ព្រោះ សមាធិជាប៉ែកខាងកោសជ្ជៈ ។ វីរិយៈខ្លាំងក្លា សមាធិខ្សោយ ឧទ្ធច្ចៈ រមែងគ្របសង្កត់បាន ព្រោះវីរិយៈជាប៉ែកខាងឧទ្ធច្ចៈ ។ តែសមាធិដែលវីរិយៈចូលប្រកបទុក រមែងមិនធ្លាក់ទៅក្នុង កោសជ្ជៈ វីរិយៈដែលសមាធិ ចូលប្រកបទុកក៏មិនធ្លាក់ទៅក្នុង ឧទ្ធច្ចៈ ។ ព្រោះហេតុនោះ ទើបគួរធ្វើឥន្ទ្រិយពីរគូនោះ ឲ្យស្មើ ប៉ុនៗ គ្នា ។ ព្រោះថា អប្បនានឹងមានបាន ក៏ព្រោះឥន្ទ្រិយ ពីរគូស្មើគ្នា ។ ម្យ៉ាងទៀត សទ្ធាសូម្បីមានកម្លាំងខ្លាំងក្លា ក៏គួរ ដល់អ្នកចម្រើនសមាធិ ។ ព្រោះអ្នកចម្រើនសមាធិ ជឿមាំធ្លាក់ចុះ មាំយ៉ាងនេះ នឹងសម្រេចអប្បនាបាន ចំណែកក្នុងសមាធិ និង បញ្ញា ឯកគ្គតា សេចក្ដីដែលចិត្តមានអារម្មណ៍តែមួយ មាន

កម្លាំងខ្លាំងក្លា រមែងគួរដល់អ្នកចម្រើនសមាធិ ។ ព្រោះថា អ្នកចម្រើនសមាធិនោះ រមែងសម្រេចអប្បនាបាន ដោយឯកគ្គតាយ៉ាងនេះ ។ បញ្ញា មានកម្លាំងខ្លាំងក្លា រមែងគួរដល់អ្នកចម្រើនវិបស្សនា ។ ព្រោះថា អ្នកចម្រើនវិបស្សនានោះ រមែងដល់ការចាក់ធ្លុះរហូតដល់ត្រៃលក្ខណ៍ ដោយបញ្ញាយ៉ាងនេះ ។ តែអប្បនានឹងមានបាន ក៏ព្រោះសទ្ធា និងបញ្ញា ទាំងពីរស្មើគ្នាដោយពិត ។ ចំណែកសតិមានកម្លាំងហើយ រមែងគួរក្នុងទីទាំងពួង ។ ព្រោះថា សតិ រមែងរក្សាចិត្តមិនឲ្យធ្លាក់ទៅក្នុងឧទ្ធច្ចៈ ដោយអំណាចសទ្ធា វីរិយៈ បញ្ញា ដែលជាប៉ែកខាងឧទ្ធច្ចៈ មិនឲ្យធ្លាក់ទៅក្នុងកោសជ្ជៈ ព្រោះសមាធិជាប៉ែកខាងកោសជ្ជៈ ។ ព្រោះហេតុនោះ សតិនោះ ទើបចាំបាច់ត្រូវប្រាថ្នាក្នុងទីទាំងពួង ដូចការផ្សំរសដោយអំបិល ចាំបាច់ប្រាថ្នាក្នុងការផ្សំអាហារគ្រប់យ៉ាង និងដូចអមាត្យអ្នកជំនាញក្នុងរាជកិច្ចគ្រប់យ៉ាង ចាំបាច់ប្រាថ្នាក្នុងរាជកិច្ចគ្រប់យ៉ាង ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា សតិ ចាំបាច់ប្រាថ្នាក្នុងទីទាំងពួង ព្រោះហេតុអ្វី ? ព្រោះចិត្តមានសតិជាទីអាស្រ័យ និងសតិមានការរក្សា ជាទីប្រាកដ វៀរចាកសតិចេញហើយនឹងផ្គង និងគ្របសង្កត់ចិត្ត

មិនបានឡើយ ។

ការវៀរចាកបុគ្គលមានបញ្ញាទន់ខ្សោយ មិនមានបញ្ញាធ្លាក់ចុះក្នុងប្រភេទនៃធម៌មានខន្ធជាដើម ឲ្យឃ្លាតឆ្ងាយ ឈ្មោះថាការវៀរចាកបុគ្គលបញ្ញាទន់ខ្សោយ ។ ការគប់រកបុគ្គលប្រកបដោយបញ្ញាជុំវិញ ដឹងសេចក្ដីកើតនិងសេចក្ដីសាបសូន្យនៃសភាវធម៌ ដែលកំណត់ដោយលក្ខណៈ ៥០ គត់ ឈ្មោះថាគប់រកបុគ្គលអ្នកមានបញ្ញា ។ ការពិចារណាប្រភេទនៃបញ្ញាដ៏ជ្រាលជ្រៅ ដែលប្រព្រឹត្តទៅក្នុងសភាវធម៌ទាំងឡាយ មានខន្ធជាដើមដ៏ជ្រាលជ្រៅ ឈ្មោះថា ការពិចារណាដោយញាណចរិយាដ៏ជ្រាលជ្រៅ ។ សេចក្ដីជាអ្នកមានចិត្តបង្អោនទៅដើម្បីកំណត់ធម្មវិចយសម្ពោជ្ឈង្គ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ឈ្មោះថា សេចក្ដីបង្អោនចិត្តទៅ ក្នុងធម្មវិចយសម្ពោ-ជ្ឈង្គនោះ ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏ធម្មវិចយសម្ពោជ្ឈង្គនោះដែលកើតដោយអាការៈយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។

## ធម៌ ៧ ប្រការ ជាហេតុកើតបស្សទ្ធិសម្ពោជ្ឈង្គ

អបិច សត្ត ធម្មា បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧប្បាទាយ សំវត្តន្តិ *ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងជាហេតុនាំឲ្យកើតបស្សទ្ធិសម្ពោជ្ឈង្គ គឺ*

១-បណីតភោជនសេវនតា *សេពភោជនប្រណីត*

២-ឧតុសុខសេវនតា *សេពរដូវជាទីសប្បាយ*

៣-ឥរិយាបថសុខសេវនតា *សេពឥរិយាបថជាទីសប្បាយ*

៤-មជ្ឈត្តបយោគតា *ប្រកបខ្លួនតាំងនៅជាកណ្តាល*

៥-សារទ្ធកាយបុគ្គលបរិវជ្ជនតា *វៀរចាកបុគ្គលអ្នកមិនស្ងប់កាយ*

៦-បស្សទ្ធកាយបុគ្គលសេវនតា *សេពបុគ្គលអ្នកស្ងប់កាយ*

៧-តទធិមុត្តតា *បង្អោនចិត្តទៅដើម្បីតម្កល់បស្សទ្ធិសម្ពោជ្ឈង្គនោះ ។*

ពិតមែន អ្នកចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ កាលបរិភោគ ភោជនជាទីសប្បាយ ដែលប្រណីតថ្លៃថ្លាក្តី សេពរដូវជាទី សប្បាយ មិនថាជារដូវត្រជាក់ រដូវក្តៅ សេពឥរិយាបថ ជាទី សប្បាយ មិនថាជាឥរិយាបថឈរជាដើមក្តី រមែងកើតសេចក្តី ស្ងប់បាន ។ តែពាក្យនោះ លោកមិនបានពោលសំដៅដល់បុគ្គល ដែលជាមហាបុរស ដែលធន់ចំពោះរដូវ និងឥរិយាបថជាទី សប្បាយ ។ កាលអ្នកមានរដូវនិងឥរិយាបថដែលត្រូវគ្នា និងមិន ត្រូវគ្នាវៀររដូវ និងឥរិយាបថដែលមិនត្រូវគ្នាចេញហើយ សេព រដូវនិងឥរិយាបថដែលត្រូវគ្នា បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតឡើង បាន ។ ការពិចារណាដល់សេចក្តីដែលខ្លួន និងបុគ្គលដទៃមានកម្ម ជារបស់ខ្លួន ហៅថា ប្រកបខ្លួនឲ្យតាំងនៅជាកណ្តាល បស្សទ្ធិ-សម្ពោជ្ឈង្គ រមែងកើតបាន ដោយប្រកបខ្លួនជាកណ្តាលយ៉ាង នេះ ។ កាលវៀរចាកបុគ្គលអ្នកមានកាយមិនស្ងប់ ដូចគ្រាច់ទៅ បៀតបៀនសត្វដទៃ ដោយគ្រឿងប្រហារ មានដុំដី និងកំណាត់ ឈើជាដើមក្តី សេពបុគ្គលអ្នកមានកាយស្ងប់ សង្រួមដៃ ជើងក្តី មានចិត្តបង្អោនទោរទន់ទៅ ដើម្បីឲ្យកើតបស្សទ្ធិសម្ពោជ្ឈង្គ ក្នុង ឥរិយាបថមានឈរ អង្គុយ ជាដើមក្តី បស្សទ្ធិសម្ពោជ្ឈង្គ រមែង

កើតបាន ។ ភិក្ខុរមែងដឹងច្បាស់ថា ក៏បស្សទ្ធិសម្ពោជ្ឈង្គនោះ ដែលកើតហើយដោយអាការៈយ៉ាងនេះ រមែងចម្រើនបរិបូណ៌ ដោយអរហត្តមគ្គ ។ (ចាកអដ្ឋកថា សុមង្គលវិលាសិនី)

## ព្រះអភិធម្ម ៧ គម្ពីរ

១-គម្ពីរធម្មសង្គណី ចែកជា ៤ គឺ

១. ចិត្តវិភត្តិកណ្ឌ ចែកចិត្តចេតសិកជាដើម, ២. រូបវិភត្តិកណ្ឌ ចែករូបជាដើម, និក្ខេបរាសិកណ្ឌ ចែកធម៌ក្នុងបទមាតិកានោះ, ៤. អត្ថុទ្ធារកណ្ឌ ចែលអត្ថជាដើម ។

២-គម្ពីរវិភង្គ ចែកវិភង្គ ១៨ ប្រការ មានខន្ធវិភង្គជាដើម ។

៣-គម្ពីរធាតុកថា ពោលអំពីការសង្គ្រោះធម៌ដែលចាត់ជាកង ធាតុផ្សេង ៗ ជាដើម ។

៤-គម្ពីរបុគ្គលប្បញ្ញត្តិ ពោលអំពីបញ្ញត្ត ៦ ប្រការ មានខន្ធប្បញ្ញត្តិជាដើម ។

៥-គម្ពីរកថាវត្ថុ ចែកព្រះសូត្រជាចំណែកនៃ

*សកវាទី និងបរវាទីជាដើម ។*

*៦-គម្ពីរយមកៈ ចែកធម៌ជាគូ ៗ ដូចធម៌ជាចំណែកកុសល និងមូលនៃធម៌ ជាចំណែកកុសលជាដើម ។*

*៧-គម្ពីរមហាបដ្ឋាន ចែកធម៌ប្រកបដោយហេតុ និងបច្ច័យជាដើម ។*

*ព្រះអភិធម្មទាំង ៧ គម្ពីរនេះ ចែកជាធម្មខន្ធ មាន ៤២.០០០ ព្រះធម្មខន្ធ ។ (ចាកអដ្ឋកថា សមន្ត.)*

## អបរិហានិយធម៌

*១-ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រជុំគ្នារឿយៗ ប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមនោះ) ។*

*២-ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងព្រមគ្នាប្រជុំ ព្រមព្រៀងគ្នាលើកទីប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចរបស់សង្ឃ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់*

កាលត្រឹមណោះ) ។

៣-ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនបញ្ញត្តសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ មិនដកសិក្ខាបទដែលតថាគតបញ្ញត្តហើយ កាន់តាម ប្រព្រឹត្តតាមសិក្ខាបទដែលតថាគតបញ្ញត្តហើយ យ៉ាងណា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

៤-ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងធ្វើសក្ការៈ គោរពរាប់អាន បូជាពួកភិក្ខុជាថេរៈអ្នកដឹងរាត្រី (ច្រើន) បួសយូរ ជាបិតានៃសង្ឃ ជាបរិនាយករបស់សង្ឃ (ជាអ្នកណែនាំសង្ឃ) ទាំងរាប់អានជឿពាក្យដែលគួរស្តាប់ របស់ភិក្ខុជាថេរៈទាំងនោះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ ។

៥-ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនលុះក្នុងអំណាចតណ្ហា ជាធម្មជាតិនាំសត្វទៅក្នុងភពថ្មីទៀត ដែលកើតឡើងហើយអស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ។

៦-ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមានសេចក្តីប្រាថ្នាក្នុងសេនាសនៈទាំងឡាយ ដែលតាំងនៅក្នុងព្រៃ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ។

៧-ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រុងស្មារតី ក្នុងខ្លួនថា ធ្វើម្តេចហ្ន៎ ពួកសព្រហ្មចារី មានសីលធម៌ជាទីស្រឡាញ់ ដែលមិនទាន់មកដល់ ក៏សូមឲ្យនិមន្តមក ពួកសព្រហ្មចារី មានសីលធម៌ជាទីស្រឡាញ់ ដែលមកដល់ហើយ សូមឲ្យនៅជាសុខដូច្នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

ម្នាលភិក្ខុទាំងឡាយ បើអបរិហាណិយធម៌ទាំង ៧ នេះ នឹងឋិតនៅក្នុងភិក្ខុទាំងឡាយ ឬថា ភិក្ខុនឹងប្រតិបត្តិក្នុងអបរិ-ហាណិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ) ។

## ពលៈ ៧ យ៉ាង

១-សទ្ធាពលំ កម្លាំងគឺសទ្ធា

២-វីរិយពលំ កម្លាំងគឺវីរិយៈ

៣-ហិរិពលំ កម្លាំងគឺហិរិៈ

៤-ឱត្តប្បពលំ កម្លាំងគឺឱត្តប្បៈ

៥-សតិពលំ កម្លាំងគឺសតិ

៦-សមាធិពលំ កម្លាំងគឺសមាធិ

៧-បញ្ញាពលំ កម្លាំងគឺបញ្ញា ។

### សេចក្តីអធិប្បាយ

*សទ្ធាពលៈ : ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកមានសទ្ធា រមែងជឿចំពោះពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ។បេ។ ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ ទ្រង់កំចាត់បង់នូវត្រៃកព ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា* ***សទ្ធាពលៈ*** *។*

វីរិយពលៈ ៖ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ប្រារព្ធនូវសេចក្ដីព្យាយាម ដើម្បីលះនូវអកុសលធម៌ទាំងឡាយ ដើម្បីបំពេញនូវកុសលធម៌ទាំងឡាយ ជាអ្នកមានកម្លាំងព្យាយាម ប្រឹងប្រែងមុតមាំ មិនដាក់ធុរៈក្នុងកុសលធម៌ទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **វីរិយពលៈ** ។

ហិរិពលៈ ៖ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្ដីអៀនខ្មាស រមែងអៀនខ្មាសកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងអៀនខ្មាសនូវការជួបប្រសព្វនូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **ហិរិពលៈ** ។

ឱត្តប្បពលៈ ៖ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្ដីតក់ស្លុត រមែងតក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងតក់ស្លុតនូវការជួបប្រសព្វនូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **ឱត្តប្បពលៈ** ។

សតិពលៈ : ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសតិ ប្រកបដោយធម៌ និងភាពជាអ្នកមានបញ្ញាចាស់ក្លាដ៏ឧត្តម ជាអ្នកនឹករលឹកចាំបាននូវអំពើដែលខ្លួនធ្វើយូរហើយផង នូវសំដីដែលខ្លួននិយាយយូរហើយផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សតិពលៈ** ។

សមាធិពលៈ អរិយសាវកក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលដល់នូវចតុត្ថជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមាធិពលៈ ។

បញ្ញាពលៈ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា រមែងប្រកបដោយបញ្ញា ជាគ្រឿងដឹងច្បាស់នូវការកើតឡើង និងសូន្យទៅ (នៃខន្ធ៥) ជាបញ្ញាប្រសើរ មោះមុតជាគ្រឿងដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បញ្ញាពលៈ ។

(ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះគាថាទាំងនេះថា)

សទ្ធាពលៈ វីរិយពលៈ ហិរិពលៈ ឱត្តប្បពលៈ សតិពលៈ សមាធិពលៈ បញ្ញាពលៈ ជាគំរប់ ៧ ។ ភិក្ខុជា

*បណ្ឌិតមានកម្លាំងដោយពលៈទាំងនោះ រមែងរស់នៅស្រួល ពិចារណាធម៌ដោយឧបាយ ហើយច្បាស់នូវអត្ថដោយបញ្ញា ការរួចស្រឡះ (ចាកអារម្មណ៍) នៃចិត្ត (របស់ភិក្ខុនោះ) ដូចជាការរលត់នៃប្រទីប ។* *(សុត្តន្ត. ៤៧ / ៥)*

## ទ្រព្យមាន ៧ យ៉ាង

| | |
|---|---|
| ១-សទ្ធាធនំ | *ទ្រព្យគឺសទ្ធា* |
| ២-សីលធនំ | *ទ្រព្យគឺសីល* |
| ៣-ហិរិធនំ | *ទ្រព្យគឺហិរិ* |
| ៤-ឱត្តប្បធនំ | *ទ្រព្យគឺឱត្តប្ប* |
| ៥-សុតធនំ | *ទ្រព្យគឺសុតៈ* |
| ៦-ចាគធនំ | *ទ្រព្យគឺចាគៈ* |
| ៧-បញ្ញាធនំ | *ទ្រព្យគឺបញ្ញា ។* |

## សេចក្ដីអធិប្បាយ

*<u>សទ្ធាធនៈ</u> ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសទ្ធា រមែងជឿចំពោះពោធិញ្ញាណ*

របស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្ត-សម្មាសម្ពុទ្ធ ។បេ។ ជាសាស្ដានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ ទ្រង់កំចាត់បង់នូវត្រៃភព ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សទ្ធាធនៈ** ។

<u>សីលធនៈ</u> ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកវៀរចាកបាណាតិបាត ។ល។ ជាអ្នកវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺសីល ។

<u>ហិរិធនៈ</u> ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្ដីអៀនខ្មាស រមែងអៀនខ្មាសចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងខ្មាសនូវការជួបប្រសព្វនូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **ទ្រព្យគឺហិរិ** ។

<u>ឱត្តប្បធនៈ</u> ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានសេចក្ដីតក់ស្លុត រមែងតក់ស្លុតចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត រមែងតក់ស្លុតចំពោះការជួបប្រសព្វនូវអកុសលធម៌ដ៏លាមក ។ ម្នាលភិក្ខុ

ទាំងឡាយ នេះហៅថា ទ្រព្យគឺឱត្តប្បៈ ។

សុតធនៈ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាពហុស្សូត ទ្រទ្រង់នូវចំណេះ សន្សំទុកនូវចំណេះ ធម៌ទាំងឡាយណា ពីរោះបទដើម ពីរោះបទកណ្តាល និងពីរោះបទចុង រមែងប្រកាសព្រហ្មចរិយធម៌ ប្រកបដោយអត្ថនិងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូរណ៍ទាំងអស់ ធម៌ទាំងឡាយនោះ ដែលអរិយសាវក មានសភាពដូច្នោះ បានស្តាប់មកច្រើន បានទ្រទ្រង់ទុកបានចាំស្ទាត់រត់មាត់ បានចូលចិត្តច្បាស់លាស់ បានយល់ច្បាស់ដោយទិដ្ឋិ គឺបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទ្រព្យគឺសុតៈ ។

ចាគធនៈ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ បានបរិច្ចាគរួចហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះ ជាអ្នកគួរសូមត្រេកអរក្នុងការចែកទាន រមែងនៅគ្រប់គ្រងផ្ទះ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **ទ្រព្យគឺចាគៈ** ។

បញ្ញាធនៈ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកមានបញ្ញា ។បេ។ ជាគ្រឿងដល់នូវការ

*អស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា* ***ទ្រព្យគឺបញ្ញា*** *។*

*ទ្រព្យគឺសទ្ធា ទ្រព្យគឺសីល ទ្រព្យគឺហិរិ ទ្រព្យគឺឱត្តប្បៈ ទ្រព្យគឺសុតៈ ទ្រព្យគឺចាគៈ ទ្រព្យគឺបញ្ញា ជាគំរប់ ៧ បុគ្គលណា ទោះស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលនោះថា ជាអ្នកមិនទ័លក្រ ការរស់នៅរបស់បុគ្គលនោះ មិនសាបសូន្យឡើយ ។ ហេតុដូច្នេះ អ្នកប្រាជ្ញកាលរលឹកនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គប្បីប្រកបរឿយ ៗ នូវសទ្ធា សីល សេចក្តីជ្រះថ្លា និងការឃើញនូវធម៌ ។*

*(សុត្តន្តបិដក ៤៧ / ១០)*

## បុគ្គលប្រៀបដូចអ្នកមុជទឹក

*ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រៀបដូចអ្នកមុជទឹកក្នុងលោកនេះ មាន ៧ ពួក ។ ៧ ពួកតើអ្វីខ្លះ ។*

១–៩ឆ, ភិក្ខវេ, ឯកច្ចោ បុគ្គលោ សកឹ

និមុគ្គោ និមុគ្គោវ ហោតិ; *ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមុជទៅហើយ ក៏មុជបាត់ទៅតែម្តង ;*

២-ឥធ បន, ភិក្ខវេ, ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា និមុជ្ជតិ ; *ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយមុជចុះទៅវិញ ;*

៣-ឥធ បន, ភិក្ខវេ, ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា ឋិតោ ហោតិ ; *ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយឈរ;*

៤-ឥធ បន, ភិក្ខវេ, ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ ; *ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយក្រឡេករមិលមើល ;*

៥-ឥធ បន, ភិក្ខវេ, ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា បតរតិ ; *ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយហែលឆ្លងទៅ ;*

៦-ឥធ បន, ភិក្ខវេ, ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា បតិគាធប្បត្តោ ហោតិ ; *ម្នាលភិក្ខុទាំងឡាយ*

*បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងហើយបានដល់នូវទីពឹង ហើយឈរនៅ;*

៧-៩៨ បន, ភិក្ខវេ, ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា តិណ្ណោ ហោតិ ថារង្គតោ ថលេ តិដ្ឋតិ ព្រាហ្មណោ ។ *ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះជាព្រាហ្មណ៍ ក្នុងលោកនេះ ងើបឡើងហើយឆ្លងទៅដល់ត្រើយ ហើយឈរ នៅលើគោក ។*

*ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលជាអ្នកមុជទៅហើយ ក៏មុជ បាត់ទៅតែម្តង តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកប្រកបដោយអកុសលធម៌ខ្មៅសុទ្ធ ។ ម្នាល ភិក្ខុទាំងឡាយ បុគ្គលជាអ្នកមុជទៅហើយ ក៏មុជបាត់ទៅតែម្តង យ៉ាងនេះឯង ។*

*ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលងើបឡើងហើយ មុជចុះ ទៅវិញ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោក នេះ រមែងងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះ កុសលធម៌ទាំងឡាយ ជាការល្អ សេចក្តីខ្មាសបាប ជាការល្អ សេចក្តីតក់ស្លុតចំពោះបាប ជាការល្អ សេចក្តីព្យាយាម ជាការល្អ*

ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ សទ្ធារបស់បុគ្គលនោះ មិនតាំងនៅមាំ មិនចំរើនឡើង រមែងសាបសូន្យទៅវិញ ។ ហិរិ... ឱត្តប្បៈ... វិរិយៈ បញ្ញារបស់បុគ្គលនោះ មិនតាំងនៅមាំ មិនចំរើនឡើង រមែងសាបសូន្យទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបឡើងហើយ មុជចុះទៅវិញយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ងើបឡើងហើយឈរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ងើបឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ សេចក្តីខ្មាសបាប ជាការល្អ សេចក្តីតក់ស្លុតចំពោះបាប ជាការល្អ សេចក្តីព្យាយាម ជាការល្អ ការដឹងច្បាស់ក្នុងកុសល-ធម៌ទាំងឡាយ ជាការល្អ ។ សទ្ធារបស់បុគ្គលនោះ ក៏មិនសាបសូន្យទៅ មិនចំរើនឡើង រមែងតាំងនៅដដែល ។ ហិរិ... ឱត្តប្បៈ... វិរិយៈ បញ្ញារបស់បុគ្គលនោះ ក៏មិនសាបសូន្យទៅ មិនចំរើនឡើង រមែងតាំងនៅដដែល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកងើបឡើងហើយឈរនៅយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបឡើងហើយក្រឡេករមិលមើល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោក

នេះ កើតឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសល-ធម៌ទាំងឡាយ ជាការល្អ ។បេ។ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ បុគ្គលនោះ ជាសោតាបន្ន ព្រោះអស់សញ្ញោជនៈ ៣ យ៉ាង ជាអ្នកមានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិប្រព្រឹត្តទៅក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកើតផ្លាលហើយក្រឡេករមិលមើល យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលកើតផ្លាលហើយហែលឆ្លងទៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ កើតឡើងដោយសេចក្តីយល់ថា សេចក្តីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ ។បេ។ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ បុគ្គលនោះ ជាសកទាគាមី ព្រោះអស់សញ្ញោជនៈ ៣ យ៉ាង ព្រោះរាគៈទោសៈមោហៈ ក៏ស្រាលស្តើង វិលមកកាន់លោកនេះ អស់វារៈតែម្តង ហើយធ្វើនូវទីបំផុតនៃទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកើតផ្លាលហើយ ឆ្លងទៅយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងោលហើយបានដល់នូវទីពឹង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ងើបឡើងដោយសេចក្ដីយល់ថា សេចក្ដីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ ។បេ។ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ បុគ្គលនោះ ជាឱបបាតិកៈ ព្រោះអស់សញ្ញោជនៈជាចំណែកខាងក្រោម ៥ យ៉ាង ហើយបរិនិព្វានក្នុងលោកនោះ មិនបានត្រឡប់មកចាកលោកនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលងើបផ្ងោលហើយដល់នៅទីពឹង យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាព្រាហ្មណ៍ ងើបផ្ងោលហើយឆ្លងទៅដល់ត្រើយនាយ ហើយឈរនៅលើគោក តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះជាព្រាហ្មណ៍ ក្នុងលោកនេះ ងើបឡើងដោយសេចក្ដីយល់ថា សេចក្ដីជឿចំពោះកុសលធម៌ទាំងឡាយ ជាការល្អ ។បេ។ ការដឹងច្បាស់ក្នុងកុសលធម៌ទាំងឡាយ ជាការល្អ ។ បុគ្គលនោះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួន ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាព្រាហ្មណ៍ ងើបផ្ងោលហើយ ឆ្លងទៅដល់

ត្រើយខាងនាយ ហើយឈរនៅលើគោក យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ នេះឯងបុគ្គល ៧ ពួក ប្រៀបដូចអ្នកមុជទឹក រមែងមានប្រាកដក្នុងលោក ។ (បិដក ៤៧,១៧)

## ធម៌៧យ៉ាងរមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ឧបាសក

១-ភិក្ខុទស្សនំ ហាបេតិ ឧបាសកញ៉ាំងការឃើញនូវភិក្ខុឲ្យសាបសូន្យ

២-សទ្ធម្មស្សវនំ បមជ្ជតិ ប្រហែសនឹងការស្តាប់ព្រះសទ្ធម្ម

៣-អធិសីលេ ន សិក្ខតិ មិនសិក្សាក្នុងអធិសីល

៤-អប្បសាទពហុលោ ហោតិ ភិក្ខូសុ ថេរេសុ ចេវ នវេសុ ច មជ្ឈិមេសុ ច ជាអ្នកមិនមានសេចក្តីជ្រះថ្លាច្រើនក្នុងពួកភិក្ខុចាស់ ថ្មី កណ្តាល

៥-ឧបារម្ភចិត្តោ ធម្មំ សុណាតិ រន្ធគវេសី

*ជាអ្នកមានចិត្តរិះគន់ស្វែងរកទោសស្តាប់ធម៌*

៦-ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ *ស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅសាសនា*

៧-តត្ថ ច បុព្វការំ ករោតិ *ធ្វើបុព្វការៈក្នុងទក្ខិណេយ្យបុគ្គលខាងក្រៅសាសនា ។*

## ធម៌ ៧ យ៉ាងរមែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ឧបាសក

១-ភិក្ខុទស្សនំ ន ហាបេតិ *មិនញុំាងការឃើញភិក្ខុ ឲ្យសាបសូន្យ*

២-សទ្ធម្មស្សវនំ នប្បមជ្ជតិ *មិនប្រហែសនឹងការស្តាប់ព្រះសទ្ធម្ម*

៣-អធិសីលេ សិក្ខតិ *សិក្សាក្នុងអធិសីល*

៤-បសាទពហុលោ ហោតិ ភិក្ខូសុ ថេរេសុ ចេវ នវេសុ ច មជ្ឈិមេសុ ច *ជាអ្នកមានសេចក្តីជ្រះថ្លាច្រើន ក្នុងពួកភិក្ខុចាស់ ថ្មី កណ្តាល*

៥-អនុចារម្ភចិត្តោ ធម្មំ សុណាតិ ន រន្ធគវេសី ជាអ្នកមានចិត្តមិនរិះគន់ មិនស្វែងរកទោសស្តាប់ធម៌

៦-ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ មិនស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅសាសនានេះ

៧-ឥធ ច បុព្វការំ ករោតិ ធ្វើបុព្វការៈក្នុងទក្ខិណេយ្យបុគ្គលក្នុងសាសនានេះ ។

☞ ឧបាសកណា ញ៉ាំងការឃើញនូវពួកភិក្ខុ ដែលមានខ្លួនចម្រើនហើយ ឲ្យសាបសូន្យ ១ ប្រហែសនឹងការស្តាប់នូវអរិយធម៌ទាំងឡាយ ១ មិនសិក្សាក្នុងអធិសីល ១ មានសេចក្តីមិនជ្រះថ្លា ក្នុងពួកភិក្ខុចម្រើនឡើងដោយក្រៃលែង ១ មានចិត្តរិះគន់ ប្រាថ្នាស្តាប់ព្រះសទ្ធម្ម ១ ស្វែងរកទក្ខិណេយ្យ-បុគ្គលដទៃ ខាងក្រៅសាសនានេះ ១ ឧបាសក ធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គលនោះ ១ ឧបាសក កាលសេពនូវអបរិហានិយធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយប្រពៃ រមែងសាបសូន្យចាក

ព្រះសទ្ធម្ម ។

ឧបាសកណា មិនញុំាងការឃើញនូវពួកភិក្ខុ ដែលមានខ្លួនចម្រើនហើយ ឲ្យសាបសូន្យ ១ មិនប្រហែសនឹងការស្ដាប់នូវអរិយធម៌ទាំងឡាយ ១ សិក្សាក្នុងអធិសីល ១ សេចក្ដីជ្រះថ្លា ក្នុងពួកភិក្ខុរបស់ឧបាសកនោះ ចម្រើនឡើងដោយក្រៃលែង ១ មិនមានចិត្តរិះគន់ស្ដាប់នូវព្រះសទ្ធម្ម ១ មិនស្វែងរកទក្ខិណេយ្យបុគ្គលដទៃ ខាងក្រៅសាសនានេះ ១ ឧបាសកតែងធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គល ក្នុងសាសនានេះ ១ ឧបាសក កាលសេពនូវអបរិហានិយធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងហើយដោយប្រពៃ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

## សម្បត្តិរបស់ឧបាសកមាន ៧ យ៉ាង

១-ភិក្ខុទស្សនំ ន ហាបេតិ ឧបាសកមិនញុំាងការឃើញនូវពួកភិក្ខុឲ្យសាបសូន្យ

២-សទ្ធម្មស្សវនំ នប្បមជ្ជតិ មិនប្រហែសនឹងការស្ដាប់នូវព្រះសទ្ធម្ម

៣–អធិសីលេ សិក្ខតិ *សិក្សាក្នុងអធិសីល*

៤–បសាទពហុលោ ហោតិ ភិក្ខូសុ ថេរេសុ ចេវ នវេសុ ច មជ្ឈិមេសុ ច *ជាអ្នកមានសេចក្ដីជ្រះថ្លាច្រើន ក្នុងពួកភិក្ខុចាស់ ថ្មី កណ្ដាល*

៥–អនុបារម្ភចិត្តោ ធម្មំ សុណាតិ ន រន្ធគវេសី *មិនមានចិត្តរិះគន់មិនស្វែងរកទោសស្ដាប់ធម៌*

៦–ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ *មិនស្វែងរកទក្ខិណេយ្យបុគ្គលដទៃ ខាងក្រៅ សាសនានេះ*

៧–ឥធ ច បុព្វការំ ករោតិ *ធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គលក្នុងសាសនានេះ ។*

*ឧបាសកណា ញុំាងការឃើញនូវពួកភិក្ខុ ដែលមានខ្លួនចម្រើនហើយ ឲ្យសាបសូន្យ ១ ប្រហែសក្នុងការស្ដាប់នូវអរិយធម៌ទាំងឡាយ ១ មិនសិក្សាក្នុងអធិសីល ១ មានសេចក្ដីមិនជ្រះថ្លាក្នុងពួកភិក្ខុ ចម្រើនឡើងដោយក្រៃលែង ១ ជាអ្នកមានចិត្តរិះគន់ ប្រាថ្នាស្ដាប់នូវព្រះសទ្ធម្ម ១*

ស្វែងរកទក្ខិណេយ្យបុគ្គលដទៃ ខាងក្រៅសាសនានេះ ១ ឧបាសកធ្វើបុព្វការៈចំពោះទក្ខិណេយ្យបុគ្គល ខាងក្រៅសាសនានេះ ១ ឧបាសកកាលសេព នូវអបរិហានិយធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ រមែងសាបសូន្យចាកព្រះសទ្ធម្ម ។

ឧបាសកណា មិនញុំាងការឃើញនូវពួកភិក្ខុដែលមានខ្លួនចម្រើនហើយឲ្យសាបសូន្យ ១ មិនប្រហែសចំពោះការស្តាប់នូវអរិយធម៌ទាំងឡាយ ១ សិក្សាក្នុងអធិសីល ១ សេចក្តីជ្រះថ្លាក្នុងពួកភិក្ខុរបស់ឧបាសកនោះ ចម្រើនដោយក្រៃលែង ១ មិនមានចិត្តរិះគន់ប្រាថ្នាស្តាប់នូវព្រះសទ្ធម្ម ១ មិនស្វែងរកទក្ខិណេយ្យបុគ្គលដទៃខាងក្រៅសាសនានេះ ១ ឧបាសកធ្វើបុព្វការៈចំពោះ ទក្ខិណេយ្យបុគ្គលក្នុងសាសនានេះ ១ ឧបាសកកាលសេពនូវអបរិហានិយធម៌ទាំង ៧ យ៉ាងនេះឯង ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ រមែងមិនសាបសូន្យចាកព្រះសទ្ធម្មឡើយ ។

# ភ្លើង ៧ ប្រការ

១-រាគគ្គិ *ភ្លើងគឺរាគៈ*

២-ទោសគ្គិ *ភ្លើងគឺទោសៈ*

៣-មោហគ្គិ *ភ្លើងគឺមោហៈ*

៤-អាហុនេយ្យគ្គិ *ភ្លើងគឺអាហុណេយ្យបុគ្គល*(១)

៥-គហបតគ្គិ *ភ្លើងគឺបុគ្គលជាម្ចាស់ផ្ទះ*(២)

៦-ទក្ខិណេយ្យគ្គិ *ភ្លើងគឺទក្ខិណេយ្យបុគ្គល*(៣)

៧-កដ្ឋគ្គិ *ភ្លើងឧស ។ (បិដក ៤៧, ៧៦)*

---

១-បុគ្គលអ្នកគួរទទួលនូវគ្រឿងសក្ការបូជា ហៅថា អាហុណេយ្យបុគ្គល ក្នុងទីនេះ សំដៅយកមាតាបិតា ព្រោះលោកមានឧបការៈច្រើនដល់បុត្តធីតា សមគួរជាអ្នកទទួលនូវគ្រឿងគំនាប់គាប់គួររបស់បុត្តធីតាបាន ត្រង់ដែលទុកលោកថាដូចភ្លើង ព្រោះថា បើបុត្តធីតាប្រតិបត្តិឆ្គាំឆ្គង នឹងមាតាបិតា រមែងទៅកើតក្នុងអបាយ មាននរកជាដើម ។

២-បុគ្គលជាម្ចាស់ផ្ទះ ក្នុងទីនេះ បានដល់ **ស្វាមី** ព្រោះជាមនុស្សមានឧបការៈច្រើនដល់មាតុគ្រាម ដោយការប្រគល់ឱ្យនូវវត្ថុផ្សេងៗ មានសំពត់និងគ្រឿងអលង្ការជាដើម ត្រង់ដែលទុកស្វាមីថា ដូចជាភ្លើង ព្រោះថា បើមាតុគ្រាមប្រព្រឹត្តកន្លងចិត្តប្តី តែងទៅកើតក្នុងអបាយ មាននរកជាដើម ។ តែន័យខ្លះ ពួកអន្ទោជ មានកូន និង -

## សញ្ញា ៧ ប្រការ

*ម្នាលភិក្ខុទាំងឡាយ សញ្ញា ៧ ប្រការនេះ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។*

*សញ្ញា ៧ ប្រការ តើដូចម្តេច ។*

១-អសុភសញ្ញា *សេចក្តីសម្គាល់ថាមិនស្អាត,*

២-មរណសញ្ញា *សេចក្តីសម្គាល់ក្នុងការស្លាប់,*

៣-អាហារេ បដិក្កូលសញ្ញា *សេចក្តីសម្គាល់ក្នុងអាហារថា ជារបស់គួរខ្ពើម,*

៤-សព្វលោកេ អនភិរតសញ្ញា *សេចក្តីសម្គាល់ក្នុងលោក ទាំងពួងថា មិនគួរត្រេកអរ,*

៥-អនិច្ចសញ្ញា *សេចក្តីសម្គាល់ថា មិនទៀង,*

---

ប្រពន្ធជាដើម ក៏ហៅថា ភ្លើង គឺបុគ្គលជាម្ចាស់ផ្ទះដែរ ។ ៣-បុគ្គលគួរទទួលទក្ខិណាទាន ហៅថា ទក្ខិណេយ្យបុគ្គល បានដល់ ភិក្ខុសង្ឃ ។ អដ្ឋកថា ។

៦-អនិច្ចេ ទុក្ខសញ្ញា សេចក្ដីសម្គាល់ថាជាទុក្ខក្នុងការមិនទៀង,

៧-ទុក្ខេ អនត្តសញ្ញា សេចក្ដីសម្គាល់ថាមិនមែនខ្លួនក្នុងរបស់ជាទុក្ខ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ អសុភសញ្ញា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងមានផលច្រើន អានិសង្សច្រើន ជាគុណឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ដូច្នេះនេះឯង តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយៗ ហើយ ចិត្តរមែងរួញខ្ញូរ បែរចេញ ចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬ ទងសរសៃ ដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញ ខ្ញូរ ងរឡើង មិនលាវិញឡើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្ញូរ បែរចេញចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយ សេចក្ដី

ព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ក៏មានឧបមេយ្យយ៉ាងនោះឯង, ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយៗ ហើយ ចិត្តនៅតែត្រាច់ទៅរកការជួបប្រសព្វដោយមេថុនធម្ម ឬការមិនខ្ពើមរអើម នៅតែតាំងឡើងបាន ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អសុភ-សញ្ញា អញចម្រើនមិនទាន់បានទេ កាលខាងដើមនិងកាលខាងចុង របស់អញមិនទាន់ប្លែកគ្នាទេ ផលនៃការចម្រើនរបស់អញមិនទាន់ចម្រេចទេ ភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអសុភសញ្ញានោះ ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយតែបើភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយៗ ហើយ ចិត្តក៏រួញ ខ្វរបែរចេញចាកការជួបប្រសព្វដោយមេថុនធម្ម មិនលាវិញឡើយសេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី ក៏តាំងឡើង ម្នាលភិក្ខុទាំងឡាយ ដំណើរនុ៎ះ ភិក្ខុគប្បីដឹងថា អសុភសញ្ញា អញចម្រើនបានហើយ កាលខាងដើមនិងកាលខាងចុង របស់អញមានសេចក្តីប្លែកគ្នា ផលនៃការចម្រើន អញបានចម្រេចហើយភិក្ខុក្នុងសាសនានេះ រមែងជាអ្នកដឹងច្បាស់ក្នុងអសុភសញ្ញានោះដោយប្រការដូច្នេះ ។ ក៏ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ

អសុភសញ្ញា ដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ មានផលច្រើន អានិសង្សច្រើន ឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុតដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។

...ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំមរណៈសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្ញួរ បែរចេញចាកការត្រេកអរក្នុងជីវិត មិនលាតិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ... ។

...ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំអាហារេបដិកូលសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្ញួរ បែរចេញចាករសតណ្ហា (ចំណង់ក្នុងរស) មិនលាតិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ... ។

...ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំសព្វលោកេ អនភិរតសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្ញួរ បែរចេញចាកលោកសន្និវាស មិនលាតិញឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ... ។

*...ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំអនិច្ចសញ្ញារឿយៗ ហើយ ចិត្តរមែងរួញ ខ្ចូរ បែរចេញចាកលាភសក្ការៈ និងសេចក្តីសរសើរ មិនលាវិញឡើយ សេចក្តីព្រងើយកន្តើយក្តី ការខ្ពើមរអើមក្តី រមែងតាំងឡើង ... ។*

*...ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំ* ***អនិច្ចេទុក្ខសញ្ញា*** *រឿយៗ ហើយ សេចក្តីសម្គាល់ ក្នុងការខ្ជិលច្រអូសទម្រន់ ប្រហែសធ្វេស មិនព្យាយាម មិនពិចារណា ថាជារបស់គួរខ្លាចដ៏ពន្លឹក រមែងកើតឡើង ហាក់ដូចពេជ្ឈឃាដ ដែលងាជាវដូច្នោះឯង ... ។*

*...ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំ* ***ទុក្ខេអនត្តសញ្ញា*** *រឿយៗ ហើយ ចិត្តក៏រមែងប្រាស់ចាកអហង្ការមមង្ការ និងមានះ*[១] *ក្នុងកាយដែលមានវិញ្ញាណនេះផង ក្នុង*

---

១-ការប្រកាន់ គឺតណ្ហាថា **ឯតំ មម** <u>ន៉ុះរបស់អញ</u> ព្រោះភាវៈជា **មមង្ការ** ។ ការប្រកាន់គឺមានះថា **ឯសោហមស្មិ** <u>ន៉ុះជាអញ</u> ព្រោះភាវៈជា **អហង្ការ** ។ ការប្រកាន់គឺទិដ្ឋិថា **ឯសោ មេ អត្តា** <u>ន៉ុះជាខ្លួនរបស់អញ</u> ព្រោះភាវៈប្រកាន់វិបល្លាសថា ជាតួខ្លួន ។ ក៏ក្នុងបណ្តាការប្រកាន់ទាំង ៣ នេះ ការប្រកាន់គឺតណ្ហា គប្បីជ្រាបដោយអំណាចតណ្ហាវិចរិត ១០៨ ប្រការ, ប្រកាន់គឺមានះ គប្បីជ្រាបដោយអំណាចមានះ ៩ យ៉ាង, ការប្រកាន់គឺទិដ្ឋិ គប្បីជ្រាបដោយអំណាចទិដ្ឋិ ៦២ ។

និមិត្តទាំងពួងទាំងពួងខាងក្រៅផង ជាចិត្តកន្ទងបង់នូវវិធា ៣ ប្រការស្ងប់រម្ងាប់ (ចាកសត្រូវគឺកិលេស) ផុតស្រឡះដោយប្រពៃ (ចាកមិច្ឆាវិមុត្តិ) ... ។ (បិដក ៤៧, ៨៦-១០០)

## មេថុនសំយោគ ៧

ជាណុស្សោណិព្រាហ្មណ៍ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ចុះការដាច់ក្តី ធ្លុះក្តី ពពាលក្តី ពព្រុសក្តី នៃព្រហ្មចរិយធម៌ តើដូចម្តេច ?

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

១-ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ ប្តេជ្ញាថា ជាអ្នកប្រព្រឹត្តធម៌ ដ៏ប្រសើរដោយប្រពៃ មិនបានប៉ះពាល់នូវការប៉ះពាល់ដោយបុគ្គលពីរៗមួយអន្លើដោយមាតុគ្រាម (សេពមេថុន) តែថា រមែងត្រេកអរនឹងការដុសខាត់ ន្ទួត ងូត ប្របាច់របស់មាតុគ្រាម ។ បុគ្គលនោះ រមែងត្រេកអរនឹងការដុសខាត់នោះ រីករាយនឹងការដុសខាត់នោះ ដល់នូវសេចក្តីត្រេកអរដោយការដុសខាត់នោះ ។ ម្នាលព្រាហ្មណ៍ នេះឯង ហៅថា ដាច់ផង ធ្លុះផង ពពាលផង

ពព្រុសផង នៃព្រហ្មចរិយធម៌ ម្នាលព្រាហ្មណ៍ នេះហៅថា បុគ្គល ប្រព្រឹត្តព្រហ្មចរិយធម៌ មិនបរិសុទ្ធ ជាអ្នកប្រកបដោយ មេថុនសំយោគ រមែងមិនផុតចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈ តថាគត ហៅថា រមែងមិនរួចចាកវដ្តទុក្ខឡើយ ។

២-ម្នាលព្រាហ្មណ៍ បុគ្គលខ្លះ ក្នុងលោកនេះ ជា សមណៈ ឬព្រាហ្មណ៍ ប្តេជ្ញាថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយប្រពៃ រមែងមិនប៉ះពាល់ចំពោះការប៉ះពាល់ដោយបុគ្គល ពីរៗ មួយអន្លើដោយមាតុគ្រាម ទាំងមិនត្រេកអរនឹងការដុស ខាត់ ងូត ងូត ប្របាច់របស់មាតុគ្រាមទេ តែថា រមែងចំអក ឡកឡឺយ សើចក្អាកក្អាយ ជាមួយនឹងមាតុគ្រាម ។បេ។

៣-បើមិនចំអកឡកឡឺយ សើចក្អាកក្អាយ ជាមួយ នឹងមាតុគ្រាមទេ រមែងនៅមៀងភ្នែកដោយភ្នែក ដៀងចំពោះ មាតុគ្រាម ។

៤-បើមិនបានមៀងភ្នែកដោយភ្នែក ដៀងចំពោះមាតុ-គ្រាមទេ រមែងស្តាប់សំឡេងនៃមាតុគ្រាម កាលសើចក្តី កាល និយាយក្តី ច្រៀងក្តី យំក្តី ខាងក្រៅជញ្ជាំង ឬខាងក្រៅកំពែង ។

៥-បើមិនស្តាប់សំឡេងនៃមាតុគ្រាម កាលសើចក្តី និយាយក្តី ច្រៀងក្តី យំក្តី ខាងក្រៅជញ្ជាំង ឬ ខាងក្រៅកំពែងទេ តែថា រលឹករឿយៗ នូវហេតុដែលធ្លាប់សើច ធ្លាប់និយាយ ធ្លាប់លេងជាមួយនឹងមាតុគ្រាម ក្នុងកាលពីដើម ។

៦-បើមិនរលឹករឿយៗ នូវហេតុដែលធ្លាប់សើច ធ្លាប់និយាយ ធ្លាប់លេងជាមួយនឹងមាតុគ្រាម ក្នុងកាលពីដើមទេ តែថា រមែងឃើញនូវគហបតិ ឬគហបតិបុត្រ ដែលស្កប់ស្កល់ មូលមិត្តបម្រើដោយកាមគុណទាំង ៥ ។

៧-បើមិនបានឃើញនូវគហបតី ឬគហបតិបុត្រ ដែលស្កប់ស្កល់ មូលមិត្ត បម្រើដោយកាមគុណទាំង ៥ ទេ តែថា ប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីប្រាថ្នានូវទេពនិកាយណាមួយថា អញសុំឲ្យបានជាទេវតា ទោះជាទេវតាណាមួយ ដោយសីលនេះផង ដោយវត្តនេះផង ដោយតបធម៌នេះផង ដោយព្រហ្មចរិយធម៌ផង ។ បុគ្គលនោះ រមែងត្រេកអរនឹងធម៌នោះ រីករាយនឹងធម៌នោះ ដល់នូវសេចក្តីត្រេកអរចំពោះធម៌នោះ ។

ម្នាលព្រាហ្មណ៍ នេះឈ្មោះថា ដាច់ផង ធ្លុះផង ពពាលផង ពព្រុសផង នៃព្រហ្មចរិយធម៌ ម្នាលព្រាហ្មណ៍ បុគ្គលនេះ

ហៅថា ប្រព្រឹត្តព្រហ្មចរិយធម៌មិនបរិសុទ្ធ ជាអ្នកប្រកបដោយមេថុនសំយោគ រមែងមិនរួចចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈ តថាគតហៅថា មិនរួចចាកវដ្តទុក្ខឡើយ ។ (សុត្តន្ត. ៤៧,១០១)

## ភរិយា ៧ ពួក

១-វធកសមាភរិយា ភរិយាស្មើដោយអ្នកសំលាប់

២-ចោរីសមាភរិយា ភរិយាស្មើដោយចោរ

៣-អយ្យសមាភរិយា ភរិយាស្មើដោយម្ចាស់

៤-មាតុសមាភរិយា ភរិយាស្មើដោយមាតា

៥-ភគិនីសមាភរិយា ភរិយាស្មើដោយប្អូនស្រី.

៦-សខីសមាភរិយា ភរិយាស្មើដោយសំឡាញ់

៧-ទាសីសមាភរិយា ភរិយាស្មើដោយខ្ញុំស្រី ។

ភរិយាដែលស្វាមីលោះមកដោយទ្រព្យ ស្ត្រីមានចិត្តប្រទូស្ត (នឹងស្វាមី) មានសេចក្តីមិនអនុគ្រោះនូវប្រយោជន៍ ជាអ្នកត្រេកត្រអាលក្នុងបុរសដទៃ មើលងាយប្តី ខ្វល់ខ្វាយ

ដើម្បីសម្លាប់(ប្តី) ស្រីណាជាភរិយានៃបុរស មានសភាព ដូច្នេះ ស្រីនោះ ហៅថា **វធកភរិយា** ។

ស្វាមីនៃស្ត្រីបាននូវទ្រព្យណា ហើយតម្កល់ទុកដើម្បីធ្វើនូវសិល្បៈក្តី នូវជំនួញក្តី នូវកសិកម្មក្តី ស្ត្រីនោះ ប្រាថ្នាដើម្បីលួចកិបយកនូវទ្រព្យ សូម្បីបន្តិចបន្តួច អំពីទ្រព្យនោះ ស្ត្រីណា ជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា **ចោរីភរិយា** ។

ស្ត្រីមិនមានសេចក្តីប្រាថ្នា នឹងធ្វើនូវការងារ ជាអ្នកខ្ជិលច្រអូស ស៊ីច្រើន រឹងរូស កាច ពោលនូវពាក្យអាក្រក់ ប្រព្រឹត្តគ្របសង្កត់នូវស្វាមី ដែលមានព្យាយាម ប្រឹងប្រែង ស្ត្រីណា ជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា **អយ្យាភរិយា** ។

ស្ត្រីណាមានសេចក្តីអនុគ្រោះនូវប្រយោជន៍ សព្វៗកាលចេះរក្សាប្តី ដូចជាមាតារក្សាកូន ទាំងរក្សានូវទ្រព្យដែលស្វាមីនោះ បានមកអំពីទីនោះៗ ស្ត្រីណាជាភរិយា នៃបុរសមានសភាពដូច្នេះ ស្ត្រីនោះហៅថា **មាតាភរិយា** ។

ស្ត្រីមានសេចក្ដីគោរពក្នុងស្វាមីរបស់ខ្លួន ដូចប្អូនស្រីគោរពបងប្រុស មានសេចក្ដីអៀនខ្មាស ប្រព្រឹត្តទៅតាមអំណាចនៃភស្ដា ស្ត្រីណា ជាភរិយានៃបុរសមានសភាព ដូច្នេះ ស្ត្រីនោះ ហៅថា **ភគិនីភរិយា** ។

ស្ត្រីណា ក្នុងលោកនេះ បានឃើញនូវប្ដីហើយ ក៏រីករាយ ដូចជាសំឡាញ់បានឃើញសំឡាញ់ ដែលមកអស់កាលយូរ ស្ត្រីនោះបរិបូរណ៍ដោយត្រកូល មានសីលធម៌ ជាស្ត្រីមានវត្តប្រតិបត្តិក្នុងប្ដី ស្ត្រីណាជាភរិយា មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា **សខីភរិយា** ។

ស្ត្រីដែលស្វាមីជេរ វាយ គំរាមដោយដំបង មិនមានចិត្តប្រទូស្ដវិញ ចេះអត់សង្កត់ដល់ប្ដី មិនក្រោធ ប្រព្រឹត្តទៅតាមអំណាចនៃភស្ដា ស្ត្រីណា ជាភរិយាមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា **ទាសីភរិយា** ។

ភរិយាណា ក្នុងលោកនេះ ដែលហៅថា វធកាភរិយា ហៅថា ចោរីភរិយា ហៅថា អយ្យាភរិយា ភរិយាទាំងនោះ មានសភាពជាស្ត្រីទ្រុស្តសីល រឹងរូស មិនមានសេចក្ដីគោរព លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកាន់នរក ។ ភរិយាណា ក្នុង

លោកនេះ ដែលហៅថា មាតាក្តី ភគិនីក្តី សខីក្តី ទាសីក្តី ភរិយាទាំងនោះជាស្ត្រីសង្រួមអស់កាលជាយូរអង្វែង ព្រោះតាំងនៅក្នុងសីលធម៌ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកាន់សុគតិ ។ (សុត្តន្តបិដក ៤៧ , ១៦៨-១៧២)

## សប្បុរិសធម៌ ៧ យ៉ាង

១–ធម្មញ្ញូ ជាអ្នកដឹងនូវធម៌,

(គឺ សុត្តៈ គេយ្យៈ ។បេ។ វេទល្លៈ) ។

២–អត្ថញ្ញូ ដឹងនូវអត្ថ (របស់ធម៌),

(ភិក្ខុ ដឹងនូវអត្ថនៃភាសិតនោះៗ ថា នេះជាអត្ថ របស់ភាសិតនេះ នេះជាអត្ថ របស់ភាសិតនេះ) ។

៣–អត្តញ្ញូ ដឹងខ្លួន

(ភិក្ខុ ដឹងខ្លួនថា អាត្មាអញ ជាអ្នកប្រកបដោយសទ្ធា មានសីល សុតៈ ចាគៈ បញ្ញា បដិភាណៈ ត្រឹមប៉ុណ្ណេះ) ។

៤–មត្តញ្ញូ ដឹងនូវប្រមាណក្នុង (ភោជន)

(ភិក្ខុ ដឹងប្រមាណ ក្នុងការទទួលចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ) ។

៥–កាលញ្ញូ ដឹងកាលគួរ

(ភិក្ខុ ដឹងនូវកាលថា នេះជាកាលគួររៀនបាលី នេះជាកាលគួរសាកសួរ នេះជាកាលគួរប្រេកប នេះជាកាលគួរពួនសម្ងំ) ។

៦–បរិសញ្ញូ ដឹងបរិស័ទ

(ភិក្ខុ ដឹងបរិស័ទថា នេះជាខត្តិយបរិស័ទ នេះជាព្រាហ្មណបរិស័ទ នេះជាគហបតិបរិស័ទ នេះជាសមណបរិស័ទ អាត្មាអញ គួរចូលទៅរកយ៉ាងនេះ គួរឈរយ៉ាងនេះ គួរធ្វើយ៉ាងនេះ គួរអង្គុយយ៉ាងនេះ គួរនិយាយយ៉ាងនេះ គួរស្ងៀមយ៉ាងនេះ ចំពោះបរិស័ទទាំងនោះ) ។

៧–បុគ្គលបរោបរញ្ញូ ដឹងបុគ្គលដែលគួរគប់រក ។

ភិក្ខុក្នុងសាសនានេះ រមែងដឹងច្បាស់នូវបុគ្គល ២ ពួក ឯបុគ្គល ២ ពួកគឺ មួយពួក ជាអ្នកចង់ចួបប្រទះពួកព្រះអរិយៈ មួយពួក មិនចង់ចួបប្រទះពួកព្រះអរិយ ។ បុគ្គលណា មិនចង់ចួបប្រទះពួកព្រះអរិយៈ បុគ្គលនោះ គេគប្បីតិះដៀល ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គលណាចង់ចួបប្រទះពួកព្រះអរិយៈ បុគ្គលនោះ គេគប្បីសរសើរ ដោយហេតុនោះៗ យ៉ាងនេះ ។ បុគ្គល ២

ពួក ចង់ចូបប្រទះពួកព្រះអរិយៈ គឺ មួយពួកចង់ស្តាប់ព្រះសទ្ធម្ម មួយពួក មិនចង់ស្តាប់ព្រះសទ្ធម្ម ។ល។ (សុត្តន្ត. ៤៧,២០៦)

## បុគ្គល ៧ នាក់យកមាសនិងកហាបណៈ ទិញដីថ្វាយព្រះសម្ពុទ្ធ

១-បុនព្វសុមិត្តគហបតិ បានទិញដីប្រមាណ ១ យោជន៍ ដោយក្រាលឥដ្ឋមាស (ពេញផ្ទៃដី) សាងវិហារ ថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាម **វិបស្សី** ។

២-សិរិវឌ្ឍគហបតិ បានទិញដីប្រមាណ ៣ គាវុត ដោយក្រាលសសរមាស សាងវិហារថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាម **សិខី** ។

៣-សោត្ថិជគហបតិ បានទិញដីប្រមាណកន្លះ-យោជន៍ ក្រាលដោយផាលមាស សាងវិហារថ្វាយ ព្រះមាន ព្រះភាគ ទ្រង់ព្រះនាម **វេស្សភូ** ។

៤-អច្ចុតគហបតិ បានទិញដីប្រមាណ ១ គាវុត ក្រាលដោយជើងដំរីមាស សាងវិហារថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាម **កកុសន្ធៈ** ។

៥-សុមង្គលគហបតិ បានទិញដីប្រមាណ ២០ ឧសភៈ ក្រាលដោយអណ្ដើកមាស សាងវិហារថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាម **កស្សបៈ** ។

៦-ឧគ្គគហបតិ បានទិញដីប្រមាណកន្ទះគាវុត ក្រាលដោយឥដ្ឋមាស សាងវិហារថ្វាយព្រះមានព្រះភាគ ទ្រង់ព្រះនាម **កោនាគមនៈ** ។

៧-សុទត្តគហបតិ បានទិញដីប្រមាណ ៨ ករីសៈ ដោយក្រាលកហាបណៈ សាងវិហារថ្វាយព្រះមាន- ព្រះភាគ ទ្រង់ព្រះនាម **សមណគោតម** ។

សម្បត្តិទាំងឡាយអស់ទៅដោយលំដាប់ ដោយប្រការដូច្នេះ ព្រោះហេតុនោះ សមគួរពិតដែលនឹងនៀយណាយក្នុងសម្បត្តិទាំងពួង សមគួរដែលនឹងរួចផុតទៅ ដូច្នេះឯង ។

(ចាកអដ្ឋកថា សេនាសនក្ខន្ធកៈ)

## វិសុទ្ធិ ៧

១-សីលវិសុទ្ធិ *សេចក្ដីបរិសុទ្ធិនៃសីល*

២-ចិត្តវិសុទ្ធិ *សេចក្ដីបរិសុទ្ធិនៃចិត្ត*

៣-ទិដ្ឋិវិសុទ្ធិ *សេចក្ដីបរិសុទ្ធិនៃទិដ្ឋិ*

៤-កង្ខាវិតរណវិសុទ្ធិ *សេចក្ដីបរិសុទ្ធិ ព្រោះឆ្លាន កន្លងសេចក្ដីសង្ស័យ ១៦ យ៉ាង*

៥-មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ *សេចក្ដីបរិសុទ្ធិ នៃមគ្គាមគ្គញ្ញាណទស្សនៈ*

៦-បដិបទាញ្ញាណទស្សនវិសុទ្ធិ *សេចក្ដីបរិសុទ្ធិ នៃបដិបទាញ្ញាណទស្សនៈ*

៧-ញ្ញាណទស្សនវិសុទ្ធិ *សេចក្ដីបរិសុទ្ធិនៃ ញ្ញាណទស្សនៈ ។ (ចាកវិសុទ្ធិមគ្គ)*

# ពួក ៨

## អវិជ្ជាមិនដឹងច្បាស់ក្នុងឋាន ៨ យ៉ាង

*ដោយបរិយាយផ្លូវព្រះសូត្រ ការមិនដឹងក្នុងឋានៈ ៤ មានទុក្ខជាដើម ឈ្មោះថា **អវិជ្ជា** ដោយបរិយាយផ្លូវព្រះអភិធម្ម ការមិនដឹងក្នុងឋានៈ ៨ ។*

១-ទុក្ខេ អញ្ញាណំ *ការមិនដឹងច្បាស់ក្នុងទុក្ខ*

២-ទុក្ខសមុទយេ អញ្ញាណំ *មិនដឹងច្បាស់ក្នុងទុក្ខសមុទ័យ*

៣-ទុក្ខនិរោធេ អញ្ញាណំ *មិនដឹងច្បាស់ក្នុងទុក្ខនិរោធ*

៤-ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ *មិនដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទា*

៥-បុព្វន្តេ អញ្ញាណំ *មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើម*

៦-អបរន្តេ អញ្ញាណំ *មិនដឹងច្បាស់ក្នុងខន្ធ*

ជាចំណែកខាងចុង

៧-បុព្វន្តាបរន្តេ អញ្ញាណំ មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើមនិងខាងចុង

៨-ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ មិនដឹងច្បាស់ក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ ។ (អភិធម្មបិដក ៧៩ / ១៤៣)

អដ្ឋកថា : បទថា ទុក្ខេ អញ្ញាណំ (ការមិនដឹងច្បាស់ក្នុងទុក្ខ) បានដល់ បញ្ញាក្នុងទុក្ខសច្ចៈ ។ សូម្បីក្នុងបទជាដើមថា ទុក្ខសមុទយេ អញ្ញាណំ ជាដើមក៏ន័យនេះ ។ ក៏បណ្តាការដឹងច្បាស់ក្នុងទុក្ខជាដើមនោះ ការដឹងក្នុងទុក្ខ (ទុក្ខេញាណំ) រមែងប្រព្រឹត្តទៅក្នុងការស្តាប់ ការពេញចិត្ត ការចាក់ធ្លុះ និងការពិចារណា ការដឹងច្បាស់ក្នុងទុក្ខសមុទ័យ ក៏ប្រព្រឹត្តទៅយ៉ាងនោះ ។ តែការដឹងក្នុងនិរោធ រមែងប្រព្រឹត្តទៅក្នុងការស្តាប់ ការចាក់ធ្លុះនិងការពិចារណានោះឯង ការដឹងក្នុងទុក្ខនិរោធគាមិនីបដិបទាក៏ដូចគ្នា ។

បទថា បុព្វន្តេ (ក្នុងខន្ធជាចំណែកខាងដើម) បានដល់ ក្នុងចំណែកដែលកន្លងទៅហើយ ។

បទថា អបរន្តេ (ក្នុងខន្ធជាចំណែកខាងចុង) បានដល់ ក្នុងចំណែកដែលនៅមិនទាន់មកដល់ ។ បទថា បុព្វន្តាបរន្តេ បានដល់ ក្នុងចំណែកទាំងពីរនោះ ។

ពាក្យថា **ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ញាណំ** (ការដឹងច្បាស់ក្នុងឥទប្បច្ចយតាធម៌ និងបដិច្ចសមុប្បាទធម៌) បានដល់ ការដឹងក្នុងសេចក្តីក្នុងបច្ច័យទាំងឡាយ និងក្នុងធម៌ដែលកើតឡើងព្រោះបច្ច័យយ៉ាងនេះថា នេះជាបច្ច័យ ធម៌នេះកើតឡើងព្រោះអាស្រ័យធម៌នេះ ដូច្នេះ ។

(អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណី ៧៦ / ៣៩៥)

ក្នុងវិសុទ្ធិមគ្គថា : ក្នុងឋានៈទាំងនោះ វៀរសច្ចៈពីរ (គឺនិរោធនិងមគ្គ) ដែលជាលោកុត្តរៈចេញ អវិជ្ជារមែងកើតឡើងក្នុងឋានៈដ៏សេស សូម្បីដោយធ្វើឲ្យជាអារម្មណ៍ ក៏បានពិត (តែ) សូម្បីយ៉ាងនោះ ក្នុងបាលីនេះ លោកក៏ប្រាថ្នាយកដោយគ្រឿងបិទបាំងប៉ុណ្ណោះឯង មែនពិត អវិជ្ជានោះ ដែលកើតឡើង

ហើយ រមែងបិទបាំងទុក្ខសច្ចៈតាំងនៅ មិនឲ្យដឹងច្បាស់នូវលក្ខណៈដែលជារស់ (គឺសភាវៈ) របស់ខ្លួនតាមការពិតបាន តែម្យ៉ាង រមែងបិទបាំងសមុទយសច្ច និរោធសច្ច មគ្គសច្ច ខន្ធបញ្ចកជាចំណែកខាងដើមនិងខាងចុង ខន្ធបញ្ចក ជាចំណែកខាងចុង ខន្ធបញ្ចកទាំងពីរចំណែកនោះ ដែលជាចំណែកខាងដើម និងខាងចុង **ឥទប្បច្ចយតា** និង**បដិច្ចសមុប្បន្នធម៌**ផងតាំងនៅ មិនឲ្យដឹងច្បាស់លក្ខណៈដែលជារសរបស់ខ្លួន តាមសេចក្ដីពិត ក្នុងទុក្ខជាដើមនោះថា នេះអវិជ្ជា នេះសង្ខារ ដូច្នេះជាដើម ព្រោះហេតុនោះ លោកទើបពោលថា (អវិជ្ជា) មិនដឹងច្បាស់ក្នុងទុក្ខ ។ល។ មិនដឹងច្បាស់ក្នុង**ឥទប្បច្ចយតា** និង **បដិច្ចសមុប្បន្នធម៌**ទាំងឡាយ ។

(វិសុទ្ធិមគ្គ ៣ / ២៥៦)

ដីកាវិសុទ្ធិមគ្គ : លោកអាចារ្យពោលថា “រមែងមិនឲ្យដើម្បីនឹងចាក់ធ្លុះលក្ខណៈ គឺរសរបស់ខ្លួនតាមការពិតបាន” ដើម្បីសម្ដែងអាការ គឺការបិទបាំងដែលលោកបានពោលទុកក្នុងពាក្យថា “បិទបាំង” សភាវៈដែលគប្បីត្រេកអរ គឺគប្បីចាក់ធ្លុះ ឈ្មោះថារស់, រស់របស់ខ្លួន ឈ្មោះថា **សរសោ**

ប្រែថា រស់របស់ខ្លួន, រស់របស់ខ្លួនតាមការពិត គឺមានពិត ឈ្មោះថា **យាថាវសរសោ** ប្រែថា រស់របស់ខ្លួនតាមការពិត, ដែលលោកបានពោលទុកក្នុងពាក្យថា "**បីឡូនដ្ឋោ**" មានការបៀតបៀនជាដើម និងធម៌ទាំងឡាយមានខាងដើមជាដើម ដែលជាប្រភេទនៃទុក្ខសច្ច, ក៏រស់នោះៗឯង ឈ្មោះថា លក្ខណៈ គឺរស់របស់ខ្លួនតាមការពិត ព្រោះជាគ្រឿងដែលនឹងគប្បីកំណត់ ។ អវិជ្ជា រមែងមិនឲ្យដើម្បីនឹងចាក់ធ្លុះលក្ខណៈ គឺរស់របស់ខ្លួនតាមការពិតនោះ គឺដើម្បីដឹងដោយប្រចក្ស ។

ពាក្យថា **លក្ខណៈទាំងពីរ** បានដល់ ខន្ធបញ្ចកខាងដើម គឺដែលជាចំណែកអតីតៈ និងខាងចុងដែលជាចំណែកអនាគត។ ម្យ៉ាងទៀត ចំណែកកណ្តាលដែលជាបច្ចុប្បន្នអទ្ធា ឈ្មោះថា ខាងដើមនិងខាងចុង ព្រោះមានចំណែកនៃខាងដើមនិងខាងចុង។ ពាក្យថា នេះអវិជ្ជា នេះសង្ខារ ជាពាក្យសម្តែងអាការ គឺការដឹងដោយប្រចក្សក្នុងឥទប្បច្ចយា និង បដិច្ចសមុប្បន្នធម៌ ។

បទថា **ឯត្ថសុ** ស្មើគ្នានឹង **ឯតេសុ យោគ ទុក្ខាទីសុ** ប្រែថា ក្នុងទុក្ខជាដើមនេះ ។ គប្បីជ្រាបថា អវិជ្ជា រមែងប្រព្រឹត្តទៅសូម្បីទាក់ទងនឹងការធ្វើឲ្យជាអារម្មណ៍ក្នុងធម៌ មាន

ទុក្ខជាដើម សូម្បីក៏ពិត ដល់យ៉ាងនោះ អវិជ្ជា ក៏មិនអាចធ្វើនិរោធនិងមគ្គ ឲ្យជាអារម្មណ៍បាន, កាលប្រព្រឹត្តទៅ ទាក់ទងនឹងការបិទបាំងនិរោធ និងមគ្គនោះ ដល់បុគ្គលអ្នកប្រាថ្នានឹងដឹងនិរោធនិងមគ្គទាំងនោះ និងដោយភាវៈដែលជាហេតុប្រកាន់ គឺក្នុងមគ្គដែលមិនមែននិរោធ និងមគ្គ ថាជានិរោធនិងមគ្គ រមែងមិនឲ្យដើម្បីចាក់ធ្លុះតាមការពិតនូវនិរោធ និងមគ្គជាដើមទាំងនោះយ៉ាងណា, សូម្បីក្នុងសច្ចមានទុក្ខជាដើមក៏យ៉ាងនោះ ។ ពិតយ៉ាងនោះ លោកអាចារ្យបានពោលថា "ក្នុងបាលីនេះ លោកក៏ប្រាថ្នាយកអវិជ្ជា ដោយជាគ្រឿងបិទបាំងប៉ុណ្ណោះឯង" អាការគឺការមិនឃើញ ដែលធ្វើសេចក្ដីងងឹត ដែលមានសច្ចៈមានទុក្ខជាដើមជាវិស័យ និងជាបច្ច័យដល់ធម៌ ដែលធ្វើការងងឹតមានលោកជាដើម ឈ្មោះថា **អញ្ញាណំ** ប្រែថា ការមិនដឹងច្បាស់ ។ (បរមត្ថមញ្ជុសា ៣, ៣០៨)

## វិជ្ជា ៨

១–បុព្វេនិវាសញ្ញាណ ប្រាជ្ញារឭកឃើញនូវលំដាប់ខន្ធដែលសត្វអាស្រ័យនៅក្នុងកាលមុន គឺអតីតជាតិ ។

២-ចុតូបបាតញ្ញាណ ប្រាជ្ញាដឹងនូវចុតិនិងបដិសន្ធិរបស់សត្វ ។

៣-អាសវក្ខយញ្ញាណ ប្រាជ្ញាដឹងនូវធម៌ដែលធ្វើអាសវៈឲ្យអស់ទៅ ។

៤-វិបស្សនាញាណ ប្រាជ្ញាឃើញច្បាស់នូវកាយនេះថា គ្រាន់តែជាធាតុទាំ ៤ ។

៥-មនោមយិទ្ធិញ្ញាណ ប្រាជ្ញាប្រកបដោយឫទ្ធិដែលសម្រេចដោយចិត្ត ។

៦-ឥទ្ធិវិធិញ្ញាណ ប្រាជ្ញាប្រកបដោយការតាក់តែងឫទ្ធិឲ្យសម្រេចដោយកាយ ។

៧-ទិព្វសោតញ្ញាណ ប្រាជ្ញាប្រកបដោយត្រចៀកទិព្វ ។

៨-ចេតោបរិយញ្ញាណ ប្រាជ្ញាកំណត់ដឹងនូវចិត្តរបស់អ្នកដទៃបាន ។

## សមាបត្តិ ៨

*សាមាបត្តិ ក្នុងរូបជ្ឈាន ៤, ក្នុងអរូបជ្ឈាន ៤ ។*

## វិមោក្ខ ៨ យ៉ាង

*(សុត្តន្តបិដក ១៦,១៥១)*

*១-បុគ្គលមានរូបជ្ឈាន តែងឃើញរូប គឺកសិណទាំងឡាយ មាននីលកសិណជាដើម នេះជាវិមោក្ខទី ១ ។*

*២-បុគ្គលមិនមានសេចក្ដីសម្គាល់ក្នុងរូបខាងក្នុង មានសក់ជាដើមរបស់ខ្លួន តែងឃើញរូបខាងក្រៅ គឺកសិណ មាននីលកសិណជាដើម នេះជាវិមោក្ខទី ២ ។*

*៣-បុគ្គលមានចិត្តចុះស៊ប់កាន់ឈាន ក្នុងវណ្ណកសិណដែលបរិសុទ្ធ នេះជាវិមោក្ខទី ៣ ។*

*៤-បុគ្គលដែលកន្លងនូវរូបសញ្ញា ដល់នូវសេចក្ដីវិនាសនៃបដិឃសញ្ញា ទាំងមិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយចូលទៅកាន់អាកាសានញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។*

៥-បុគ្គលដែលកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។

៦-បុគ្គលដែលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន (ដោយធ្វើទុកក្នុងចិត្ត) ថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។

៧-បុគ្គលដែលកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។

៨-បុគ្គលដែលកន្លង នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលទៅកាន់សញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញានិងវេទនា) នេះជាវិមោក្ខទី ៨ ។

## អដ្ឋកថា

ក្នុងបទទាំងនោះ បទថា វិមោក្ខោ (ការរួចផុត) សួរថា

ឈ្មោះថា **វិមោក្ខ** ដោយអត្ថថាដូចម្ដេច ? ឆ្លើយថា ដោយអត្ថថា រួចផុត សួរថា វិមោក្ខនេះ មានអត្ថថា រួចផុត តើដូចម្ដេច ? ឆ្លើយថា មានអត្ថថា រួចផុតដោយល្អអំពីធម៌ជាសត្រូវ និងរួចផុតដោយល្អដោយអំណាចសេចក្ដីត្រេកអរក្នុងអារម្មណ៍ ។ លោកអធិប្បាយថា **វិមោក្ខ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ព្រោះអស់សេចក្ដីសង្ស័យ ដោយសេចក្ដីមិនប្រកាន់ ដូចទារកអ្នកបញ្ចេញអវយវៈតូចធំ ដេកលើភ្លៅរបស់បិតា ។ ក៏សេចក្ដីនេះ មិនមានក្នុងវិមោក្ខពេលក្រោយ តែមានក្នុងផ្នែកខាងដើមទាំងអស់ ។

ក្នុងបទថា រូបី រូបានិ បស្សតិ (បុគ្គលមានរូបតែងឃើញរូបទាំងឡាយ) នេះ មានសេចក្ដីថា រូបជារូបជ្ឈានដែលធ្វើឲ្យកើតឡើងដោយអំណាចនីលកសិណជាដើម ក្នុងសក់ជាដើមខាងក្នុងឈ្មោះថា **រូបី** ។ ព្រោះមានរូបជ្ឈានដោយបទនេះ លោកសម្ដែងរូបាវចរជ្ឈាន ៤ ដល់បុគ្គលដែលធ្វើឈានឲ្យកើតក្នុងកសិណទាំងឡាយដែលមានវត្ថុខាងក្នុង ។

បទថា អជ្ឈត្តំ អរូបសញ្ញី (មិនសម្គាល់រូបខាងក្នុងរបស់ខ្លួន) គឺមិនមានសេចក្ដីសម្គាល់ក្នុងរូបខាងក្នុងរបស់ខ្លួន

សេចក្ដីថា មិនធ្វើរូបាវចរជ្ឈានឲ្យកើតក្នុងអាការ ៣២ មានសក់ជាដើមរបស់ខ្លួន ។ បទថា ពហិទ្ធា រូបានិ បស្សតិ (តែងឃើញរូបខាងក្រៅ) សេចក្ដីថា រមែងជារូបមាននីលកសិណជាដើម សូម្បីខាងក្រៅ ដោយញាណចក្ខុ ។ ដោយបទនេះ លោកធ្វើបរិកម្មខាងក្រៅហើយសម្ដែងរូបាវចរជ្ឈាន ៤ នៃឈានដែលធ្វើឲ្យកើតហើយខាងក្រៅ ។

លោកសម្ដែងឈានក្នុងវណ្ណកសិណ មានពណ៌ខៀវ ជាដើម ដែលបរិសុទ្ធិល្អហើយដោយបទនេះថា សុភន្តេវ អធិមុត្តោ ហោតិ (មានចិត្តចុះស៊ប់ក្នុងកសិណដែលស្អាត) ដូច្នេះ ក្នុងបទនោះមិនមានសេចក្ដីចងចិត្តថា ល្អក្នុងអប្បនាខាងក្នុងក៏ពិតមែន ប៉ុន្តែអ្នកដែលធ្វើកសិណដែលល្អបរិសុទ្ធិហើយនោះ រមែងជាអ្នកគួរពោលបានថា អ្នកដែលបង្អោនចិត្តជឿថា កសិណជារបស់ល្អយ៉ាងនេះ ដូច្នោះ លោកទើបសម្ដែងយ៉ាងនេះ ។ តែក្នុងបដិសម្ភិទាមគ្គលោកពោលថា “វិមោក្ខ ក្នុងបទថា អ្នកដែលបង្អោនចិត្តជឿថា កសិណល្អ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា តាម

ទំនងនេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយមេត្តា ដ៏ទូលំទូលាយ រកប្រមាណមិនបាន ជាចិត្តឥតចងពៀរ ឥតព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះហេតុប្រៀបផ្ទឹមខ្លួនឲ្យស្មើនឹងសត្វទាំងអស់ ក្នុងទិសទាំងពួង សត្វទាំងឡាយដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនមេត្តា ។ល។ ភិក្ខុមានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិសទី ១ ។ល។ សត្វទាំងឡាយដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនករុណា ភិក្ខុមានចិត្តប្រកបដោយមុទិតាផ្សាយទៅកាន់ទិសទី ១ ។ល។ សត្វទាំងឡាយដែលគេ មិនគួរខ្ពើមរអើម ព្រោះបានចម្រើនមុទិតា ភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ។ល។ សត្វទាំងឡាយ ដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនឧបេក្ខា យ៉ាងនេះឯង ឈ្មោះថា វិមោក្ខក្នុងបទថា អ្នកដែលបង្អោនចិត្តជឿថា កសិណល្អ”[១] ដូច្នេះ ។

បទថា អយំ អដ្ឋមោ វិមោក្ខោ (នេះជាវិមោក្ខទី ៨) សេចក្ដីថា នេះឈ្មោះវិមោក្ខដែលខ្ពស់បំផុតទី ៨ ព្រោះសេចក្ដី

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ១៨៤ / ២៩៣ ។

ដែលខន្ធ ៤ បរិសុទ្ធិដោយប្រការទាំងពួង ព្រោះសេចក្ដីដែលរួចផុតហើយ ។

បទថា អនុលោមំ (តាមលំដាប់) គឺតាំងពីបទដើមដរាបដល់បទចុងបង្អស់ ។ បទថា បដិលោមំ (បញ្ច្រាសលំដាប់) គឺតាំងពីបទចុងបង្អស់ដរាបដល់បទដើម ។ បទថា អនុលោម–បដិលោមំ (ទាំងតាមលំដាប់ ទាំងបញ្ច្រាសលំដាប់) នេះលោកពោលអំពីអំណាចនៃការដែលសមាបត្តិ មិនតាំងមាំ ព្រោះជំនាញពេកទៅ វិលទៅផ្លូវឯណោះវិលទៅផ្លូវនេះ ។ បទថា យត្ថិច្ឆកំ (តាមសេចក្ដីប្រាថ្នាក្នុងទីណា) គឺ សម្ដែងដល់ឱកាស សេចក្ដីថា ប្រាថ្នាក្នុងឱកាសណាៗ ។ បទថា យទិច្ឆកំ (តាមសេចក្ដីប្រាថ្នាយ៉ាងណា) គឺសម្ដែងដល់សមាបត្តិ បានដល់ប្រាថ្នាសមាបត្តិណាៗ ។ បទថា យាវតិច្ឆកំ (តាមសេចក្ដីប្រាថ្នាត្រឹមណា) គឺសម្ដែងដល់កំណត់ផ្លូវឆ្ងាយ បានដល់ ប្រាថ្នាផ្លូវឆ្ងាយប្រមាណត្រឹមណា ។ បទថា សមាបជ្ជតិ (បានចូល) គឺចូលកាន់សមាបត្តិនោះៗ ។ បទថា វុដ្ឋាតិ (បានចេញ) គឺ

ចេញចាកសមាបត្តិនោះហើយតាំងនៅ ។

បទថា ឧភតោភាគវិមុត្តោ (រួចទាំងពីរផ្នែក) សេចក្ដីថា រួចផុតដោយចំណែកពីរ គឺរួចផុតពីរូបកាយដោយអរូបសមាបត្តិ ផុតពីនាមកាយដោយមគ្គ ។ ដូចដែលលោកពោលទុកដូច្នេះថា ៖

(ព្រះមានព្រះភាគ ទ្រង់ដោះស្រាយថា ម្នាលឧបសីវៈ) អណ្ដាតភ្លើងដែលត្រូវកម្លាំងខ្យល់បក់ រមែងរលត់ទៅ មិនដល់នូវការរាប់ (ថាទៅក្នុងទីណាទេ) យ៉ាងណាមិញ មុនីរួចស្រឡះហើយចាកនាមកាយ រមែងរលត់ទៅ មិនដល់នូវការរាប់ (ថាទៅក្នុងទីណា) យ៉ាងនោះដែរ ។[១]

ក៏ភិក្ខុនេះ រួចផុតហើយដោយចំណែកពីរ ចេញចាកអាកាសានញ្ចាយតនៈជាដើម យ៉ាងណាមួយ ហើយសម្រេចព្រះអរហត្ត និងជាអនាគាមី ចេញចាកនិរោធហើយសម្រេចព្រះអរហត្ត រួមជា ៥ យ៉ាង ។ តែអាចារ្យពួកខ្លះពោលថា ព្រោះសូម្បីរូបាវចរចតុត្ថជ្ឈាន ក៏សហគតដោយឧបេក្ខា មានអង្គពីរ សូម្បីអរូបាវចរជ្ឈាន ក៏ជាដូច្នោះដែរ ដូច្នោះ ភិក្ខុចេញចាក

---

១. ខុទ្ទ. សុត្ត. ឧបសីវមាណវកបញ្ហា. ៥៤. ១១៧/៣៤៨ ។

រូបាវចរចតុត្ថជ្ឈាន សូម្បីសម្រេចព្រះអរហត្ត ក៏ឈ្មោះថា ឧភតោភាគវិមុត្ត ដូច្នេះ ។ ក៏បញ្ហាឧភតោភាគវិមុត្ត នេះ តាំងឡើងសូម្បីខាងក្រោមលោហប្រាសាទ អាស្រ័យការពណ៌នារបស់ព្រះចូឡសុមនត្ថេរ អ្នកទ្រង់ព្រះត្រៃបិដក ប្រើវេលាយូរទើបដល់ការគួសបង្ហាញ ។

មានរឿងថា ក្នុងគិរិវិហារ អន្តេវាសិករបស់ព្រះថេរៈ ស្តាប់បញ្ហានោះ អំពីមាត់របស់ភិក្ខុដែលកាន់បិណ្ឌបាតិកមួយរូប ហើយពោលថា ម្នាលអាវុសោ កាលអាចារ្យរបស់យើង អធិប្បាយធម៌ ក្នុងខាងក្រោមលោហប្រាសាទដែលអ្នកណាៗ មិនធ្លាប់ស្តាប់ហើយ ពួកភិក្ខុទើបសួរថា លោកដ៏ចម្រើន ក៏ព្រះថេរៈបានពោលយ៉ាងណា អន្តេវាសិកឆ្លើយថា ម្នាលអាវុសោ ព្រះថេរៈបានពោលថា រូបបាវចរចតុត្ថជ្ឈាន សហគតដោយឧបេក្ខា មានអង្គពីរ រមែងគ្របសង្កត់កិលេសបានក៏ពិត តែទោះជាយ៉ាងនោះ រូបាវចរចតុត្ថជ្ឈាន រមែងកម្រើកក្នុងឋានៈនៃរូបា-រម្មណ៍ សូម្បីជាចំណែកជិតនៃកិលេសទាំងឡាយ ព្រោះធម្មតាកិលេសទាំងនេះ ចូលទៅអាស្រ័យអារម្មណ៍ក្នុងនីលកសិណជាដើមយ៉ាងណាមួយ ក្នុងភពជាន់ក្រោមទាំង ៥ រមែងកម្រើក

មួយទៀត រូបាវចរជ្ឈាន រមែងមិនឈានទៅកាន់អារម្មណ៍នោះ ព្រោះដូច្នោះ ភិក្ខុផ្ចាស់រូបដោយប្រការទាំងពួង ហើយគ្រប សង្កត់កិលេសដោយអំណាចអរូបជ្ឈានហើយ ទើបសម្រេច ព្រះអរហត្ត ជាឧភតោភាគវិមុត្ត ដូច្នេះ ក៏ព្រះថេរៈគ្រាពោល ពាក្យនេះហើយ ទើបនាំសូត្រនេះមកថា "បុគ្គលជាឧភតោភាគ-វិមុត្ត តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះ ឃើញដោយបញ្ញា នេះហៅថា បុគ្គលជាឧភតោភាគវិមុត្ត"[១] ដូច្នេះ ។ (ចាកអដ្ឋកថា មហានិទានសូត្រ) ។

## សម្បទា ៨ យ៉ាង

ឧដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ សទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។

ឧដ្ឋានសម្បទា : កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិត ដោយទំធ្វើការងារ ទោះបីធ្វើស្រែចម្ការក្តី ជំនួញក្តី រក្សាគោក្តី

១. អភិ. បុគ្គ. ឯកនិទ្ទេស. ៨៣. ៤០/២៣៨ ។

ធ្វើសេនាយោធាក្តី ធ្វើជារាជបុរសក្តី ចេះសិល្បៈ ណាមួយក្តី ជាអ្នកឈ្លាសក្នុងអំពើនោះៗ មិនខ្ជិលច្រអូស បរិបូរណ៍ដោយការលៃលក មានល្បិចក្នុងការនោះថា គួរធ្វើ គួរចាត់ចែង ម្នាលភិក្ខុទាំងឡាយ នេះហៅថា **ឧដ្ឋានសម្បទា** ។

អារក្ខសម្បទា : កុលបុត្តក្នុងលោកនេះ មានភោគៈច្រើន ដែលខ្លួនរកបានមកដោយការប្រឹងប្រែងព្យាយាម សន្សំដោយកម្លាំងដៃ បែកញើសហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ហើយថែទាំភោគៈទាំងនោះ ដោយការរក្សាគ្រប់គ្រង ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ កុំឲ្យព្រះរាជាទាំងឡាយ រឹបជាន់យក កុំឲ្យពួកចោរលួចយក កុំឲ្យភ្លើងឆេះ កុំឲ្យទឹកលិច កុំឲ្យពួកទាយាទមិនជាទីគាប់ចិត្ត យកទៅបាន ម្នាលភិក្ខុទាំងឡាយ នេះហៅថា **អារក្ខសម្បទា** ។

កល្យាណមិត្តតា : កុលបុត្តក្នុងលោកនេះ នៅក្នុងស្រុកណាក្តី និគមណាក្តី ក្នុងស្រុក ឬនិគមនោះ មានពួកគហបតី ឬពួកគហបតិបុត្ត ទោះបីនៅក្មេងតែជាអ្នកចម្រើនដោយសីល ទោះបីចាស់ ក៏ចម្រើនដោយសីល មានសទ្ធាបរិបូរណ៍ មានសីលបរិបូរណ៍ មានចាគៈបរិបូរណ៍ មានបញ្ញា

*បរិបូរណ៍ កុលបុត្តដែលឋិតនៅ ចរចា សាកសួរ ជាមួយនឹងពួកគហបតីទាំងនោះ ហើយសិក្សារឿយៗ នូវសទ្ធាសម្បទា នឹងពួកបុគ្គលដែលជាអ្នកមានសទ្ធាបរិបូរណ៍ តាមសមគួរ សិក្សារឿយៗ នូវសីលសម្បទា នឹងពួកបុគ្គលជាអ្នកមានសីលបរិបូរណ៍ តាមសមគួរ សិក្សារឿយៗ នូវចាគសម្បទា នឹងពួកអ្នកមានចាគៈបរិបូរណ៍ តាមសមគួរ សិក្សារឿយៗ នូវបញ្ញាសម្បទា នឹងពួកបុគ្គលអ្នកមានបញ្ញាបរិបូរណ៍ តាមសមគួរ ម្នាលភិក្ខុទាំងឡាយ នេះហៅថា* **កល្យាណមិត្តតា** ។

សមជីវិតា : *កុលបុត្តក្នុងលោកនេះ ស្គាល់សេចក្តីចម្រើនភោគៈទាំងឡាយផង ស្គាល់សេចក្តីសាបសូន្យភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតតាមសមគួរ មិនទូលាយពេក មិនត្បិតត្បៀតពេក ដោយបំណងយ៉ាងនេះថា សេចក្តីចម្រើនរបស់អាត្មាអញនឹងគ្របសង្កត់សេចក្តីវិនាសបាន ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងមិនគ្របសង្កត់សេចក្តីចម្រើនយ៉ាងនេះបានទេ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអ្នកថ្លឹងក្តី សិស្សរបស់អ្នកថ្លឹងក្តី លើកជញ្ជីងឡើងហើយដឹងថា ស្រាលព្រោះ (ខ្វះ)ប៉ុណ្ណេះ ឬធ្ងន់ព្រោះ (លើស) ប៉ុណ្ណេះ យ៉ាងណាមិញ*

ម្នាលភិក្ខុទាំងឡាយ កុលបុត្តស្គាល់សេចក្ដីចម្រើននូវភោគៈទាំងឡាយផង ស្គាល់សេចក្ដីសាបសូន្យភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិត តាមសមគួរ មិនទូលាយដៃពេក មិនត្បិតត្បៀតពេក ដោយបំណងយ៉ាងនេះថា សេចក្ដីចម្រើន របស់អាត្មាអញ នឹងគ្របសង្កត់សេចក្ដីវិនាសបាន ឯសេចក្ដីវិនាសរបស់អាត្មាអញ នឹងមិនអាចគ្របសង្កត់សេចក្ដីចម្រើន យ៉ាងនេះបានទេ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកុលបុត្តនេះ មានសេចក្ដីចម្រើនតិច គឺខ្វត់ទ្រព្យ ហើយចិញ្ចឹមជីវិតលើសលុប អ្នកផងតែងតិះដៀលកុលបុត្តនោះថា កុលបុត្តនេះ ស៊ីភោគៈដូចគេស៊ីផ្លែល្វា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកុលបុត្តនេះ មានសេចក្ដីចម្រើនច្រើន គឺ មានទ្រព្យ ហើយចិញ្ចឹមជីវិតរលីបរលាប អ្នកផងតែងតិះដៀលកុលបុត្តនោះថា កុលបុត្តនេះ មុខតែនឹងស្លាប់ ឥតមានទីពឹង ។ ម្នាលភិក្ខុទាំងឡាយ កាលណាកុលបុត្តនេះ ស្គាល់សេចក្ដីចម្រើនភោគៈទាំងឡាយផង ស្គាល់សេចក្ដីវិនាសភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនទូលាយដៃពេក មិនត្បិតត្បៀតពេក ដោយបំណងថា សេចក្ដីចម្រើនរបស់អាត្មាអញ

នឹងគ្របសង្កត់សេចក្ដីវិនាសបាន ឯសេចក្ដីវិនាសរបស់អាត្មាអញ នឹងមិនអាចគ្របសង្កត់សេចក្ដីចម្រើនយ៉ាងនេះបានទេ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សមជីវិតា** ។

សទ្ធាសម្បទា ៖ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ជាអ្នកមានសទ្ធា ជឿការត្រាស់ដឹងរបស់ព្រះតថាគត ព្រះមានព្រះភាគអង្គនោះ ។បេ។ ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវសច្ចៈទាំង ៤ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សទ្ធាសម្បទា** ។

សីលសម្បទា ៖ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ជាអ្នកវៀរចាកកិរិយាសម្លាប់សត្វ ។បេ។ ជាអ្នកវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺការផឹកនូវទឹកស្រវឹងបានខាងឯសុរានិងមេរ័យ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **សីលសម្បទា** ។

ចាគសម្បទា ៖ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្ដីកំណាញ់ ហើយនៅគ្រប់គ្រងផ្ទះ ។បេ។ ជាអ្នកគួរឲ្យគេសូមបាន ត្រេកអរក្នុងការឲ្យនិងការចែករំលែក ម្នាលភិក្ខុទាំងឡាយ នេះហៅថា

ចាគសម្បទា ។

បញ្ញាសម្បទា ៖ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ជាអ្នកមានបញ្ញា ។បេ។ ជាដំណើរអាចយល់សេចក្តីអស់ទៅនៃទុក្ខដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បញ្ញាសម្បទា ។

ម្នាលភិក្ខុទាំងឡាយ នេះសម្បទាទាំង ៨ យ៉ាង ។

☞ បុគ្គលអ្នកប្រឹងប្រែង មានវិធានការ មិនបណ្តែតបណ្តោយក្នុងការងារទាំងឡាយ តែងចិញ្ចឹមជីវិតស្មើ រក្សាទ្រព្យដែលខ្លួនរកបានមក មានសទ្ធា បរិបូរណ៍ដោយសីល ឈ្លាសក្នុងសំដី លះចោលសេចក្តីកំណាញ់ ជម្រះនូវផ្លូវសម្រាប់ទៅកាន់លោកខាងមុខ ឲ្យមានសួស្តីជានិច្ច ធម៌ទាំង ៨ យ៉ាងនេះនាំមកនូវសេចក្តីសុខ ក្នុងលោកទាំងពីរ ដែលព្រះសម្ពុទ្ធទ្រង់ព្រះនាមថាសច្ចៈ ទ្រង់សម្តែងហើយ ដល់កុលបុត្តអ្នកមានសទ្ធា នៅគ្រប់គ្រងផ្ទះ មួយទៀត ការបរិច្ចាគ និងបុណ្យដ៏សេសនេះ តែងចម្រើនដល់ពួកគ្រហស្ថ ដើម្បីសេចក្តីចម្រើននិងប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងលោក

*ខាងមុខផង យ៉ាងនេះ ។* *(សុត្តន្ត. ៤៨ / ៣២២)*

## សប្បុរិសទាន ៨ យ៉ាង

១-សុចឹ ទេតិ *បុគ្គលឲ្យវត្ថុស្អាត*

២-បណីតំ ទេតិ *ឲ្យវត្ថុថ្លៃថ្លា*

៣-កាលេន ទេតិ *ឲ្យតាមកាល*

៤-កប្បិយំ ទេតិ *ឲ្យវត្ថុគួរ*

៥-វិចេយ្យ ទេតិ *ជ្រើសរើសហើយទើបឲ្យ*

៦-អភិណ្ហំ ទេតិ *ឲ្យទានរឿយៗ*

៧-ទទំ ចិត្តំ បសាទេតិ *កំពុងឲ្យញុំាងចិត្ត ឲ្យជ្រះថ្លា*

៨-ទត្វា អត្តមនោ ហោតិ *លុះឲ្យហើយ រមែងមានសេចក្តីពេញចិត្ត ។*

☞ *បុគ្គលរមែងឲ្យនូវទានទាំងឡាយ គឺ ទឹកនិងភោជន ដ៏ស្អាតថ្លៃថ្លា តាមកាល វត្ថុដ៏គួររឿយៗ ចំពោះព្រហ្មចារី*

*បុគ្គលទាំងឡាយដូចជាស្រែដ៏ល្អ ពួកអ្នកប្រាជ្ញ រមែងសរសើរនូវទានទាំងឡាយ ដែលបុគ្គលលះបង់នូវអាមិសៈជាច្រើន ដែលមិនគួរឲ្យកើតសេចក្តីក្តៅក្រហាយ ហើយឲ្យយ៉ាងនេះ អ្នកប្រាជ្ញមានបញ្ញា ជាអ្នកមានសទ្ធា បានបូជាយ៉ាងនេះហើយ មានចិត្តរួចស្រឡះ រមែងចូលទៅកាន់ទេវលោកដែលមិនមានសេចក្តីទុក្ខ មានតែសេចក្តីសុខ ។ (សុត្តន្តបិដក ៤៨,១៧៣)*

## ការកើតឡើងនៃទានមាន ៨ យ៉ាង

*១-បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទាន គឺ បាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ និងប្រទីបជាទាន ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យនូវវត្ថុណា ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ ឃើញពួកខត្តិយមហាសាលក្តី ព្រាហ្មណមហាសាលក្តី គហបតិមហាសាលក្តី ដែលកំពុងឆ្អែតស្កប់ស្កល់ ម្ចូលមិត្រ បម្រើដោយកាមគុណទាំង ៥ ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ! អញលុះតែបែកធ្លាយ រាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកខត្តិយមហាសាល*

ក្តី ព្រាហ្មណមហាសាលក្តី គហបតិមហាសាលក្តី បុគ្គលនោះ ក៏តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណ ធម៌ដ៏លើសលប់ឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកខត្តិយមហាសាលខ្លះ ព្រាហ្មណមហាសាលខ្លះ គហបតិមហាសាលខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេច ព្រោះចិត្តដ៏បរិសុទ្ធ ។

២-ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទាន គឺបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ ប្រទីបជាទាន ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យនូវវត្ថុណា ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ បានឮថា ពួកទេវតាចាតុម្មហារាជិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា “ឱហ្ន៎ ! អាត្មាអញ

លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ” បុគ្គលនោះ ក៏តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ដ៏លើសលប់ឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេច ព្រោះចិត្តដ៏បរិសុទ្ធ ។

៣-៧ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទាន គឺបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ និងប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ ឲ្យនូវវត្ថុណា ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ បានឮថា ពួកទេវតាតាវត្តិង្ស ។បេ។ ពួកទេវតាយាម... ពួកទេវតាតុសិតៈ... ពួកទេវតានិម្មានរតី... ពួកទេវតាបរនិម្មិតវសវត្តី... មានអាយុ

វែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ! អាត្មាអញ លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី... បុគ្គលនោះ ក៏តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ដ៏លើសលប់ឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី... ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេច ព្រោះចិត្តដ៏បរិសុទ្ធ ។

៨-ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានគឺ បាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ ឲ្យនូវវត្ថុណា ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ បានឮថា ពួកទេវតា

ព្រហ្មកាយិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្ដីសុខច្រើន បុគ្គលនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា “ឱហ្ន៎ ! អាត្មាអញ លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាព្រហ្មកាយិកៈ បុគ្គលនោះ ក៏តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ដ៏លើសលប់ឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាព្រហ្មកាយិកៈ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ទានចំពោះបុគ្គលប្រាសចាករាគៈ មិនចំពោះបុគ្គលប្រកបដោយរាគៈទេ ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេច ព្រោះប្រាសចាករាគៈ ។ ការកើតឡើងនៃទាន មាន ៨ ប្រការនេះឯង ។

(សុត្តន្តបិដក ៤៨ / ១៦៤-១៦៨)

## អដ្ឋកថា ទានូបបត្តិសូត្រ

*បទថា ទានូបបត្តិយោ បានដល់* **ឧបបត្តិ** *(ការកើតឡើង) មានទានជាបច្ច័យ ។ បទថា* បទហតិ *ប្រែថា "តាំងទុក"។ បទថា* អធិដ្ឋាតិ *ជាវេវចនៈ របស់ពាក្យថា* បទហតិ *នោះឯង ។ បទថា* ភាវេតិ *"ឲ្យចម្រើន" ។*

*បទថា* ហីនេធិមុត្តំ *បានដល់ ឱនទៅក្នុងចំណែកទាប គឺកាមគុណ ៥ ។ បទថា* ឧត្តរឹ អភាវិតំ *បានដល់ មិនបាន អប់រំដើម្បីជាប្រយោជន៍ដល់មគ្គនិងផល ខ្ពស់ឡើងជាងនោះ ។ បទថា* តត្តូបបត្តិយា សំវត្តតិ *សេចក្តីថា រមែងប្រព្រឹត្តទៅ ដើម្បីត្រូវការកើតក្នុងឋានដែលខ្លួនប្រាថ្នាហើយ ធ្វើកុសល ។ បទថា* វីតរាគស្ស *បានដល់ អ្នកដកកាគៈដោយមគ្គ ឬអ្នក គ្របសង្កត់រាគៈដោយសមាបត្តិ ។ មែនពិត ត្រឹមតែទាន ប៉ុណ្ណោះ មិនអាចនឹងកើតក្នុងព្រហ្មលោកបាន តែទាន រមែង ជាគ្រឿងប្រដាប់ជុំវិញរបស់ចិត្ត ដែលប្រកបដោយសមាធិ និង វិបស្សនា តាំងអំពីនោះ បុគ្គលអ្នកមានចិត្តទន់ ដោយការឲ្យ ទាន ចម្រើនព្រហ្មវិហារ កើតក្នុងព្រហ្មលោក ដោយហេតុនោះ*

*ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា វីតរាគស្ស ទោសរាគស្ស ដូច្នេះ ។ (មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ)*

## សេចក្ដីសាបសូន្យ ៨ យ៉ាង

១-សទ្ធា នត្ថិ កុសលេសុ ធម្មេសុ
*មិនមានសទ្ធាក្នុងកុសលធម៌*

២-ហិរិ នត្ថិ កុសលេសុ ធម្មេសុ
*មិនមានហិរិក្នុងកុសលធម៌*

៣-ឱតប្បំ នត្ថិ កុសលេសុ ធម្មេសុ
*មិនមានឱត្តប្បៈក្នុងកុសលធម៌*

៤-វីរិយំ នត្ថិ កុសលេសុ ធម្មេសុ
*មិនមានវិរិយៈក្នុងកុសលធម៌*

៥-បញ្ញា នត្ថិ កុសលេសុ ធម្មេសុ
*មិនមានបញ្ញា ក្នុងកុសលធម៌*

៦-កោធនោ *មានសេចក្ដីក្រោធ*

៧-ឧបនាហី *មានការចងគំនុំ*

៨-ន សន្តិ ភិក្ខូ ឱវាទកា មិនមានពួកភិក្ខុ
ជាអ្នកទូន្មាន ។

## សេចក្តីចម្រើន ៨ យ៉ាង

១-សទ្ធា អត្ថិ កុសលេសុ ធម្មេសុ
មានសទ្ធាក្នុងកុសលធម៌

២-ហិរិ អត្ថិ កុសលេសុ ធម្មេសុ
មានហិរិក្នុងកុសលធម៌

៣-ឱតប្បំ អត្ថិ កុសលេសុ ធម្មេសុ
មានឱត្តប្បៈ ក្នុងកុសលធម៌

៤-វីរិយំ អត្ថិ កុសលេសុ ធម្មេសុ
មានវីរិយៈ ក្នុងកុសលធម៌

៥-បញ្ញា អត្ថិ កុសលេសុ ធម្មេសុ
មានបញ្ញា ក្នុងកុសលធម៌

៦-អក្កោធនោ មិនមានសេចក្តីក្រោធ

៧-អនុបនាហី មិនមានការចងគំនុំ

៨-សន្តិ ភិក្ខុ ឲ្យាធការ មានពួកភិក្ខុជាអ្នកទទួនាន ។
(សុត្តន្ត. ៣២ , ១៣៨-១៤៤)

## មហាសំវេគវត្ថុ ៨ យ៉ាង

មហាសំវេគវត្ថុ ៨ យ៉ាង គឺ ជាតិ ជរា ព្យាធិ មរណៈ អបាយទុក្ខ ៤ ឈ្មោះមហាសំវេគវត្ថុ ៨ ។

ន័យមួយទៀត ជាតិជរាព្យាធិមរណៈ ៤ អបាយទុក្ខ ជាគំរប់ ៥ ទុក្ខមានវដ្ដៈជាមូលក្នុងអតីត ១ ទុក្ខមានវដ្ដៈជាមូលក្នុងអនាគត ១ ទុក្ខមានការស្វែងរកអាហារជាមូលក្នុងបច្ចុប្បន្ន ១ ។

# ពួក ៩

## ព្រះពុទ្ធវចនៈមានអង្គ ៩

*សេចក្ដីថា ក៏ព្រះពុទ្ធវចនៈទាំងអស់មាន ៩ ប្រភេទគឺ* ***សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភុតធម្មៈ*** *និង* ***វេទល្លៈ*** *។*

*បណ្ដាព្រះពុទ្ធវចនៈដែលមានអង្គ ៩ នោះ ឧភតោវិភង្គ និទ្ទេស ខន្ធកៈ បរិវារៈ និងព្រះសូត្រ មានមង្គលសូត្រ រតន-សូត្រ នាលកសូត្រ និងតុវដ្ដកសូត្រជាដើម ក្នុងសុត្តនិបាត និងព្រះតម្រាស់របស់ព្រះតថាគត ដែលមានឈ្មោះថាសូត្រ សូម្បីដទៃ គប្បីជ្រាបថាជា* ***សុត្តៈ*** *។*

*ព្រះសូត្រដែលមានគាថាសូម្បីទាំងអស់ គប្បីជ្រាបថាជា* ***គេយ្យៈ*** *។ សគាថវគ្គទាំងអស់ ក្នុងសំយុត្តនិកាយ គប្បីជ្រាបថា* ***គេយ្យៈ*** *ដោយពិស្ដារ ។*

*ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថាលាយ និង ពុទ្ធវចនៈសូម្បីដទៃដែលមិនបានសង្គ្រោះចូលដោយអង្គ ៨ គប្បីជ្រាបថាជា* ***វេយ្យាករណៈ*** *។*

ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះថាសូត្រ ក្នុងសុត្តនិបាត គប្បីជ្រាបថាជា **គាថា** ។

ព្រះសូត្រ ៨២ សូត្រ ដែលបដិសំយុត្តដោយគាថាដែលសម្រេចដោយសោមនស្សញ្ញាណ គប្បីជ្រាបថា ជា **ឧទាន** ។

ព្រះសូត្រ ១១០ សូត្រ ដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា "**វុត្តំ ហេតំ ភគវតា** ពាក្យនេះ សមដូចពាក្យដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយ" គប្បីជ្រាបថាជា **ឥតិវុត្តកៈ** ។

ជាតក ៥៥០ មានអបណ្ណកជាតកជាដើម គប្បីជ្រាបថាជា **ជាតក** ។

ព្រះសូត្រដែលប្រកបដោយអច្ឆរិយព្ភូតធម៌ សូម្បីទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា "ម្នាលភិក្ខុ-ទាំងឡាយ អច្ឆរិយព្ភូតធម៌ ៤ ប្រការនេះ រមែងមានក្នុងព្រះអានន្ទ" គប្បីជ្រាបថាជា **អព្ភូតធម្ម** ។

ព្រះសូត្រដែលមានមនុស្សជាដើមទូលសួរហើយ បានទូវការដឹង និងសេចក្តីត្រេកអរសូម្បីទាំងអស់ មានចូឡវេទល្ល-

*សូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហាសូត្រ សង្ខារភាជនីសូត្រ និងមហាបុណ្ណមសូត្រជាដើម គប្បីជ្រាបថាជា* ***វេទល្លៈ*** *។*

*កាលពោលដោយអង្គ ព្រះពុទ្ធវចនៈមានអង្គ ៩ ដោយប្រការដូច្នេះ ។ (សមន្តប្បាសាទិកា ១ / ៤៥)*

## ហេតុនៃសេចក្ដីចម្រើននូវពួកធម៌ ជាចំណែកនៃធម៌ជាគ្រឿងត្រាស់ដឹង

*១-ភិក្ខុក្នុងសាសនានេះ ជាអ្នកមានមិត្រល្អ មានសម្លាញ់ល្អ សេពគប់នឹងមិត្រល្អ*

*២-ភិក្ខុជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូរណ៍ដោយអាចារៈ និងគោចរៈ ឃើញនូវភ័យក្នុងទោសទាំងឡាយសូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។*

*៣-ភិក្ខុជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាផូរផង់ជាទីសប្បាយទូលាយចិត្ត គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេក-*

កថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា

៤-ភិក្ខុជាអ្នកប្រារព្ធនូវសេចក្ដីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ចេញ ដើម្បីញុំាងពួកកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្ដីប្រឹងប្រែងខ្ជាប់ខ្ជួន មិនដាក់ចុះនូវធុរៈចោលក្នុងធម៌ទាំងឡាយជាកុសល

៥-ភិក្ខុជាអ្នកមានបញ្ញា ប្រកបដោយបញ្ញាដែលអាចកំណត់នូវការកើតឡើងនិងការវិនាសទៅ (នៃខន្ធបញ្ចកៈ) ជាគ្រឿងទំលាយនូវកិលេសដ៏ប្រសើរ ជាធម្មជាតិដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។

***ម្យ៉ាងទៀត ភិក្ខុនោះតាំងនៅក្នុងធម៌ទាំង ៥ នេះ ហើយគប្បីចម្រើននូវធម៌ ៤ យ៉ាងតទៅទៀត គឺ***

*១-ចម្រើនអសុភ ដើម្បីលះរាគៈ*

*២-ចម្រើនមេត្តា ដើម្បីលះព្យាបាទ*

*៣-ចម្រើនអានាបានស្សតិ ដើម្បីផ្ដាច់ផ្ដិលនូវវិតក្កៈ*

*៤-ចម្រើនអនិច្ចសញ្ញា ដើម្បីដកចោលនូវអស្មិមានះ ។*

*សេចក្ដីសម្គាល់ថា មិនមែនខ្លួន រមែងប្រាកដដល់ភិក្ខុ*

អ្នកមានសេចក្ដីសម្គាល់ថា មិនទៀង ភិក្ខុអ្នកមានសេចក្ដីសម្គាល់ថាមិនមែនខ្លួន រមែងដល់នូវព្រះនិព្វាន ជាគ្រឿងដកចោលនូវអស្មិមានះក្នុងបច្ចុប្បន្ន ។ (សុត្តន្ត. ៤៩ / ២)

## ការខ្ពង់ខ្ពស់ជាងគ្នា

ពួកមនុស្សអ្នកនៅក្នុងឧត្តរកុរុទ្វីប ខ្ពង់ខ្ពស់ហួសពួកទេវតាជាន់តាវត្តិង្សផង និងពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាង

១–អបរិគ្គហា មិនមានសេចក្ដីអន្ទះសា

២–និយតាយុកា មិនមានសេចក្ដីហួងហែង

៣–វិសេសភុនោ មានអាយុទៀង មានកំណើតដ៏វិសេស ។

ពួកទេវតាជាន់តាវត្តិង្ស ខ្ពង់ខ្ពស់ហួសពួកមនុស្ស អ្នកនៅក្នុងឧត្តរកុរុទ្វីបផង និង ពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីបផង ដោយស្ថាន ៣ យ៉ាង

១–ទិព្វេន អាយុនា អាយុជាទិព្វ

២-ឧត្តរកុរុ វណ្ណេន សម្បុរជាទិព្វ

៣-ឧត្តរកុរុ សុខេន សុខជាទិព្វ ។

ពួកមនុស្សអ្នកនៅក្នុងជម្ពូទ្វីប ខ្ពង់ខ្ពស់ហួសពួកមនុស្ស នៅក្នុងឧត្តរកុរុទ្វីបផង និងពួកទេវតាជាន់តាវត្តិង្សផង ដោយស្ថាន ៣ យ៉ាង

១-សូរា មានសេចក្តីក្លៀវក្លា

២-សតិមន្តោ មានស្មារតី (ខ្ជាប់ខ្ជួន)

៣-អធិព្រហ្មចរិយវាសោ មានការបំពេញ ព្រហ្មចរិយធម៌ដ៏វិសេស ។ (សុត្តន្ត. ៤៩ / ៨៤)

## សត្តាវាសមាន ៩

(ប្រទេសជាទីនៅរបស់សត្វ)

១-ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ក៏មាន ដូចពួកមនុស្សនិងទេវតាពួកខ្លះ និងអសុរកាយពួកខ្លះ

២-ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ក៏មាន ដូចពួកព្រហ្មកាយិកាទេវតា ដែលកើតក្នុងជាន់ បឋមជ្ឈានភូមិ

៣-ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ក៏មាន ដូចពួកទេវតាជាន់អភស្សរៈ

៤-ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ក៏មាន ដូចពួកទេវតាជាន់សុភកិណ្ហៈ

៥-ពួកសត្វឥតសញ្ញា ឥតមានទទួលការដឹង ក៏មាន ដូចពួកទេវតាជាន់អសញ្ញីសត្វ

៦-ពួកសត្វលុះបានកន្លងរូបសញ្ញា បានរម្ងាប់បដិឃ-សញ្ញា មិនបានធ្វើទុកក្នុងចិត្តចំពោះនានត្តសញ្ញា ដោយប្រការទាំងពួង ហើយបានដល់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ ក៏មាន

៧-ពួកសត្វកន្លងអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ក៏មាន

៨-ពួកសត្វកន្លងវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមានដូច្នេះ

៩-ពួកសត្វកន្លងអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នៅសញ្ញានាសញ្ញាយតនជ្ឈាន.

(សុត្តន្ត. ៤៩ / ៩២)

## វិបស្សនាញាណ ៩

១-ឧទយព្វយានុបស្សនាញាណ ញាណដែលដឹងការកើត និងការរលត់របស់សង្ខារទាំងឡាយ ។

២-ភង្គានុបស្សនាញាណ ញាណដែលលែងចោល (មិនកាន់យក) នូវការកើត ហើយពិចារណាត្រឹមតែការរលត់ ។

៣-ភយតុបដ្ឋានញាណ ញាណដែលសម្លឹងមើលអាការរបស់សង្ខារដែលប្រាកដហើយ ដោយអំណាចនៃគន្ធជារបស់គួរខ្លាច ដូចការសម្លឹងមើលអាការរបស់សត្វកាចមានសីហជាដើមដែលគួរខ្លាច ។

៤-អាទីនវានុបស្សនាញាណ ញាណដែលសម្លឹងមើលអាការត្រង់ទោសនៃសង្ខារ ដែលខ្លួនឃើញហើយ ដោយអាការគួរខ្លាចយ៉ាងនោះ ដូចជាការឃើញទោសនៃផ្ទះដែល

ភ្លើងឆេះសព្វទាំងអស់ហើយ ។

៥-និព្វិទានុបស្សនាញាណ ញាណដែលប្រព្រឹត្ត ទៅដោយការនឿយណាយ ក្នុងខន្ធដែលមានទោស ដែល ឃើញហើយ ។

៦-មុញ្ចិតុកម្យតាញាណ ញាណដែលប្រព្រឹត្តទៅ ដោយអំណាចជាអ្នកប្រាថ្នា ដើម្បីនឹងចេញឱ្យផុតទៅពីធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ នោះ ដូចសត្វមានត្រីជាដើម ត្រូវការរួចផុតចាកគ្រឿងទាក់ មានសំណាញ់ជាដើម ។

៧-បដិសង្ខានុបស្សនាញាណ ញាណដែល ប្រព្រឹត្តទៅដោយអំណាចនៃការពិចារណារឿយៗ ក្នុងខន្ធ សូម្បី ដែលមានទោសដែលខ្លួនឃើញហើយ ដើម្បីញ៉ាំងឧបាយនៃ ការរួចផុត ឲ្យដល់ព្រមដូចបក្សីសមុទ្រ ដូច្នោះ ។

៨-សង្ខារុបេក្ខាញាណ ញាណដែលប្រព្រឹត្តទៅ ដោយអាការ គឺការព្រងើយកន្តើយក្នុងសង្ខារទាំងនោះ ដែល មានទោស ដែលខ្លួនឃើញហើយ ដូចបុរសមានភរិយា លែងលះហើយ ដូច្នោះ ។

៩–អនុលោមញាណ ញាណទី ៩ គឺ សច្ចានុលោមិកញាណដែលប្រព្រឹត្តទៅក្នុងមគ្គវិថី មុនគោត្រភូញាណ ដោយអនុលោមដល់វិបស្សនាញាណ ៨ ដែលប្រព្រឹត្តទៅហើយក្នុងកាលមុន ព្រោះមានលក្ខណៈ មានអនិច្ចលក្ខណៈជាដើមជាអារម្មណ៍ និងដល់ពោធិបក្ខិយធម៌ ៣៧ ដែលនឹងសម្រេចក្នុងខណៈនៃមគ្គខាងលើ ។

រួមជា ៩ ប្រការ ឈ្មោះថា បដិបទាញាណទស្សនវិសុទ្ធិ ព្រោះជាបដិបទានៃការបរិសុទ្ធិរបស់ញាណទស្សនៈ ដោយអត្ថថា ដឹងត្រៃលក្ខណ៍ ដោយអត្ថថា ឃើញដោយប្រចក្ស និងព្រោះបរិសុទ្ធចាកធម៌ជាសត្រូវ ។

(ចាកវិសុទ្ធិមគ្គ និង អភិធម្មត្ថសង្គហៈ)

# ពួក១០

## នាថករណធម៌

(ធម៌សម្រាប់ធ្វើឱ្យមានទីពឹង)

*ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ៖ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាបុគ្គលមានទីពឹង កុំជាបុគ្គលមិនមានទីពឹងឡើយ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានទីពឹង រមែងនៅជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នាថករណធម៌ (ធម៌សម្រាប់ធ្វើឲ្យមានទីពឹង) នេះមាន ១០ យ៉ាង*

១–ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ចាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរ–សម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូរណ៍ដោយអាចារៈ និងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។*

២-ភិក្ខុ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ, យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ, តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា, *ភិក្ខុជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ សន្សំនូវពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា មានលំអបទដើម លំអបទ កណ្តាល លំអបទចុង ប្រកាសនូវព្រហ្មចរិយៈ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏បរិបូរណ៍បរិសុទ្ធទាំងអស់ ធម៌មានសភាពដូច្នោះ ភិក្ខុនោះ ក៏ចេះចាំច្រើន បានចាំទុក ចាំជាប់ក្នុងចិត្ត បានចាក់ធ្លុះល្អ ដោយទិដ្ឋិ ។*

៣-ភិក្ខុ កល្យាណមិត្តោ ហោតិ កល្យាណ-សហាយោ កល្យាណសម្បវង្កោ *ភិក្ខុមានមិត្តល្អ មាន*

*សំឡាញ់ល្អ ជាអ្នកពត់ខ្លួនតាមមិត្តសំឡាញ់ល្អ ។*

៤-ភិក្ខុ សុវចោ ហោតិ សោវចស្ស-ករណេហិ ធម្មេហិ សមន្នាគតោ, ខមោ បទក្ខិណាគ្គាហី អនុសាសនឹ, *ភិក្ខុជាអ្នកប្រដៅងាយ ប្រកបដោយធម៌ទាំងឡាយ ជាគ្រឿងធ្វើឲ្យប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅដោយផ្ចិតផ្ចង់ ។*

៥-ភិក្ខុ យានិ តានិ សព្រហ្មចារីនំ ឧច្ចាវចានិ កឹករណីយានិ. តត្ថ ទក្ខោ ហោតិ អនលសោ តត្រុចាយាយ វីមំសាយ សមន្នា-គតោ, អលំ កាតុំ អលំ សំវិធាតុំ ។ *អំពើណាដ៏ខ្ពស់និងទាប ដែលពួកសព្រហ្មចារីបុគ្គល ត្រូវសួរគ្នីគ្នា ហើយទើបធ្វើ ភិក្ខុជាអ្នកឈ្លាសវៃ មិនខ្ជិលច្រអូស ក្នុងអំពើនោះ ប្រកបដោយការពិចារណា ដោយឧបាយក្នុងអំពើនោះថា គួរធ្វើគួរចាត់ចែងបាន ។*

៦-ភិក្ខុ ធម្មកាមោ ហោតិ បិយសមុទា-

ហារោ, អភិធម្មេ អភិវិនយេ ឧឡារបាមុជ្ជោ ។ *ភិក្ខុជាអ្នកប្រាថ្នាធម៌ ពេញចិត្តនឹងការនិយាយធម៌ មានសេចក្ដីរីករាយដ៏លើសលុប ក្នុងអភិធម៌ និងអភិវិន័យ ។*

៧-ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ, កុសលានំ ធម្មានំ ឧបសម្បទាយ, ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ, *ភិក្ខុជាអ្នកប្រារព្ធ ព្យាយាមដើម្បីលះបង់នូវអកុសលធម៌ និងញុំាងពួកកុសលធម៌ ឲ្យសម្រេចជាអ្នកមានកម្លាំង សង្វាតមាំមួន មិនដាក់ចុះ នូវធុរៈក្នុងកុសលធម៌ទាំងឡាយ ។*

៨-ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរ-បិណ្ឌបាត- សេនាសន- គិលានប្បច្ចយភេសជ្ជ-បរិក្ខារេន : *ភិក្ខុជាអ្នកសន្ដោស ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមាន តាមបាន ។*

៩-ភិក្ខុ សតិមា ហោតិ បរមេន សតិនេ-បក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ។ *ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងបញ្ញាដ៏ឧត្តម ជាអ្នករលឹកឃើញ រលឹកតាមនូវអំពើដែលធ្វើយូរហើយផង នូវពាក្យដែលនិយាយយូរហើយផង ។*

១០-ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិ-និយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិ-កាយ សម្មា ទុក្ខក្ខយគាមិនិយា : *ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាគ្រឿងដឹងនូវការកើត និងការរលត់នៃ(ខន្ធ)ដ៏ប្រសើរ ជាប្រាជ្ញាសម្រាប់ទំលុះទំលាយនូវកិលេស ប្រព្រឹត្តទៅក្នុងធម៌ជាគ្រឿងអស់ទៅនៃទុក្ខ ដោយប្រពៃ ។* *(សុត្តន្តបិដក ៥០ / ៥១)*

## កថាវត្ថុ ១០

១-អប្បិច្ឆកថា *ពោលដោយការប្រាថ្នាតិច*

២-សន្តុដ្ឋិកថា ពោលដោយការសន្តោស

៣-បវិវេកកថា ពោលដោយការស្ងប់ស្ងាត់

៤-អសំសគ្គសកថា ពោលដោយការ
មិនជាប់ជំពាក់

៥-វីរិយារម្ភកថា ពោលការប្រារព្ធសេចក្ដីព្យាយាម

៦-សីលកថា ពោលដោយសីល

៧-សមាធិកថា ពោលដោយសមាធិ

៨-បញ្ញាកថា ពោលពាក្យនាំឲ្យកើតបញ្ញា

៩-វិមុត្តិកថា ពោលដោយវិមុត្តិ (ការរួចផុត)

១០-វិមុត្តិញ្ញាណទស្សនកថា ពោលដោយ
វិមុត្តិញ្ញាណទស្សនៈ ។

## ឱវាទ ១០ យ៉ាង

១-អន្តោអគ្គិ ពហិ ន នីហរិតព្វោ មិនគួរនាំភ្លើង
ខាងក្នុងចេញទៅខាងក្រៅ

២-ពហិអអគ្គិ អន្តោ ន បវេសេតព្វោ មិនគួរនាំភ្លើង
ខាងក្រៅចូលមកខាងក្នុង
៣-ទទន្តស្សេវ ទាតព្វំ គប្បីឲ្យដល់អ្នកដែលឲ្យប៉ុណ្ណោះ
៤-អទទន្តស្ស ន ទាតព្វំ មិនគប្បីឲ្យដល់អ្នកដែលមិនឲ្យ
៥-ទទន្តស្សាបិ អទទន្តស្សាបិ ទាតព្វំ គប្បីឲ្យដល់អ្នក
ទាំងដែលឲ្យ ទាំងដែលមិនឲ្យ
៦-សុខំ និសីទិតព្វំ គប្បីអង្គុយឲ្យជាសុខ
៧-សុខំ ភុញ្ជិតព្វំ គប្បីបរិភោគឲ្យជាសុខ
៨-សុខំ និបជ្ជិតព្វំ គប្បីដេកឲ្យជាសុខ
៩-អគ្គិ បរិចរិតព្វោ គប្បីបម្រើភ្លើង
១០-អន្តោទេវតា នមស្សិតព្វា គប្បីនមស្ការ
ទេវតាខាងក្នុង ។

## អ ធិ ប្បា យ

១-(ឱវាទទី ១ សេដ្ឋីពោលសំដៅយកសេចក្តីនេះថា) នាងឃើញទោសរបស់ឪពុកក្មេក និងស្វាមីរបស់នាងហើយ

កុំពោលក្នុងខាងក្រៅគឺ ក្នុងផ្ទះនោះៗ ព្រោះថា ដែលឈ្មោះថាភ្លើងដូចជាភ្លើងប្រភេទនេះ រមែងមិនមាន ។

២-(ឱវាទទី ២ សំដៅយកសេចក្ដីនេះថា) បើស្រី ឬប្រុសទាំងឡាយ ក្នុងស្រុកជិតផ្ទះអ្នកស្និទ្ធស្នាល និយាយដល់ទោសរបស់ឪពុកក្មេកនិងស្វាមី នាងកុំនាំយកពាក្យដែលជនទាំងនោះនិយាយហើយ មកនិយាយទៀតថា "អ្នកឈ្មោះឯណោះ និយាយលើកទោសយ៉ាងនេះ របស់លោកទាំងឡាយ" ព្រោះដែលឈ្មោះថា ភ្លើងដូចជាភ្លើងនោះ រមែងមិនមាន ។

៣-ក៏ពាក្យដែលបិតារបស់នាងទូន្មានថា "នែនាង នាងគួរឲ្យដល់ជនទាំងឡាយ ដែលឲ្យប៉ុណ្ណោះ" សេដ្ឋីពោលសំដៅយក (សេចក្ដីនេះ) ថា "គួរឲ្យដល់អ្នកដែលកាន់យកគ្រឿងឧបករណ៍ដែលខ្ចីទៅហើយ សងវិញប៉ុណ្ណោះ" ។

៤-សូម្បីពាក្យថា "មិនគួរឲ្យដល់អ្នកដែលមិនឲ្យ" នេះ សេដ្ឋីពោលសំដៅសេចក្ដីថា "មិនគួរឲ្យដល់អ្នកដែលកាន់យកគ្រឿងឧបករណ៍ដែលខ្ចីទៅហើយ មិនសងវិញ" ។

៥-ក៏ឯពាក្យថា "គួរឲ្យដល់អ្នកទាំងដែលឲ្យទាំងដែលមិនឲ្យ" នេះ សេដ្ឋីពោលសំដៅសេចក្តីថា "កាលញាតិ និងមិត្តក្រលំបាកមកដល់ហើយ, ជនទាំងនោះ អាចនឹងសងវិញ ឬមិនអាចក៏ដោយ, ឲ្យដល់ញាតិនិងមិត្តទាំងនោះឯង គួរ" ។

**៦-"សុខំ និសីទិតព្វ"ន្តិ ឥទម្បិ សស្សុសសុរសាមិកេ ទិស្វា វុដ្ឋាតព្វដ្ឋានេ និសីទិតុំ ន វដ្តតីតិ សន្ធាយ វុត្តំ ។**

សូម្បីពាក្យថា "គប្បីអង្គុយជាសុខ" នេះ សេដ្ឋីពោលសំដៅសេចក្តីថា "មិនគួរអង្គុយក្នុងទីកន្លែង ឃើញម្តាយក្មេកឪពុកក្មេកនិងស្វាមីហើយ ត្រូវក្រោកឡើង " ។

៧-ចំណែកពាក្យថា "គប្បីបរិភោគជាសុខ" នេះ សេដ្ឋីពោលសំដៅសេចក្តីថា "ការមិនបរិភោគមុនឪពុកក្មេក និងស្វាមី បម្រើលោកទាំងនោះ ដឹងវត្ថុដែលលោកទាំងនោះ គ្រប់ៗ(វត្ថុ)លោកបានហើយ ឬមិនទាន់បាន ហើយខ្លួនឯងបរិភោគពេលក្រោយ ទើបគួរ" ។

៨-សូម្បីពាក្យថា "គប្បីដេកជាសុខ" នេះ សេដ្ឋីពោលសំដៅសេចក្តីថា "មិនគប្បីឡើងកាន់ទីដេក ដេកមុនឪពុក-

ក្មេកនិងស្វាមី, គួរធ្វើវត្តបដិបត្តិដែលខ្លួនគួរធ្វើដល់លោកទាំងនោះហើយ ខ្លួនឯងដេកពេលក្រោយ ទើបគួរ" ។

៩-ក៏ពាក្យថា "គប្បីបម្រើភ្លើង" នេះ សេចក្ដីពោលសំដៅសេចក្ដីថា "ការឃើញទាំងឪពុកក្មេកទាំងស្វាមី ឲ្យដូចជាគំនរភ្លើង និងដូចស្ដេចនាគ ទើបគួរ" ។

១០-សូម្បីពាក្យថា "គប្បីនមស្ការទេវតាខាងក្នុង" នេះ សេចក្ដីពោលសំដៅសេចក្ដីថា "ការឃើញឪពុកក្មេកនិងស្វាមី ឲ្យដូចជាទេវតា ទើបសមគួរ" ។

(គោលធម៌ ចាកអដ្ឋកថាធម្មបទ បុប្ផវគ្គ)

## សេចក្ដីក្រោធកើតមានដោយអាការ ១០ យ៉ាង

១-អនត្ថម្មេ អចរីតិ កោធោ ជាយតិ ក្រោធកើតព្រោះគិតថា គេបានប្រព្រឹត្តហើយនូវសេចក្ដីវិនាសដល់អញ

២-អនត្ថម្មេ ចរតីតិ កោធោ ជាយតិ ក្រោធកើតព្រោះគិតថា គេកំពុងប្រព្រឹត្តនូវសេចក្ដីវិនាសដល់អញ

៣-អនត្ថម្មេ ចរិស្សតីតិ កោធោ ជាយតិ ក្រោធកើតព្រោះគិតថា គេនឹងប្រព្រឹត្តនូវសេចក្តីវិនាសដល់អញ

៤-បិយស្ស មេ មនាបស្ស អនត្ថំ អចរីតិ ក្រោធកើតព្រោះគិតថា គេបានប្រព្រឹត្តហើយនូវសេចក្តីវិនាសដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ

៥-បិយស្ស មេ មនាបស្ស អនត្ថំ ចរតីតិ ថាគេកំពុងប្រព្រឹត្តនូវសេចក្តីវិនាស ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ

៦-បិយស្ស មេ មនាបស្ស អនត្ថំ ចរិស្សតីតិ ថាគេនឹងប្រព្រឹត្តនូវសេចក្តីវិនាស ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ

៧-អប្បិយស្ស មេ អមនាបស្ស អត្ថំ អចរីតិ ថាគេបានប្រព្រឹត្តហើយនូវសេចក្តីចម្រើន ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញ

៨-អប្បិយស្ស មេ អមនាបស្ស អត្ថំ ចរតីតិ ថាគេកំពុងប្រព្រឹត្តនូវសេចក្តីចម្រើន ដល់បុគ្គល មិនជាទី

ស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញ

៩-អប្បិយស្ស មេ អមនាបស្ស អត្ថំ ចរិស្សតីតិ ថា គេនឹងប្រព្រឹត្តនូវសេចក្ដីចម្រើន ដល់បុគ្គល មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញ

១០-អដ្ឋានេ កោបោ ជាយតិ ក្រោធកើត ក្នុងអំពើមិនជាហេតុ ។ (សុត្តន្តបិដក ៦៥ / ៦១)

## ហេតុនៃសេចក្ដីទុក្ខណាមួយក្នុងហេតុ ១០ យ៉ាង

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុ នៃសេចក្ដីទុក្ខណាមួយក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺ

១-គប្បីដល់នូវវេទនាដ៏អាក្រក់

២-សេចក្ដីវិនាសទ្រព្យ

៣-បែកធ្លាយសរីរៈ

៤-អាពាធជាទម្ងន់

៥-ក្រឡកចិត្ត (ឆ្កួត)

៦-រឹបជាន់អំពីស្ដេច

៧-ពោលពាក្យបង្អាច់ដ៏អាក្រក់

៨-អស់ពួកញាតិរលីង

៩-ពុកផុយភោគសម្បត្តិទាំងឡាយ

១០-ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះ របស់បុគ្គលនោះ.

បុគ្គលមិនមានប្រាជ្ញា លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។ (សុត្តន្ត. ៥២ / ៥១)

## ធម៌ ១០ យ៉ាង បព្វជិតគប្បីពិចារណារឿយៗ

១-វេវណ្ណិយម្ហិ អជ្ឈុបគតោតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ : បព្វជិតគប្បីពិចារណារឿយៗ ថា អាត្មាអញកាន់យកនូវភេទដ៏ប្លែកអំពីភេទរបស់គ្រហស្ថ

២-បរប្បដិពទ្ធា មេ ជីវិកាតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ : បព្វជិតគប្បីពិចារណារឿយៗ ថា ការប្រព្រឹត្តិចិញ្ចឹមជីវិត របស់អាត្មាអញប្រព្រឹត្តជាប់ដោយបុគ្គលដទៃ

៣-អញ្ញោ មេ អាកប្បោ ករណីយោតិ

បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ : *បព្វជិតគប្បីពិចារណារឿយៗ ថា អាកប្បកិរិយាផ្សេងអំពីគ្រហស្ថ អាត្មាអញគួរធ្វើ*

៤-កច្ចិ នុ ខោ មេ អត្តា សីលតោ ន ឧបវទតីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ : *បព្វជិតគប្បីពិចារណារឿយៗ ថាអាត្មាអញ មិនតិះដៀលខ្លួនឯងដោយសីលធម៌បានទេឬ*

៥-កច្ចិ នុ ខោ មំ អនុវិច្ច វិញ្ញូ សព្រហ្មចារី សីលតោ ន ឧបវទន្តីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ : *បព្វជិតគប្បីពិចារណារឿយៗ ថា ពួកសព្រហ្មចារី ជាវិញ្ញូជន គយគន់មើលហើយ មិនតិះដៀលអាត្មាអញ ដោយសីលធម៌បានទេឬ*

៦-សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ : *បព្វជិតគប្បីពិចារណារឿយៗ ថា ការ*

*ព្រាត់ប្រាសនិរាសចាកសត្វ និងសង្ខារទាំងអស់ ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃអាត្មាអញតែងមានជាធម្មតា*

៧-កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ : *បព្វជិតគប្បីពិចារណារឿយៗ ថា អាត្មាអញ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្ម ជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរលឹកឃើញ អាត្មាអញ នឹងធ្វើនូវកម្មណា ល្អ ឬអាក្រក់ អាត្មាអញ គង់នឹងបានជាអ្នកទទួលយកនូវផលនៃកម្មនោះពុំខានឡើយ*

៨-កថម្ភូតស្ស មេ រត្តិន្ទិវា វីតិបតន្តីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ : *បព្វជិតគប្បីពិចារណារឿយៗថា យប់និងថ្ងៃទាំងឡាយ ចេះតែកន្លងទៅៗ តើអាត្មាអញបានធ្វើដូចម្តេចខ្លះហើយ*

៩-កច្ចិ នុ ខោ អហំ សុញ្ញាគារេ

អភិរមាមីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ : *បព្វជិត គប្បីពិចារណារឿយៗថា សព្វថ្ងៃនេះ អាត្មាអញមាន សេចក្តីអភិរម្យត្រេកអរក្នុងផ្ទះស្ងាត់ដែរឬទេ*

១០-អត្ថិ នុ ខោ មេ ឧត្តរិមនុស្សធម្មា អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ, សោហំ បច្ឆិមេ កាលេ សព្រហ្មចារីហិ បុដ្ឋោ ន មង្កុ ភវិស្សាមីតិ បព្វជិតេន អភិណ្ហំ បច្ចវេក្ខិតព្វំ *បព្វជិតគប្បីពិចារណារឿយៗថា ឧត្តរិមនុស្សធម៌ គឺ ធម៌ជា របស់មនុស្សដ៏ប្រសើរក្រៃលែង មានដល់អាត្មាអញដែរឬ ធម៌ ដ៏វិសេស ដែលគួរនឹងឃើញ ដោយប្រាជ្ញាដ៏ប្រសើរ អាត្មាអញ បានត្រាស់ដឹងហើយ ឬ អាត្មាអញនោះ សព្រហ្មចារីទាំងឡាយ សួរក្នុងកាលជាទីបំផុត(មរណសម័យ) នឹងមិនអឹមអៀនទេឬ ។*

*(សុត្តន្ត. ៥០ / ១៨៨)*

# ពួក១១

## ទោស ១១ ប្រការរមែងកើតប្រាកដដល់បុគ្គល ជាអ្នកដេរ និងជាអ្នកគម្រាម

១-អនធិគតំ នាធិគច្ឆតិ មិនបាននូវគុណ-វិសេសដែលខ្លួនមិនទាន់បាន

២-អធិគតា បរិហាយតិ សាបសូន្យចាក គុណវិសេសដែលខ្លួនបានហើយ

៣-សទ្ធម្មស្ស ន វោទាយន្តិ ព្រះសទ្ធម្ម របស់ភិក្ខុនោះ មិនផូរផង់

៤-សទ្ធម្មេសុ អធិមានិកោ ហោតិ ប្រកបដោយសេចក្ដីស្មានថា បានក្នុងព្រះសទ្ធម្ម

៥-អនភិរតោ ព្រហ្មចរិយំ ចរតិ មិនត្រេកអរនឹងការប្រព្រឹត្តព្រហ្មចរិយ

៦-អញ្ញតរំ សង្កិលិដ្ឋំ អាបត្តឹ អាបជ្ជតិ ត្រូវអាបត្តិណាមួយដ៏សៅហ្មង

៧-សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ *លះបង់សិក្ខាហើយត្រឡប់មកដើម្បីភេទថោកទាប*

៨-គាឡ្ហំ រោគាតង្កំ ផុសតិ *តែងមានរោគឈឺថ្កាត់ដ៏ធ្ងន់*

៩-ឧម្មាទំ ចាបុណាតិ ចិត្តក្ខេបំ *តែងដល់នូវការឆ្កួត រវើរវាយចិត្ត*

១០-សម្មូឡ្ហោ កាលំ ករោតិ *តែងវង្វេងស្មារតីធ្វើមរណកាល*

១១-កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក ។*

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលតិះដៀលព្រះអរិយៈ ជេរប្រទេចពួកភិក្ខុជាសព្រហ្មចារី ហើយមិនគប្បីដល់នូវសេចក្តីវិនាសទាំង ១១ យ៉ាងណាមួយនោះ មិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ ។* (សុត្តន្ត. ៥១ / ២៣៨)

## ធម៌ ១១ ប្រការ ជាហេតុកើតវីរិយសម្ពោជ្ឈង្គ

*ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីនាំឲ្យកើតឡើងនៃវីរិយសម្ពោជ្ឈង្គ គឺ*

១-អបាយភយបច្ចវេក្ខណតា *ការពិចារណាឃើញភ័យក្នុងអបាយ*

២-អានិសំសទស្សាវិតា *ការឃើញអានិសង្ស*

៣-គមនវីថិបច្ចវេក្ខណតា *ការពិចារណាឃើញនូវផ្លូវដែលគួរទៅ*

៤-បិណ្ឌបាតាបចាយនតា *សេចក្ដីគោរពកោតក្រែងក្នុងបិណ្ឌបាត*

៥-ទាយជ្ជមហត្តបច្ចវេក្ខណតា *ការពិចារណាឃើញភាពជាធំនៃការទទួលទ្រព្យមត៌ក*

៦-សត្ថុមហត្តបច្ចវេក្ខណតា *ការពិចារណាឃើញមានព្រះសាស្ដាជាធំ*

៧-ជាតិមហត្តបច្ចវេក្ខណតា *ការពិចារណាសេចក្ដីមានជាតិជាធំ*

៨-សព្រហ្មចារិមហត្តបច្ចវេក្ខណតា ការពិចារណាសេចក្តីមានសព្រហ្មចារីជាធំ

៩-កុសីតបុគ្គលបរិវជ្ជនតា ការវៀរចាកបុគ្គលខ្ជិលច្រអូស

១០-អារទ្ធវីរិយបុគ្គលសេវនតា ការគប់រកបុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម

១១-តទធិមុត្តតា បង្អោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គនោះ ។

## ១.ការពិចារណាឃើញភ័យក្នុងអបាយ

បណ្តាធម៌ ១១ ប្រការនោះ កាលភិក្ខុអ្នកចម្រើនវីរិយសម្ពោជ្ឈង្គ សូម្បីពិចារណាឃើញភ័យក្នុងអបាយ យ៉ាងនេះថា អ្នកណាៗ មិនអាចញុំាងវីរិយសម្ពោជ្ឈង្គឲ្យកើតឡើងបាន ក្នុងវេលាដែលសោយទុក្ខធំ ចាប់ផ្តើមតាំងពីត្រូវដាក់ទោសដោយគ្រឿងឃុំឃាំង ៥ ប្រការ ក្នុងនរកក្តី ក្នុងវេលាដែលត្រូវគេចាប់ដោយគ្រឿងចាប់ មានអន្ទាក់ សំណាញ់ និង អួនជាដើមខ្លះ ក្នុងវេលាដេញគៀង ចាក់ដោយគ្រឿងប្រហារ មានឈើបន្ទា

ជាដើម ឲ្យអួសរទេះខ្លះ ក្នុងកំណើតសត្វតិរច្ឆានក្តី ក្នុងវេលាដែលទុរន់ទុរាដោយសេចក្តីហេវ ក្តៅក្រហាយ ច្រើនពាន់ឆ្នាំខ្លះ មួយពុទ្ធន្តរខ្លះ ក្នុងប្រេតវិស័យក្តី ក្នុងវេលាដែលត្រូវសោយទុក្ខដែលកើតពីខ្យល់និងកំដៅថ្ងៃជាដើម ដោយផ្ទះរាងខ្ពស់ ប្រមាណ ៦០ ហត្ថ ៨០ ហត្ថ នៅសល់តែស្បែកដណ្តប់ឆ្អឹង ក្នុងពួកកាលកញ្ជិកអសុរក្តី ម្នាលភិក្ខុ វេលានេះប៉ុណ្ណោះ ជាវេលាធ្វើសេចក្តីព្យាយាមរបស់អ្នកដូច្នេះ វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងបាន។

## ២.ការឃើញអានិសង្ស

ការឃើញអានិសង្សយ៉ាងនេះថា អ្នកខ្ជិលច្រអូស មិនអាចបានលោកុត្តរធម៌ ៩ ប្រការ អ្នកដែលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះទើបអាចបាន នេះជាអានិសង្សរបស់សេចក្តីព្យាយាម ដូច្នេះ វីរិយសម្ពោជ្ឈង្គ ក៏រមែងកើតបាន ។

## ៣.ការពិចារណាឃើញនូវផ្លូវដែលគួរទៅ

ការពិចារណា ឃើញនូវផ្លូវដែលគួរទៅយ៉ាងនេះថា គួរដើរផ្លូវដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះមហាសាវកគ្រប់ព្រះអង្គដើរទៅហើយ ផ្លូវនោះ អ្នកខ្ជិលច្រអូសមិនអាចដើរទៅបាន

ដូច្នេះ វិរិយសម្ពោជ្ឈង្គ ក៏រមែងកើតបាន ។

## ៤.ការគោរពកោតក្រែងចំពោះបិណ្ឌបាត

កាលពិចារណា សេចក្ដីកោតក្រែងចំពោះបិណ្ឌបាត យ៉ាងនេះថា មនុស្សពួកណាទំនុកបម្រុងលោកដោយបច្ច័យ មានបិណ្ឌបាតជាដើម មនុស្សទាំងនោះនេះ ក៏មិនមែនញាតិ មិនមែនទាសៈ និងកម្មកររបស់លោកឡើយ ទាំងមនុស្សពួកនោះ ក៏មិនមែនថ្វាយបច្ច័យមានចីវរជាដើម ដែលប្រណីតដល់លោក ដោយគិតថានឹងអាស្រ័យលោកចិញ្ចឹមជីវិត ដោយពិត គេប្រាថ្នាឲ្យឧបការៈដែលខ្លួនធ្វើហើយមានផលច្រើន ទើបថ្វាយ សូម្បីព្រះសាស្ដា ក៏ទ្រង់មិនបានពិចារណាឃើញយ៉ាងនេះថា ភិក្ខុនេះបរិភោគបច្ច័យទាំងនេះហើយ នឹងមានរាងកាយរឹងមាំ កម្លាំងច្រើនទៅជាសុខដូច្នេះហើយទ្រង់អនុញ្ញាតបច្ច័យដល់លោក ដោយពិត ព្រះអង្គទ្រង់ពិចារណាឃើញថា ភិក្ខុបរិភោគបច្ច័យទាំងនេះ បំពេញសមណធម៌ នឹងផុតចាកទុក្ខក្នុងវដ្ដៈបានដូច្នេះ ទើបទ្រង់អនុញ្ញាតបច្ច័យទុក ឥឡូវនេះ លោកខិលច្រអូស មិនគោរពកោតក្រែងបិណ្ឌបាតនោះ ដែលឈ្មោះថា ការគោរពកោតក្រែងចំពោះបិណ្ឌបាត រមែងមានដល់អ្នកប្រារព្ធសេចក្ដីព្យាយាមប៉ុណ្ណោះ

ដូច្នេះ វីរិយសម្ពោជ្ឈង្គ ក៏កើតឡើងបាន ដូចវីរិយសម្ពោជ្ឈង្គ កើតដល់ព្រះមហាមិត្តត្ថេរៈ ដូច្នោះ ។

## ៥.ការពិចារណាសេចក្តីមានទ្រព្យមត៌កជាធំ

កាលពិចារណាសេចក្តីមានទ្រព្យមត៌កជាធំ យ៉ាងនេះថា ក៏ទ្រព្យមត៌ករបស់ព្រះសាស្តាមានច្រើន គឺអរិយទ្រព្យ ៧ ប្រការ ទ្រព្យមត៌កនោះ អ្នកខ្ជិលច្រអូសមិនអាចទទួលបាន, ដូចយ៉ាងថា មាតាបិតា រមែងកាត់បុត្រអ្នកប្រព្រឹត្តខុស ធ្វើឲ្យជាអ្នកខាងក្រៅ ថា "អ្នកនេះ មិនមែនកូនរបស់យើងទេ កាលមាតាបិតា កន្លង កំបាំងទៅ គេក៏មិនបានទទួលទ្រព្យមត៌កយ៉ាងណា សូម្បីបុគ្គល អ្នកខ្ជិលច្រអូសក៏ដូច្នោះ រមែងមិនបានមត៌ក គឺអរិយទ្រព្យនេះ អ្នកប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ រមែងបានទទួល" ដូច្នេះ វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងបាន ។

## ៦.ការពិចារណាសេចក្តីមានព្រះសាស្តាជាធំ

កាលពិចារណាសេចក្តីមានព្រះសាស្តាជាធំ យ៉ាងនេះថា ព្រះសាស្តារបស់លោកជាធំ ព្រោះក្នុងវេលាដែលព្រះសាស្តា របស់លោកទ្រង់ចុះកាន់បដិសន្ធិ ក្នុងព្រះគភ៌របស់ព្រះមាតាក្តី

វេលាស្ដេចចេញមហាភិនិក្រមក្ដី វេលាត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណក្ដី វេលាប្រកាសព្រះធម្មចក្រ សម្ដែងយមកបាដិហារ្យ ស្ដេចចុះចាកទេវលោក និងទ្រង់ដាក់អាយុសង្ខារក្ដី វេលាស្ដេចរំលត់ខន្ធបរិនិព្វានក្ដី ម៉ឺនលោកធាតុក៏ញាប់ញ័រហើយ លោកបួសក្នុងព្រះសាសនារបស់សាស្ដា ឃើញបែប ដូច្នេះហើយ ជាអ្នកខ្ជិលច្រអូស គួរហើយឬ ដូច្នេះ វិរិយសម្ពោជ្ឈង្គ រមែងកើតឡើងបាន ។

## ៧. ការពិចារណាសេចក្ដីមានជាតិជាធំ

កាលពិចារណាសេចក្ដីមានជាតិជាធំ យ៉ាងនេះថា សូម្បីដោយជាតិ ឥឡូវនេះ លោកមិនមែនអ្នកមានជាតិថោកទាបទេ លោកឈ្មោះថា កើតហើយក្នុងវង្សរបស់ព្រះបាទឧក្កាករាជ ដែលបន្តគ្នាមកដោយមហាសម្មតប្រវេណី មិនលាយជាមួយនឹងជនជាតិដទៃ ជាព្រះនត្តារបស់ព្រះបាទសុទ្ធោទនមហារាជ និងព្រះនាងមហាមាយាទេវី ជាព្រះអនុជរបស់ព្រះរាហុល ពុទ្ធជិនោរស ដែលឈ្មោះថា លោកជាពុទ្ធជិនបុត្រ ឃើញបែបដូច្នេះហើយ នៅដូចជាអ្នកខ្ជិលច្រអូស មិនសមគួរ ដូច្នេះ វិរិយសម្ពោជ្ឈង្គ រមែងកើតឡើងបាន ។

## ៨.ការពិចារណាសេចក្ដីមានសព្រហ្មចារីជាធំ

*កាលពិចារណាសេចក្ដីមានសព្រហ្មចារីជាធំ យ៉ាងនេះថា ព្រះសារីបុត្រ ព្រះមោគ្គល្លានទិងព្រះសាវកដ៏ធំ ៨០ រូប ចាក់ធ្លុះ រហូតអស់ (ត្រាស់ដឹង) លោកុត្តរធម៌ ដោយសេចក្ដីព្យាយាម ទាំងនោះ លោកនឹងដើរតាមផ្លូវរបស់សព្រហ្មចារីទាំងនោះ ឬ មិនដើរតាមហ្ន៎ ដូច្នេះ វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងបាន ។*

## ៩.ការវៀរចាកបុគ្គលខ្ជិលច្រអូស

## ១០.ការគប់រកបុគ្គលប្រារព្ធសេចក្ដីព្យាយាម

## ១១.ការបង្អោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គនោះ

*កាលវៀរបុគ្គលអ្នកខ្ជិលច្រអូស អ្នកលះបង់សេចក្ដីព្យា-យាមផ្លូវកាយនិងផ្លូវចិត្ត ដែលដូចជាពោះថ្លាន់ស៊ីពេញពោះ ហើយក៏ឈប់នៅនឹងកន្លែងក្ដី គប់រកបុគ្គលប្រារព្ធសេចក្ដីព្យា-យាម អ្នកឧទ្ទិសខ្លួនប្រាថ្នាបដិបត្តិធម៌ក្ដី មានចិត្តបង្អោនទៅ ដើម្បីឲ្យសេចក្ដីព្យាយាមកើតឡើង ក្នុងឥរិយាបថទាំងឡាយ មាន ឈរ អង្គុយ ជាដើមក្ដី វីរិយសម្ពោជ្ឈង្គ រមែងកើតឡើង បាន ។ ភិក្ខុរមែងដឹងច្បាស់ថា វីរិយសម្ពោជ្ឈង្គនោះ ដែលកើត*

ឡើងហើយ ដោយអាការៈយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ ដោយអរហត្តមគ្គ ។

## ធម៌ ១១ ប្រការ ជាហេតុកើតបីតិសម្ពោជ្ឈង្គ

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងជាហេតុនាំឲ្យកើតបីតិសម្ពោជ្ឈង្គគឺ

១-ពុទ្ធានុស្សតិ រលឹកដល់ព្រះពុទ្ធគុណ

២-ធម្មានុស្សតិ រលឹកដល់គុណព្រះធម៌

៣-សង្ឃានុស្សតិ រលឹកដល់គុណព្រះសង្ឃ

៤-សីលានុស្សតិ រលឹកដល់សីល

៥-ចាគានុស្សតិ រលឹកដល់ចាគ

៦-ទេវតានុស្សតិ រលឹកដល់ទេវតា

៧-ឧបសមានុស្សតិ ឧបសមានុស្សតិ

៨-លូខបុគ្គលបរិវជ្ជនតា វៀរចាកបុគ្គលសៅហ្មង (មិនស្អាត)

៩-សិនិទ្ធបុគ្គលសេវនតា គប់រកបុគ្គលអ្នក

*ហ្មត់ចត់ (ស្អាត)*

១០–បសាទនីយសុត្តន្តបច្ចវេក្ខណតា *ពិចារណាសេចក្ដីក្នុងព្រះសូត្រជាទីតាំងនៃសេចក្ដីជ្រះថ្លា*

១១–តទធិមុត្តតា *ការបង្អោនចិត្តទៅក្នុងបីតិសម្ពោជ្ឈង្គនោះ ។*

*ពិតមែន អ្នកចម្រើនបីតិសម្ពោជ្ឈង្គ កាលរលឹកដល់ព្រះពុទ្ធគុណ បីតិសម្ពោជ្ឈង្គផ្សាយជ្រួតជ្រាបទូទៅពេញសរីរៈដរាបណា ឧបចារសមាធិ រមែងកើតឡើង ។ កាលរលឹកដល់គុណព្រះធម៌ និងព្រះសង្ឃក្ដី ពិចារណាបារិសុទ្ធិសីល ៤ ដែលខ្លួនរក្សាមិនដាច់ធ្លុះធ្លាយជាវេលាយូរក្ដី សូម្បីគ្រហស្ថ ពិចារណាសីល ១០ សីល ៥ ក្ដី ពិចារណាចាគៈ ការបរិច្ចាគថា ក្នុងវេលាប្រសព្វទុព្ភិក្ខភ័យជាដើម យើងថ្វាយភោជនដែលប្រណីតដល់សព្រហ្មចារីទាំងឡាយ ហើយថ្វាយភោជនឈ្មោះយ៉ាងនេះដូច្នេះក្ដី សូម្បីគ្រហស្ថពិចារណាដល់ទានដែលថ្វាយដល់លោកអ្នកមានសីល ក្នុងវេលាបែបនោះក្ដី ពិចារណាដល់គុណ ដូចដែលទេវតាប្រកបហើយដល់ភាពជាទេវតា ថា មាននៅក្នុងខ្លួនក្ដី ពិចារណាឃើញថា កិលេសដែលគ្របសង្កត់បានហើយសូម្បី*

ដោយសមាបត្តិ រហូតអស់ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ មិនកើតកម្រើកដូច្នេះក្តី, វៀរចាកបុគ្គលសៅហ្មង អ្នកមានសេចក្តីស្រអាប់ដែលសន្សំទុក ព្រោះមិនធ្វើដោយគោរព ក្នុងវេលាឃើញព្រះចេតិយ ពោធិព្រឹក្ស និងឃើញព្រះថេរៈ អ្នកដូចជាល្អងធូលីលើខ្នងលា ព្រោះមិនមានសេចក្តីជ្រះថ្លាស្រឡាញ់ប្រាថ្នាក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើមក្តី សេពបុគ្គលអ្នកហ្មត់ចត់ អ្នកច្រើនដោយសេចក្តីជ្រះថ្លា មានចិត្តទន់ក្នុងព្រះរតន-ត្រ័យ មានព្រះពុទ្ធជាដើមក្តី, ពិចារណាសេចក្តីក្នុងព្រះសូត្រដែលជាទីតាំងនៃសេចក្តីជ្រះថ្លា ដែលសម្តែងគុណរបស់ព្រះរតនត្រ័យក្តី មានចិត្តបង្អោនទៅដើម្បីឲ្យកើតបីតិ ក្នុងឥរិយាបថទាំងឡាយមានឈរ អង្គុយ ជាដើមក្តី បីតិសម្ពោជ្ឈង្គ រមែងកើតឡើងបាន ។ ភិក្ខុរមែងដឹងច្បាស់ថា បីតិសម្ពោជ្ឈង្គនោះ ដែលកើតហើយ ដោយអាការៈយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។

## ធម៌ ១១ ប្រការ ជាហេតុកើតសមាធិសម្ពោជ្ឈង្គ

*ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងជាហេតុនាំឲ្យកើតសមាធិសម្ពោជ្ឈង្គ គឺ*

១-*វត្ថុវិសទកិរិយតា* *ធ្វើវត្ថុឲ្យស្អាត*

២-*ឥន្ទ្រិយសមត្តបដិបាទនតា* *ការប្រមូលឥន្ទ្រិយឲ្យស្មើ*

៣-*និមិត្តកុសលតា* *ឈ្លាសក្នុងនិមិត្ត*

៤-*សមយេ ចិត្តស្ស បគ្គណ្ហនតា* *ផ្គងចិត្តក្នុងសម័យដែលគួរផ្គង*

៥-*សមយេ ចិត្តស្ស និគ្គណ្ហនតា* *គ្របសង្កត់ចិត្តក្នុងសម័យដែលគួរគ្របសង្កត់*

៦-*សមយេ សម្បហំសនតា* *ធ្វើចិត្តឲ្យរីករាយក្នុងសម័យដែលគួរឲ្យរីករាយ*

៧-*សមយេ អជ្ឈុបេក្ខនតា* *សម្លឹងព្រងើយក្នុងសម័យដែលគួរសម្លឹងព្រងើយ*

៨-អសមាហិតបុគ្គលបរិវជ្ជនតា វៀរចាកបុគ្គលអ្នកមានចិត្តមិនជាសមាធិ

៩-សមាហិតបុគ្គលសេវនតា គប់រកបុគ្គលអ្នកមានចិត្តជាសមាធិ

១០-ឈានវិមោក្ខបច្ចវេក្ខណតា ពិចារណាឈាននិងវិមោក្ខ

១១-តទធិមុត្តតា បង្អោនចិត្តទៅក្នុងសមាធិ-សម្ពោជ្ឈង្គនោះ ។

## អធិប្បាយធម៌ ១១ ប្រការ

ក្នុងធម៌ ១១ ប្រការនោះ ចំពោះការធ្វើវត្ថុឲ្យស្អាត និងការប្រមូលឥន្ទ្រិយឲ្យស្មើគ្នា គប្បីជ្រាបតាមន័យដែលពោលមកហើយនុ៎ះឯង ។

សេចក្ដីឈ្លាសក្នុងការកំណត់កសិណនិមិត្ត ជាអារម្មណ៍ ឈ្មោះថា ឈ្លាសក្នុងនិមិត្ត ។ ការផ្គងចិត្តទុក ដោយការតាំងធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គ ក្នុង

សម័យដែលចិត្តរួញរា ព្រោះមានសេចក្ដីព្យាយាមធូរថយពេក ជាដើម ឈ្មោះថា ផ្គងចិត្តក្នុងសម័យដែលគួរផ្គង ។

ការគ្រប់សង្កត់ចិត្តទុក ដោយការតាំងបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ក្នុងសម័យដែលចិត្តរវើរវាយ ព្រោះប្រារព្ធសេចក្ដីព្យាយាមច្រើនពេកជាដើម ឈ្មោះថា គ្របសង្កត់ចិត្តក្នុងសម័យដែលគួរគ្របសង្កត់ ។

ពាក្យថា ធ្វើចិត្តឲ្យរីករាយ ក្នុងសម័យដែលគួររីករាយ អធិប្បាយថា សម័យណាចិត្តមិនស្រស់ថ្លា ព្រោះមានបញ្ញា និងសេចក្ដីព្យាយាមខ្សោយពេក ឬព្រោះមិនសម្រេចសុខដែលកើតពីសេចក្ដីស្ងប់ សម័យនោះ ក៏ធ្វើចិត្តឲ្យតក់ស្លុត ដោយពិចារណាសំវេគវត្ថុ រឿងដែលជាទីតាំងនៃសេចក្ដីតក់ស្លុត ៨ ប្រការ ។ រឿងដែលជាទីតាំងនៃសេចក្ដីតក់ស្លុត ៨ ប្រការ គឺ ជាតិ ១ ជរា ១ ព្យាធិ ១ មរណៈ ១ ទុក្ខក្នុងអបាយ ១ ទុក្ខក្នុងអតីតមានវដ្ដៈជាមូល ១ ទុក្ខក្នុងអនាគត មានវដ្ដៈជាមូល ១ ទុក្ខក្នុងបច្ចុប្បន្ន មានការស្វែងរកអាហារជាមូល ១ ។ មួយទៀត ការធ្វើសេចក្ដីជ្រះថ្លាឲ្យកើតឡើង ដោយមករលឹកដល់គុណព្រះរតនត្រ័យ យ៉ាងនេះក៏ហៅថា ការធ្វើចិត្តឲ្យរីករាយ ក្នុងសម័យ

ដែលគួរឲ្យរីករាយ ។

ឈ្មោះថា សម្លឹងព្រងើយ ក្នុងសម័យដែលគួរសម្លឹងព្រងើយ អធិប្បាយថា សម័យណាចិត្តអាស្រ័យការបដិបត្តិប្រពៃ មិនរួញរា មិនរវើរវាយ មិនអណ្តែតអណ្តូង មិនរាយ-មាយ ប្រព្រឹត្តទៅស្មើក្នុងអារម្មណ៍ ដំណើរក្នុងសមថវិថី សម័យនោះមិនត្រូវខ្វល់ខ្វាយក្នុងការផ្គង គ្របសង្កត់ និងធ្វើចិត្តឲ្យរីករាយដូចសារថីមិនត្រូវខ្វល់ខ្វាយ ក្នុងកាលសេះរត់ស្មើល្អដូច្នោះ យ៉ាងនេះហៅថា សម្លឹងព្រងើយក្នុងសម័យដែលគួរសម្លឹងព្រងើយ ។

ការវៀរចាកបុគ្គលអ្នកមានចិត្តរវើរវាយ មិនសម្រេចឧបចារៈ ឬអប្បនា ឲ្យឆ្ងាយ ឈ្មោះថា វៀរចាកបុគ្គលអ្នកមានចិត្តមិនជាសមាធិ ។

ការសេពគប់រក ចូលទៅអង្គុយជិត បុគ្គលអ្នកមានចិត្តជាសមាធិដោយឧបចារភាវនា ឬអប្បនាភាវនា ឈ្មោះថា គប់រកបុគ្គលអ្នកមានចិត្តជាសមាធិ ។

សេចក្តីជាអ្នកមានចិត្តបង្អោនទៅរទន់ទៅ ដើម្បីឲ្យកើតសមាធិ ក្នុងឥរិយាបថទាំងឡាយមានឈរ អង្គុយជាដើម ឈ្មោះថា បង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គ ។

ព្រោះថា កាលបដិបត្តិយ៉ាងនេះ សមាធិសម្ពោជ្ឈង្គនោះ រមែងកើតបាន ។ កាលភិក្ខុដឹងច្បាស់ថា ក៏សមាធិសម្ពោជ្ឈង្គនោះ ដែលកើតហើយដោយអាការៈយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។ (អដ្ឋកថា សុមង្គលវិលាសិនី)

## អានិសង្សមេត្តាមាន ១១ ប្រការ

មេត្តាចេតោវិមុត្តិដែលបុគ្គលធ្វើឲ្យច្រើនហើយ ចម្រើនហើយ ធ្វើឲ្យក្រាស់ក្រែលហើយ ធ្វើឲ្យដូចជាយានជំនិះហើយ ធ្វើឲ្យជាទីនៅហើយ ឲ្យតាំងនៅញឹកញយហើយសន្សំទុក មិនឲ្យបាត់ ប្រារព្ធដោយល្អហើយ នឹងមានអានិសង្ស ១១ ប្រការ ជាពិតប្រាកដ

១-សុខំ សុបតិ បុគ្គលនោះដេកលក់ជាសុខ

២-សុខំ បដិពុជ្ឈតិ ភ្ញាក់ឡើងជាសុខ

៣-ន បាបកំ សុបិនំ បស្សតិ មិនយល់

*សុបិន្តអាក្រក់*

៤-មនុស្សានំ បិយោ ហោតិ *ជាទីស្រឡាញ់របស់ពួកមនុស្ស*

៥-អមនុស្សានំ បិយោ ហោតិ *ជាទីស្រឡាញ់របស់ពួកអមនុស្ស*

៦-ទេវតា រក្ខន្តិ *ពួកទេវតាតែងរក្សា*

៧-នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ *ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី ក៏មិនប៉ះពាល់ដល់បុគ្គលនោះ*

៨-តុវដំ ចិត្តំ សមាធិយតិ *ចិត្តបុគ្គលនោះរមែងចូលកាន់សមាធិដោយរួសរាន់*

៩-មុខវណ្ណោ វិប្បសីទតិ *បុគ្គលនោះមានពណ៌សម្បុរមុខស្រស់បស់*

១០-អសម្មូឡ្ហោ កាលំ ករោតិ *បុគ្គលនោះមិនបានវង្វេងស្មារតីធ្វើមរណកាល*

១១-ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកុបគោ ហោតិ *កាលបើមិនទាន់បានត្រាស់ដឹងនូវគុណធម៌ជាន់ខ្ពស់ទេ ជាអ្នកបានទៅកើតក្នុងព្រហ្មលោក ។*

*(វិនយបិដក ភាគ១៣ ទំព័រ១០៤)*

## ចរណៈមាន ១៥

*ចែកជា ៣ ពួក គឺសីលមួយពួក, សទ្ធម្មមួយពួក, ឈានមួយពួក ។*

## ពួកសីលមាន ៤

១-សីលសំវរៈ *សេចក្តីសង្រួមកាយ វាចា*

២-ឥន្ទ្រិយសំវរៈ *សេចក្តីសង្រួមឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយជាដើម មិនឲ្យអភិជ្ឈាទោមនស្ស បាបធម៌ កើតឡើងបាន*

៣-ភោជនេមត្តញ្ញុតា *សេចក្តីជាអ្នកដឹងប្រមាណក្នុងភោជន*

៤-ជាគរិយានុយោគៈ *សេចក្តីព្យាយាម ជារបស់មនុស្សអ្នកភ្ញាក់ ។*

## សទ្ធម្មមាន ៧

១-សទ្ធា *សេចក្ដីជឿចំពោះ របស់ដែលគួរជឿ*

២-ហិរិ *សេចក្ដីខ្មាសចំពោះទុច្ចរិតបាបធម៌*

៣-ឱត្តប្បៈ *សេចក្ដីតក់ស្លុតចំពោះទុច្ចរិតបាបធម៌*

៤-ពាហុសច្ចៈ *សេចក្ដីជាអ្នកចេះដឹងច្រើន*

៥-វីរិយៈ *សេចក្ដីព្យាយាម*

៦-សតិ *សេចក្ដីរលឹក*

៧-បញ្ញា *សេចក្ដីដឹងទូទៅ*

## មួយអន្លើដោយឈាន ៤

១-បឋមជ្ឈាន *ឈានទី ១ ប្រកបដោយអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ។*

២-ទុតិយជ្ឈាន *ឈានទី ២ ប្រកបដោយអង្គ ៣ បីតិ សុខៈ ឯកគ្គតា ។*

៣-តតិយជ្ឈាន ឈានទី ៣ ប្រកបដោយអង្គ ២ សុខៈ ឯកគ្គតា ។

៤-ចតុត្ថជ្ឈាន ឈានទី ៤ ប្រកបដោយអង្គ ២ ឯកគ្គតា ឧបេក្ខា ។

ធម៌មានប្រភេទ ១៥ នេះ ឈ្មោះថា **ចរណៈ** ព្រោះជាធម៌សម្រាប់បុគ្គលសញ្ចរទៅកាន់ទិសដែលមិនធ្លាប់ទៅ គឺព្រះនិព្វាន ។ (អដ្ឋកថា សមន្តប្បាសាទិកា)

## ធម៌ដែលធ្វើឱ្យជាអ្នកប្រដៅក្រមាន ១៦

១-ភិក្ខុជាអ្នកមានសេចក្តីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្តីប្រាថ្នាលាមក ។

២-ភិក្ខុជាអ្នកលើកខ្លួនឯងបន្ទះបន្ថាប់អ្នកដទៃ

៣-ភិក្ខុជាអ្នកក្រោធ ជាអ្នកមានសេចក្តីក្រោធគ្របសង្កត់

៤-ភិក្ខុជាអ្នកក្រោធ ជាអ្នកចងគំនុំព្រោះសេចក្តីក្រោធជាហេតុ

៥-ភិក្ខុជាអ្នកក្រោធ ជាអ្នកជេរប្រទេចព្រោះសេចក្តីក្រោធជាហេតុ

៦-ភិក្ខុជាអ្នកក្រោធ ជាអ្នកបញ្ចេញវាចាជិតសេចក្ដីក្រោធ

៧-ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយក៏ទីងតបត នឹងភិក្ខុអ្នកចោទវិញ

៨-ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយក៏បណ្ដេញភិក្ខុអ្នកចោទវិញ

៩-ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយនិយាយគ្របសង្កត់ភិក្ខុអ្នកចោទវិញ

១០-ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយក៏និយាយបន្ទែបន្ទប់នូវភិក្ខុអ្នកចោទ ដោយហេតុដទៃ ឬពាក្យផ្សេងៗ និយាយគេចកែដោយសំដីខាងក្រៅ ធ្វើសេចក្ដីក្រោធ សេចក្ដីប្រទូស្ត និងសេចក្ដីអាក់អន់ចិត្តឲ្យប្រាកដឡើង

១១-ភិក្ខុដែលត្រូវភិក្ខុអ្នកចោទ ចោទហើយ មិនឆ្លើយក្នុងដំណើររបស់ខ្លួន

១២-ភិក្ខុជាអ្នកលុបគុណគេ ជាអ្នកប្រឡងវាសនា

១៣-ភិក្ខុជាអ្នកប្រណែន ជាអ្នកកំណាញ់

១៤-ភិក្ខុជាអ្នកអួតអាង ជាអ្នកមានពុតមាយា

១៥-ភិក្ខុជាអ្នករឹងរូស ជាអ្នកមើលងាយគេ

*១៦-ភិក្ខុជាអ្នកប្រកាន់តាមតែសេចក្ដីយល់ឃើញរបស់ខ្លួន ជាអ្នកប្រកាន់មាំ លះបង់ទិដ្ឋិបានដោយក្រ ។*

*(សុត្តន្តបិដក ភាគ២០ ទំព័រ៣៥៥-៣៥៨)*

## ទាន ២១ យ៉ាង

*បាដិបុគ្គលិកទាន មាន ១៤*

១-តថាគតេ អរហន្តេ សម្មាសម្ពុទ្ធេ ទានំ ទេតិ *ឲ្យទានចំពោះព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។*

២-បច្ចេកសម្ពុទ្ធេ ទានំ ទេតិ *ឲ្យទានចំពោះព្រះបច្ចេកសម្ពុទ្ធ*

៣-តថាគតសាវកេ អរហន្តេ ទានំ ទេតិ *ឲ្យទានចំពោះព្រះអរហន្ត ជាសាវករបស់តថាគត ។*

៤-អរហត្តផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ *ឲ្យទានចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល*

៥-អនាគាមិស្ស ធាតុំ ទេតិ *ឲ្យទានចំពោះអនាគាមិបុគ្គល*

៦-អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេ ធាតុំ ទេតិ *ឲ្យទានចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល*

៧-សកទាគាមិស្ស ធាតុំ ទេតិ *ឲ្យទានចំពោះសកទាគាមិបុគ្គល*

៨-សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេ ធាតុំ ទេតិ *ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល*

៩-សោតាបន្នេ ធាតុំ ទេតិ *ឲ្យទានចំពោះសោតាបន្នបុគ្គល*

១០-សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នេ ធាតុំ ទេតិ *ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល*

១១-ពាហិរកេ កាមេសុ វីតរាគេ ទានំ ទេតិ *ឲ្យទានចំពោះអ្នកបួសខាងក្រៅ (ពុទ្ធសាសនា) ដែលប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ*

១២-បុថុជ្ជនសីលវន្តេ ទានំ ទេតិ *ឲ្យទានចំពោះបុថុជ្ជនមានសីល*

១៣-បុថុជ្ជនទុស្សីលេ ទានំ ទេតិ *ឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល*

១៤-តិរច្ឆានគតេ ទានំ ទេតិ *ឲ្យទានចំពោះសត្វតិរច្ឆាន ។*

### *សង្ឃគតាទក្ខិណាទាន មាន ៧*

១-ពុទ្ធប្បមុខេ ឧភតោសង្ឃេ ទានំ ទេតិ *បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន*

២-តថាគតេ បរិនិព្វុតេ ឧភតោសង្ឃេ ទានំ ទេតិ *កាលបើព្រះតថាគតបរិនិព្វានទៅ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក ។*

៣-ភិក្ខុសង្ឃេ ទានំ ទេតិ *ឲ្យទានចំពោះតែភិក្ខុសង្ឃ*

៤-ភិក្ខុនីសង្ឃេ ទានំ ទេតិ *ឲ្យទានចំពោះតែភិក្ខុនីសង្ឃ ។*

៥-ឯត្តកេ មេ ភិក្ខូ ច ភិក្ខុនិយោ ច សង្ឃតោ ឧទ្ទិស្សថាតិ ទានំ ទេតិ *បុគ្គល (ទៅនិមន្តអំពីភិក្ខុសង្ឃ)ថា សូមលោកម្ចាស់ទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះ ពួកភិក្ខុនីប៉ុណ្ណេះ អំពីសង្ឃដើម្បីខ្ញុំ ហើយទើបឲ្យទាន*

៦-ឯត្តកេ មេ ភិក្ខូ សង្ឃតោ ឧទ្ទិស្សថាតិ ទានំ ទេតិ *បុគ្គល(ទៅនិមន្តអំពីសំណាក់សង្ឃ) ថា សូមលោកម្ចាស់ទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះអំពីសង្ឃ ដើម្បីខ្ញុំ ហើយទើបឲ្យទាន ។*

៧-ឯត្តកា មេ ភិក្ខុនិយោ សង្ឃតោ ឧទ្ទិស្សថាតិ ទានំ ទេតិ *បុគ្គល (ទៅនិមន្តអំពីសំណាក់សង្ឃ) ថា សូមលោកម្ចាស់ទាំងឡាយ ចាត់ពួកភិក្ខុនីប៉ុណ្ណេះ អំពីសង្ឃ ដើម្បីខ្ញុំ ហើយទើបឲ្យទាន ។*

*(សុត្តន្តបិដក ភាគ២៨ ទំព័រ២២០-២២៦)*

## ពោធិបក្ខិយធម៌ ៣៧ ប្រការ

*សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។*

## សតិប្បដ្ឋាន ៤

១-កាយានុបស្សនាសតិប្បដ្ឋាន : *ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។*

២-វេទនានុបស្សនាសតិប្បដ្ឋាន : *ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។*

៣-ចិត្តានុបស្សនាសតិប្បដ្ឋាន : *ពិចារណាឃើញ*

នូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។

៤–ធម្មានុបស្សនាសតិប្បដ្ឋាន : ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។

## **សម្មប្បធាន ៤**

១–ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន,

២–ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមក

ដែលកើតឡើងហើយ,

៣-ញ៉ាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញ៉ាំងកុសលធម៌ដែលមិនទាន់កើតឡើងឲ្យកើតឡើង,

៤-ញ៉ាំងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញ៉ាំងកុសលធម៌ ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនភ្លេចភ្លាំងទៅ ឲ្យចម្រើនធំទូលាយ ពេញបរិបូរណ៍ក្រៃលែងឡើង ។ (សុត្តន្ត. ៤២,៣៧)

## ឥទ្ធិបាទ ៤

១-ឆន្ទិទ្ធិបាទ សេចក្តីពេញចិត្តជាទីតាំងនៃឫទ្ធិ

២-វីរិយិទ្ធិបាទ សេចក្តីប្រឹងប្រែងជាទីតាំងនៃឫទ្ធិ

៣-ចិត្តិទ្ធិបាទ សេចក្តីសន្សំគិតរិះជាទីតាំងនៃឫទ្ធិ

៤-វិមំសិទ្ធិបាទ បញ្ញាដឹងគ្រប់យ៉ាងជាទីតាំងនៃឫទ្ធិ ។

## ឥន្ទ្រិយ ៥

១-សទ្ធិន្ទ្រិយំ : *សេចក្ដីជឿ ចាត់ជារបស់ធំ*

២-វីរិយិន្ទ្រិយំ : *សេចក្ដីព្យាយាម ចាត់ជារបស់ធំ*

៣-សតិន្ទ្រិយំ : *សតិ ចាត់ជារបស់ធំ*

៤-សមាធិន្ទ្រិយំ : *សមាធិ ចាត់ជារបស់ធំ*

៥-បញ្ញិន្ទ្រិយំ : *បញ្ញា ចាត់ជារបស់ធំ ។*

## ពល ៥

១-សទ្ធាពលំ *ធម្មជាតិមិនរំកើបក្នុងសភាពដែលមិនគួរជឿ ហៅថា សទ្ធាពលៈ ។*

២-វីរិយពលំ *ធម្មជាតិមិនញាប់ញ័រក្នុងកោសជ្ជៈ ហៅថា វីរិយពលៈ ។*

៣-សតិពលំ *ធម្មជាតិមិនញាប់ញ័រក្នុងសេចក្ដីប្រមាទ ហៅថា សតិពលៈ ។*

៤-សមាធិពលំ *ធម្មជាតិមិនញាប់ញ័រក្នុងឧទ្ធច្ចៈ ហៅថា សមាធិពលៈ ។*

៥-បញ្ញាពលំ ធម្មជាតិមិនញាប់ញ័រក្នុងអវិជ្ជា
ហៅថា បញ្ញាពលៈ ។

## ពោជ្ឈង្គ ៧

១-សតិសម្ពោជ្ឈង្គ អង្គនៃមិជាគ្រឿងត្រាស់ដឹង
គឺសតិ ។

២-ធម្មវិចយសម្ពោជ្ឈង្គ អង្គនៃមិជាគ្រឿងត្រាស់ដឹង
គឺធម្មវិចយៈ ។

៣-វីរិយសម្ពោជ្ឈង្គ អង្គនៃមិជាគ្រឿងត្រាស់ដឹង
គឺវីរិយៈ ។

៤-បីតិសម្ពោជ្ឈង្គ អង្គនៃមិជាគ្រឿងត្រាស់ដឹង
គឺបីតិ ។

៥-បស្សទ្ធិសម្ពោជ្ឈង្គ អង្គនៃមិជាគ្រឿងត្រាស់ដឹង
គឺបស្សទ្ធិ បានដល់ ភាពនៃកាយនិងចិត្តស្ងប់រម្ងាប់រៀបរយ ។

៦-សមាធិសម្ពោជ្ឈង្គ អង្គនៃមិជាគ្រឿងត្រាស់ដឹង

គឺសមាធិ បានដល់ តាំងចិត្តឲ្យនៅក្នុងអារម្មណ៍ ជាគុណនាំឲ្យឃើញត្រៃលក្ខណ៍ជាដើម ។

៧-ឧបេក្ខាសម្ពោជ្ឈង្គ អង្គនៃមិជាគ្រឿងត្រាស់ដឹង គឺឧបេក្ខា សេចក្ដីព្រងើយកន្ដើយ មិនសោមនស្ស ជាគុណឲ្យសម្រេចប្រយោជន៍ទាំងពួងបាន ។

## អរិយមគ្គប្រកបដោយអង្គ ៨

១-សម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រូវ

២-សម្មាសង្កប្បៈ សេចក្ដីត្រិះរិះត្រូវ

៣-សម្មាវាចា សម្ដីត្រូវ

៤-សម្មាកម្មន្តៈ ការងារត្រូវ

៥-សម្មាអាជីវៈ កិរិយាចិញ្ចឹមជីវិតត្រូវ

៦-សម្មាវាយាមៈ ព្យាយាមត្រូវ

៧-សម្មាសតិ សេចក្ដីរលឹកត្រូវ

៨-សម្មាសមាធិ កិរិយាតម្កល់ចិត្តឲ្យនឹងត្រូវ ។

## ព្រះពុទ្ធវចនៈ ៨៤.០០០ ព្រះធម្មក្ខន្ធ

*ព្រះពុទ្ធវចនៈ ៨៤.០០០ ព្រះធម្មក្ខន្ធ គឺអ្វីខ្លះ ? មែនពិត ព្រះពុទ្ធវចនៈទាំងអស់នេះឯងមាន ៨៤.០០០ ប្រភេទ ដោយអំណាចនៃធម្មក្ខន្ធដែលព្រះអានន្ទរៀបរួមទុកយ៉ាងនេះថា ៖*

ទ្វាសីតិ ពុទ្ធតោ គណ្ហិ
ទ្វេ សហស្សានិ ភិក្ខុតោ
ចតុរាសីតិសហស្សានិ
យេ មេ ធម្មា បវត្តិនោ ។

*ធម៌ទាំងឡាយដែលតម្កល់នៅហើយរបស់ខ្ញុំ ខ្ញុំរៀនមកអំពីព្រះពុទ្ធជាម្ចាស់ ៨២.០០០ អំពីព្រះភិក្ខុ ២.០០០ រួមជា ៨៤.០០០ ព្រះធម្មក្ខន្ធ" ដូច្នេះ ។*

*បណ្ដាព្រះពុទ្ធវចនៈទាំងនោះ ព្រះសូត្រមានអនុសន្ធិ ១ ហៅថា ធម្មក្ខន្ធ ១ ។ ព្រះសូត្រណាមានច្រើនអនុសន្ធិ ក៏រាប់ចំនួនធម្មក្ខន្ធតាមអនុសន្ធិក្នុងព្រះសូត្រនោះ ។ ក្នុងការប្រព័ន្ធ ជាគាថា ការសួរបញ្ហាជាធម្មក្ខន្ធ១ ការវិស្សជ្ជនា ក៏ជាធម្មក្ខន្ធ១ ។*

ក្នុងព្រះអភិធម្ម ការចែកតិកៈ និងទុកៈមួយពួកៗ និងការចែកវារៈចិត្តមួយយ៉ាងៗ (១ដងៗ) ក៏ជាធម្មក្ខន្ធ ១ ។

ក្នុងព្រះវិន័យមានវត្ថុ , មាតិកា, បទភាជនីយ៍, អាបត្តិ , អនាបត្តិ , អន្តរាបត្តិ , ការកំណត់តិកៈ , ធម៌ដែលជាអតេកិច្ឆៈ , ដែលជាសតេកិច្ឆៈ , ក្នុងវត្ថុជាដើម យ៉ាងនេះមួយភាគៗ គប្បីជ្រាបថា ជាមួយធម្មក្ខន្ធ ៗ ។

ពោលដោយព្រះធម្មក្ខន្ធ គប្បីជ្រាបថាជាព្រះធម្មក្ខន្ធ ៨៤.០០០ ធម៌ ដោយអាការៈយ៉ាងនេះ ៕

# អត្ថបទកំណាព្យ

## ភរិយា ៧ ពួក

- ព្រះមានព្រះភាគ ទ្រង់ជាសាស្តា ហៅកូនប្រសា របស់សេដ្ឋី
ឈ្មោះសុជាតា មិនគោរពប្តី ចេះតែស្រដីកញ្ច្រៀវខ្ចរខ្ចារ ។
- ព្រះអង្គទ្រង់ត្រាស់បញ្ជាក់ប្រាប់ថា នែសុជាតា រីភរិយា
មានប្រាំពីរពួក ចូរនាងម្ចីម្នា មានចិត្តល្អជាស្តាប់ដោយប្រពៃ ។
- ភរិយា ១ ជាអ្នកសម្លាប់ មិនឋិតក្នុងច្បាប់ រកប្រុសដទៃ
មានចិត្តប្រទូស្តគយគន់រំពៃ ខ្វល់ខ្វាយលកលៃសម្លាប់ប្តីឯង ។
- ភរិយា ១ ទុកស្មើដោយចោរ មានចិត្តរហោ ឥតក្រែងរអែង
លួចកិបយកប្រាក់ប្រាកដជាក់ស្តែង ទ្រព្យស្វាមីឯងទុកធ្វើកិច្ចការ ។
- ភរិយា ១ ទុកស្មើដោយម្ចាស់ រឹងរូសកាចឆ្នាស ជូនស្រែកឡូឡា
ពោលពាក្យអាក្រក់ឥតខ្លាចរអា នឹងស្វាមីណា ព្យាយាមប្រឹងប្រែង ។
- ភរិយា ១ ស្មើដោយមាតា ចេះថៃរក្សា ជួយរៀបចាត់ចែង
ចេះអនុគ្រោះដល់ស្វាមីឯង ដោយការសម្តែងខ្លួនដូចមាតា ។
- ភរិយា ១ ស្មើដោយប្អូនស្រី គោរពស្វាមីដែលជាភស្តា
ធ្វើខ្លួនដូចប្អូន គោរពបងណា មានចរិយាមានការអៀនខ្មាស ។
- ភរិយា ១ ស្មើដោយសំឡាញ់ មានចិត្តស្រឡាញ់ ក្នុងប្តីពេកណាស់
មានសីលធម៌ប្រពៃល្អល្អះ ធ្វើវត្តឥតខ្ចះតាមតួនាទី ។

- ភរិយា ១ ស្មើដោយខ្ញុំស្រី ទោះត្រូវជេរស្តី គំរាមញក់ញី
មិនប្រទូស្តវិញ អត់ធនគ្រប់ទី មានចិត្តសម្ដីលុះតាមភស្តា ។
- ទី ១ ទី ២ ទី ៣ នេះជា ហៅភរិយាមិនល្អឡើយណា
ជាស្ត្រីទ្រុស្តសីល រឹងរូសហានក្លា បែកធ្លាយកាយា តែងទៅអបាយ ។
- ទី ៤ ជាដើម ហៅភរិយា ហទ័យសម្ភារ ព្យាយាមខ្វល់ខ្វាយ
ជាស្ត្រីសង្រួមក្នុងសីលទាំងឡាយ លុះបែកធ្លាយកាយ កើតជាទេព្ដា ។
- ភរិយានេះ មានពិតប្រាកដ ដែលទ្រង់កំណត់ទៅតាមហេតុការណ៍
តាមការប្រព្រឹត្តិ ជាចរិយា សត្វក្នុងលោកាសន្សំខុសគ្នា ។
- រៀបរាប់ប៉ុណ្ណេះបានជាបណ្ដាំ ត្រូវអ្នកចងចាំណាកូនពុំងា
គួរខំប្រព្រឹត្តតាមព្រះធម្មា នឹងបានផុតពៀរផុតចាកទុក្ខហោង ។

## ឱវាទ ១០ យ៉ាង

## បទពាក្យ ៨

- ឱវាទ ១០ យ៉ាងគួរកូនចងចាំ កំណត់ចំណាំទុកដោយប្រពៃ
ព្រោះជាឱវាទដែលធនញ្ជ័យ ទូន្មានកូនស្រីឈ្មោះវិសាខា ។
-**កុំនាំភ្លើងក្នុងចេញទៅខាងក្រៅ** នេះលោកសំដៅយករាល់ទោសា
របស់ស្វាមី មាតាបិតា កុំពោលចរចាខាងក្រៅផ្ទះឡើយ ។

-**កុំនាំភ្លើងក្រៅចូលមកខាងក្នុង** កូនអើយត្រូវប្រុងអ្នកនឹងបានស្បើយ
បើឮគេពោលទោសឪពុកហើយ កុំនាំមកឡើយពោលក្នុងផ្ទះឯង ។
- មាតា ស្វាមី ក៏ន័យដូចគ្នា សូមកូនពុំងាចេះគិតកោតក្រែង
កុំចេះតែស្តីនាំឱ្យចម្បែង ត្រូវចេះថ្លាថ្លែង គ្រប់ពេលវេលា ។
- ភ្លើងទាំងពីរនេះក្លាខ្លាំងណាស់ណា កូនត្រូវរក្សាឱ្យបានល្អជា
តែមិនប្រយ័ត្នកើតទាស់ទែងគ្នា មានកម្មវេរាឆេះក្នុងអបាយ ។
- រីឯទី ៣ កូនត្រូវចាំជាក់ **គួរឱ្យដល់អ្នកដែលឱ្យនាំងឡាយ**
នេះសំដៅយកអ្នកជិតឬឆ្ងាយ ខ្ចីទ្រព្យទាំងឡាយសងវិញសឹមឱ្យ ។
- ចំណែកទី ៤ កូនអើយកុំឆ្ងល់ **មិនគួរឱ្យដល់អ្នកដែលមិនឱ្យ**
នេះសំដៅយកអ្នកខ្ចីទ្រព្យហើយ មិនសងវិញឡើយចេះតែមកខ្ចី ។
- រីឯទី ៥ លោកបានបញ្ជាក់ **គួរឱ្យដល់អ្នកដែលឱ្យវិញក្តី**
និងអ្នកនោះឯង**មិនឱ្យវិញក្តី** នេះលោកស្រដី សំដៅយកញាតិ ។
- ប្រាំមួយ **គប្បីអង្គុយជាសុខ** កូនកុំសំកុកកុំចិត្តចង្អៀត
ឃើញម្តាយឪពុក ស្វាមី ត្រូវឃ្លាត កូនគួរវវាតក្រោកចាកទីឋាន ។
- ប្រាំពីរ **បរិភោគជាសុខ** ណា នៅក្នុងន័យថា នៃកូនកល្យាណ
បម្រើស្វាមី ពុកម្តាយថ្កើងថ្កាន រួចហើយទើបបានខ្លួនឯងហូបក្រោយ ។
- ប្រាំបី **គប្បីដេកជាសុខ** ស្រួល កូនគួរសម្រួលធ្វើវត្តឱ្យហើយ
ចំពោះឪពុក មិនត្រូវតោះតើយ រៀបភួយមុងខ្នើយ មើលទីសម្រាន ។

- ស្វាមីនិងម្ដាយក៏ន័យដូចគ្នា កូនត្រូវម៉្នីម៉្នា ប្រឹងធ្វើឱ្យបាន
កុំខ្ជាចនឿយហត់ត្រូវអ្នកក្លាហាន រួចហើយសឹមបានអ្នកដេកខាងក្រោយ ។
- ប្រាំបួន **គប្បីបម្រើនូវភ្លើង** កូនអើយត្រូវយើងកុំនៅកន្តើយ
ព្រោះឪពុកម្ដាយស្វាមីហ្នឹងហើយ អ្នកនឹងបានស្បើយព្រោះការបម្រើ ។
- រីឯទី ១០ **គួរនមស្ការ~ នូវទេវតាខាងក្នុង** ប្រសើរ
ព្រោះឪពុកម្ដាយ ទៅតាមដំណើរ កូនគួរបម្រើឱ្យបានប្រពៃ ។
- ចំណែកស្វាមី ក៏ន័យដូចគ្នា ដែលភរិយា ត្រូវតែលកលៃ
ឃើញដូចទេវតា ចិត្តល្អប្រពៃ បម្រើតាមន័យ គោរពបូជា ។
- ឱវាទ ១០ យ៉ាងកូនចូរដឹងចុះ អ្នកត្រូវបណ្ដុះ ដោយចិត្តសម្ភារ
ប្រព្រឹត្តកោតក្រែងគ្រប់ពេលវេលា នឹងបានផុតព្យេរផុតចាកទុក្ខហោង ។

វត្តនិគ្រោធវ័ន ថ្ងៃ ១៤ កើត ខែមិគសិរ ព.ស.២៥៥៤

**ភិក្ខុ ភួង~សុវណ្ណ សុវណ្ណជោតោ**

## គម្ពីរដែលជាឧបករណ៍
## ក្នុងការរៀបរៀងសៀវភៅនេះ

១-ព្រះត្រៃបិដក

២-អដ្ឋកថា សមន្តប្បាសាទិកា

៣-អដ្ឋកថា សុមង្គលវិលាសិនី

៤-អដ្ឋកថា មនោរថបូរណី

៥-អដ្ឋកថា ធម្មសង្គណី

៦-អភិធម្មត្ថសង្គហៈ

៧-វិសុទ្ធិមគ្គ

៨-សារត្ថទីបនីដីកា

៩-បរមត្ថជោតិកៈ

អក្ខរាវិរុទ្ធ សរសេរតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជ ជោតញ្ញាណោ **ជួន-ណាត** ។